# ភាពចម្រុងចម្រើន?

## ការស្វែងរកដំណឹងល្អដ៏ពិត

*Michael Otieno Maura*
*Conrad Mbewe*
*Ken Mbugua*
*John Piper*
*Wayne Grudem*

*Africa Christian Textbooks Registered Trustees*
*The Gospel Coalition*
*ACTION Cambodia*
*2019*

Prosperity? Seeking the True Gospel

English Edition Published by Africa Christian Textbooks Registered Trustees.

Copyright © 2015

All rights reserved.

This edition in Khmer copyright © 2019

ផលិតដោយ៖ សកម្មភាពកម្ពុជា resources@actioncambodia.org
ប្រអប់សំបុត្រលេខ ១១៧៨ រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា

បកប្រែដោយ៖ លោក ឈាង បូរ៉ា

ជំនួយការបកប្រែ៖ លោក វ៉ើល ណាថាន

ពិនិត្យផ្ទៀងផ្ទាត់ដោយ៖ លោក ម៉េង មនោ, លោកស្រី ឡូញ ណារ៉ុង, ទេព រ៉ូ

សូមថ្លែងអំណរគុណចំពោះ៖ លោកស្រី ឡូញ ស្រីរ័ត្ន, លោក ខែម បូឡុង, កញ្ញា សួន សុជាតា, លោកស្រី សំ ថាវី, លោក ផុន ស្រីអែម, លោកស្រី ថាវ ប៊ុនរី និងលោកគ្រូ តឹក អ៊ែនឌ្រូ

យើងខ្ញុំបានរក្សាអក្ខរាវិរុទ្ធនៃសម្រង់ខគម្ពីរដែលមាននៅក្នុងព្រះគម្ពីរបកប្រែចាស់ រក្សាសិទ្ធិ□ឆ្នាំ១៩៥៤ ដោយសមាគមព្រះគម្ពីរសកល, ព្រះគម្ពីរសញ្ញាថ្មី កែសម្រួល រក្សាសិទ្ធិ□ឆ្នាំ២០១៤, ២០១៦ (គកស) ដោយសមាគមព្រះគម្ពីរសកល, ព្រះគម្ពីរដ៏វិសុទ្ធជាភាសាខ្មែរបច្ចុប្បន្ន រក្សាសិទ្ធិ□ឆ្នាំ២០០៥ (គខប) ដោយសមាគមព្រះគម្ពីរសកល, ព្រះគម្ពីរគ្រិស្តបរិស័ទខ្មែរ រក្សាសិទ្ធិ□ឆ្នាំ២០១៤ (គគខ) ដោយព័ន្ធកិច្ចព្រះបន្ទូលនៃជីវិត, ក៏ដូចជាអសាធារណនាមមួយចំនួន ប៉ុន្តែសំណេរនៅក្នុងអត្ថបទទាំងមូលយើងខ្ញុំបានខិតខំព្យាយាមគោរពតាមអក្ខរាវិរុទ្ធនៃវចនានុក្រមខ្មែររបស់សម្តេចសង្ឃរាជ ជួន ណាត។

Published in partnership with The Gospel Coalition and Africa Christian Textbooks Registered Trustees

English Book Design by Beau Walsh, The Cultural North | www.culturalnorth.us

អ្នករចនាអត្ថបទភាសាខ្មែរ៖ លោក វ៉ើល ណាថាន និងលោក ទេព រ៉ូ

For ordering information please visit:

ប្រសិនបើលោកអ្នកចង់ជាវសៀវភៅនេះ សូមចូលទៅកាន់គេហទំព័រ៖

http://www.cambodianchristianresources.com/prosperity/

បោះពុម្ពលើកទី១ ចំនួន៨.០០០ក្បាល ២០១៩ នៃគ.ស. នៅព្រះរាជាណាចក្រកម្ពុជា

ISBN-13: 978-99963-850-9-4

# មាតិកា


បុព្វកថា ..........................................................................៥

បុព្វកថានៃសៀវភៅជាភាសាអង់គ្លេស ..................................៩

សេចក្ដីផ្ដើម៖ ដំណឹងល្អដ៏ខុសឆ្គង......................................១៣

ជំពូក១៖ ការយល់ដឹងដ៏ខុសឆ្គងលើព្រះគម្ពីរ........................៤៣

ជំពូក២៖ ភាពចម្រុងចម្រើនដ៏ពិត និងមិនពិត....................... ៨៥

ជំពូក៣៖ ជីវិតនៃដំណឹងល្អ ............................................ ១១៧

ជំពូក៤៖ ការរងទុក្ខ .......................................................១៤៩

ជំពូក៥៖ ដំណឹងល្អដ៏ពិត.............................................. ១៨៣

ជំពូក៦៖ ព្រះពរនៃដំណឹងល្អដ៏ពិត ..................................២០៩

សេចក្ដីបន្ថែមទី១៖ ការអំពាវនាវ១២ចំណុចចំពោះ
គ្រូៗដែលបង្រៀនភាពចម្រុងចម្រើន...............................២៤៥

សេចក្ដីបន្ថែមទី២៖ លុយ............................................. ២៧៩

សេចក្ដីបន្ថែមទី៣៖ គ្រូៗដែលបង្រៀនភាពចម្រុងចម្រើន ..... ២៨៧

សេចក្ដីបន្ថែមទី៤៖ ឯកសារបន្ថែម៖ សៀវភៅនានា
ដែលនិយាយពីការបង្រៀននៃភាពចម្រុងចម្រើន ................ ២៨៩



លោកអ្នកអាចស្ដាប់សៀវភៅនេះជាសំឡេង
ដោយគ្រាន់តែចូលទៅកាន់គេហទំព័រ៖
cambodianchristianresources.com/prosperity/

# បុព្វកថា

សៀវភៅមួយនេះត្រូវបានបកប្រែឡើង ដើម្បីទាស់ប្រឆាំងនឹងដំណឹងល្អដែលសន្យា «ភាពចម្រុងចម្រើន» ឬក៏ «សុខភាព និងទ្រព្យសម្បត្តិ» ដែលបាននាំឲ្យមានចលាចលដ៏ធ្ងន់ធ្ងរនៅក្នុងប្រទេស កម្ពុជា និងនៅជុំវិញពិភពលោកទាំងមូលនេះ។ មានគ្រូអធិប្បាយមួយចំនួនដែលកំពុងតែសន្យាភាពចម្រុងចម្រើនបែបលោកីយ៍ទៅកាន់មនុស្ស ដោយការនោះកំពុងតែនាំឲ្យពួកគេចាកចេញឆ្ងាយពីព្រះអម្ចាស់យេស៊ូវគ្រីស្ទ និងពីដំណឹងល្អដ៏ពិតដែលមានចែងនៅក្នុងព្រះគម្ពីរ។ ការបង្រៀនដ៏ខុសឆ្គងមួយនេះបានបត់បែនសេចក្ដីពិតក្នុងរបៀបដល់ថ្នាក់ថា មានមនុស្សជាច្រើនទំនងជាមិនដឹងខ្លួនផងថាពួកគាត់កំពុងតែទទួលការជះឥទ្ធិពលនោះផងដែរ។

គោលបំណងរបស់យើងក្នុងសៀវភៅមួយនេះគឺ លើកឡើងអំពីគោលការណ៍ចម្បងៗ និងគំនិតនានាពីសេចក្ដីបង្រៀននៃភាពចម្រុងចម្រើន ជាជាងប្រកែកគ្នាជាមួយនឹងពួកគ្រូៗទាំងនោះដោយផ្ទាល់។ ប៉ុន្តែ យើងក៏បាននឹកគិតដល់អ្នកដែលជះឥទ្ធិពលជាច្រើននាក់ផងដែរ ហើយយើងបានរាយឈ្មោះគ្រូៗដែល

ជះឥទ្ធិពលបែបដូចខាងលើនោះមួយចំនួននៅក្នុងសេចក្ដីបន្ថែមទី៣។ ទោះបីជាយ៉ាងណាក្ដី លើសពីអ្វីៗទាំងអស់ ក៏យើងចង់លើកទឹកចិត្តឲ្យមិត្តអ្នកអានល្បងលសេចក្ដីអធិប្បាយដែលពួកគាត់ឮដោយឲ្យយកមកផ្ទៀងផ្ទាត់នឹងព្រះគម្ពីរ។ សៀវភៅមួយនេះនឹងព្យាយាមជួយលោកអ្នកក្នុងការនេះ។

តាមរយៈសៀវភៅមួយនេះ សេចក្ដីប៉ងប្រាថ្នារបស់យើង (ចំពោះអស់អ្នកដែលត្រូវបានគេបោកប្រាស់ និងកំពុងតែយល់ច្រឡំដោយសេចក្ដីអធិប្បាយនៃភាពចម្រុងចម្រើន) គឺបង្វែរឲ្យពួកគាត់ត្រឡប់មកស្រឡាញ់ដំណឹងល្អដែលមានចែងនៅក្នុងព្រះគម្ពីរ និងទៅរកសេចក្ដីសង្គ្រោះនៅក្នុងព្រះយេស៊ូវគ្រីស្ទ។ យើងក៏សង្ឃឹមផងដែរថា សៀវភៅមួយនេះនឹងផ្ដត់ផ្គង់ដល់គ្រីស្ទបរិស័ទដើម្បីឲ្យពួកគាត់ហ៊ាននិយាយទាស់ប្រឆាំងនឹងសេចក្ដីបង្រៀនដ៏ខុសឆ្គងដែលពួកគាត់ឮប្រកាសចេញពីក្រុមជំនុំជាច្រើន។ យើងក៏អធិស្ឋានឲ្យគ្រូៗដែលបង្រៀនភាពចម្រុងចម្រើនអានសៀវភៅមួយនេះផងដែរ។ យើងទទួលស្គាល់ថា ពួកគាត់មួយចំនួនត្រូវការកែប្រែចិត្តចេញពីកំហុសរបស់ខ្លួន ហើយចុះចូល និងឱបក្រសោបយកព្រះយេស៊ូវគ្រីស្ទជាព្រះអង្គសង្គ្រោះរបស់ខ្លួន ហើយពួកគាត់មួយចំនួនទៀតត្រូវការសិក្សាការកាត់ស្រាយព្រះគម្ពីរឲ្យ

បានត្រឹមត្រូវ ដូចដែលព្រះបន្ទូលរបស់ព្រះជាម្ចាស់បានចែងដែរ។

នេះគឺជាបញ្ហាដ៏មានគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរបំផុត ហើយយើងបានបោះពុម្ពសៀវភៅនេះដោយមានការអន្តរាគមន៍ភ្លាមៗ។ យើងដឹងហើយថាសាវ័ក ពេត្រុស បានប្រើប្រាស់ពាក្យពេចន៍យ៉ាងធ្ងន់ធ្ងរក្នុងសំបុត្រទីពីររបស់គាត់ ដើម្បីថ្កោលទោសគ្រូៗដែលលោភលន់ និងគ្រូៗដែលបានកេងប្រវ័ញ្ចពីគ្រីស្ទបរិស័ទ។ ខណៈពេលដែលយើងឃើញថា មានគ្រូៗនៅជុំវិញយើងសព្វថ្ងៃនេះកំពុងតែនាំមនុស្សឲ្យវង្វេងផ្លូវ ដោយសេចក្តីបង្រៀនដែលមិនត្រាប់តាមព្រះគម្ពីរ និងសេចក្តីសន្យាដែលមិនកោតខ្លាចព្រះជាម្ចាស់ នោះយើងមិនអាចឈរស្ងៀមដោយមិនធ្វើអ្វីបានឡើយ។ តាមរយៈសៀវភៅមួយនេះ យើងណែនាំលោកអ្នកទៅកាន់ព្រះដ៏មានអធិបតេយ្យភាព និងដំណឹងល្អដ៏ល្អឥតខ្ចោះរបស់ទ្រង់។ យើងឈរលើមូលដ្ឋាននេះ ដើម្បីជំទាស់នឹងដំណឹងល្អដែលសន្យាភាពចម្រុងចម្រើន។

យើងសូមថ្លែងអំណរគុណទៅកាន់លោកគ្រូ Michael Otieno Maura, លោកគ្រូ Ken Mbugua និងលោកគ្រូ Conrad Mbewe ដែលបានលះបង់ពេលវេលា និងកម្លាំងកាយក្នុងការនិពន្ធសៀវភៅមួយនេះ ក៏ដូចជាថ្លែងអំណរគុណទៅកាន់អស់អ្នក

ដែលបានជួយបោះពុម្ពសៀវភៅមួយនេះក្នុងភាសាអង់គ្លេស និងបានអនុញ្ញាតឲ្យយើងអាចបកប្រែសៀវភៅនេះក្នុងភាសាខ្មែរ។

យើងក៏សូមថ្លែងអំណរគុណដល់ក្រុម the Gospel Coalition និង Africa Christian Textbooks Registered Trustees ដែលបានអនុញ្ញាតឲ្យយើងបកប្រែសៀវភៅមួយនេះ ក៏ដូចជាថ្លែងអំណរគុណទៅកាន់លោក Bill Walsh ដែលបានទាក់ទងមកកាន់ខាងយើង និងផ្ដល់យោបល់ឲ្យយើងសហការជាមួយគ្នាក្នុងការបកប្រែ និងបោះពុម្ពសៀវភៅមួយនេះ ដើម្បីជាការកសាងរូបកាយរបស់ព្រះគ្រីស្ទនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងការថ្វាយសិរីល្អទៅកាន់ព្រះជាម្ចាស់។

បើគ្មានការបរិច្ចាគដ៏សប្បុរសពីមនុស្សជាច្រើន នោះយើងក៏ទំនងមិនជាអាចបោះពុម្ពសៀវភៅនេះបានផងដែរ។ យើងសូមថ្លែងអំណរគុណ និងថ្វាយការសរសើរតម្កើងដល់ព្រះជាម្ចាស់។

**សកម្មភាពកម្ពុជា**

**Africa Christian Textbooks Registered Trustees**

**The Gospel Coalition**

# បុព្វកថានៃសៀវភៅ
# ជាភាសាអង់គ្លេស

This book has been published as a result of a partnership between The Gospel Coalition and Africa Christian Textbooks Registered Trustees (Kenya).

The book builds on the foundation of the earlier title *Gaining the World, Losing the Soul* which was first published [in English] in 2012. Over the last few years new chapters have been added and the original chapters have been updated and revised.

This book has been written to counter the great damage that the so called “prosperity” or “health and wealth” gospel is doing in Africa and around the world. Some preachers are making promises of worldly prosperity to men and women and leading them far away from the Lord Jesus

Christ and the genuine gospel that is found in the Bible. So widespread is this false teaching that many people may not even realise that they have been influenced by it.

Our task in this book is to address the core principles and ideas of this prosperity teaching, rather than argue with particular preachers. But there are many influential people we have in mind who, in different ways and forms, have articulated and spread this prosperity gospel (we reference some examples in Appendix III). More than anything else, we encourage readers to examine the preaching they hear in the light of the Bible. This book strives to help you do that.

Through this book, our desire is that those who have been deceived or confused by prosperity preaching will come instead to cherish the gospel of the Bible and find salvation in Jesus Christ. We also hope that this book will equip Christians to speak out against the false teaching they hear proclaimed from many pulpits. We pray that prosperity teachers themselves would read this book. We believe that some of them need to repent of their errors and

submit to and embrace Jesus Christ as their saviour, while others need to learn how to properly handle the Bible as the word of God.

This is a deadly serious issue and we publish this book with a sense of urgency. We know that Peter used strong language in his second letter to condemn arrogant and greedy teachers who took advantage of Christians. As we see teachers around us today leading people astray with unbiblical and ungodly promises, we cannot stand by and do nothing. With this book we point you to our sovereign God and his perfect gospel. On this we stand against the prosperity gospel.

We are grateful to Michael Otieno Maura, Ken Mbugua and Conrad Mbewe for giving their time and energy to writing these chapters as well as to their churches for allowing them to devote that time and energy to this task.

We are thankful to Baker Publishing Group for allowing the publication of the chapters by John Piper and Wayne Grudem.

We are also very grateful to Caleb Nakina for his review of the whole book and for his editing.

Once again we have been saved by our friend David Reynolds who pulled everything together at the end and completed the final edit. This book was made possible because of the hard work that David put into Gaining the World, Losing the Soul back in 2012. Thanks David!

It has been a privilege to partner with The Gospel Coalition in this project. It has been a delight to work with Bill Walsh and also with his son Beau who designed the cover of the book and formatted the chapters. We are so grateful for Bill's leadership and patience.

This book would not have been published without generous donations from many people. We are thankful and praise God.

**Africa Christian Textbooks Registered Trustees**

**The Gospel Coalition**

## សេចក្ដីផ្ដើម៖

# ដំណឹងល្អដ៏ខុសឆ្គង

Kenneth Mbugua

*«ខ្ញុំឆ្ងល់ណាស់ ពីដំណើរដែលអ្នករាល់គ្នាបានផ្លាស់ប្រែចេញពីព្រះ ដែលទ្រង់ហៅអ្នករាល់គ្នាមក ក្នុងព្រះគុណនៃព្រះគ្រីស្ទ ជាឆាប់ម្ល៉េះ នឹងទៅតាមដំណឹងល្អផ្សេងទៀតនោះ ដែលមិនមែនជាដំណឹងល្អ១ទៀតទេ គឺមានមនុស្សខ្លះបំភាន់អ្នករាល់គ្នាវិញ ហើយចង់បង្ខូចដំណឹងល្អព្រះគ្រីស្ទផង ប៉ុន្តែ បើយើងខ្ញុំ ឬទេវតាពីស្ថានសួគ៌ នឹងប្រាប់ដំណឹងណាមកអ្នករាល់គ្នា ខុសពីដំណឹងល្អ ដែលយើងខ្ញុំបានប្រាប់ហើយ នោះឲ្យគេត្រូវបណ្ដាសាចុះ ឯសេចក្ដីដែលខ្ញុំទើបនឹងនិយាយអម្បាញ់មិញនេះ នោះខ្ញុំនិយាយម្ដងទៀតថា បើអ្នកណាប្រាប់ដំណឹងណា ខុសអំពីដំណឹងល្អ ដែលអ្នករាល់គ្នាបានទទួលហើយ នោះឲ្យគេត្រូវបណ្ដាសាចុះ ដ្បិតតើខ្ញុំរកបញ្ចុះបញ្ចូលអ្នកណា តើជាមនុស្ស ឬព្រះ ឬចង់បំពេញចិត្ត*

*មនុស្សឬអី បើសិនជាខ្ញុំចង់បំពេញចិត្តមនុស្ស នោះខ្ញុំមិនមែនជាបាវបម្រើរបស់ព្រះគ្រីស្ទទេ។ បងប្អូនអើយ ខ្ញុំចង់ប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា ដំណឹងល្អដែលខ្ញុំបានថ្លែងប្រាប់ នោះមិនមែនតាមមនុស្សទេ ដ្បិតខ្ញុំមិនបានទទួលមកពីមនុស្ស ក៏គ្មានអ្នកណាបង្រៀនខ្ញុំផង គឺដោយព្រះយេស៊ូវគ្រីស្ទបានបើកសម្ដែងវិញ» (កាឡាទី ១:៦-១២)។*

សូម្បីតែទេវតាក៏នឹងត្រូវបណ្ដាសាដែរ បើគាត់ហ៊ានប្រកាសដំណឹងល្អដែលទាស់ប្រឆាំងនឹងព្រះបន្ទូលរបស់ព្រះជាម្ចាស់។ គ្មានគ្រីស្ទបរិស័ទណាម្នាក់នៅលើលោកនេះដែលគាត់មិនត្រូវសញ្ជឹងគិតលើពាក្យរបស់សាវ័ក ប៉ុល ទៅកាន់ក្រុមជំនុំកាឡាទីដោយមិនយកចិត្តទុកដាក់ឡើយ។ ចំពោះក្រុមជំនុំ ដំណឹងល្អគឺជាអំណោយទានដ៏មានតម្លៃបំផុតដែលពួកគាត់ត្រូវតែថែរក្សាការពារ និងចែកចាយបន្ត។ ហេតុដូច្នេះហើយបានជាគ្រីស្ទបរិស័ទ ជាពិសេសគ្រូគង្វាល យើងមិនត្រូវឈប់ពិនិត្យនូវអ្វីដែលយើងជឿ និងអធិប្បាយ ហើយសួរខ្លួនឯងថា៖ «*តើនេះជាដំណឹងល្អមែនឬ? តើនេះជាដំណឹងល្អដែលព្រះជាម្ចាស់បានបើកសម្ដែង*

*ឲ្យយើងឃើញក្នុងព្រះគម្ពីរ?»* នេះហើយជាអ្វីដែលយើងព្យាយាមស្វែងរកនៅក្នុងសៀវភៅនេះ។

សៀវភៅនេះមិនរំពឹងលើផ្នត់គំនិតរបស់យើងនោះឡើយ។ វាមិនមែនជារឿងបុគ្គលនឹងបុគ្គលនោះទេ។ យើងមិនមែនដាក់ខ្លួនទាស់នឹងគ្រូអធិប្បាយផ្សេងៗ ដើម្បីប្រកួតថានរណាខ្លាំង ឬក៏ល្អជាងនរណានោះទេ។ ដូចនឹងសាវ័ក ប៉ុល យើងមិនព្យាយាមប្រកាសពីខ្លួនឯងទេ តែអំពីព្រះគ្រីស្ទវិញ (២កូរិនថូស ៤:៥)។ យើងព្យាយាមនិពន្ធដោយយកអំណាចនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ទុកជាមូលដ្ឋានដែលមានការបើកសម្តែងក្នុងព្រះគម្ពីរ។ យើងព្យាយាមកុំឲ្យខ្លួនឯងបត់បែនព្រះបន្ទូល ដើម្បីបំពេញគោលបំណងខ្លួន ប៉ុន្តែឲ្យកាត់ស្រាយព្រះបន្ទូលដោយមានភាពស្មោះត្រង់ (២កូរិនថូស ៤:២)។

នៅពេលដែលយើងបានអានដំណឹងល្អដោយយកចិត្តទុកដាក់ដែលយើងបានទទួលក្នុងព្រះគម្ពីរ នោះយើងមានសេចក្តីសន្និដ្ឋានមួយថាមានដំណឹងល្អដ៏ខុសឆ្គង—ដំណឹងល្អដែលសន្យាពីភាពចម្រុងចម្រើន—កំពុងតែសាយភាយលើទ្វីបរបស់យើង។ នៅបណ្តាប្រទេសជុំវិញពិភពលោក មានគ្រូៗនៅក្រុមជំនុំជាច្រើនកំពុងតែបង្រៀនពីដំណឹងល្អដ៏ខុសឆ្គងនេះ។ វាគឺ

ជាការកុហកដ៏ពោរពេញដោយគ្រោះថ្នាក់ដែលយកសាសនាមកគ្របបាំង។ អស់អ្នកដែលបានទទួលការជះឥទ្ធិពលពីការបង្រៀនបែបនេះ គឺកំពុងតែត្រូវបានទទួលការបង្វែរចេញពីដំណឹងល្អរបស់ព្រះជាម្ចាស់ ទៅកាន់ការបោកបញ្ឆោតដែលយកមនុស្សធ្វើជាគោល។ សាវ័ក ប៉ុល បានបង្រៀនថា គ្មានអ្វីគ្រោះថ្នាក់ជាងការជឿដំណឹងល្អខុសឆ្គងនោះទេ ដូច្នេះយើងក៏គិតដូចគាត់ផងដែរ។ គ្មានអ្វីគ្រោះថ្នាក់លើសនេះទេ ពីព្រោះព្រលឹងវិញ្ញាណរបស់យើងពឹងផ្អែកលើវា។

យើងបាននិពន្ធសៀវភៅនេះឡើងទុកជាការនិយាយទៅកាន់គ្រូៗដែលអធិប្បាយដំណឹងល្អដ៏ខុសឆ្គងមួយនេះ និងទៅកាន់អស់អ្នកដែលបានលង់ក្នុងសេចក្តីបង្រៀននេះ ហើយយើងអធិស្ឋានសូមការអត់ធ្មត់ ក្តីមេត្តា ប្រាជ្ញា និងភាពទន់ភ្លន់ពីព្រះជាម្ចាស់ខណៈពេលដែលយើងព្យាយាមកែតម្រង់ភាពខុសឆ្គងដោយមានការបន្ទាបខ្លួន ហើយយើងសង្ឃឹមថាការនេះនឹងនាំយើងឲ្យមកជ្រកកោនក្រោមអំណាចនៃព្រះបន្ទូលព្រះជាម្ចាស់។

យើងនឹងមិនយកសេចក្តីពិតមកប្រឡាក់ស្ករនោះឡើយ។ សាវ័ក ប៉ុល មានភាពសាហាវ និងការនិយាយចំៗយ៉ាងមុតមាំពេលដែលគាត់ទាក់ទងជាមួយនឹងអស់អ្នកដែលកំពុងតែកែ

បំផ្លាញដំណឹងល្អ។ ដូចដែលគាត់បានធ្វើ យើងក៏ចង់លើកទឹកចិត្តអ្នកជឿឲ្យបដិសេធចំពោះ «ដំណឹងល្អផ្សេងទៀត» ដែលមិនមែនជាដំណឹងល្អដែលមកពីព្រះគ្រីស្ទ។ ហើយមានមនុស្សជាច្រើនដែលពិបាកនឹងទទួលយកសារនេះណាស់។ ហើយមូលហេតុមួយក្នុងចំណោមមូលហេតុជាច្រើនដែលធ្វើឲ្យពិបាកទទួល គឺដោយព្រោះមានសំឡេងរបស់គ្រូៗជាច្រើនដែលគេបានទុកចិត្ត ដែលជាអ្នកគាំទ្រដំណឹងល្អដ៏ខុសឆ្គងនេះ។

ប៉ុន្តែ ចូរចាំថាកេរ្តិ៍ឈ្មោះល្បីល្បាញមិនមែនជារឿងសំខាន់នោះឡើយ។ ចំណុចសម្គាល់នៃសេចក្ដីពិតគឺមិនអាស្រ័យទៅលើការមានក្រុមជំនុំធំៗ ឋានៈល្បីល្បាញដូចជាតារាៗ ឬក៏ការជះឥទ្ធិពលដ៏ខ្លាំងក្លានោះទេ។ ដាច់ខាត! យើងត្រូវតែឈរលើការបើកសម្ដែងពីព្រះបន្ទូល ហើយមិនមែនរៀបរៀងដំណឹងល្អទៅតាមតែចិត្តអ្នកស្ដាប់ឡើយ។ សាវ័ក ប៉ុល បានដាស់តឿនក្រុមជំនុំកាឡាទីកុំឲ្យជឿ*បុគ្គលណា*ដែលប្រកាសដំណឹងល្អផ្សេងពីដំណឹងល្អដែលព្រះគ្រីស្ទបានប្រទានដល់គាត់—សូម្បីតែទេវតាក៏មិនឲ្យជឿដែរ។ នោះឯងក៏ជាចំណុចដែលយើងចង់យកចិត្តទុកដាក់ទៅលើចំណុចនេះផងដែរ។ យើងអង្វរករបងប្អូនដោយក្ដីស្រឡាញ់ សូមបងប្អូនទទួលយកនូវព្រះបន្ទូលរបស់

ព្រះជាម្ចាស់ដោយមានការបន្ទាបខ្លួន។ ការនេះអាចនឹងសង្គ្រោះព្រលឹងវិញ្ញាណរបស់លោកអ្នក (យ៉ាកុប ១:២១)។

តើអ្វីទៅដែលហៅថាដំណឹងល្អដែលសន្យាពីភាពចម្រុងចម្រើន? វាជា «ដំណឹងល្អ» ដែលអះអាងថា អស់អ្នកដែលជឿនឹងលែងមានការឈឺថ្កាត់ ភាពក្រីក្រ ហើយរាល់ការរងទុក្ខនឹងឈប់មានទៀតហើយដោយពឹងលើមូលដ្ឋាននៃការសុគតរបស់ព្រះគ្រីស្ទនៅលើឈើឆ្កាង។ «ដំណឹងល្អ» ផ្សេងមួយនេះសន្យាទៅកាន់អស់អ្នកដែលទទួលជឿថា ពួកគេនឹងទទួលបានព្រះពរដែលអាចមើលឃើញខាងឯសម្ភារៈនិយម និងសាច់ឈាម ហើយក៏ទាមទារដែរថាព្រះហឫទ័យរបស់ព្រះជាម្ចាស់គឺឲ្យកូនៗរបស់ទ្រង់មានភាពចម្រុងចម្រើននៅក្នុងជីវិតនេះ ហើយក្នុងភ្លាមៗនេះ។ ប៉ុន្តែ ដំណឹងល្អដែលសន្យាពីភាពចម្រុងចម្រើននេះមានរួមទាំងការបកស្រាយខុសដ៏សំខាន់ៗបួនយ៉ាង ដែលជាចំណុចខុសៗគ្នាបួនយ៉ាងពីដំណឹងល្អដែលមានចែងទុកក្នុងព្រះគម្ពីរ។ «ដំណឹងល្អ» ផ្សេងមួយនេះប្រកាសពីព្រះដ៏តូចតាច។ វាមិនបានលើកឡើងអំពីតម្រូវការដ៏ធំបំផុតរបស់មនុស្សលោកទេ។ វាបានដកចេញនូវអំណាចនៃដំណឹងល្អ។ ហើយវាក៏បានលួចសិរីល្អរបស់ព្រះជាម្ចាស់ផងដែរ។

# ការបកស្រាយខុសទី១៖ ព្រះដ៏តូចតាច

តើលោកអ្នកចង់បានអ្វីខ្លាំងជាងគេបំផុត? ចម្លើយទៅលើសំណួរនេះនឹងជួយឲ្យលោកអ្នកដឹងថាអ្វីទៅជាព្រះរបស់ខ្លួន។ គ្រូៗដែលអធិប្បាយដំណឹងល្អដែលសន្យាពីភាពចម្រុងចម្រើនត្រាស់ហៅឲ្យមនុស្សត្រឡប់ទៅរកព្រះយេស៊ូវ។ ប៉ុន្តែ មូលហេតុដែលពួកគាត់ថាយើងគួរនឹងត្រឡប់ទៅរកព្រះយេស៊ូវគឺ ដើម្បីសុខភាព ទ្រព្យសម្បត្តិ ប្តី ប្រពន្ធ ការងារ និងការឡើងបុណ្យសក្តិ។ នៅក្នុងដំណឹងល្អដ៏ខុសឆ្គងមួយនេះ យើងមិនបានទទួលការលើកទឹកចិត្តឲ្យចង់បានព្រះយេស៊ូវ សង្វាតដេញតាមព្រះយេស៊ូវ ឬក៏ឲ្យយកព្រះគ្រីស្ទជាទ្រព្យធននោះឡើយ។ ផ្ទុយពីនោះ ពួកគាត់បែរជាចាត់ទុកព្រះយេស៊ូវថា គ្រាន់តែជាឈ្នាន់មួយនៃការទទួលបានសម្ភារៈនិយម ដែលចិត្តអាត្មានិយមស្រេកឃ្លានចង់បាន។ ហើយអ្វីដែលចិត្តរបស់លោកអ្នកចង់បានខ្លាំងជាងព្រះជាម្ចាស់ នោះឯងបានក្លាយជាព្រះរបស់លោកអ្នក។

ព្រះបន្ទូលបានចែងយ៉ាងច្បាស់ហើយថា ព្រះជាម្ចាស់គឺជាគោលដៅនៃសេចក្តីសង្គ្រោះរបស់យើង មិនមែនមាសប្រាក់នោះទេ។ ការស្គាល់ព្រះអង្គ ការរួបរួមគ្នាជាមួយនឹងទ្រង់ និងការមាន

ភាពត្រូវគ្នាវិញជាមួយនឹងទ្រង់ គឺជាអ្វីដែលព្រះគម្ពីរបង្រៀនយើងថាជាគោលបំណងនៃសេចក្តីសង្គ្រោះ។ «ព្រោះព្រះគ្រីស្ទទ្រង់បានរងទុក្ខម្តង ដោយព្រោះបាបដែរ គឺជាព្រះដ៏សុចរិត ទ្រង់រងទុក្ខជំនួសមនុស្សទុច្ចរិត ដើម្បីនឹងនាំយើងរាល់គ្នាទៅដល់ព្រះ» (១ពេត្រុស ៣:១៨)។ ចូរកត់សម្គាល់លើពាក្យ *«ដើម្បី»* ដែលមានចែងក្នុងខគម្ពីរនេះ។ ពាក្យ «ដើម្បី» ជួយយើងក្នុងការយល់អំពីមូលហេតុដែលព្រះគ្រីស្ទបានរងទុក្ខ និងសុគត។ ព្រះអង្គបានរងទុក្ខ ហើយសុគត *ដើម្បីនឹងនាំយើងរាល់គ្នាទៅដល់ព្រះជាម្ចាស់។*

ព្រះយេស៊ូវគ្រីស្ទផ្ទាល់បានសង្ខេបយ៉ាងល្អឥតខ្ចោះពីចំណុចគោល និងគោលដៅនៃសេចក្តីសង្គ្រោះរបស់យើងក្នុងសេចក្តីអធិស្ឋានរបស់ទ្រង់ទៅកាន់ព្រះវរបិតា៖ «នេះជាជីវិតដ៏នៅអស់កល្បជានិច្ច គឺឲ្យគេបានស្គាល់ដល់ទ្រង់ដ៏ជាព្រះពិតតែ១ នឹងព្រះយេស៊ូវគ្រីស្ទ ដែលទ្រង់បានចាត់ឲ្យមកផង» (យ៉ូហាន ១៧:៣)។ ពេលដែលសាវ័ក ប៉ុល បានបង្រៀនក្រុមជំនុំកូឡូសអំពីរបៀបដែលសិរីល្អរបស់ព្រះជាម្ចាស់ធ្វើការនៅក្នុងយើង គាត់បានផ្តោតលើភាពរួបរួមគ្នារបស់យើងជាមួយនឹងព្រះគ្រីស្ទ។ «ព្រះទ្រង់បានសព្វព្រះហឫទ័យ នឹងសម្តែងឲ្យពួកបរិសុទ្ធនោះដឹងថា

សិរីល្អដ៏បរិបូររបស់សេចក្តីអាថ៌កំបាំងនេះជាយ៉ាងណា ក្នុងពួកសាសន៍ដទៃ គឺថា ព្រះគ្រីស្ទទ្រង់សណ្ឋិតនៅក្នុងអ្នករាល់គ្នា ដែលជាទីសង្ឃឹមយ៉ាងឧត្តម» (កូឡុស ១:២៧)។

ដំណឹងល្អគឺជាដំណឹងអំពីព្រះជាម្ចាស់ដ៏អស្ចារ្យបំផុតដែលទ្រង់បានប្រទានអំណោយទានដ៏ល្អបំផុតដែលយើងអាចនឹកស្មានមិនដល់៖ គឺព្រះអង្គផ្ទាល់។ នេះហើយគឺជាចំណុចដ៏អស្ចារ្យបំផុតនៃដំណឹងល្អ៖ មនុស្សមានបាបអាចស្គាល់ព្រះជាម្ចាស់ និងអាចមានអំណរក្នុងទ្រង់យ៉ាងអស់កល្បជានិច្ចបាន។ វាស្ត្ររបស់ព្រះជាម្ចាស់ក្នុងប្រវត្តិសាស្ត្រនានាតែងតែយល់ថា គ្មានអ្វីល្អជាងនេះទៀតនោះទ្បើយ។ ប៉ុន្តែ ដំណឹងល្អដែលសន្យាពីភាពចម្រុងចម្រើនបានកាត់បន្ថយព្រះជាម្ចាស់ឲ្យក្លាយទៅជាបុរសដែលមានវ័យចំណាស់ម្នាក់ដែលមានលុយកាក់ច្រើន ដោយញែកអំណោយទាននៃសម្ភារៈនិយមថាជាគោលបំណងនៃដំណឹងល្អ។ អត្ថប្រយោជន៍ដែលនៅបណ្តោះអាសន្ននៃការចម្រុងចម្រើនគឺត្រង់ថា ព្រះយេស៊ូវមិនបានសុគត ដើម្បីប្រទានឲ្យយើងមានការចម្រុងចម្រើនផ្នែកសម្ភារៈនិយមទ្បើយ។

ព្រះយេស៊ូវបានសុគត ដើម្បីនាំឲ្យយើងត្រឡប់ទៅកាន់ព្រះជាម្ចាស់វិញ។ ហើយចំណុចចម្បងនៃសេចក្តីសង្គ្រោះដែលព្រះ

អង្គបានទិញសម្រាប់យើងគឺ ដើម្បីឲ្យយើងអាចស្គាល់ព្រះជាម្ចាស់ក្នុងលក្ខណៈដែលជ្រាលជ្រៅ ហើយផ្ទាល់ៗទៀតផង។ តើលោកអ្នកអាចចាប់ផ្ដើមដឹងហើយឬនៅថា មេរៀនដែលប្ដូរ*ព្រះជាម្ចាស់*ចេញ ហើយយក*ទ្រព្យសម្បត្តិ សុខភាព និងភាពចម្រុងចម្រើន*មកជំនួស នោះគ្រាន់តែផ្ដល់ដល់យើងនូវព្រះដ៏តូចតាចដែលមិនមែនជាព្រះសោះឡើយ? ទ្រព្យសម្បត្តិ សុខភាព និងភាពចម្រុងចម្រើនមិនមែនជាសិរីល្អនៃដំណឹងល្អនោះឡើយ អ្វីទាំងនេះក៏មិនមែនជាមូលហេតុនៃអ្វីមួយដែលព្រះគ្រីស្ទបានសុគតសម្រាប់ផងដែរ តែតាមពិតទៅ អ្វីៗទាំងអស់នេះក៏ជាអំណោយទានដ៏តូចតាចណាស់ ពេលដែលយើងប្រៀបធៀបទៅនឹងការប្រកបគ្នាជាមួយព្រះដ៏អស្ចារ្យ។ អ្វីទាំងអស់នេះគឺជាអ្វីមួយដែលលោកីយ៍កំពុងតែសង្វាតដេញតាម។ វាគឺជាព្រះដ៏ក្លែងក្លាយ។ ការអធិប្បាយថា គោលបំណងនៃសេចក្ដីសង្គ្រោះរបស់យើង គឺជាព្រះពរនៃភាពចម្រុងចម្រើនខាងឯសម្ភារៈនិយមដែលនៅបណ្ដោះអាសន្នគឺជាការប្ដូរគ្រីស្ទសាសនាឲ្យទៅជាការថ្វាយបង្គំព្រះក្លែងក្លាយ ហើយជាការប្ដូរសិរីល្អរបស់ព្រះជាម្ចាស់មកជំនួសរបស់អ្វីមួយដែលថោកជាង។

## ការបកស្រាយខុសទី២៖
## តម្រូវការដ៏ធំបំផុតរបស់យើង

ពេលដែលលោកអ្នកចូលមន្ទីរពេទ្យដោយបានធ្លាក់ខ្លួនឈឺ ការងារចម្បងរបស់គ្រូពេទ្យគឺពិនិត្យរកមុខជំងឺដែលជាហេតុបណ្តាលឲ្យលោកអ្នកមានរោគសញ្ញា។ ប្រសិនបើគាត់រកប្រ-ភពនៃបញ្ហារបស់លោកអ្នកខុស នោះការព្យាបាលរបស់គាត់ក៏នឹងខុសដែរ។ ហើយលើសពីនោះទៅទៀត «ដំណោះស្រាយ» បែបនោះក៏អាចនឹងនាំឲ្យកាន់តែធ្ងន់ធ្ងរលើសដើម។ ដើម្បីឲ្យយើងពិតជាអាចប្រទានពរដល់អ្នកដទៃមែននោះ ដាច់ខាត យើងក៏ត្រូវស្វែងរកឲ្យបានត្រឹមត្រូវអំពីតម្រូវការដ៏ធំបំផុតរបស់ពួកគេ។

តើអ្វីទៅជាតម្រូវការដ៏ចម្បងបំផុតរបស់មនុស្សលោក? តើព្រះជាម្ចាស់បានដោះស្រាយនូវបញ្ហាអ្វីពេលដែលទ្រង់ចាត់ព្រះរាជបុត្រាតែមួយគត់របស់ទ្រង់ឲ្យយាងមកសុគត? គ្រូៗដែលអធិប្បាយពីភាពចម្រុងចម្រើន ណែនាំមនុស្សឲ្យមើលខាងឯសាច់ឈាម ថវិកា និងការតយុទ្ធក្នុងទំនាក់ទំនងថាជាបញ្ហាដ៏ចម្បងដែលទាមទារឲ្យមានការផ្សះផ្សា។ ហេតុដូច្នេះហើយបានជាពួកគាត់អធិប្បាយអំពីព្រះគ្រីស្ទថាជាយាននៃការដោះស្រាយបញ្ហាទាំងនោះ ទោះបើព្រះគម្ពីរបានចែងយ៉ាងច្បាស់លាស់អំពី

បញ្ហាដ៏ចម្បងរបស់មនុស្សលោកហើយក៏ដោយ។ ហើយបញ្ហានោះអាក្រក់ជាងការដាច់លុយ ឬក៏ការស្រេកឃ្លានទៅទៀត!

ការដែលព្រះយេស៊ូវបានផ្គត់ផ្គង់អាហារដល់មនុស្ស៥.០០០នាក់ដោយប្រើតែនំបុ័ងប្រាំដុំ និងត្រីពីរកន្ទុយ គឺជាការអស្ចារ្យដ៏ល្បីល្បាញមួយជាងគេបំផុត។ ប៉ុន្តែ មានមនុស្សជាច្រើនមិនបានដឹងថាមានអ្វីបានកើតឡើងបន្ទាប់ពីពួកបណ្តាជនបានទទួលទានអាហារ។ ក្រោយពីពួកមនុស្សម្នីម្នាបានឃើញការសម្គាល់ដ៏អស្ចារ្យ ពួកគាត់ចង់មានការបះបោរ ហើយចាប់យកព្រះយេស៊ូវធ្វើជាស្តេច (យ៉ូហាន ៦:១៥)។ តើពួកមនុស្សម្នាទាំងនោះមានគំនិតដ៏ត្រឹមត្រូវដែរឬទេទាក់ទងនឹងដំណឹងល្អ? បើយោងតាមព្រះយេស៊ូវ ពួកគាត់មិនមានទេ។ ពួកមនុស្សម្នាបានស្វះស្វែងរកព្រះយេស៊ូវយ៉ាងខ្លាំង រហូតដល់លោតទឹក ចុះទូក កាត់បឹងទៅតាមព្រះអង្គ (យ៉ូហាន ៦:២២-២៤)។ ប៉ុន្តែ នៅចុងបញ្ចប់ពេលដែលពួកគាត់បានរកព្រះអង្គឃើញ ទ្រង់មិនបានសរសើរពួកគាត់ទេ។ ព្រះយេស៊ូវបានជ្រាបពីបំណងចិត្តរបស់ពួកគេ ហើយក៏បានបន្ទោសយ៉ាងខ្លាំង៖

*«ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្នករាល់គ្នារកខ្ញុំ មិនមែនដោយព្រោះបានឃើញទីសម្គាល់*

*ទេ គឺដោយព្រោះតែបានបរិភោគនំប៉័ងឆ្អែតប៉ុណ្ណោះ កុំឲ្យខំប្រឹងឲ្យបានតែអាហារ ដែលតែងតែពុករលួយនោះឡើយ ចូរខំឲ្យបានអាហារ ដែលនៅស្ថិតស្ថេរ ដរាបដល់ជីវិតអស់កល្បជានិច្ចវិញ ជាអាហារដែលកូនមនុស្សនឹងឲ្យមកអ្នករាល់គ្នា ដ្បិតគឺកូនមនុស្សនេះហើយ ដែលព្រះវរបិតាដ៏ជាព្រះ ទ្រង់បានដៅចំណាំទុក» (យ៉ូហាន ៦:២៦-២៧)។*

ពួកគាត់កំពុងតែដើរតាមព្រះយេស៊ូវ ដើម្បីទទួលបានប្រយោជន៍ខាងផ្នែកសម្ភារៈនិយម។ ព្រះយេស៊ូវបានធ្វើទីសម្គាល់ និងការអស្ចារ្យ ដើម្បីឲ្យពួកគាត់ទទួលជឿលើទ្រង់ ហើយទទួលបានជីវិតអស់កល្បជានិច្ច (យ៉ូហាន ២០:៣០-៣១)។ ប៉ុន្តែ ពួកមនុស្សម្នាទាំងនោះគ្រាន់តែមានចំណាប់អារម្មណ៍លើការទទួលទានអាហារថ្ងៃត្រង់ដោយឥតគិតថ្លៃតែប៉ុណ្ណោះ។ ពួកគាត់បានគិតថា ព្រះមេស្ស៊ីនឹងផ្តល់នូវរាល់គ្រប់អ្វីៗដែលពួកគាត់ប្រាថ្នាចង់បាននៅក្នុងជីវិតនេះ ប៉ុន្តែបើប្រៀបធៀបទៅ ពួកគាត់កំពុងតែមើលរំលងពីអ្វីដែលល្អជាងនោះទៅទៀតដែលព្រះអង្គកំពុងតែចង់ផ្តល់ឲ្យពួកគាត់។ ប្រសិនបើលោកអ្នកកំពុងតែដើរតាមព្រះយេស៊ូវ ដើម្បីទទួលបានប្រយោជន៍ផ្នែកសម្ភារៈនិយម នោះ

មានន័យថា លោកអ្នកបានបរាជ័យហើយក្នុងការដឹងថាអ្វីទៅជាតម្រូវការដ៏សំខាន់បំផុតក្នុងជីវិតខ្លួន។

ដូច្នេះ ព្រះយេស៊ូវបានលើកឡើងយ៉ាងច្បាស់៖ សុខភាព និងទ្រព្យសម្បត្តិគឺមិនមែនជាតម្រូវការដ៏ធំបំផុតរបស់យើងនោះទេ។ ប៉ុន្តែតើអ្វីជាតម្រូវការដ៏ធំបំផុត? ដើម្បីឲ្យយល់ការនេះបាន យើងត្រូវតែត្រឡប់ទៅមើលមូលដ្ឋានគ្រឹះសាជាថ្មីឡើងវិញ៖ តើព្រះជាម្ចាស់ជានរណា ហើយថាតើយើងជាអ្នកណា? ក្នុងកណ្ឌគម្ពីររ៉ូមជំពូក១ យើងបានឃើញពីការរម្លឹកថា ព្រះជាម្ចាស់ជាព្រះដ៏សុចរិត ហើយយើងជាមនុស្សមានបាប។ ហើយដោយសារសេចក្ដីសុចរិតរបស់ព្រះអង្គ និងដោយសារអំពើអាក្រក់របស់យើង យើងត្រូវប្រឈមមុខនឹងការថ្កោលទោសដ៏យុត្តិធម៌របស់ទ្រង់។ ប្រសិនបើខ្ញុំយល់ថា ព្រះដ៏ពេញដោយព្រះចេស្ដា និងព្រះដ៏បរិសុទ្ធកំពុងតែខ្ញាល់នឹងខ្ញុំ នោះការខ្វះខាតខាងឯថវិកា ភាពតានតឹងខាងទំនាក់ទំនង និងការចង់ឡើងឋានៈក្នុងការងារនឹងលែងក្លាយជាអាទិភាពចម្បងរបស់ខ្ញុំទៀតហើយ។ បញ្ហានៃអំពើបាបរបស់ខ្ញុំនឹងក្លាយជាអាទិភាពដ៏ចម្បងវិញ។

តើអ្វីទៅជាបញ្ហានៃអំពើបាបនេះ? ជាថ្មីម្ដងទៀត កណ្ឌគម្ពីររ៉ូមជំពូក១គឺជាជំនួយដល់យើង។ ជំពូកនេះពន្យល់ថា ទោះបើ

យើងស្គាល់ព្រះអង្គ ក៏ស្គាល់ក្នុងលក្ខណៈនៃការពុករលួយរបស់យើងដែរ យើងមិនអាចថ្វាយសិរីល្អដល់ព្រះអង្គដូចដែលយើងគួរធ្វើនោះទេ។ ផ្ទុយទៅវិញ យើងបែរជាថ្វាយសិរីល្អដែលជាកម្មសិទ្ធិរបស់ព្រះអាទិករទៅកាន់អ្វីៗដែលទ្រង់បានបង្កើតទៅវិញ (រ៉ូម ១:២២-២៣)។ ការថ្វាយបង្គំព្រះក្លែងក្លាយបែបនេះឯងគឺជាចំណុចស្នូលនៃអំពើបាប។ តម្រូវការចម្បងរបស់យើងគឺរកដំណោះស្រាយសម្រាប់បញ្ហានៃអំពើបាបនេះ។

នៅពេលដែលយើងចាប់ផ្ដើមយល់ថា រាល់ការឈឺចាប់នៃជីវិតគឺជាមុខសញ្ញានៃរោគជំងឺដ៏ពិតរបស់យើង (គឺអំពើបាបដែលបន្ថោកបន្ទាបព្រះជាម្ចាស់) នោះយើងក៏នឹងចាប់ផ្ដើមស្វែងរកដំណឹងល្អ ដែលមិនគ្រាន់តែទាក់ទងនឹងមុខសញ្ញារបស់យើងប៉ុណ្ណោះនោះទេ តែក៏ទាក់ទងនឹងឫសគល់ផងដែរ។ យើងត្រូវការឲ្យព្រះជាម្ចាស់អត់ទោសបាបយើង ដកនូវសេចក្ដីក្រោធរបស់ទ្រង់ចេញពីយើង ហើយរាប់យើងជាសុចរិតក្នុងព្រះនេត្ររបស់ទ្រង់។ នេះឯងគឺជាអ្វីដែលយើងត្រូវការនាពេលឥឡូវនេះ និងអស់កល្បជានិច្ច។ ពេលដែលគ្រូគង្វាល (ក្នុងនាមជាគ្រូពេទ្យខាងឯព្រលឹងវិញ្ញាណ) មិនបានធ្វើរោគវិនិច្ឆ័យលើបញ្ហាដ៏ត្រឹមត្រូវ នោះគាត់ក៏នឹងវាយថ្នាំទៅកាន់អ្នកជំងឺរបស់គាត់ដោយប្រើ

ប្រាស់ដំណឹងល្អដ៏ខុសឆ្គងផងដែរ ដែលនេះគឺដូចជាថ្នាំដ៏មិនល្អអញ្ចឹង ហើយការនោះនឹងបណ្តាលឲ្យអ្នកឈឺកាន់តែឈឺដុនដាបទៅៗ។

## ការបកស្រាយខុសទី៣៖ ការដកអំណាចពីដំណឹងល្អចេញ

ពេលដែលសាវ័ក ប៉ុល សរសេរទៅកាន់ក្រុមជំនុំកូរិនថូស គាត់ កំពុងតែកែតម្រង់បញ្ហាដែលយើងឃើញសព្វថ្ងៃនេះផងដែរ។ ក្រុមជំនុំកូរិនថូសបានទទួលដំណឹងល្អដ៏ពិតពីបបូរមាត់នៃសាវ័ក ប៉ុល (១កូរិនថូស ១៥:១-៤) ប៉ុន្តែយូរៗទៅ គ្រូអធិប្បាយក៏ចាប់ផ្តើមប្តូរសារឲ្យស៊ីគ្នាទៅនឹងចិត្តអ្នកស្តាប់។ ហើយខណៈពេលដែលពួកគាត់ផ្លាស់ប្តូរសារនៃដំណឹងល្អចេញ ពួកគាត់មិនគ្រាន់តែបានផ្លាស់ប្តូរការផ្តោតលើចំណុចចម្បងចោលប៉ុណ្ណោះទេ ប៉ុន្តែពួកគាត់ដកអំណាចពីដំណឹងល្អចេញតែម្តង។

ក្រុមជំនុំដែលអធិប្បាយដំណឹងល្អ ដែលសន្យាភាពចម្រុងចម្រើនក៏តែងតែប្រព្រឹត្តការខុសឆ្គងដូចនេះដែរ។ គ្រូគង្វាលរបស់ពួកគាត់ទំនងជានឹងលើកឡើងក្នុងសេចក្តីអធិប្បាយរបស់គាត់អំពីឈើឆ្កាង ហើយថែមទាំងថាព្រះគ្រីស្ទបានសុគតសម្រាប់

អំពើបាបយើង ប៉ុន្តែពួកគាត់នឹងថាគោលបំណងនៃការសុគត របស់ព្រះគ្រីស្ទគឺសម្រាប់ឲ្យយើងទទួលបានការព្យាបាល និងភាពចម្រុងចម្រើនឡើង។ តាមពិតទៅ នេះគឺជាប្រធានបទដែលស៊ីគ្នាជាមួយនឹងក្រុមជំនុំទាំងអស់ ព្រោះមានមនុស្សជាច្រើនកំពុងតែរងទុក្ខ ហើយមានការខ្វះខាតខាងឯផ្នែកថវិកា ក៏ដូចជាការឈឺថ្កាត់ទៀតផង។ យើងគ្រប់គ្នាសុទ្ធតែមានតម្រូវការ និងសេចក្ដីប្រាថ្នាផ្នែកសម្ភារៈនិយម។ វាពិតជាសារដែលទាក់ទាញមែនៈ *ចូរមកកាន់ព្រះយេស៊ូវ នោះលោកអ្នកនឹងមានជីវិតដ៏ល្អប្រសើរឥឡូវនេះភ្លាម។* ប៉ុន្តែ នេះគឺជាសារដ៏តូចតាចណាស់ ព្រោះវាមិនមានអំណាចដូចដែលដំណឹងល្អដ៏ពិតមាននោះទេ តែគឺអំណាចដែលអាចសង្គ្រោះមនុស្សប្រុស មនុស្សស្រី និងកុមារាកុមារី*ចេញពីអំពើបាបរបស់ពួកគេបាន* (ម៉ាថាយ ១:២១)។

មនុស្សយើងមិនចូលចិត្ត បើមានមនុស្សណាម្នាក់ប្រាប់យើងថាយើងជាមនុស្សមានបាបដ៏អាក្រក់ ឬក៏កំពុងតែធ្លាក់នរកនោះទេ។ យើងចង់ឮគេប្រាប់ពីរបៀបដែលយើងនឹងទទួលការលើកមុខលើកមាត់នៅកន្លែងធ្វើការ ប្រសើរជាងអ្នកផ្សេងក្នុងលោកីយ៍នេះ ហើយទទួលបានការដោះស្រាយយ៉ាងលឿនទាក់ទងនឹងបញ្ហារបស់យើងលើលោកនេះ។ ហេតុដូច្នេះហើយបានជាដំណឹង

ល្អដែលមិនផ្តោតលើចំណុចទាំងនេះ គឺមិនសូវមានន័យសោះ ចំពោះមនុស្សជាច្រើន (១កូរិនថូស ១:១៨)។ ហើយការនេះ កើតឡើងព្រោះនិស្ស័យយើងមានភាពខ្វាក់ខាងឯព្រលឹងវិញ្ញាណ ហើយក៏គ្មានញាណដឹងអំពីភាពស្រស់ស្អាតរបស់ព្រះជាម្ចាស់ដ៏ នៅអស់កល្បជានិច្ច។ ប៉ុន្តែ ជាជាងប្រកាសដំណឹងល្អដែលព្រះ ជាម្ចាស់ប្រើប្រាស់សម្រាប់ដាស់តឿនឲ្យមនុស្សមានបាបមើល ឃើញសិរីល្អ ភាពសង្ហា និងសេចក្តីសង្គ្រោះរបស់ព្រះជាម្ចាស់ គ្រូ គង្វាលដែលអធិប្បាយដំណឹងល្អដែលសន្យាភាពចម្រុងចម្រើន បែរជាបោះបង់ចោលដំណឹងល្អ ហើយព្យាយាមស្វែងរកភាពស្កប់ ចិត្តនៃសេចក្តីប្រាថ្នា ដែលគ្មានការកោតខ្លាចព្រះទៅវិញ។ សារ របស់ពួកគាត់គ្មានលទ្ធភាពក្នុងការសង្គ្រោះឡើយ។ គ្រូគង្វាល ដែលអធិប្បាយដំណឹងល្អដែលសន្យាភាពចម្រុងចម្រើនបានប្តូរ ចេញនូវអំណាចនៃដំណឹងល្អជាមួយនឹងសារដែលគ្មានអំណាច។

ប្រសិនបើលោកអ្នកបានយល់ព្រមទទួលជឿថា ព្រះគ្រីស្ទ បានសង្គ្រោះលោកអ្នក ដើម្បីឲ្យលោកអ្នកមានភាពចម្រុងចម្រើន ក្នុងជីវិតនេះ នោះមានន័យថា លោកអ្នកបានដាក់ក្តីសង្ឃឹម លើសារដែលគ្មានអំណាចហើយ។ ផ្ទុយពីដំណឹងល្អរបស់ព្រះ ជាម្ចាស់ ដែលបានបើកសម្តែងមកកាន់យើងក្នុងព្រះគម្ពីរ ដំណឹង

ល្អដែលសន្យាភាពចម្រុងចម្រើនមិនអាចសង្គ្រោះព្រលឹងវិញ្ញាណរបស់លោកអ្នកទេ (រ៉ូម ១:១៦) តែវាក៏ថែមទាំងមិនអាចផ្ដល់ជីវិតដល់លោកអ្នកផងដែរ (២ធីម៉ូថេ ១:៩-១០)។ វាមិនអាចផ្ដល់នូវសន្តិភាពដល់លោកអ្នកជាមួយនឹងព្រះជាម្ចាស់បានឡើយ (រ៉ូម ៥:១) ឬក៏ផ្សះផ្សាលោកអ្នកជាមួយនឹងទ្រង់បានដែរ (២កូរិន-ថូស ៥:១៨-២០)។ ដំណឹងល្អដែលសន្យាភាពចម្រុងចម្រើនមិនអាចនាំលោកអ្នកចូលមកក្នុងគ្រួសាររបស់ព្រះជាម្ចាស់បានទេ (យ៉ូហាន ១:១២-១៣) វាមិនអាចផ្ដល់នូវក្ដីសង្ឃឹមនៃជីវិតអស់កល្បជានិច្ចដល់លោកអ្នក (កូឡុស ១:២១-២៣) ឬក៏ធានាថាលោកអ្នកនឹងរស់ឡើងវិញបានដែរ (យ៉ូហាន ១១:២៥-២៧)។ ប៉ុន្តែ អំណាចនៃដំណឹងល្អរបស់ព្រះជាម្ចាស់គឺថា ទ្រង់អាចសង្គ្រោះលោកអ្នក*យ៉ាងអស់កល្បជានិច្ច* ដោយប្ដូរឋានៈរបស់លោកអ្នកពីមនុស្សដែលស្ថិតក្រោមសេចក្ដីក្រោធរបស់ព្រះអង្គ ហើយស័ក្តិសមនឹងធ្លាក់នរក ឲ្យក្លាយទៅជាបុត្រាបុត្រីរបស់ព្រះជាម្ចាស់ដែលទ្រង់រាប់ជាសុចរិតយ៉ាងអស់កល្បជានិច្ច។ នេះឯងគឺជាអំណាច។

ប្រសិនបើលោកអ្នកបានបែរចេញពីការអធិប្បាយអំពីឈើឆ្កាង នោះមានន័យថា លោកអ្នកបានបែរចេញពីសារតែមួយគត់

ដែលមានអំណាចក្នុងការសង្គ្រោះបុគ្គលណាម្នាក់ពីអំពើបាប។ ព្រះគ្រីស្ទត្រូវតែសុគត ព្រោះនោះគឺជាផ្លូវតែមួយគត់ក្នុងការបង់ថ្លៃលោះអំពើបាបរបស់យើង។ តើផ្ទះថ្មីមួយនោះ ឡានថ្មី ឬក៏ការងារថ្មីតម្រូវឲ្យព្រះរាជបុត្រារបស់ព្រះជាម្ចាស់ត្រូវសុគតដែរឬទេ? មើលទៅដំណឹងល្អដែលសន្យាភាពចម្រុងចម្រើនហាក់បីដូចជាស៊ីគ្នានឹងសម័យនេះណាស់ ហើយវាក៏ពិតជាល្បីមែន ប៉ុន្តែតាមរយៈការផ្តោតលើព្រះពរខាងឯផ្នែកសម្ភារៈនិយម វាមើលរំលងចំណុចស្នូលនៃដំណឹងល្អ ហើយក៏ដកគោលបំណង និងអំណាចសំខាន់ៗចេញពីសារនៃដំណឹងល្អផងដែរ។

## ការបកស្រាយខុសទី៤៖
## ការលួចសិរីល្អរបស់ព្រះជាម្ចាស់

កំហុសឆ្គងដ៏សាមញ្ញបំផុតដែលបុគ្គលគ្រប់ៗរូបធ្លាប់ប្រព្រឹត្តគឺការគិតថា៖ *«ខ្ញុំគឺជាចំណុចស្នូលនៃចក្រវាល»*។ ពេលដែលយើងអានព្រះគម្ពីរ នោះយើងមិនគ្រាន់តែចាប់ផ្តើមយល់ឃើញថា ព្រះជាម្ចាស់ជាព្រះដែលបានបង្កើតនូវរាល់គ្រប់អ្វីៗនោះទេ ប៉ុន្តែយើងក៏ឃើញដែរថា រាល់គ្រប់អ្វីៗដែលទ្រង់បានបង្កើតមកគឺអំពី*ទ្រង់*។ ព្រះគម្ពីរ និងដំណឹងល្អផ្ទាល់ចង្អុលបង្ហាញឲ្យយើង

សម្លឹងមើលព្រះជាម្ចាស់ដោយឥតឈប់ឈរ។ ហើយពេលដែលយើងគិតអំពីការសម្ដែងរបស់ព្រះជាម្ចាស់លើលោកនេះ និងក្នុងព្រះគម្ពីរ នោះពាក្យដែលយើងត្រូវប្រើប្រាស់ម្ដងហើយម្ដងទៀតគឺ *សិរីល្អ*។ យើងមិនអាចចាប់ផ្ដើមយល់ពីភាពធ្ងន់ធ្ងរនៃអំពើបាប ឬក៏ការគ្រោងទុក និងគោលបំណងនៃដំណឹងល្អបានឡើយ លុះត្រាតែយើងចាប់ផ្ដើមយល់ពីសិរីល្អរបស់ព្រះជាម្ចាស់ជាមុនសិន។

សិរីល្អរបស់ព្រះជាម្ចាស់គឺជាសភាព និងលក្ខណសម្បត្តិរបស់ទ្រង់ដែលលើសលប់ និងហួរហៀរ។ សិរីល្អរបស់ព្រះអង្គរួមមានដូចជាលក្ខណសម្បត្តិនៃភាពបរិសុទ្ធដ៏គ្មានដែនកំណត់ សេចក្ដីសុចរិត ក្ដីស្រឡាញ់ ភាពស្មោះត្រង់ ព្រះគុណ ក្ដីមេត្តាករុណា ភាពស្អាតស្អំ ភាពសង្ហា អំណាច និងប្រាជ្ញា។ ហើយតួនាទីនៃការមានភាពអរសប្បាយក្នុងការមានជីវិតលើលោកនេះដែលព្រះជាម្ចាស់បានបង្កើតគឺសម្រាប់សិរីល្អទ្រង់ និង*ការថ្វាយសិរីល្អដល់ទ្រង់*។ គោលបំណងនៃជីវិតរបស់យើងគឺ ផ្ដោតសំខាន់លើសិរីល្អរបស់ព្រះជាម្ចាស់ ទាក់ទាញចំណាប់អារម្មណ៍ចំពោះសិរីល្អរបស់ព្រះជាម្ចាស់ រស់នៅសម្រាប់សិរីល្អរបស់ព្រះជាម្ចាស់ និងមានការអរសប្បាយក្នុងសិរីល្អរបស់ព្រះជាម្ចាស់។ ព្រះជាម្ចាស់ពិតជាស័ក្ដិសមនឹងទទួលការនេះពីយើងណាស់។ ពេលដែល

យើងលួចសិរីល្អរបស់ព្រះជាម្ចាស់ នោះមិនមែនមានន័យថា ព្រះអង្គមានសិរីល្អតិចជាងមុននោះទេ។ ព្រះអង្គមិនអាចមាន សិរីល្អតិចជាងមុនបាននោះឡើយ។ ប៉ុន្តែ វាមានន័យថា យើង បានបរាជ័យខ្លួនឯងក្នុងការថ្វាយសិរីល្អទៅកាន់ទ្រង់តាមរបៀប ដែលយើងគួរនឹងធ្វើ។

នៅពេលដែលយើងមើលពីតម្រូវការដ៏ធំបំផុតរបស់មនុស្ស លោក នោះយើងមើលឃើញថាការបដិសេធក្នុងការថ្វាយសិរីល្អ ទៅកាន់ព្រះជាម្ចាស់ ស្របពេលដែលយើងបែរទៅថ្វាយសិរីល្អទៅ កាន់អ្វីៗដែលទ្រង់បានបង្កើតទៅវិញ គឺជាបញ្ហាដ៏ចម្បងនៃអំពើ បាបដែលញែកយើងចេញពីព្រះអាទិកររបស់យើង។ ពេលដែល ដំណឹងល្អដែលសន្យាភាពចម្រុងចម្រើនលាក់បាំងការយល់ដឹង បែបនេះអំពីអំពើបាប វាមិនបានបង្ហាញឲ្យយើងឃើញថា ការ ថ្វាយសិរីល្អដល់ព្រះជាម្ចាស់នោះគឺជាចំណុចស្នូលដែលបាត់ បង់ក្នុងជីវិតរបស់យើងឡើយ។

ពេលដែលគ្រូគង្វាលដែលអធិប្បាយពីដំណឹងល្អដែលសន្យា ពីភាពចម្រុងចម្រើនផ្តោតលើតម្រូវការផ្នែកសម្ភារៈនិយម នោះ មានន័យថា ពួកគាត់មិនបាននាំឲ្យមនុស្សយើងកែប្រែចិត្តទេ ពីព្រោះសាររបស់ពួកគាត់មិនបាននាំឲ្យមនុស្សយើងឃើញពីភាព

អស្ចារ្យនៃសិរីល្អរបស់ព្រះជាម្ចាស់ឡើយ។ ជាជាងបង្រៀនយើងពីអ្វីដែលព្រះជាម្ចាស់ស័ក្តិសមនឹងទទួលពីយើង ការអធិប្បាយពីភាពចម្រុងចម្រើនបែរជាលើកទឹកចិត្តយើងឲ្យគិតពីអ្វីដែលយើងនឹងយកពីព្រះជាម្ចាស់ទៅវិញ។ ការលោតរាំកញ្ចោងដោយអំណរដោយផ្តោតលើរបៀបដែលព្រះជាម្ចាស់នឹងធ្វើឲ្យលោកអ្នកក្លាយជាអ្នកមាន និងអ្នកពូកែ គឺមិនមែនជាការថ្វាយបង្គំព្រះជាម្ចាស់ទេ! ការយល់ខុសអំពីបញ្ហាដ៏ធំបំផុតរបស់មនុស្សលោកនឹងលួចសិរីល្អពីព្រះជាម្ចាស់។

ដូច្នេះ ដំណឹងល្អដែលសន្យាភាពចម្រុងចម្រើនក៏នឹងថែមទាំងលួចសិរីល្អពីព្រះជាម្ចាស់ តាមរយៈការមានគំនិតយល់ដឹងដោយខុសឆ្គងនឹង*គម្រោងការ*នៃដំណឹងល្អ។ ក្នុងកណ្ឌគម្ពីរ អេភេសូរ ១:៣-១៤ សាវ័ក ប៉ុល បានពន្យល់ពីគោលបំណង និងគម្រោងការនៃដំណឹងល្អ។ ក្នុងព្រះគ្រីស្ទ ព្រះជាម្ចាស់បានជ្រើសរើសយើងតាំងពីមុនព្រះអង្គចាក់គ្រឹះផែនដីមកម្ល៉េះ (១:៤) ព្រះអង្គបានគ្រោងទុកក្នុងការយកយើងធ្វើជាបុត្រាបុត្រីចិញ្ចឹមរបស់ទ្រង់ (១:៥) ទ្រង់បានប្រោសលោះយើងតាមរយៈព្រះលោហិត និងអត់ទោសឲ្យយើង (១:៧) យើងបានទទួលការបើកសម្តែង (១:៩) និងទទួលបានការបោះត្រាដោយព្រះវិញ្ញាណបរិសុទ្ធ

(១:១៣) ហើយព្រះអង្គក៏បានធានាថាយើងនឹងទទួលបានកេរ្តិ៍អាករនៅឯស្ថានសួគ៌ (១:១៤)។ នេះហើយជាមូលហេតុដែលដំណឹងល្អគឺពិតជាដំណឹងដ៏ល្អមែន។ ហើយចាប់ពីដើមរហូតដល់ចប់ ដំណឹងល្អរបស់ព្រះជាម្ចាស់គឺ «ដើម្បីនឹងសរសើរដល់ព្រះគុណដ៏ឧត្តមរបស់ទ្រង់» (១:៦, ១២, ១៤)។

ដំណឹងល្អផ្សះផ្សាយើងជាមួយនឹងព្រះជាម្ចាស់។ វាដកចេញនូវចំណុចដែលរារាំងយើងពីព្រះជាម្ចាស់ ហើយធ្វើឲ្យយើងមានសមត្ថភាពក្នុងការមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងព្រះជាម្ចាស់ ក្នុងលក្ខណៈដែលយើងអាចនឹងថ្វាយសិរីល្អដល់ទ្រង់យ៉ាងអស់កល្បជានិច្ច។ ហើយព្រះវរបិតាបានអនុញ្ញាតឲ្យយើងទទួលបានព្រះពរទាំងនេះក្នុងព្រះរាជបុត្រារបស់ទ្រង់ (សូមស្វែងរកឃ្លា «ក្នុងព្រះគ្រីស្ទ» ឬក៏ពាក្យពេចន៍ស្រដៀងគ្នានៅក្នុងកណ្ឌគម្ពីរអេភេសូរជំពូក១)។ យើងមិនអាចមានភាពអរសប្បាយក្នុងព្រះពរទាំងនេះក្រៅពីព្រះគ្រីស្ទបានឡើយ ព្រោះព្រះជន្មដ៏ល្អឥតខ្ចោះ និងព័ន្ធកិច្ចដែលព្រះអង្គបានសម្រេចនៅលើឈើឆ្កាងបានទិញព្រះពរទាំងនោះសម្រាប់យើង។ រាល់គ្រប់ចំណុច ក្នុងគម្រោងនៃដំណឹងល្អគឺ ដើម្បីបង្វែរយើងចេញពីការផ្តល់សិរីល្អដល់ខ្លួនឯង (អេភេសូរ ២:៨-៩) ហើយបង្ហាញយើងទៅកាន់សិរីល្អរបស់ព្រះ

ជាម្ចាស់ ដែលទ្រង់ជាក្ដីសង្ឃឹម និងគោលបំណងរបស់យើង។

ដំណឹងល្អគឺជាការថ្វាយសិរីល្អដល់ព្រះជាម្ចាស់។ ព្រះពរទាំងប៉ុន្មានដែលយើងបានលើកឡើង (ការជ្រើសរើស ការយកធ្វើជាកូនចិញ្ចឹម ការទទួលការប្រោសលោះ ការទទួលការអត់ទោស។ល។) គឺសុទ្ធតែជាចំណុចដែលនាំយើងទៅកាន់ព្រះជាម្ចាស់។ ហើយព្រះពរទាំងនេះអាចកើតឡើងបានតាមតែរយៈព្រះរាជបុត្រារបស់ព្រះជាម្ចាស់ ដែលព្រះអង្គបានទិញក្នុងរបៀបដែលនឹងនាំយើងឲ្យកាន់តែឃើញក្ដីមេត្តាករុណា និងក្ដីស្រឡាញ់ដ៏ពោរពេញដោយព្រះគុណរបស់ព្រះជាម្ចាស់។ យើងមិនអាចធ្វើអ្វីមួយ ដើម្បីឲ្យយើងស័ក្តិសមនឹងទទួលបានព្រះពរទាំងនេះបានទេ។ យើងបានត្រឹមតែទទួលប៉ុណ្ណោះ ដើម្បីឲ្យយើងដឹងថានរណាស័ក្តិសមទទួលសិរីល្អ។ ខណៈពេលដែលយើងមើលទៅកាន់ព្រះគ្រីស្ទតែមួយអង្គគត់ ដើម្បីទទួលយកនូវព្រះពរខាងក្រៅទាំងនោះ ដែលយើងមិនអាចធ្វើអ្វីមួយ ដើម្បីនឹងទទួលបានដោយខ្លួនឯង នោះយើងមិនអាចថ្វាយសិរីល្អទៅកាន់នរណាម្នាក់ក្រៅពីព្រះជាម្ចាស់ផ្ទាល់បានឡើយ (១កូរិនថូស ១:៣០-៣១)។

ប៉ុន្តែ ដំណឹងល្អដែលសន្យាភាពចម្រុងចម្រើនលួចសិរីល្អរបស់ព្រះជាម្ចាស់នៅក្នុងគ្រប់ជំហាន។ វាបានលួចតាមរយៈ

ការប្តូរអត្ថន័យនៃព្រះពរដែលយើងទទួលក្នុងព្រះគ្រីស្ទ។ អស់អ្នកដែលឮសាររបស់វានឹងត្រឡប់ទៅផ្ទះវិញដោយមានចិត្តចង់បានទ្រព្យសម្បត្តិដែលនៅលើផែនដីនេះ ជាជាងការចង់បានការប្រកបគ្នាជាមួយនឹងព្រះជាម្ចាស់។ នៅពេលដែលយើងចង់បានទ្រព្យសម្បត្តិខ្លាំងជាងចង់បានព្រះជាម្ចាស់ នោះទ្រព្យសម្បត្តិនឹងទទួលបានសិរីល្អ ដែលធាតុពិតគួរតែជាព្រះជាម្ចាស់តែមួយគត់ដែលគួរទទួលបានទេតើ។ ក្នុងរឿងប្រៀបប្រដូចនៃទ្រព្យសម្បត្តិដែលត្រូវបានលាក់ទុក ដែលមានចែងក្នុងកណ្ឌគម្ពីរ ម៉ាថាយ ១៣:៤៤ យើងឃើញថា បុរសម្នាក់នោះបានលក់ចោលនូវរាល់ទ្រព្យសម្បត្តិដែលគាត់មានលើលោកនេះ ដើម្បីឲ្យគាត់អាចនឹងទទួលបាននគរស្ថានសួគ៌។ អ្វីដែលដំណឹងល្អដែលសន្យាភាពចម្រុងចម្រើនផ្តល់ឲ្យយើងគឺផ្ទុយគ្នាទាំងស្រុងពីដំណឹងល្អដ៏ពិត។

ដំណឹងល្អដែលសន្យាភាពចម្រុងចម្រើនកាន់តែលួចសិរីល្អរបស់ព្រះជាម្ចាស់ តាមរយៈការដែលវាបង្វែរអ្នកស្តាប់ចេញពី *ភាពគ្រប់គ្រាន់របស់ព្រះគ្រីស្ទ* ជាជាងពឹងលើព្រះគ្រីស្ទតែមួយអង្គគត់។ ចំពោះគ្រូៗដែលអធិប្បាយដំណឹងល្អដែលសន្យាភាពចម្រុងចម្រើនបែរជាផ្សាយថាមានរបៀបជាច្រើនក្នុងការទទួលបានព្រះពរ៖ ការលាបប្រេង «ដាំគ្រាប់មួយ» «ទឹកបរិសុទ្ធ» ហើយនិង

ការអធិស្ឋានពី «បុរសរបស់ព្រះជាម្ចាស់»។ ដំណឹងល្អដ៏ខុសឆ្គងនេះបន្ទាបបន្ថោកភាពគ្រប់គ្រាន់របស់ព្រះគ្រីស្ទតាមរយៈការប្រកាសថាវិធីសាស្ត្រ និងមនុស្សគឺជាផ្លូវនៃការទទួលបានព្រះពរពីព្រះជាម្ចាស់ ពោលគឺដោយមិនពឹងលើព្រះគ្រីស្ទជាផ្លូវ។ សារបែបនេះបដិសេធថាទ្រង់គឺជាចំណុចស្នូល ហើយវាលួចសិរីល្អរបស់ព្រះជាម្ចាស់។

ពេលដែលយើងស្វែងរកព្រះពរ ក្រៅពីក្នុងព្រះគ្រីស្ទ ដែលមិនថ្វាយសិរីល្អដល់ព្រះជាម្ចាស់ នោះមានន័យថា យើងបានធ្វើឲ្យឈើឆ្កាងបែកចេញពីចំណុចកណ្ដាលនៃព្រះគម្ពីរ។ ព្រះបន្ទូលបង្រៀនយើងថា ផែនការគោលរបស់ព្រះជាម្ចាស់ក្នុងការនាំសិរីល្អដល់ព្រះនាមរបស់ទ្រង់គឺមានឈើឆ្កាងនៅក្នុងចំណុចកណ្ដាល។ ព្រះគម្ពីរសញ្ញាចាស់មានចំណុចសម្គាល់ និងតំណាងជាច្រើនដែលចង្អុលយើងទៅកាន់ព្រះគ្រីស្ទ និងព័ន្ធកិច្ចរបស់ទ្រង់នៅលើឈើឆ្កាង (លូកា ២៤:២៧)។ វិធីថ្វាយយញ្ញបូជាបង្រៀនយើងពីតម្រូវការដ៏ធំបំផុតរបស់យើង ហើយរៀបចំយើងក្នុងការប្រុងប្រៀបឲ្យទទួលព្រះគ្រីស្ទ (ហេព្រើរ ៩)។ ពួកហោរាបានទាយទុកពីការយាងមក និងការរងទុក្ខរបស់ទ្រង់ (១ពេត្រុស ១:១០-១២)។ ហើយជាអស់កល្បជានិច្ច យើងក៏នឹងមិនចេះ

ភ្លេច ក៏ដូចជាឈប់ថ្វាយសិរីល្អទៅកាន់ព្រះយេស៊ូវទាក់ទងនឹងយញ្ញបូជារបស់ទ្រង់ដែរ (វិវរណៈ ៥:៦, ១២)។

នៅក្នុងចំណុចកណ្តាលនៃផែនការរបស់ព្រះជាម្ចាស់គឺឈើឆ្កាង ដើម្បីនឹងបង្ហាញ និងចែកចាយសិរីល្អរបស់ទ្រង់យ៉ាងអស់កល្បជានិច្ច។ ប៉ុន្តែ គ្រូៗដែលអធិប្បាយដំណឹងល្អដែលសន្យាភាពចម្រុងចម្រើនមើលក្នុងព្រះគម្ពីរ ហើយរើសតែខគម្ពីរណាដែលលើកឡើងតែពីព្រះពរ នៅលើផែនដីនេះ ដែលរាស្ត្ររបស់ព្រះជាម្ចាស់ធ្លាប់ទទួលដោយអំណរពីមុន។ ការដែលពួកគាត់យកព្រះពរនៅលើផែនដីនេះមកធ្វើជាចំណុចចម្បងៗនៃព្រះគម្ពីរ គឺជាការប្រឆាំងផ្ទាល់ជាមួយនឹងរបៀបដែលព្រះគ្រីស្ទកាត់ស្រាយព្រះបន្ទូល (ឧ. លូកា ២៤:២៧)។ ការធ្វើបែបនេះធ្វើឲ្យមនុស្សយើងបែរចេញពីចំណុចស្នូលនៃឈើឆ្កាងរបស់ព្រះគ្រីស្ទ ហើយលួចសិរីល្អពីព្រះជាម្ចាស់។ គ្មានទោសណាធ្ងន់ជាងនេះ ដែលទាស់នឹងដំណឹងល្អដែលសន្យាភាពចម្រុងចម្រើននេះឡើយ៖ *វាលួចសិរីល្អរបស់ព្រះជាម្ចាស់។*

# សេចក្តីសន្និដ្ឋាន

ដំណឹងល្អដែលសន្យាភាពចម្រុងចម្រើនគឺជាសារដ៏គ្រោះថ្នាក់ ព្រោះវាធ្វើពុតថានាំយកនូវដំណឹងល្អ ប៉ុន្តែវានាំនូវដំណឹងល្អខុសឆ្គងដែលនាំមនុស្សយើងចេញពីព្រះជាម្ចាស់។ វាបង្ហាញគេថាព្រះជាម្ចាស់ជាព្រះដ៏តូចតាចកំប៉ិកកំប៉ុក ហើយគឺគ្រាន់តែជាផ្លូវនៃការនាំឲ្យមានអត្ថប្រយោជន៍ផ្នែកសម្ភារៈនិយមតែប៉ុណ្ណោះ។ វាបានធ្វើរោគវិនិច្ឆ័យលើបញ្ហាដ៏ធំបំផុតរបស់យើងខុស ទោះបើព្រះគម្ពីរបានចែងយ៉ាងច្បាស់ថាអំពើបាប និងការបែកចេញពីព្រះជាម្ចាស់ជាបញ្ហាដ៏ធំបំផុតរបស់យើងក៏ដោយ។ ទោះបើមានគេហៅសារដ៏ខុសឆ្គងនេះថា ជាដំណឹងល្អក៏ដោយ ក៏វាគ្មានអំណាចក្នុងការសង្គ្រោះយើងដែរ។ ខណៈពេលដែលវាបង្វែរចំណាប់អារម្មណ៍របស់យើងចេញពីសិរីល្អរបស់ព្រះជាម្ចាស់ទៅកាន់ការបង្កើតរបស់មនុស្សយើង ព្រមទាំងព្រះពរបណ្តោះអាសន្ន។ ដំណឹងល្អដែលសន្យាភាពចម្រុងចម្រើនថ្វាយសិរីល្អទៅកាន់មនុស្ស និងរបស់របរផ្សេងៗនៃលោកីយ៍នេះជាជាងព្រះជាម្ចាស់។ នេះហើយជាមូលហេតុដែលធ្វើឲ្យដំណឹងល្អនេះជាសារដ៏ខុសឆ្គង។

ជំពូក១៖

# ការយល់ដឹងដ៏ខុសឆ្គង លើព្រះគម្ពីរ

Kenneth Mbugua

*«ដូចជាក្នុងគ្រប់ទាំងសំបុត្ររបស់លោក ដែលសុទ្ធតែសម្ដែងពីសេចក្ដីទាំងនេះ នោះមានសេចក្ដីខ្លះដែលពិបាកយល់ ហើយពួកអ្នកខ្លៅល្ងង់ និងពួកមិនខ្ជាប់ខ្ជួន គេបង្វែរន័យសេចក្ដីទាំងនោះ ដូចជាគេបង្វែរបទគម្ពីរឯទៀតដែរ ឲ្យខ្លួនគេត្រូវវិនាស។ ដូច្នេះ ពួកស្ងួនភ្ងាអើយ ចូរប្រយ័ត្ន ដោយព្រោះអ្នករាល់គ្នាដឹងសេចក្ដីនោះជាមុនហើយ ក្រែងលោ ធ្លាក់ពីសេចក្ដីខ្ជាប់ខ្ជួនរបស់អ្នករាល់គ្នាចេញ ដោយបណ្ដោយតាមសេចក្ដីវង្វេងរបស់ពួកទទឹងច្បាប់នោះ» (២ពេត្រុស ៣:១៦-១៧)។*

ការកាត់ស្រាយដ៏ខុសឆ្គងលើព្រះគម្ពីរគឺជាឫសគល់នៃភាពខុសឆ្គងនៃដំណឹងល្អដែលសន្យាភាពចម្រុងចម្រើន។ ពួកគេបានបង្វែរព្រះបន្ទូលរបស់ព្រះជាម្ចាស់ដោយអចេតនា និងចេតនា ហើយជាលទ្ធផលសារនោះគឺជាការច្នៃឡើងដោយមនុស្សដែលបោកប្រាស់។ ប្រសិនបើលោកអ្នកពិតជាកំពុងតែសង្វាតរកសេចក្ដីពិត ហើយសិក្សាព្រះបន្ទូលដោយមានចិត្តបន្ទាបខ្លួនមែននោះព្រះជាម្ចាស់នឹងរំដោះលោកអ្នកចេញពីការកុហកដ៏សូន្យឈឹងនេះ ដែលជាដំណឹងល្អដ៏ខុសឆ្គង ហើយទ្រង់នឹងប្រទានជីវិតដល់លោកអ្នកក្នុងទ្រង់។ ទំនុកចិត្តរបស់ខ្ញុំមានមូលដ្ឋានលើសេចក្ដីសន្យារបស់ព្រះគ្រីស្ទក្នុងកណ្ឌគម្ពីរ យ៉ូហាន ៨:៣១-៣២៖ «បើអ្នករាល់គ្នានៅជាប់ក្នុងពាក្យខ្ញុំ នោះអ្នករាល់គ្នាជាសិស្សខ្ញុំមែន អ្នករាល់គ្នានឹងស្គាល់សេចក្ដីពិត ហើយសេចក្ដីពិតនោះនឹងប្រោសឲ្យអ្នករាល់គ្នាបានរួច»។

ព្រះជាម្ចាស់បានបើកសម្ដែងសេចក្ដីពិតដល់យើងក្នុងព្រះគម្ពីរ។ ប៉ុន្តែ សេចក្ដីពិតនេះមានការប្រកួតប្រជែងជាច្រើនណាស់ ដូចជាចិត្តដែលជាគ្រឿងបញ្ឆោតរបស់យើង (យេរេមា ១៧:៩) និងសាតាំង «ដែលបាននាំលោកីយ៍ទាំងមូលឲ្យវង្វេងចេញ» (វិវរណៈ ១២:៩) ព្រមទាំងលោកីយ៍ដែលពោរពេញដោយសេចក្ដី

កុហក។ ក្នុងនាមជាគ្រីស្ទបរិស័ទ យើងត្រូវតែចងចាំដោយឥតឈប់ឈរថាសេចក្តីពិតគឺមិនអាស្រ័យលើការបោះឆ្នោត ទស្សនៈ ឬក៏ការប្រកួតប្រជែងដែលមានប្រជាប្រិយនោះឡើយ។ ព្រះជាម្ចាស់បានបើកសម្តែងសេចក្តីពិតដល់យើង ហើយដាច់ខាតយើងត្រូវតែខំប្រឹងយល់នូវអ្វីដែលទ្រង់កំពុងតែប្រាប់យើង។ តើយើងអាចធ្វើការនេះបានដោយរបៀបណា?

ដាច់ខាត! យើងត្រូវតែចូលទៅកាន់ព្រះគម្ពីរដោយសួរថា «តើព្រះជាម្ចាស់សព្វព្រះហឫទ័យណែនាំអំពីអ្វីក្នុងបទគម្ពីរនេះ?» នេះដូចជាសំណួរដែលយើងត្រូវសួរពេលដែលយើងអានសំបុត្រ ឬក៏សារពីគ្នាទៅវិញទៅមក។ យើងអានសារទាំងមូល ហើយព្យាយាមសន្មតថា តើអ្នកនិពន្ធចង់មានន័យយ៉ាងដូចម្តេច ព្រមទាំងព្យាយាមចាំពីអ្វីដែលបុគ្គលម្នាក់នោះធ្លាប់សរសេរមកកាន់យើង ហើយក៏ថែមទាំងព្យាយាមយល់ពាក្យពេចន៍ដែលយើងមិនសូវស្គាល់ផងដែរ។ ហើយពេលដែលយើងយល់ច្បាស់ពីអត្ថន័យនៃសារ នោះយើងនឹងឆ្លើយតបយ៉ាងសមស្រប។

ប៉ុន្តែ គ្រូអធិប្បាយជាច្រើនកាត់ស្រាយព្រះបន្ទូលព្រះជាម្ចាស់ដោយមានការយកចិត្តទុកដាក់តិចជាងការដែលពួកគាត់កាត់ស្រាយសារពីមិត្តភក្តិរបស់ខ្លួនទៅទៀត។ ជានិច្ចជាកាល គ្រូៗ

ដែលអធិប្បាយដំណឹងល្អដែលសន្យាភាពចម្រុងចម្រើនចូលទៅកាន់ព្រះបន្ទូលព្រះជាម្ចាស់ក្នុងករណីថាវាអាចមានន័យតាមតែពួកគាត់ចង់ឲ្យវាមានន័យតាមចិត្តខ្លួន។ ពួកគាត់យកឃ្លាចេញដោយខុសបរិបទ ហើយមើលរំលងខគម្ពីរផ្សេងៗ ព្រមទាំងបត់បែនពាក្យពេចន៍ទៀតផង។ ប្រសិនបើមានគេអានសំបុត្រ និងសាររបស់យើងក្នុងរបៀបដូចគ្នា នោះគេក៏នឹងយល់យើងក្នុងរបៀបដ៏ខុសឆ្គងផងដែរ។ យើងមិនគួរឲ្យមានកំហុសបែបនេះកើតឡើងចំពោះសារដ៏សំខាន់បំផុតជាងគេបានឡើយ។ ចូរកុំមើលរំលងដំណឹងល្អរបស់ព្រះជាម្ចាស់ ព្រោះលោកអ្នករវល់ពេកក្នុងការព្យាយាមបង្កើតដំណឹងល្អមួយបែបផ្សេងទៀត។

ប្រសិនបើលោកអ្នកចូលរួមក្នុងក្រុមជំនុំណាមួយ ហើយឮដំណឹងល្អដែលសន្យាពីភាពចម្រុងចម្រើននោះលោកអ្នកនឹងមានការពិបាកណាស់ក្នុងការទទួលជឿថា វាមិនមែនជាដំណឹងល្អពីព្រះគ្រីស្ទ។ យ៉ាងហោចណាស់ លោកអ្នកក៏ធ្លាប់ទន្ទិញឲ្យចាំមាត់នៅខគម្ពីរមួយចំនួនក្នុងព្រះគម្ពីរដែលហាក់បីដូចជាការអះអាងពីទេវវិទ្យាលើភាពចម្រុងចម្រើនដែរ។ ប៉ុន្តែ បញ្ហាគឺមិនមែនលើខគម្ពីរដែលលោកអ្នកបានរៀនសូត្រនោះទេ តែលើរបៀបដែលគ្រូៗដែលអធិប្បាយដំណឹងល្អដែលសន្យាភាពចម្រុងចម្រើនកាត់

ស្រាយយ៉ាងខុសឆ្គងវិញទេតើ។

ក្នុងជំពូកនេះ យើងចង់លើកឡើងនូវការកាត់ស្រាយដ៏ខុសឆ្គងម្តងហើយម្តងទៀតមួយចំនួនលើព្រះគម្ពីរដែលគ្រូៗប្រើប្រាស់សម្រាប់ប្រកាសដំណឹងល្អដែលសន្យាភាពចម្រុងចម្រើន។ យើងចង់រកមើលនូវអ្វីដែលព្រះជាម្ចាស់ពិតជាកំពុងមានបន្ទូលមកកាន់យើងក្នុងគម្ពីរទាំងនោះ តាមរយៈការសិក្សាលើបរិបទនៃខគម្ពីរ ហើយដកស្រង់យកនូវអត្ថន័យចេញ ជាជាងដាក់ការកាត់ស្រាយរបស់យើងលើខគម្ពីរទាំងនោះ។ ដាច់ខាត! យើងត្រូវតែមើលព្រះបន្ទូលរបស់ព្រះជាម្ចាស់ដោយមានការគោរពកោតខ្លាច និងការយកចិត្តទុកដាក់។

## ភាពក្រីក្ររបស់ទ្រង់ និងទ្រព្យសម្បត្តិរបស់យើង

ចូរយើងចាប់ផ្ដើមមើលក្នុងកណ្ឌគម្ពីរ ២កូរិនថូស ៨:៩ «ដ្បិតអ្នករាល់គ្នាបានស្គាល់ព្រះគុណនៃព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នាហើយ ថាទោះបើទ្រង់ជាសេដ្ឋីក៏ដោយ គង់តែទ្រង់បានត្រឡប់ជាក្រ ដោយព្រោះអ្នករាល់គ្នា ដើម្បីឲ្យអ្នករាល់គ្នាបានមានឡើង ដោយសារសេចក្ដីកម្ររបស់ទ្រង់»។ គ្រូៗអធិប្បាយដំណឹងល្អដែលសន្យាភាពចម្រុងចម្រើនប្រើប្រាស់ខគម្ពីរ

នេះដោយយកមកប្រកាសថាព្រះគ្រីស្ទបានសុគត ដើម្បីធ្វើឲ្យយើងក្លាយជាអ្នកមាន។ ប៉ុន្តែ ប្រសិនបើលោកអ្នកអាននូវបរិបទនៃកណ្ឌគម្ពីរ២កូរិនថូសជំពូក៨ នោះភ្លាមៗលោកអ្នកនឹងឃើញថា បរិបទនេះគឺនិយាយអំពីការដែលគ្រីស្ទបរិស័ទផ្គត់ផ្គង់ទៅកាន់អ្នកដទៃ។ ហើយលើសពីនេះទៅទៀត គ្រីស្ទបរិស័ទដែលសាវ័ក ប៉ុល កំពុងស្នើសុំឲ្យក្រុមជំនុំកូរិនថូសត្រាប់តាមក្នុងការផ្គត់ផ្គង់ដោយមានការលះបង់គឺជាអ្នកដែលក្រជាងក្រុមជំនុំកូរិនថូសទៅទៀត។

*«បងប្អូនអើយ យើងខ្ញុំប្រាប់ឲ្យអ្នករាល់គ្នាដឹង ពីព្រះគុណនៃព្រះ ដែលបានផ្តល់មកពួកជំនុំទាំងប៉ុន្មាន នៅស្រុកម៉ាសេដូនថា កាលមានសេចក្តីទុក្ខលំបាកកំពុងតែល្បងគេជាខ្លាំង នោះសេចក្តីអំណរជាបរិបូរ នឹងសេចក្តីកំសត់ទុគ៌តរបស់គេ បានបណ្តាលឲ្យគេមានចិត្តសទ្ធាដ៏លើសលប់វិញ» (២កូរិនថូស ៨:១-២)។*

អស់អ្នកដែលសាវ័ក ប៉ុល កំពុងលើកឡើងគឺជាគំរូនៃការកោតខ្លាចព្រះ (គឺគ្រីស្ទបរិស័ទដ៏ក្រីក្រនៅឯស្រុកម៉ាសេដូន) ដែលពួកគាត់កំពុងលះបង់ ដើម្បីផ្គត់ផ្គង់តម្រូវការរបស់អ្នកដទៃ។ បន្ទាប់

មក ក្នុងខ៩នៃជំពូកនេះសាវ័ក ប៉ុល បានលើកឡើងពីចំណុចគោលដោយប្រៀបធៀបពួកគេទៅនឹងគំរូដ៏ល្អលើសខ្លួនពួកគេទៅទៀត ពោលគឺព្រះអង្គដែលបានលះបង់ខ្លួនឯងផ្ទាល់ ដើម្បីប្រយោជន៍របស់យើង។

ដូច្នេះ វាជាការខុសឆ្គងទាំងស្រុងហើយក្នុងការអានជំពូកនេះ ហើយសន្និដ្ឋានថាវានិយាយអំពីការដែល*យើងក្លាយជាអ្នកមាន*។ តែផ្ទុយពីនោះទៅវិញ មានគំរូពីរយ៉ាងដែលយើងគួរគ្រាប់តាម ព្រះជាម្ចាស់កំពុងតែបង្រៀនយើងតាមរយៈសាវ័ក ប៉ុល ថាយើងគួររស់នៅដោយមានការលះបង់ និងសន្តានចិត្តល្អ។ ការមានទ្រព្យសម្បត្តិគឺមិនមែនជាមូលហេតុដែលក្រុមជំនុំម៉ាសេដូន និងព្រះគ្រីស្ទមានអំណរនោះទេ ប៉ុន្តែមកពីក្តីស្រឡាញ់របស់ព្រះជាម្ចាស់ដែលនាំឲ្យពួកគាត់ហ៊ានផ្តត់ផ្គង់យ៉ាងច្រើនក្រៃលែង*ដល់តម្រូវការអ្នកដទៃ*។

ប៉ុន្តែ បើដូច្នេះមែន តើអ្វីទៅជាទ្រព្យសម្បត្តិដែលខគម្ពីរនេះលើកឡើងថា ព្រះគ្រីស្ទបានលះបង់ ហើយគ្រីស្ទបរិស័ទនឹងទទួលបាន? តើព្រះគ្រីស្ទបានលះបង់ទ្រព្យសម្បត្តិផ្នែកសម្ភារៈនិយម ដើម្បីឲ្យទ្រង់ក្លាយជាព្រះសង្គ្រោះ? ព្រះគម្ពីរ និងតក្កដ៏សាមញ្ញនឹងបង្ហាញយើងយ៉ាងច្បាស់ថា នោះ*មិនមែន*ជាអ្វីដែល

ព្រះគ្រីស្ទបានលះបង់ទេ។

*«កុំឲ្យគ្រប់គ្នាស្វែងរកតែប្រយោជន៍ផ្ទាល់ខ្លួនឡើយ ត្រូវស្វែងរកចំពោះអ្នកដទៃផង ត្រូវតែមានគំនិតគិតដូចជាព្រះគ្រីស្ទយេស៊ូវវិញ ដែលទោះបើទ្រង់មានរូបអង្គជាព្រះក៏ដោយ គង់តែមិនបានរាប់សេចក្តីដែលស្មើនឹងព្រះនោះ ទុកជាសេចក្តីដែលគួរកាន់ខ្ជាប់ឡើយ គឺទ្រង់បានលះបង់ព្រះអង្គទ្រង់ មកយករូបភាពជាបាវបម្រើវិញ ព្រមទាំងប្រសូតមកមានរូបជាមនុស្សផង» (ភីលីព ២:៤-៧)។*

ពិតប្រាកដណាស់! កាលព្រះគ្រីស្ទនៅលើផែនដី ព្រះអង្គជាអ្នកក្រីក្រ ដូចដែលព្រះគម្ពីរដំណឹងល្អទាំងបួនបានបើកបង្ហាញ (លូកា ៩:៥៨)។ ប៉ុន្តែ ដូចដែលខគម្ពីរខាងលើបានពន្យល់ ព្រះគ្រីស្ទបានបន្ទាបខ្លួនដោយយាងចេញពីស្ថានសួគ៌ និង*ពីការប្រកបគ្នាខាងឯវិញ្ញាណដ៏ស្និទ្ធស្នាល និងពីសិរីល្អជាមួយនឹងព្រះវរបិតាទ្រង់*ដែលព្រះអង្គមានអំណរជាមួយគ្នានៅទីនោះ ដើម្បីយាងមកយកនិស្ស័យលើផែនដីជាមនុស្ស។ នោះគឺល្អប្រសើរ

យ៉ាងខ្លាំងជាងទ្រព្យសម្បត្តិសម្ភារៈនិយម។ ទ្រព្យសម្បត្តិដែលព្រះគ្រីស្ទបានលះបង់ (ជាបណ្ដោះអាសន្ន) សម្រាប់យើងគឺជាទ្រព្យសម្បត្តិខាងវិញ្ញាណ និងនៅឯស្ថានសួគ៌។ ហើយ ជាចុងបញ្ចប់ នេះគឺជាទ្រព្យសម្បត្តិដែលព្រះគ្រីស្ទសុគតសម្រាប់យើង៖ ការផ្សះផ្សា និងការប្រកបគ្នាជាមួយនឹងព្រះជាម្ចាស់ (យ៉ូហាន ១៧:២៤)។

ប៉ុន្តែ នៅសម័យកាលដែលនឹងមកដល់ ពេលនោះនឹងមានផ្លូវដែលធ្វើពីមាសក្នុងក្រុងយេរូសាឡឹមថ្មី បើយោងតាមកណ្ឌគម្ពីរវិវរណៈជំពូក២១ (វិវរណៈ ២១:២១)។ តើនោះគឺជាការជំរុញចិត្តរបស់គ្រីស្ទបរិស័ទក្នុងការចង់ទៅទីក្រុងនោះមែនឬ? សូមបន្តអាន ពីព្រោះពីរខបន្ទាប់ទៀត នោះលោកអ្នកនឹងឃើញថា សិរីល្អរបស់ព្រះវរបិតា និងកូនចៀមនឹងធ្វើឲ្យស្ថានសួគ៌មានពន្លឺ (វិវរណៈ ២១:២៣)។ ប្រាកដណាស់! *ការនេះ*នឹងធ្វើឲ្យគ្រីស្ទបរិស័ទមានអំណរខ្លាំងជាងផ្លូវដែលធ្វើពីមាសទៅទៀត។

ប្រសិនបើលោកអ្នកមានមន្ទិលសង្ស័យពីអ្វីដែលព្រះគម្ពីររាប់ថាសំខាន់ សូមរកមើលខគម្ពីរយោងទាក់ទងនឹងព្រះពរផ្នែកសម្ភារៈនិយមក្នុងកណ្ឌគម្ពីរវិវរណៈ ហើយបន្ទាប់មករកមើលខគម្ពីរយោងដែលនិយាយពីសិរីល្អ និងការថ្វាយបង្គំព្រះជាម្ចាស់។

ដួងចិត្តដែលស្រឡាញ់ព្រះជាម្ចាស់នឹងប្រាថ្នាចង់ទៅដល់ថ្ងៃដែលយើងនឹងចូលរួមក្នុងការថ្វាយបង្គំ និងសរសើរទ្រង់។ ហើយពួកបរិសុទ្ធណាដែលមានការស្កប់ស្កល់ក្នុងព្រះជាម្ចាស់នឹងចង់ផ្គត់ផ្គង់ដូចក្រុមជំនុំម៉ាសេដូន និងព្រះគ្រីស្ទ ជាជាងការរវីរវល់នឹងការថាតើខ្លួនអាចប្រមូលយកអ្វីខ្លះសម្រាប់ជីវិតឥឡូវនេះ។

## សុខភាព និងការប្រោសឲ្យជា

កណ្ឌគម្ពីរ អេសាយ ៥៣:៥ គឺជាខគម្ពីរមួយដែលពួកគេប្រើប្រាស់ជាសំណើថាព្រះជាម្ចាស់នឹងធ្វើឲ្យយើងមានសុខភាពល្អ «តែទ្រង់ត្រូវរបួស ដោយព្រោះអំពើរំលងរបស់យើង ក៏ត្រូវវាយជាំ ដោយព្រោះអំពើទុច្ចរិតរបស់យើងទេ ឯការវាយផ្ចាលដែលនាំឲ្យយើងបានជាមេត្រី នោះបានធ្លាក់ទៅលើទ្រង់ ហើយយើងរាល់គ្នាបានប្រោសឲ្យជាដោយសារស្នាមរំពាត់នៅអង្គទ្រង់»។ ចំណុចសម្គាល់៖ ជាដំបូង ខគម្ពីរមួយនេះ និងខគម្ពីរនៅជុំវិញខគម្ពីរនេះគឺកំពុងតែពណ៌នាពីការរងទុក្ខរបស់ព្រះមេស្ស៊ី និងការសុគតជាយញ្ញបូជារបស់ទ្រង់សម្រាប់យើង។ តើហេតុអ្វីបានជាព្រះគ្រីស្ទរងទុក្ខ ហើយសុគត? ខគម្ពីរបានពន្យល់យ៉ាងច្បាស់ថាព្រះអង្គបានសុគតសម្រាប់អំពើរំលង និងអំពើទុច្ចរិតរបស់យើង

ព្រមទាំងអំពើបាបរបស់យើងដែរ។ ប្រសិនបើព្រះអង្គបានសុគតសម្រាប់អំពើបាបរបស់យើង តើអ្វីទៅជាលទ្ធផលនៃការប្រោសឲ្យជាដែលការសុគតរបស់ទ្រង់នាំឲ្យមាន? អត្ថន័យយ៉ាងច្បាស់នៃខគម្ពីរគឺថា យើងបានទទួលការប្រោសឲ្យជាចេញពីពិរុទ្ធភាពនៃអំពើបាបរបស់យើងតាមរយៈការលះបង់របស់ព្រះគ្រីស្ទ។

ដូចដែលសាវ័ក ពេត្រុស បានលើកឡើងថា «ទ្រង់បានផ្ទុកអំពើបាបរបស់យើងរាល់គ្នា នៅលើរូបអង្គទ្រង់ ជាប់លើឈើឆ្កាង ដើម្បីឲ្យយើងបានរស់ខាងឯសេចក្ដីសុចរិត ដោយបានស្លាប់ខាងឯអំពើបាបហើយ គឺដោយស្នាមជាំរបស់ទ្រង់ ដែលអ្នករាល់គ្នាបានជា» (១ពេត្រុស ២:២៤)។ ការដែលយើងបានស្លាប់ខាងឯអំពើបាប និងការដែលយើងរស់នៅក្នុងសេចក្ដីសុចរិត គឺជាការប្រោសឲ្យជាដ៏អស់កល្បជានិច្ច និងគួរឲ្យស្ញប់ស្ញែងដែលយញ្ញបូជារបស់ព្រះគ្រីស្ទបានសម្រេចសម្រាប់យើង។

វាក៏ជាការពិតដែរ ដូចដែលព្រះគម្ពីរបានពន្យល់ ព័ន្ធកិច្ចរបស់ទ្រង់លើឈើឆ្កាងក៏ទាក់ទងនឹងការរងទុក្ខទាំងអស់ផងដែរ។ តាមរយៈការដោះស្រាយបញ្ហាអំពើបាបរបស់យើង ព្រះអង្គបានអះអាងថាលទ្ធផលនៃអំពើបាបរបស់យើងដែលបានបង្ខូចផែនដីនេះ មានរួមទាំងការរងទុក្ខ គឺនឹងត្រូវបានដកចេញ។ ប៉ុន្តែ ព្រះ

បន្ទូលរបស់ព្រះជាម្ចាស់ក៏បានលើកឡើងស្មើគ្នាយ៉ាងច្បាស់ដែលថា ការបញ្ចប់ដ៏អស្ចារ្យនៃសេចក្តីសង្គ្រោះនឹងមិនកើតឡើងរហូតទាល់តែដល់ថ្ងៃដែលព្រះយេស៊ូវយាងមកវិញ ដើម្បីនាំឲ្យសម័យនេះឈានដល់ទីបញ្ចប់ (រ៉ូម ៨:១៨-២៥; ១កូរិនថូស ១៥:២០-២៨)។ យើងមិនទទួលប្រយោជន៍នៃព័ន្ធកិច្ចទាំងអស់នេះរបស់ព្រះគ្រីស្ទលើលោកនេះទេ។

មានថ្ងៃមួយ រាងកាយរបស់យើងនឹងទទួលសិរីល្អ ផែនដីនេះនឹងទទួលការស្តារឡើងវិញ ហើយពេលនោះនឹងលែងមានការស្រក់ទឹកភ្នែកទៀតហើយ។ ជំនឿលើអនាគតដែលពិតជានឹងកើតឡើង ផ្តល់នូវកម្លាំងដល់យើងក្នុងការតស៊ូនឹងភាពឈឺចាប់ក្នុងលោកីយ៍នេះ «ខ្ញុំរាប់អស់ទាំងសេចក្តីទុក្ខលំបាកនៅជាន់នេះថា ជាសេចក្តីមិនគួរប្រៀបផ្ទឹមនឹងសិរីល្អ ដែលនឹងបើកសម្តែងមកឲ្យយើងរាល់គ្នាឃើញនោះទេ» (រ៉ូម ៨:១៨)។ យើងនឹងមិនគេចផុតពីការរងទុក្ខខណៈពេលដែលយើងរស់នៅក្នុងជីវិតដែលពុករលួយលើផែនដីដែលបានបាក់បែកនេះឡើយ ប៉ុន្តែយើងអាចមើលទៅកាន់អនាគតដែលនឹងកើតមានឡើងដោយមានទំនុកចិត្តថា រាល់អ្វីៗនឹងមិនអីទេ។

ប៉ុន្តែ តើមានសញ្ញាសម្គាល់នៃក្តីសង្ឃឹមតឡូវនេះដែល

រម្លឹកយើងថា ការរងទុក្ខនឹងទទួលបានការដកចេញទាំងស្រុង ដោយសារព័ន្ធកិច្ចរបស់ព្រះគ្រីស្ទដែរឬទេ? ប្រាកដណាស់! មានមូលហេតុដែលអ្នកនិពន្ធកណ្ឌគម្ពីរដំណឹងល្អបានពណ៌នាពីការប្រោសឲ្យជាថាជាការបំពេញកណ្ឌគម្ពីរ អេសាយ ៥៣:៤ (ម៉ាថាយ ៨:១៧)។ ហើយក៏មានមូលហេតុនៅពេលដែលព្រះយេស៊ូវប្រោសឲ្យរាងកាយជាផង និងអត់ទោសបាបផង។ លោកគ្រូ ចន មែកខធ័រ (John McArthur) ជួយបង្ហាញភាពភ្ជាប់គ្នារវាងការប្រោសឲ្យជា ការរងទុក្ខរបស់ព្រះគ្រីស្ទ និងការរងទុក្ខរបស់យើង៖

> *«ហោរា អេសាយ កំពុងតែលើកឡើងថា ព្រះមេស្ស៊ីនឹងទទួលលទ្ធផលនៃអំពើបាបជំនួសមនុស្ស ជាពិសេសការទុក្ខព្រួយ និងភាពស្រងូតស្រងាត់នៃជីវិតនេះ...សាវ័ក ម៉ាថាយ បានឃើញភាពស្រដៀងគ្នានៃការបំពេញក្នុងពាក្យពេចន៍របស់ហោរា អេសាយ ក្នុងព័ន្ធកិច្ចនៃការប្រោសឲ្យជារបស់ព្រះយេស៊ូវ ព្រោះអ្នកបម្រើបានបង់ថ្លៃលោះដោយព្រះជន្មទ្រង់ផ្ទាល់សម្រាប់ភាពឈឺថ្កាត់ដែលជាលទ្ធផលចេញពីអំពើបាបនេះ (៧,*

*៨; សូមអានបន្ថែមក្នុងកណ្ឌគម្ពីរ ១ពេត្រុស ២:២៤)។ ក្នុងពេលវេលាដ៏អស់កល្បជានិច្ចនៅឯស្ថានសួគ៌ រាល់ភាពឈឺថ្កាត់នឹងត្រូវបានដកចេញ ដូច្នេះការប្រោសឲ្យជាមានការរាប់បញ្ចូលក្នុងប្រយោជន៍នៃការប្រោសលោះរបស់ព្រះគ្រីស្ទ។»*[១]

ព័ន្ធកិច្ចនៃការព្យាបាលរបស់ព្រះគ្រីស្ទបានបំពេញទំនាយ និងបើកបង្ហាញអំណាចរបស់ទ្រង់ ហើយក៏ជាភស្តុតាងថា ព្រះអង្គជាព្រះជាម្ចាស់។ ប៉ុន្តែ ការប្រោសរាងកាយឲ្យជាគឺមិនមែនជាគោលបំណងចម្បងនោះឡើយ វាជាមធ្យោបាយ ដើម្បីនាំដល់ទីបញ្ចប់។ ការឈានដល់ទីបញ្ចប់គឺថា យើងនឹងទទួលជឿព្រះគ្រីស្ទ ដើម្បីឲ្យអំពើបាបយើងទទួលបានការអត់ទោស ហើយទទួលបានការផ្សះផ្សាជាមួយនឹងព្រះជាម្ចាស់ (យ៉ូហាន ២០:៣០-៣១)។ ពិតណាស់! ព្រះជាម្ចាស់នៃយើងនៅបន្តព្យាបាលជំងឺ។ ព្រះអង្គនៅតែបន្តធ្វើការអស្ចារ្យ។ ហើយយើងអាចដឹងយ៉ាងប្រាកដថា នឹងមានថ្ងៃមួយ ដែលនឹងលែងមានរោគជំងឺ និងការរងទុក្ខទៀតហើយ។

---

១ *The MacArthur Study Bible*, កែសម្រួល John MacArthur, Jr. អេឡិចត្រូនិក កែសម្រួល (Nashville: Word, ១៩៩៧), អេសាយ ៥៣:៤។

ប៉ុន្តែ ចូរកុំប្រើប្រាស់ព្រះគម្ពីរក្នុងលក្ខណៈខុសឆ្គង ដើម្បីអះអាងក្តីសន្យាដែលព្រះជាម្ចាស់មិនដែលប្រទានឲ្យសោះ។

ព្រះជាម្ចាស់មិនបានសន្យាថា ជីវិតនេះនឹងមិនមានការរងទុក្ខឡើយ។ ប៉ុន្តែ ព្រះអង្គបានសន្យាចំពោះយើងថា យើងនឹងមានព្រះគុណក្នុងការរងទុក្ខរបស់យើង (២កូរិនថូស ១២:៩-១០) ហើយនៅទីបំផុតសេចក្តីល្អៗតាមរយៈការរងទុក្ខរបស់យើង (រ៉ូម ៨:២៨)។ ដូចនឹងសាវ័ក ប៉ុល យើងឱបក្រសោបក្តីសង្ឃឹមនៃការរស់ឡើងវិញក្នុងការរងទុក្ខ (ភីលីព ៣:១០-១១)។ យើងមានជំនឿលើដំណឹងល្អ ហើយឱបទំនុកចិត្តដែលយើងមានក្នុងព្រះគ្រីស្ទដែលនឹងនៅគង់វង្សយូរអង្វែងជាងការឈឺចាប់ដែលយើងមានក្នុងជីវិតនេះ។[២]

## ការអធិស្ឋានរបស់យើង និងក្តីសន្យារបស់ព្រះជាម្ចាស់

ពេលដែលគ្រីស្ទបរិស័ទប្រឈមមុខនឹងភាពពិបាកក្នុងជីវិតនេះ នោះពួកគាត់នឹងអធិស្ឋានសូមកម្លាំង ការដឹកនាំ និងជំនួយពីព្រះជាម្ចាស់។ ការអធិស្ឋានគឺជាចំណុចចាំបាច់ណាស់សម្រាប់ជីវិតអ្នកជឿ និងក្រុមជំនុំ។ ប៉ុន្តែ សុខភាពនៃជីវិតអធិស្ឋានគឺមិន

២ យើងនឹងមើលបន្ថែមទៀតលើប្រធានបទនេះក្នុងជំពូកនិយាយអំពីការរងទុក្ខ។

អាស្រ័យលើចំនួនពាក្យអធិស្ឋាននោះទេ។ អ្វីដែលយើងអធិស្ឋានបើកសម្ដែងពីដួងចិត្តរបស់យើង។ ជាទូទៅ ក្រុមជំនុំដែលអធិប្បាយដំណឹងល្អដែលសន្យាភាពចម្រុងចម្រើនមានពេលអធិស្ឋានយូរក្នុងកម្មវិធីរបស់ពួកគេ ហើយនោះគឺជាការល្អ។ ប៉ុន្តែអ្វីដែលយើងអធិស្ឋានទូលសុំនោះសំខាន់ជាងរយៈពេលនៃការដែលយើងចំណាយពេលអធិស្ឋានទៅទៀត។

គ្រូៗដែលអធិប្បាយដំណឹងល្អដែលសន្យាភាពចម្រុងចម្រើនលើកទឹកចិត្តក្រុមជំនុំឲ្យអធិស្ឋានដោយឈរលើសេចក្ដីសន្យាដែលពួកគាត់បានយល់ច្រឡំអត្ថន័យ ហើយឲ្យអធិស្ឋានសុំដោយមានការជំរុញចិត្តមិនត្រឹមត្រូវ។ ក្ដីសន្យាដែលថាគ្រីស្ទបរិស័ទអាចនឹងទូលសុំអ្វីក៏បានពីព្រះវរបិតា ហើយទ្រង់នឹងប្រទានឲ្យពួកគាត់ គឺយើងអាចរកឃើញពីរទៅបីកន្លែងក្នុងកណ្ឌគម្ពីរដំណឹងល្អ។ ក្ដីសន្យានេះគឺជាក្ដីសន្យាមួយដ៏ល្អបំផុតក្នុងព្រះគម្ពីរ ហើយវាក៏ជាក្ដីសន្យាដ៏ល្អប្រសើរជាងការដែលគ្រូៗដែលអធិប្បាយដំណឹងល្អដែលសន្យាភាពចម្រុងចម្រើនបានយល់ទៅទៀត។

ព្រះជាម្ចាស់សន្យាថានឹងឆ្លើយតបនូវសេចក្ដីអធិស្ឋានរបស់កូនៗទ្រង់។ នោះគឺជាអ្វីដែលខគម្ពីរកំពុងលើកឡើង ហើយនោះ

ក៏ជាអត្ថន័យនៃអ្វីដែលខគម្ពីរនោះបានលើកឡើងផងដែរ។ ប៉ុន្តែនេះក៏មិនមែនជាចំណុច *ទាំងអស់*ដែលខគម្ពីរទាំងនេះកំពុងតែលើកឡើង និងកំពុងតែផ្តល់អត្ថន័យនោះដែរ។ ចូរយើងពិនិត្យឲ្យកាន់តែស៊ីជម្រៅលើកណ្ឌគម្ពីរ យ៉ូហាន ១៥:៧ ថែមទៀត «បើអ្នករាល់គ្នានៅជាប់នឹងខ្ញុំ ហើយពាក្យខ្ញុំនៅជាប់ក្នុងអ្នករាល់គ្នា នោះចូរសូមអ្វីតាមតែប្រាថ្នាចុះ សេចក្តីនោះនឹងបានសម្រេចដល់អ្នករាល់គ្នាជាមិនខាន»។

ខគម្ពីរនេះមានការចាប់ផ្តើមដោយមានលក្ខខណ្ឌ៖ *«បើអ្នករាល់គ្នានៅជាប់នឹងខ្ញុំ ហើយពាក្យខ្ញុំនៅជាប់ក្នុងអ្នករាល់គ្នា។»* ប្រសិនបើលោកអ្នកដកលក្ខខណ្ឌនេះចេញពីឃ្លា នោះលោកអ្នកនឹងប្រាកដជាយល់ក្តីសន្យានេះខុសជាមិនខាន។ បើយើងនៅជាប់ក្នុងព្រះយេស៊ូវគ្រីស្ទ និងព្រះបន្ទូលរបស់ទ្រង់នៅជាប់ក្នុងយើង នោះអ្វីៗដែលយើងទូលសូមគឺជាការដែលព្រះអង្គសព្វព្រះហឫទ័យក្នុងការប្រទានឲ្យ។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់គឺជាព្រះហឫទ័យរបស់ទ្រង់ដែលត្រូវបានបើកសម្តែងមកកាន់យើង។ ហើយខណៈពេលដែលយើងកាន់តែស្គាល់ព្រះអង្គ ដូចដែលព្រះបន្ទូលព្រះអង្គបានបើកសម្តែងអំពីទ្រង់មកកាន់យើង រហូតដល់ចំណុចដែលសេចក្តីប្រាថ្នារបស់ព្រះអង្គក្លាយជាសេចក្តីប្រាថ្នា

របស់យើង នោះឆន្ទៈរបស់ទ្រង់ក៏នឹងក្លាយជាឆន្ទៈរបស់យើងផង ដែរ។ ពេលដែលការនេះពិតជាបានកើតឡើងមែន នោះយើងក៏ នឹងពិតជាប្រាថ្នាចង់បាន និងអធិស្ឋានសូមនូវអ្វីដែលព្រះជាម្ចាស់ សព្វព្រះហឫទ័យដែរ។

នោះក៏ជាតក្កដូចគ្នាដែរ ដែលយើងឃើញក្នុងខគម្ពីរមួយផ្សេង ទៀតដែលមានការយល់ច្រឡំ៖ «យើងដឹងថា គ្រប់ការទាំងអស់ ផ្សំគ្នា សម្រាប់សេចក្ដីល្អដល់ពួកអ្នកដែលស្រឡាញ់ព្រះ» (រ៉ូម ៨:២៨)។ តើនេះមានន័យថា ព្រះជាម្ចាស់នឹងផ្ដល់ឲ្យនូវរាល់អ្វីៗ ដែលខ្ញុំចង់បានមែនឬ? សូមអានម្ដងទៀត។ ពួកមនុស្សដែលខ គម្ពីរនេះកំពុងនិយាយទៅកាន់ គឺ*អស់អ្នកដែលស្រឡាញ់ទ្រង់*។ ប្រសិនបើលោកអ្នកស្រឡាញ់ព្រះជាម្ចាស់ នោះលោកអ្នកនឹងចង់ ឲ្យសិរីល្អ និងព្រះហឫទ័យទ្រង់មានក្នុងជីវិតរបស់លោកអ្នកខ្លាំង ជាងអ្វីៗផ្សេងៗទៀត។ ហើយនេះគឺជាសេចក្ដីប្រាថ្នាដែលព្រះ ជាម្ចាស់សព្វព្រះហឫទ័យចង់បំពេញ។ ព្រះយេស៊ូវគ្រីស្ទផ្ទាល់ បានបង្ហាញពីការនេះពេលដែលទ្រង់អធិស្ឋាន «ឱព្រះវរបិតានៃ ទូលបង្គំអើយ បើសិនជាបាន នោះសូមឲ្យពែងនេះកន្លងហួសពី ទូលបង្គំទៅ ប៉ុន្ដែ កុំតាមចិត្តទូលបង្គំឡើយ សូមតាមតែព្រះហឫ- ទ័យទ្រង់វិញ» (ម៉ាថាយ ២៦:៣៩)។ ក្នុងភាពជាមនុស្សរបស់

ព្រះអង្គ ទ្រង់សព្វព្រះហឫទ័យចង់ឲ្យមានការដោះលែងចេញពីភាពរងទុក្ខ។ ប៉ុន្តែ មានអ្វីមួយផ្សេងដែលព្រះអង្គសព្វព្រះហឫទ័យលើសហ្នឹងទៅទៀត—ព្រះហឫទ័យ និងសិរីល្អរបស់ព្រះវរបិតារបស់ទ្រង់។ នេះឯងជារបៀបអធិស្ឋានដែលព្រះជាម្ចាស់សព្វព្រះហឫទ័យក្នុងការទទួលពីយើង។

ព្រះគម្ពីរបង្រៀនយ៉ាងច្បាស់ថា ព្រះជាម្ចាស់ធ្វើនូវអ្វីដែលទ្រង់សព្វព្រះហឫទ័យនឹងធ្វើ «ការអ្វីក៏ដោយ ដែលព្រះយេហូវ៉ាសព្វព្រះហឫទ័យចង់ធ្វើ នោះក៏បានធ្វើទៅ ទាំងនៅលើមេឃ នៅផែនដី នៅក្នុងសមុទ្រ ហើយនៅទីជម្រៅទាំងប៉ុន្មានផង» (ទំនុកតម្កើង ១៣៥:៦)។ ប៉ុន្តែ ក្នុងព្រះគ្រីស្ទយេស៊ូវ ព្រះហឫទ័យរបស់ព្រះជាម្ចាស់ និងយើងមានការរួបរួមគ្នា។ ពេលដែលយើងកាន់តែមានការខ្ជាប់ខ្ជួនក្នុងព្រះបន្ទូលទ្រង់ នោះព្រះជាម្ចាស់នឹងបំផ្លាស់បំប្រែយើងតាមរយៈព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់ ក៏ដូចជានឹងរចនាសេចក្តីប្រាថ្នា តម្លៃ និងភាពឆេះឆួលរបស់យើងឲ្យក្លាយដូចជាព្រះអង្គដែរ។ អ្វីទាំងអស់នេះផ្តល់អត្ថន័យទៅលើឆន្ទៈរបស់យើង ដែលយើងបង្ហាញឲ្យព្រះជាម្ចាស់ជ្រាបតាមរយៈការអធិស្ឋានរបស់យើង។

តើចំណុចនេះធ្វើឲ្យសេចក្តីសន្យាក្នុងកណ្ឌគម្ពីរយ៉ូហានជំពូក

១៥មិនសូវមានភាពអស្ចារ្យមែនឬ? ទេ! ផ្ទុយពីនេះ ព្រះជាម្ចាស់ដែលមានពេញដោយអធិបតេយ្យភាពបានសម្រេចថា ព្រះអង្គនឹងបំពេញព្រះហឫទ័យទ្រង់តាមរយៈសេចក្ដីអធិស្ឋានរបស់គ្រីស្ទបរិស័ទ «ដ្បិតគឺជាព្រះហើយ ដែលបណ្ដាលចិត្តអ្នករាល់គ្នា ឲ្យមានទាំងចំណង់ចង់ធ្វើ ហើយឲ្យបានប្រព្រឹត្តតាមបំណងព្រះហឫទ័យទ្រង់ដែរ» (ភីលីព ២:១៣)។ ព្រះអង្គបានសម្រេចព្រះហឫទ័យថាឲ្យសេចក្ដីអធិស្ឋានរបស់លោកអ្នកមានអំណាច។ ព្រះជាម្ចាស់*មិនលើកឡើងថា* «មិនបាច់ខំអធិស្ឋានទេ ព្រោះយើងនឹងធ្វើនូវអ្វីដែលល្អបំផុតដោយមិនចាំបាច់ត្រូវការឯង។» ផ្ទុយពីនោះ ព្រះអង្គសព្វព្រះហឫទ័យក្នុងការធ្វើនូវអ្វីៗដែលល្អបំផុត*តាមរយៈការអធិស្ឋានរបស់យើង*។ ព្រះអង្គបំផ្លាស់បំប្រែចិត្តគំនិត ដើម្បីឲ្យមនុស្សយើងចង់បានព្រះទ័យដ៏ល្អឥតខ្ចោះរបស់ទ្រង់ ហើយពេលដែលគ្រីស្ទបរិស័ទអធិស្ឋានតាមសេចក្ដីប្រាថ្នាដែលចេះកោតខ្លាចទ្រង់ទៅកាន់ព្រះអង្គ នោះព្រះអង្គសព្វព្រះហឫទ័យធ្វើការ។

ព្រះគម្ពីរមានពេញទៅដោយគំរូដ៏ល្អៗជាច្រើនអំពីវាស្ដ្ររបស់ព្រះជាម្ចាស់ដែលអធិស្ឋានតាមព្រះហឫទ័យរបស់ព្រះអង្គ។ ឧទាហរណ៍ សូមអានពីរបៀបអធិស្ឋានរបស់ហោរា ដានីយ៉ែល ត្រង់

ថាសេចក្ដីអធិស្ឋានរបស់គាត់ គាត់បានគ្រាប់តាមព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ក្នុងកណ្ឌគម្ពីរដានីយ៉ែលជំពូក៩ យើងអានអំពីការដែលគាត់បានឃើញទំនាយរបស់ព្រះជាម្ចាស់ថា ការបំផ្លិចបំផ្លាញក្រុងយេរូសាឡឹមនឹងឈានដល់ទីបញ្ចប់បន្ទាប់ពីចិតសិបឆ្នាំកន្លងផុតទៅ ដែលនោះជាពេលវេលាដែលកំពុងឈានមកដល់ឆាប់ៗ។ តើការនោះបានធ្វើឲ្យហោរា ដានីយ៉ែល មានចិត្តស្កប់ស្កល់ដែរឬទេ? ទេ! តាមពិត ការនោះបានលើកទឹកចិត្តគាត់ឲ្យកាន់តែអធិស្ឋាន។ ការឆ្លើយតបរបស់ហោរា ដានីយ៉ែល គឺតមអាហារ និងអធិស្ឋានទៅកាន់ព្រះជាម្ចាស់ឲ្យទ្រង់សម្រេចព្រះហឫទ័យទ្រង់។ ព្រះជាម្ចាស់សព្វព្រះហឫទ័យនឹងសេចក្ដីអធិស្ឋានរបស់ហោរា ដានីយ៉ែល ហើយក៏បានឆ្លើយតបសេចក្ដីអធិស្ឋានរបស់គាត់ ខណៈពេលដែលពួកឈ្លើយវិលត្រឡប់ទៅស្រុកវិញ។ នេះឯងជារបៀបដែលព្រះជាម្ចាស់ធ្វើការ ហើយនេះក៏ជាគំរូនៃរបៀបដែលយើងគួរអធិស្ឋានផងដែរ។

ដាច់ខាត!  យើងត្រូវតែមានការប្រុងប្រយ័ត្នក្នុងការកាត់ស្រាយកណ្ឌគម្ពីរយ៉ូហានជំពូក១៥ និងខគម្ពីរដូចៗគ្នាផ្សេងៗទៀតដោយមើលថា តើព្រះគម្ពីរបង្រៀនយើងពីអ្វីទៅទាក់ទងនឹងរបៀបព្រះជាម្ចាស់សម្រេចព្រះហឫទ័យដ៏ពេញដោយអធិបតេយ្យ

ភាពរបស់ទ្រង់តាមរយៈការអធិស្ឋានរបស់យើង។ ពេលដែលដួងចិត្តរបស់យើងពេញទៅដោយព្រះបន្ទូលរបស់ព្រះជាម្ចាស់ នោះយើងក៏នឹងប្រាថ្នាចង់បានព្រះហឫទ័យ និងសិរីល្អរបស់ទ្រង់លើសខ្លួនឯង ដើម្បីឲ្យយើងអាចនឹងអធិស្ឋានដូចដែលព្រះគ្រីស្ទបានអធិស្ឋាននៅក្នុងសួនច្បារ គែតសេម៉ានី ដែរ។ ប៉ុន្តែ បើយើងមើលរំលងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ហើយចាប់ផ្តើមគិតតែពីសេចក្តីប្រាថ្នាដែលមិនចេះកោតខ្លាចព្រះជាម្ចាស់ នោះមានន័យថា យើងមិនបានកំពុងរស់នៅក្នុងព្រះយេស៊ូវគ្រីស្ទនៅឡើយទេ។ ហើយយើងក៏មិនអាចទាមទារជំនួយពីព្រះជាម្ចាស់បានដែរ ខណៈពេលដែលយើងទាស់ប្រឆាំងនឹងព្រះហឫទ័យទ្រង់។ ព្រះជាម្ចាស់មានគម្រោងការដ៏អស្ចារ្យទាក់ទងនឹងការអធិស្ឋាន ហើយយើងក៏មិនចង់បាត់ឱកាសរួមចំណែកក្នុងគម្រោងការនោះដែរ ដោយសារយើងបានកាត់ស្រាយព្រះបន្ទូលរបស់ទ្រង់យ៉ាងខុសឆ្គងក្នុងលក្ខណៈដ៏អាត្មានិយម។

## ការសាបព្រោះ និងការច្រូតកាត់

គំនិតមួយក្នុងចំណោមគំនិតជាច្រើនទៀតក្នុងព្រះគម្ពីរដែលមានគេបានប្រើប្រាស់យ៉ាងខុសឆ្គងខ្លាំងជាងគេ គឺទាក់ទងនឹង*ការ*

*សាបព្រោះ និងការច្រូតកាត់*។ ក្នុងក្រុមជំនុំជាច្រើនគេផ្សាយថា «គោលការណ៍នៃការច្រូតកាត់ និងការសាបព្រោះ»។ មានខគម្ពីរពីរដែលគេប្រើប្រាស់ម្តងហើយម្តងទៀតក្នុងការគាំទ្រគំនិតនេះ៖ កណ្ឌគម្ពីរ ២កូរិនថូស ៩:៦ («ខ្ញុំចង់និយាយដូច្នេះ គឺថា អ្នកណាដែលព្រោះដោយកំណាញ់ នោះនឹងច្រូតបានតិច ហើយអ្នកណាដែលព្រោះដោយសទ្ធា នោះនឹងច្រូតបានច្រើនវិញ») និងកណ្ឌគម្ពីរ កាឡាទី ៦:៧ («កុំឲ្យច្រឡំឡើយ នឹងបញ្ឆោតព្រះមិនបានទេ ដ្បិតពូជណាដែលមនុស្សព្រោះចុះ នោះនឹងច្រូតបានពូជនោះឯងវិញ»)។ តើអ្វីទៅជាសារនៃខគម្ពីរទាំងពីរនេះ?

ជាដំបូង យើងគួរគត់សម្គាល់ថា ខគម្ពីរនេះគឺងាយស្រួលយល់ណាស់។ ខគម្ពីរនេះមានន័យដូចនឹងអ្វីដែលមានចែង ហើយព្រះវិញ្ញាណបានចែងបែបនោះ ដែលនេះជំរុញឲ្យយើងសាបព្រោះដោយគិតពីចម្រូតនៅថ្ងៃអនាគត។ នេះឯងជារបៀបដែលជីវិតយើងមានដំណើរការជាធម្មតា។ យើងទាំងអស់គ្នាសុទ្ធតែចង់រស់នៅក្នុងរបៀបដែលនឹងបង្កើតផលផ្លែ។ ការសាបព្រោះនឹងគ្មានអត្ថន័យឡើយ បើយើងមិនមានសង្ឃឹមក្នុងការច្រូតកាត់។ បញ្ហាជាមួយនឹងគ្រូៗដែលអធិប្បាយដំណឹងល្អដែលសន្យាភាពចម្រុងចម្រើនគឺមិនមែនត្រង់ថាពួកគាត់រំពឹងឲ្យមានការ

ច្រូតកាត់បន្ទាប់ពីការសាបព្រោះនោះទេ ប៉ុន្តែត្រង់ថា*គំនិតរបស់គាត់អំពីអ្វីដែលយើងនឹងច្រូតនោះវាតូចពេកណាស់*។ ពួកគាត់គិតតែពីអ្វីៗដែលពួកគាត់អាចទទួលបានភ្លាមៗនេះ ខណៈពេលដែលពួកគាត់អាចនឹងទទួលបានអ្វីផ្សេងទៀតដ៏នៅអស់កល្បជានិច្ច។ ពួកគាត់ផ្តោតលើគោលប្រយោជន៍ដែលមិនអាចធ្វើឲ្យខ្លួនមានភាពស្កប់ស្កល់ ហើយបែរជាមើលរំលងព្រះពរដែលអាចនឹងផ្តល់ការស្កប់ស្កល់យ៉ាងជ្រាលជ្រៅ។ ហើយពួកគាត់អធិប្បាយពីទ្រព្យសម្បត្តិលុយកាក់ខណៈពេលដែលនៅខាងមុខគាត់មានអំណោយដែលមិនអាចកាត់ថ្លៃបាន។

គោលការណ៍នៃដំណឹងល្អដែលសន្យាភាពចម្រុងចម្រើន ទាក់ទងនឹងការសាបព្រោះ និងការច្រូតកាត់ គឺបែកឆ្ងាយចេញពីសេចក្តីបង្រៀននៃព្រះគម្ពីរក្នុងចំណុចជាច្រើន។ វាបង្ខូចទស្សនៈនៃស្ថានសួគ៌ដែលព្រះគម្ពីរលើកទឹកចិត្តឲ្យយើងមាន។ ទស្សនៈស្ថានសួគ៌នេះគួរតែជាចំណុចដែលជំរុញយើងឲ្យចេះគិតទាក់ទងនឹងរបៀបដែលយើងប្រើប្រាស់ (សាបព្រោះ) ពេលវេលា កម្លាំង ភាពប៉ិនប្រសព្វ និងលុយកាក់របស់យើង។

> *«កុំឲ្យប្រមូលទ្រព្យសម្បត្តិ ទុកសម្រាប់ខ្លួន នៅផែនដី ជាកន្លែងដែលមានកន្លាត នឹងច្រែះស៊ីបំផ្លាញ ហើយ*

*ចោរទំលុះប្លន់នោះឡើយ ត្រូវប្រមូលទ្រព្យសម្បត្តិ ទុកសម្រាប់ខ្លួន នៅឯស្ថានសួគ៌វិញ ដែលជាកន្លែងគ្មានកន្លាត ឬច្រែះស៊ីបំផ្លាញឡើយ  ក៏គ្មានចោរទំលុះ ឬប្លន់ផង ពីព្រោះសម្បត្តិទ្រព្យរបស់អ្នកស្ថិតនៅកន្លែងណា នោះចិត្តអ្នកក៏នឹងនៅកន្លែងនោះដែរ» (ម៉ាថាយ ៦:១៩-២១)។*

គំនិតត្រង់នេះគឺថា ការមានទ្រព្យសម្បត្តិគឺជាការល្អ ហេតុដូច្នេះហើយបានជាយើងគួរមានគោលដៅក្នុងការមានទ្រព្យសម្បត្តិដែលនឹងនៅអស់កល្បជានិច្ច ជាជាងទ្រព្យសម្បត្តិដែលច្រែះស៊ី ឬក៏កន្លាតស៊ីបំផ្លាញ ដែលនឹងមិននៅអស់កល្បជានិច្ចឡើយ។ ដំណឹងល្អដែលគ្រាន់តែផ្តល់ឲ្យមានទ្រព្យសម្បត្តិនៅលើផែនដីនេះ គឺជាដំណឹងល្អដ៏ក្រីក្រ ហើយអន់ណាស់។ ផ្ទុយពីនោះចំណេះដឹងនៃរាស្ត្ររបស់ព្រះជាម្ចាស់ត្រង់ថា ទ្រព្យសម្បត្តិរបស់ពួកគាត់ដែលនៅស្ថានសួគ៌ គឺជាចំណុចដែលផ្តល់ជាកម្លាំងចិត្តដល់ពួកគាត់ក្នុងការតស៊ូពេលមានការបៀតបៀន និងការដាក់ទ្រព្យសម្បត្តិរបស់ពួកគាត់លើផែនដីនេះដោយមានការហ៊ានលះបង់។ ដូចដែលអ្នកនិពន្ធកណ្ឌគម្ពីរហេព្រើរបានលើកឡើងទាក់ទងនឹងអ្នកអានសំបុត្ររបស់គាត់ដែលជាអ្នកជឿ៖ «ដ្បិត

អ្នករាល់គ្នាមានចិត្តអាណិតអាសូរ ដល់ពួកអ្នកដែលជាប់ចំណង ក៏ទ្រាំឲ្យមនុស្សប្លន់យករបស់ទ្រព្យខ្លួនដោយអំណរ ដោយដឹងថា ខ្លួនមានទ្រព្យសម្បត្តិ ដែលប្រសើរជាង ហើយក៏នៅជាប់លាប់ផង នៅឯស្ថានសួគ៌» (ហេព្រើរ ១០:៣៤)។ នេះឯងគឺជាការសាបព្រោះ និងការច្រូតកាត់ដែលព្រះជាម្ចាស់ប្រទានទៅកាន់រាស្ត្ររបស់ទ្រង់៖ ការសាបព្រោះខាងឯវិញ្ញាណ និងការច្រូតកាត់ដែលនៅអស់កល្បជានិច្ច។

ដំណឹងល្អដែលសន្យាភាពចម្រុងចម្រើនក៏លើកទឹកចិត្តឲ្យស្រឡាញ់លុយផងដែរ ខណៈពេលដែលព្រះគម្ពីរបានលើកឡើងយ៉ាងចំៗអំពីគ្រោះថ្នាក់នៃការរស់នៅបែបនេះ។ សេចក្តីបង្រៀនរបស់សាវ័ក ប៉ុល លើចំណុចនេះគឺយើងមិនត្រូវមើលរំលងឲ្យសោះ៖

> *«ដ្បិតការដែលស្រឡាញ់ប្រាក់ នោះហើយជាមេឫសនៃសេចក្តីអាក្រក់គ្រប់យ៉ាង ដែលអ្នកខ្លះបានឈោងតាម ហើយត្រូវលួងលោមឲ្យឃ្លាតចេញពីសេចក្តីជំនឿ ទាំងចាក់ទំលុះខ្លួនគេ ដោយសេចក្តីព្រួយលំបាកជាច្រើន» (១ធីម៉ូថេ ៦:១០-១១)។*

ចំណុចជាច្រើនដែលពួកគេប្រើប្រាស់ដោយហៅវាថា គោលការណ៍នៃការសាបព្រោះ និងការច្រូតកាត់ គឺជាគុំពិតជាចំណុចបិទបាំងសម្រាប់ការស្រឡាញ់លុយកាក់ទេតើ។ ប៉ុន្តែ មិនថាយើងហៅវាយ៉ាងម៉េចក៏ដោយ បើយើងគ្រាន់តែផ្តោតលើសម្ភារៈនិយមនោះយើងនឹងគ្រាន់តែទទួលបានប្រយោជន៍ខាងឯផ្នែកសម្ភារៈនិយមប៉ុណ្ណោះ មិនមែនប្រយោជន៍ខាងឯព្រលឹងវិញ្ញាណទ្បើយ។ ប្រាកដណាស់ លោកអ្នកនឹងច្រូតបាននូវអ្វីដែលលោកអ្នកសាបព្រោះ។ តាមពិតទៅ នៅចុងបញ្ចប់ មានមនុស្សជាច្រើនច្រូតការទុក្ខព្រួយ និងការឈឺចាប់ ក្រោយពីពួកគាត់អនុវត្តនូវអ្វីដែលខ្លួនគិតថាជាគោលការណ៍ចេញពីព្រះគម្ពីរ។ ប្រសិនបើយើងស្រឡាញ់លុយកាក់ ទោះបើព្រះជាម្ចាស់បានព្រមានយើងយ៉ាងចំៗថាកុំឲ្យស្រឡាញ់វា នោះយើងនឹងទទួលបានក្តីអរសប្បាយដែលមិននៅគង់វង្ស និងមានប្រយោជន៍តែបណ្តោះអាសន្ន។ ប៉ុន្តែ ដូចដែលលុយមិនអាចនាំមកនូវភាពស្កប់ស្កល់ដល់ព្រលឹងយើង ឬក៏ព្យាបាលដួងចិត្តរបស់យើងបាន នោះនៅចុងបញ្ចប់ការមិនស្តាប់បង្គាប់បែបនេះក្នុងការសាបព្រោះនឹងនាំមកនូវការកើតទុក្ខ និងសេចក្តីស្លាប់ជាមិនខាន។

លើសពីនោះទៅទៀត ផ្នត់គំនិតនៃដំណឹងល្អដែលសន្យាភាព

ចម្រុងចម្រើនទាក់ទងនឹងការសាបព្រោះ និងច្រូតកាត់គឺជាការ បដិសេធពីព្រះគម្ពីរទាំងស្រុងដោយពួកគាត់លើកឡើងថា ព្រះ ជាម្ចាស់មិនមានបញ្ហាអ្វីទេ បើយើងយករូបព្រះក្លែងក្លាយមក ជំនួសព្រះអង្គវិញ។ តើខ្ញុំចង់មានអត្ថន័យយ៉ាងដូចម្ដេចទៅ? ពេលដែលយើងប្រើប្រាស់ព្រះគម្ពីរទុកជាអំណះអំណាងសម្រាប់ ការដេញតាមលុយកាក់ដែលបានក្លាយជារូបព្រះក្លែងក្លាយរបស់ យើង នោះមានន័យថា យើងកំពុងតែចាត់ទុកព្រះជាម្ចាស់ជាអ្នក ស្ម័គ្រចិត្តក្នុងការផ្គត់ផ្គង់រូបព្រះក្លែងក្លាយដែលយើងចូលចិត្តជាង គេហើយ។ ប៉ុន្តែ សេចក្ដីក្រោធរបស់ព្រះជាម្ចាស់គឺឆេះយ៉ាងខ្លាំង ទាស់នឹងអស់អ្នកណាដែលយកសិរីល្អដ៏ស្រស់ស្អាតរបស់ទ្រង់ មកដាក់ជាលេខបន្ទាប់ ដើម្បីចេញទៅសង្វាតតាមព្រះនានា។

*«ប៉ុន្តែ សេចក្ដីអ្វីដែលមានប្រយោជន៍ដល់ខ្ញុំពីមុន នោះខ្ញុំបានរាប់ជាខាតវិញ ដោយព្រោះព្រះគ្រីស្ទ ហើយខ្ញុំ ក៏រាប់គ្រប់ទាំងអស់ទុកដូចជាខាតដែរ ដោយព្រោះសេច-ក្ដីដែលប្រសើរជាង គឺដោយស្គាល់ព្រះគ្រីស្ទយេស៊ូវ ជា ព្រះអម្ចាស់នៃខ្ញុំ ដែលដោយយល់ដល់ទ្រង់ ខ្ញុំបានខាត គ្រប់ទាំងអស់ ហើយបានរាប់ទាំងអស់ទុកដូចជាសំរាម ប្រយោជន៍ឲ្យបានព្រះគ្រីស្ទវិញ» (ភីលីព ៣:៧-៨)។*

អស់អ្នកណាដែលអនុវត្តគោលការណ៍នៃការសាបព្រោះ និងច្រូតកាត់ទាក់ទងនឹងដំណឹងល្អដែលសន្យាភាពចម្រុងចម្រើននឹងប្រាកដជាមិនអាចយល់ខគម្ពីរនេះបានឡើយ។ សាវ័ក ប៉ុល កំពុងតែលើកឡើងថា អ្វីៗដែលគ្រូៗដែលអធិប្បាយពីដំណឹងល្អដែលសន្យាភាពចម្រុងចម្រើនកំពុងចង់ឲ្យយើងសូមពីព្រះជាម្ចាស់ គឺជា *អ្វីៗដែលសាវ័ក ប៉ុល បានលះអាល័យចោល ដើម្បីឲ្យអាចទទួលយកព្រះជាម្ចាស់បាន។* តើ*លោកអ្នក*ចង់បានអ្វី៖ ទ្រព្យសម្បត្តិ ឬក៏ព្រះជាម្ចាស់? តើទ្រព្យសម្បត្តិរបស់លោកអ្នកនៅឯណា?

ចូរយើងពិនិត្យមើលឲ្យចំៗលើខគម្ពីរមួយចំនួនដែលគ្រូៗដែលអធិប្បាយពីដំណឹងល្អដែលសន្យាភាពចម្រុងចម្រើនប្រើប្រាស់ជាអំណះអំណាងទាក់ទងនឹងការបង្រៀនរបស់គេអំពីការសាបព្រោះ និងការច្រូតកាត់។ កណ្ឌគម្ពីរ ២កូរិនថូស ៩:៦ គឺស្ថិតនៅក្នុងបរិបទដូចគ្នាដែលយើងបានពិនិត្យមើលពីមុនៗមក ហើយត្រង់នេះសាវ័ក ប៉ុល កំពុងតែសរសើរដល់ក្រុមជំនុំម៉ាសេដូនទាក់ទងនឹងអំណោយទាននៃការផ្គត់ផ្គង់ផ្នែកថវិកាទៅកាន់ក្រុមជំនុំនៅឯក្រុងយេរូសាឡឹម មិនថាពួកគាត់ខ្លួនឯងក្រីក្រប៉ុណ្ណាក៏ដោយ។ តើសាវ័ក ប៉ុល បានបង្រៀនអ្វីចំពោះអស់អ្នកដែលផ្គត់ផ្គង់ដោយមានចិត្តសទ្ធា ថាពួកគេគួរនឹងរំពឹងទទួលអ្វីបានមកវិញ ដោយ

សារពួកគេមានចិត្តសទ្ធាបែបនោះ?

ពេលដែលគ្រីស្ទបរិស័ទសាបព្រោះដោយមានចិត្តសទ្ធា នោះពួកគាត់នឹងច្រូតកាត់សិរីល្អ និងព្រះកិត្តិយសដល់ព្រះជាម្ចាស់។ ហើយគ្មានចម្រូតណាល្អប្រសើរលើសនេះឡើយ! សូមបន្តអានក្នុងកណ្ឌគម្ពីរ២កូរិនថូសជំពូក៩ នោះលោកអ្នកនឹងឃើញថា សាវ័ក ប៉ុល បានលើកឡើងថាចិត្តសទ្ធារបស់ពួកគាត់ «នឹងបង្កើតសេចក្ដីអរព្រះគុណដល់ព្រះ» (៩:១១)។ តាមរយៈការផ្គត់ផ្គង់រាស្រ្តរបស់ព្រះជាម្ចាស់ ពួកគាត់បានបង្កើតឲ្យមាន «ការអរព្រះគុណជាច្រើនដល់ព្រះជាម្ចាស់ទៀតផង» (៩:១២ គគខ)។ ហើយអស់អ្នកដែលបានទទួលអំណោយទានក៏នឹង «សរសើរតម្កើងដល់ព្រះ ដោយព្រោះអ្នករាល់គ្នាសម្ដែងច្បាស់ថា ខ្លួនជាអ្នកចុះចូលតាមដំណឹងល្អនៃព្រះគ្រីស្ទពិត» (៩:១៣)។ ដូចដែលព្រះយេស៊ូវគ្រីស្ទបានបង្រៀនផងដែរ «ចូរឲ្យពន្លឺរបស់អ្នករាល់គ្នាបានភ្លឺនៅមុខមនុស្សលោកយ៉ាងនោះដែរ ដើម្បីឲ្យគេឃើញការល្អដែលអ្នករាល់គ្នាប្រព្រឹត្ត រួចសរសើរតម្កើង ដល់ព្រះវរបិតានៃអ្នករាល់គ្នា ដែលគង់នៅស្ថានសួគ៌» (ម៉ាថាយ ៥:១៦)។ សារនៃខគម្ពីរនេះគឺច្បាស់ណាស់៖ ចូរឲ្យ ដើម្បីឲ្យព្រះជាម្ចាស់ទទួលបានសិរីល្អ។ នៅពេលដែលយើងសាបព្រោះសម្រាប់ព្រះជាម្ចាស់ នោះ

យើងក៏នឹងច្រូតកាត់ព្រះពរដ៏ធំទាក់ទងនឹងការថ្វាយសិរីល្អ និងព្រះកិត្តិយសដល់ព្រះជាម្ចាស់។

ប៉ុន្តែ ទោះបើសាវ័ក ប៉ុល មិនបានសង្កត់លើអត្ថន័យនេះយ៉ាងខ្លាំងក៏ដោយ ក៏គាត់នៅតែបានលើកឡើងអំពីប្រយោជន៍ផ្នែកសម្ភារៈនិយមខ្លះៗផងដែរ។ តើសាវ័ក ប៉ុល បានពណ៌នាពីរបៀប និងគោលបំណងនៃព្រះពរទាក់ទងនឹងផ្នែកសម្ភារៈនិយមចំពោះអ្នកផ្គត់ផ្គង់ដែលមានចិត្តសទ្ធាដោយរបៀបណា? សាវ័កប៉ុល បានលើកឡើងថា អស់អ្នកដែលផ្គត់ផ្គង់នឹងទទួលបានយ៉ាងគ្រប់គ្រាន់ពីព្រះជាម្ចាស់ ដើម្បីឲ្យគាត់មានសមត្ថភាពបន្តប្រទានពរដល់អ្នកដទៃទៀត៖ «ហើយព្រះទ្រង់អាចនឹងធ្វើឲ្យគ្រប់ទាំងព្រះគុណបានចម្រើនដល់អ្នករាល់គ្នា ប្រយោជន៍ឲ្យមានទាំងអស់គ្រប់គ្រាន់ជានិច្ច ដើម្បីឲ្យបានចម្រើនឡើងខាងឯការល្អគ្រប់ជំពូក» (២កូរិនថូស ៩:៨)។ គាត់មិនបានសន្យាភាពហ៊ឺហាទៅកាន់ពួកគាត់ទេ ប៉ុន្តែគឺភាពគ្រប់គ្រាន់។ ហើយគោលបំណងនៃអ្វីៗដែលពួកគាត់ទទួលបាន គឺមិនមែនឲ្យប្រមូលទ្រព្យសម្បត្តិនោះទេ ប៉ុន្តែឲ្យផ្គត់ផ្គង់អ្នកដទៃវិញ៖ «អ្នករាល់គ្នានឹងបានចម្រើនកាន់តែច្រើនឡើងគ្រប់ជំពូក សម្រាប់ជាការសទ្ធាគ្រប់យ៉ាង» (៩:១១)។ ប្រសិនបើលោកអ្នកគិតថា ខគម្ពីរនេះ

កំពុងនិយាយសំដៅលើការដែលយើងក្លាយជាអ្នកមាន នោះលោកអ្នកបានមើលរំលងអត្ថន័យនៃខគម្ពីរទាំងនេះទាំងស្រុងហើយ។ ព្រះជាម្ចាស់បានសន្យាទៅកាន់បុត្រាបុត្រីរបស់ទ្រង់ថា ពួកគាត់នឹងមានគ្រប់គ្រាន់ ដើម្បីបម្រើទ្រង់ មិនមែនភាពហ៊ឺហា ដើម្បីនឹងមើលរំលងទ្រង់នោះទេ។

ចំណែកឯកណ្ឌគម្ពីរ កាឡាទី ៦:៧ វិញ ការដែលយើងសិក្សាបរិបទនឹងផ្តល់ជាព័ត៌មានដល់យើងថាសាវ័ក ប៉ុល ក៏កំពុងតែផ្តោតលើអ្វីផ្សេងទៀតឆ្ងាយណាស់ពីអ្វីដែលជាដំណឹងល្អដែលសន្យាភាពចម្រុងចម្រើន។ ខគម្ពីរនេះមិនមែនអំពីការទទួលយកនោះទេ ប៉ុន្តែគឺអំពីការផ្តល់ជូនទេតើ។ គ្រីស្ទបរិស័ទគួរតែ «យកអាសាគ្នាទៅវិញទៅមក» (៦:២) «ចែកគ្រប់ទាំងរបស់ល្អឲ្យដល់គ្រូ» (៦:៦) «កុំឲ្យយើងណាយចិត្តនឹងធ្វើការល្អឡើយ» (៦:៩) ហើយ «ធ្វើល្អដល់មនុស្សទាំងអស់» (៦:១០)។ ពិតណាស់ ការសាបព្រោះក្នុងជំពូកនេះគឺអំពីការប្រទានពរដល់អ្នកដទៃ។ ដូច្នេះ តើអ្វីទៅជាចម្រូត?

ត្រង់ចំណុចនេះសាវ័ក ប៉ុល បានលើកឡើងអំពីច្បាប់នៃការសាបព្រោះ និងការច្រូតកាត់ក្នុងលក្ខណៈនៃការព្រមានទាក់ទងនឹងលទ្ធផលនៃការមិនព្រមប្រព្រឹត្តការល្អ។ សាវ័ក ប៉ុល បាន

ព្រមានក្រុមជំនុំកាឡាទីថា «អ្នកណាដែលព្រោះខាងឯសាច់ឈាមរបស់ខ្លួន នឹងច្រូតបានសេចក្តីពុករលួយពីសាច់ឈាមនោះឯង តែអ្នកណាដែលព្រោះខាងឯព្រះវិញ្ញាណ នោះនឹងច្រូតបានជីវិតអស់កល្បជានិច្ច ពីព្រះវិញ្ញាណវិញ» (កាឡាទី ៦:៨)។ តាមពិតទៅ បទគម្ពីរនេះប្រាប់យើងថា ជាជាងការគាំទ្រដំណឹងល្អដែលសន្យាភាពចម្រុងចម្រើន សាវ័ក ប៉ុល កំពុងតែស្តីបន្ទោសដោយប្រើប្រាស់ពាក្យយ៉ាងធ្ងន់ធ្ងរ។ អស់អ្នកណាដែលសាបព្រោះសម្រាប់ព្រះជាម្ចាស់នឹងច្រូតបានព្រះពរខាងឯព្រលឹងវិញ្ញាណ។

ប្រសិនបើលោកអ្នកឲ្យទៅកាន់អ្នកដទៃដោយមានចិត្តចង់ទទួលបានទ្រព្យសម្បត្តិមកវិញសម្រាប់ខ្លួនឯង នោះមានន័យថា លោកអ្នកសាបព្រោះខាងឯសាច់ឈាមហើយ។ អស់អ្នកណាដែលដើរតាមសាច់ឈាមនឹងមិនទទួលបាននគរស្ថានសួគ៌ទុកជាមរតកឡើយ។ ប៉ុន្តែ ការប្រទានពរដល់អ្នកដទៃដែលមិនគិតពីខ្លួនឯង គឺជាភស្តុតាងថា ព្រះវិញ្ញាណបរិសុទ្ធកំពុងតែធ្វើការក្នុងលោកអ្នក។ ការទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច គឺជាចម្រូតសម្រាប់អស់អ្នកដែលកោតខ្លាចព្រះ ហើយត្រង់នេះ សាវ័ក ប៉ុល លើកទឹកចិត្តឲ្យក្រុមជំនុំកាឡាទីបន្តឆ្ពោះទៅមុខទៀត ព្រោះនៅថ្ងៃមួយពួកគាត់នឹងទទួលបានផលផ្លែនៃកិច្ចការ

របស់ពួកគាត់។ ព្រះជាម្ចាស់ផ្គត់ផ្គង់យើង ដើម្បីឲ្យយើងអាចផ្គត់-ផ្គង់អ្នកដទៃ ហើយរង្វាន់របស់យើងគឺមិនមែនខាងឯផ្នែកសម្ភារៈនិយម ឬក៏លោកីយ៍នេះទ្បើយ ប៉ុន្តែខាងឯវិញ្ញាណ ហើយនៅអស់កល្បជានិច្ច។

## ទេវវិទ្យានៃពាក្យពេចន៍ជំនឿ

សារដែលមានប្រជាប្រិយភាពមួយទៀតរបស់គ្រូៗដែលអធិ-ប្បាយដំណឹងល្អដែលសន្យាភាពចម្រុងចម្រើនគឺទេវវិទ្យានៃពាក្យពេចន៍ជំនឿ។ ពួកគាត់បង្រៀនថា ពាក្យពេចន៍របស់យើងមានអំណាចក្នុងការបង្កើតឲ្យមានអ្វីមួយកើតឡើង។ ពួកគាត់ថា យើងអាចត្រាស់ហៅឲ្យមានសុខភាពល្អ និងភាពចម្រុងចម្រើនឲ្យកើតឡើងបានតាមរយៈការដែលយើងប្រកាសសេចក្តីប្រាថ្នារបស់យើងដោយមានសេចក្តីសង្ឃឹមថានឹងទទួលបាន។ ជាថ្មីម្តងទៀត សេចក្តីបង្រៀនដ៏ខុសឆ្គងនេះមានមូលដ្ឋានលើការយល់ដឹងដ៏ខុសឆ្គងលើខគម្ពីរមួយចំនួន។

ជំនឿដែលពួកគាត់កំពុងអនុវត្តក្នុងសេចក្តីបង្រៀននេះគឺមិនមែនជាជំនឿលើព្រះជាម្ចាស់ទេ តែជាជំនឿជឿជាក់លើខ្លួនឯងវិញ។ ពួកគាត់បានលើកទឹកចិត្តឲ្យលោកអ្នកចាត់ទុកខ្លួនឯង

ថាជាចៅហ្វាយនៃជោគវាសនារបស់ខ្លួនឯងទៅវិញ។ បើលោកអ្នកគ្រាន់តែជឿ ហើយទូលសុំដោយមានទំនុកចិត្ត នោះលោកអ្នកអាចនឹងរៀបផ្លូវអនាគតខ្លួនឯង ហើយក៏នឹងទទួលបាននូវអ្វីៗដែលដួងចិត្តរបស់លោកអ្នកប្រាថ្នាចង់បានជាមិនខាន។ ពេលដែលបុគ្គលណាម្នាក់មិនទទួលបានរបស់សម្ភារៈនិយមដែលគាត់ទាមទារ និងជឿថានឹងទទួលបាន នោះពួកគាត់តែងតែទម្លាក់កំហុសលើការមិនមានជំនឿគ្រប់គ្រាន់។

ទោះបើភាគច្រើន គ្រូគង្វាលបែបនេះមិនមានមូលដ្ឋានលើព្រះបន្ទូលសម្រាប់សេចក្តីបង្រៀនរបស់ពួកគាត់ក៏ដោយ ក៏ពេលខ្លះពួកគាត់នឹងប្រើប្រាស់កណ្ឌគម្ពីរ ហេព្រើរ ១១:១ ជាអំណះអំណាងដែរ។ អ្នកនិពន្ធកណ្ឌគម្ពីរហេព្រើរបានលើកឡើងថា «រីឯជំនឿ នោះគឺជាចិត្តដែលដឹងជាក់ថានឹងបានដូចសង្ឃឹម»។ ដោយរំពឹងលើឃ្លា «ជាចិត្តដែលដឹងជាក់ថា» (ការបកប្រែមួយចំនួនទៀត «ជាការជឿជាក់លើអ្វី» (គខប និងគកស) «ធ្វើឲ្យ...មានអ្វី» (គគខ) គ្រូគង្វាលនៃពាក្យពេចន៍ជំនឿប្រើប្រាស់ខគម្ពីរនេះថា ជំនឿ*បង្កើត*ឲ្យមានអ្វីៗ។ បើនោះជាការពិតមែន នោះព្រះជាម្ចាស់នឹងមិនមែនជាព្រះអាទិករតែមួយអង្គគត់ឡើយ ប៉ុន្តែយើងក៏អាចនឹងមានចំណែកក្នុងការបង្កើតតាមរយៈការនិយាយនូវអ្វីៗ

ដែលចិត្តយើងចង់បានឲ្យកើតមានឡើងនោះដែរ។

ជាថ្មីម្តងទៀត ចម្លើយលើការកាត់ស្រាយដ៏ខុសឆ្គងនេះគឺៈ កាត់ស្រាយព្រះគម្ពីរដោយមានការគោរពកោតខ្លាច និងការមើលនូវបរិបទនៃខគម្ពីរដែលត្រូវបានទាញយកមកមើល។ តាមរយៈការមើលកណ្ឌគម្ពីរហេព្រើរ នោះយើងឃើញយ៉ាងច្បាស់ថា អ្នកនិពន្ធ*មិនមែន*កំពុងបង្រៀនឲ្យអ្នកអានពីរបៀបនៃការប្រើប្រាស់អំណាចនៃជំនឿ*ឲ្យផ្លាស់ប្តូរ*កាលៈទេសៈនៅជុំវិញខ្លួនឡើយ។ ប្រមាណខមុនៗ អ្នកនិពន្ធបានសរសើរអ្នកអានទាក់ទងនឹងការ «ទ្រាំនឹងទុក្ខលំបាក ទាំងតតាំងជាខ្លាំងដែរ» (ហេព្រើរ ១០:៣២) និង «ទ្រាំឲ្យមនុស្សប្លន់យករបស់ទ្រព្យខ្លួនដោយអំណរ» (ហេព្រើរ ១០:៣៤)។ បន្ទាប់មក ក្នុងខ៣៥ អ្នកនិពន្ធបានលើកទឹកចិត្តឲ្យពួកគេបន្តដោយមានទំនុកចិត្តដដែល ដែលពួកគាត់បានបង្ហាញក្នុងកាលៈទេសៈដ៏លំបាកលំបិន។ តើអ្វីទៅជាទំនុកចិត្តនោះ?

ជាដំបូង ទំនុកចិត្តនោះគឺជាជំនឿដែលផ្អែកលើការអត់ធ្មត់ មិនមែនលើការគិតថាខ្លួនឯងមានសិទ្ធិទទួលតែការល្អៗនោះទេ។ «ដ្បិតអ្នករាល់គ្នាត្រូវការនឹងសេចក្តីអត់ធ្មត់ ដើម្បីឲ្យបានទទួលសេចក្តីដែលបានសន្យា ដោយធ្វើតាមព្រះហឫទ័យព្រះ»

(ហេព្រើរ ១០:៣៦)។ យើងឃើញជំនឿនៃគ្រីស្ទបរិស័ទរបស់អ្នកអានកណ្ឌគម្ពីរហេព្រើរថាជាជំនឿពិតត្រង់ដោយពួកគាត់មានការទ្រាំទ្រនឹងការរងទុក្ខ មិនមែនគេចចេញនោះទេ៖ «តែយើងរាល់គ្នាមិនមែនជាពួកអ្នក ដែលថយទៅវិញ ឲ្យត្រូវវិនាសនោះឡើយ គឺជាពួកអ្នកដែលមានជំនឿសម្រាប់ឲ្យព្រលឹងបានសង្គ្រោះវិញ។» (ហេព្រើរ ១០:៣៩)។ លើសពីនោះទៅទៀត ទំនុកចិត្តមួយនេះផ្តោតលើអ្វីៗដែលនៅអស់កល្បជានិច្ច ដូចដែលយើងឃើញយ៉ាងច្បាស់លាស់ពីអំណះអំណាងនេះ៖ «ដោយដឹងថា ខ្លួនមានទ្រព្យសម្បត្តិ ដែលប្រសើរជាង ហើយក៏នៅជាប់លាប់ផង នៅឯស្ថានសួគ៌» (ហេព្រើរ ១០:៣៤)។ «រង្វាន់ជាធំ» របស់ពួកគាត់គឺមិនមែនជាអ្វីដែលមិនស្ថិតស្ថេរដូចជាសុខភាពនៃរាងកាយដែលនឹងត្រូវស្លាប់ ឬក៏ទ្រព្យសម្បត្តិដែលនឹងត្រូវទុកចោលឡើយ។

ជំនឿដែលមានចែងក្នុងកណ្ឌគម្ពីរហេព្រើរជំពូក១០ និង១១ បានលើកទឹកចិត្តឲ្យគ្រីស្ទបរិស័ទមើលរំលងការរងទុក្ខនៅបច្ចុប្បន្នកាលនោះ ហើយមើលទៅកាន់ធាតុពិតនៃភាពអស់កល្បជានិច្ចដែលត្រូវបានរៀបចំទុកសម្រាប់ពួកគាត់។ ទំនុកចិត្តក្នុងកេរ្ដិ៍មរតកនៅអនាគតរបស់ពួកគាត់បានផ្តល់ជាកម្លាំងចិត្តក្នុង*ការចោល*នូវទ្រព្យសម្បត្តិលើលោកីយ៍នេះ។ ខណៈពេលដែលលោកីយ៍នេះ

រស់នៅសម្រាប់អ្វីៗដែលពួកគាត់អាចទទួលបានឥឡូវនេះ គ្រីស្ទបរិស័ទមានការជំរុញចិត្តដែលខុសគ្នាផ្ទុយពីនោះទាំងស្រុង។

ដូច្នេះហើយបានជាគំរូនៃជំនឿដែលមានចែងក្នុងកណ្ឌគម្ពីរហេព្រើរជំពូក១១ គឺមិនមែនជាគំរូទាក់ទងនឹងអំណាចនៃការមានជំនឿដែលអាចបំផ្លាស់បំប្រែកាលៈទេសៈនោះទេ (ព្រះជាម្ចាស់ជាអង្គដែលបំផ្លាស់បំប្រែកាលៈទេសៈ មិនមែនជំនឿឡើយ)។ តែផ្ទុយទៅវិញ វាជាគំរូរបស់អស់អ្នកដែលប្រព្រឹត្តឡើងដោយមានមូលដ្ឋានលើអនាគតដ៏ពិតដែលមិនអាចមើលឃើញ លើកលែងតែតាមរយៈជំនឿ ព្រោះវាមិនមែនជារបស់សម្ភារៈនិយម ឬក៏នៅលោកីយ៍នេះឡើយ។ កណ្ឌគម្ពីរហេព្រើរជំពូក១០ និង១១មានរួមទាំងអ្នកជឿដែលត្រូវបានទទួលការធ្វើបាប វាយប្រហារ ចាប់ដាក់គុក ហើយថែមទាំងត្រូវបានគេសម្លាប់ទៀតផង។ ជំនឿរបស់ពួកគាត់បានធ្វើឲ្យពួកគាត់អាចទ្រាំទ្រនឹងការនោះបាន ហើយក្រោយពីស្លាប់ ទទួលបានគោលដៅ និងរង្វាន់នៃជំនឿរបស់ខ្លួនបានដែរពោលគឺសិរីល្អដ៏នៅអស់កល្បជានិច្ចដែលកំពុងរង់ចាំពួកគាត់។ «គេសង្វាតចង់បានស្រុក១ដ៏ប្រសើរជាង គឺខាងស្ថានសួគ៌វិញ» (ហេព្រើរ ១១:១៦)។

វាជាអំពើបាបដ៏ធ្ងន់ធ្ងរណាស់ក្នុងការបង្រៀនអ្នកជឿ (ដែល

ទទួលបានការត្រាស់ហៅឲ្យទ្រាំទ្រដោយមានទស្សនៈលើវង្វាន់ដ៏នៅអស់កល្បជានិច្ច) ថាពួកគាត់គួរសង្វាតដេញតាម ហើយទាមទាររង្វាន់ឥឡូវៗនេះ។ ការបង្រៀនដ៏ខុសឆ្គងបែបនេះរារាំងពួកបរិសុទ្ធដែលកំពុងរងទុក្ខពីព្រះគុណ និងក្ដីសង្ឃឹមមានក្នុងជំនឿដ៏ពិត។ សារនៃ «ពាក្យពេចន៍ជំនឿ» (ពេលត្រូវបានបើកបង្ហាញថាវាជាសេចក្ដីកុហក) បានបណ្ដេញមនុស្សជាច្រើនចេញពីក្រុមជំនុំ និងការដើរតាមព្រះគ្រីស្ទទាំងស្រុង។ សូមឲ្យអស់អ្នកដែលមានទំនួលខុសត្រូវ និងអភ័យឯកសិទ្ធិក្នុងការអធិប្បាយព្រះបន្ទូលរបស់ព្រះគ្រីស្ទចងចាំនូវពាក្យពេចន៍ផ្ទាល់របស់ទ្រង់៖ «ប៉ុន្តែបើអ្នកណាធ្វើឲ្យកូនតូចណាមួយនេះ ដែលជឿដល់ខ្ញុំ រវាតចិត្តចេញ នោះស៊ូឲ្យគេយកថ្មត្បាល់កិនយ៉ាងធំចងកអ្នកនោះ ហើយពន្លង់ទៅក្នុងសមុទ្រទីជ្រៅវិញ ធ្វើយ៉ាងនោះនឹងមានប្រយោជន៍ដល់អ្នកនោះជាជាង» (ម៉ាថាយ ១៨:៦)។

## សេចក្ដីសន្និដ្ឋាន

ដំណឹងល្អដែលសន្យាភាពចម្រុងចម្រើនមានមូលដ្ឋានលើការកាត់ស្រាយព្រះគម្ពីរយ៉ាងខុសឆ្គង ដោយបំផ្លាញអត្ថន័យដ៏ច្បាស់លាស់ទាំងស្រុង។ ក្នុងរបៀបនេះ វាបង្វែរគ្រីស្ទបរិស័ទ

ចេញពីការបម្រើព្រះជាម្ចាស់ឲ្យទៅថ្វាយបង្គំខ្លួនឯង និងទុកចិត្ត លើដំណឹងល្អដែលមិនពិតទៅវិញ។ ដាច់ខាត! យើងត្រូវតែកាត់ស្រាយព្រះបន្ទូលរបស់ព្រះជាម្ចាស់ដោយមានភាពស្មោះត្រង់ និងការយកចិត្តទុកដាក់ ដើម្បីឲ្យយើងអាចស្គាល់សេចក្តីពិត ហើយអាចទទួលបានសេរីភាពតាមរយៈសេចក្តីពិតនោះ។

ពេលដែលព្រះអម្ចាស់យេស៊ូវគ្រីស្ទយាងចេញពីស្ថានសួគ៌ ហើយយកភាពជាមនុស្ស ព្រះអង្គមិនបានលះបង់ចោលនូវប្រយោជន៍ខាងឯ*សម្ភារៈនិយម*នោះឡើយ។ ព្រះអង្គបានលះបង់ទ្រព្យសម្បត្តិនៅឯ*ស្ថានសួគ៌* សិរីល្អ និងក្តីស្រឡាញ់ដែលទ្រង់មានជាមួយនឹងព្រះវរបិតាទ្រង់ ដើម្បីយាងមកផែនដីយើងនេះ ដែលជាប្រយោជន៍ធ្វើឲ្យយើងអាចមានចំណែកក្នុងព្រះពរទាំងនោះជាមួយនឹងទ្រង់យ៉ាងអស់កល្បជានិច្ច។ ពេលដែលព្រះគ្រីស្ទមានព្រះជន្មដែលពេញដោយការរងទុក្ខ ហើយសុគតនៅលើឈើឆ្កាង ការរងទុក្ខរបស់ទ្រង់ត្រូវបានរៀបចំឡើង ដើម្បីព្យាបាលរបួសដ៏ធ្ងន់ធ្ងររបស់យើង ពោលគឺអំពើបាបរបស់យើង។ ព្រះជាម្ចាស់បានសន្យាមកយើងនូវអ្វីមួយដែលសំខាន់ ហើយមានតម្លៃខ្ពស់ជាងសុខភាព និងទ្រព្យសម្បត្តិនាពេលឥឡូវនេះទៅទៀត។ ដោយសារការសុគត និងការមានព្រះជន្មរស់ឡើងវិញ

របស់ទ្រង់ នោះព្រះយេស៊ូវបានសន្យាទៅកាន់រាស្ត្ររបស់ទ្រង់ នូវការផ្សះផ្សាដែលនៅស្ថិតស្ថេរជាមួយនឹងព្រះជាម្ចាស់ ហើយជីវិតដែលគ្មានអំពើបាបនៅស្ថានសួគ៌។

ខណៈពេលដែលរាស្ត្ររបស់ព្រះជាម្ចាស់ដកពិសោធន៍នឹងសេចក្ដីសង្គ្រោះដែលមាននៅក្នុងព្រះយេស៊ូវ នោះពួកគាត់ក៏នឹងចង់ឲ្យព្រះជាម្ចាស់ទទួលបាននូវសិរីល្អលើសជាងអ្វីៗផ្សេងៗទៀត។ ហើយផែនការរបស់ព្រះជាម្ចាស់គឺធំធេងណាស់ ហេតុដូច្នេះហើយបានជាព្រះអង្គប្រើប្រាស់សេចក្ដីប្រាថ្នាដ៏សុចរិតរបស់រាស្ត្រទ្រង់ ដែលទូលសុំឡើងក្នុងសេចក្ដីអធិស្ឋាន ដើម្បីនឹងបំពេញព្រះហឫទ័យរបស់ទ្រង់។ ដូច្នេះ យើងមិនគួរមានការភ្ញាក់ផ្អើលឡើយ ដែលព្រះគម្ពីរបានលើកទឹកចិត្តយើងឲ្យសាបព្រោះដោយសប្បុរសក្នុងការប្រព្រឹត្តរបស់យើង ទាក់ទងនឹងការជំរុញចិត្តខាងឯព្រលឹងវិញ្ញាណ។ ខណៈពេលដែលយើងធ្វើការនេះ ព្រះអង្គបានសន្យាមកកាន់យើងនូវចម្រូតដ៏នៅអស់កល្បជានិច្ចដែលទ្រង់បានរៀបចំសម្រាប់យើងនៅឯស្ថានសួគ៌។

ជំពូក២៖

# ភាពចម្រុងចម្រើនដ៏ពិត និងមិនពិត

Michael Otieno Maura

*«គាត់ក៏សង់ទីក្រុង១ ហើយដាក់ឈ្មោះទីក្រុងនោះតាមឈ្មោះអេណុកកូនខ្លួន» (លោកុប្បត្តិ ៤:១៧)។*

*«សេតគាត់ក៏បង្កើតបានកូនប្រុស១ដែរ ដាក់ឈ្មោះថា អេណុស ហើយនៅជាន់នោះ គេចាប់តាំងអំពាវនាវដល់ព្រះនាមព្រះយេហូវ៉ា» (លោកុប្បត្តិ ៤:២៥-២៦)។*

នៅបណ្ដាប្រទេសជុំវិញពិភពលោកសព្វថ្ងៃនេះ មានមនុស្សជាច្រើនកំពុងនិយាយអំពីភាពចម្រុងចម្រើន។ វាគ្របដណ្ដប់ការគិតគូររបស់យើង ហើយសាយភាយក្នុងការសន្ទនារបស់យើង។ ខណៈពេលដែលវាកំពុងតែគ្របដណ្ដប់សង្គមរបស់យើង

វាក៏កំពុងចាប់ផ្តើមជ្រាបចូលក្នុងវេទិកាអធិប្បាយផងដែរ។ មានគ្រូគង្វាលជាច្រើនកំពុងអធិប្បាយអំពីដំណឹងល្អនៃភាពចម្រុងចម្រើនផ្នែកសម្ភារៈនិយម។ ប៉ុន្តែ ភាពចម្រុងចម្រើននេះដែលកំពុងឆក់យកដួងចិត្ត និងគំនិតបុរស និងស្ត្រី ចាប់តាំងពីលើផ្លូវថ្នល់រហូតដល់ក្នុងក្រុមជំនុំ គឺជាភាពចម្រុងចម្រើនដ៏មិនពិត។ វាជាភាពចម្រុងចម្រើនដ៏មិនពិតដែលព្រះគម្ពីរបានទាស់ប្រឆាំង ហើយព្រមានយើងម្តងហើយម្តងទៀត។

ចាប់តាំងពីកណ្ឌគម្ពីរ លោកុប្បត្តិ ៤:១៧-២៦ យើងអាចឃើញពីភាពជំទាស់គ្នារវាងគ្រួសារលោក កាអ៊ីន ដែលមិនចេះកោតខ្លាចព្រះជាម្ចាស់ និងគ្រួសារលោក សេត ដែលចេះកោតខ្លាចព្រះ។ គ្រួសារលោក កាអ៊ីន មានអំនួតជាច្រើនទាក់ទងនឹងអ្វីដែលគាត់បានសម្រេច និងពីភាពចម្រុងចម្រើនរបស់គាត់ផ្នែកសម្ភារៈនិយម។ ពេលមើលពីក្រៅទៅ ពួកគាត់ហាក់បីដូចជាទទួលបានជោគជ័យ ប៉ុន្តែអ្វីដែលពួកគាត់បានសម្រេចគឺពួកគាត់បានលើកឡើងដោយមិននិយាយអំពីព្រះជាម្ចាស់។ ដោយសារពួកគេដាច់ឆ្ងាយចេញពីព្រះជាម្ចាស់ ភាពចម្រុងចម្រើនរបស់ពួកគាត់គឺនៅត្រឹមតែបណ្តោះអាសន្ន ហើយនិងរសាត់បាត់ទៅ ពោលគឺវានៅត្រឹមលើផែនដីនេះ និងសម្រាប់ផែនដីនេះតែប៉ុណ្ណោះ។

ចំណែកឯគ្រួសារលោក សេត វិញពួកគាត់មិនមានអ្វីដែលពួកគាត់បានសម្រេចផ្នែកសម្ភារៈនិយម ដើម្បីនឹងបង្ហាញទេ។ ប៉ុន្តែពួកគាត់ស្រែកហៅរកព្រះនាមព្រះអម្ចាស់វិញ នោះឯងជាសិរីល្អរបស់ពួកគាត់។ គ្រួសារមួយនេះស្គាល់ពីភាពចម្រុងចម្រើនដ៏ពិត ហើយភាពចម្រុងចម្រើនដ៏ពិតនោះនឹងនៅយ៉ាងអស់កល្បជានិច្ច ព្រោះមានមូលដ្ឋានគ្រឹះលើព្រះជាម្ចាស់។

សព្វថ្ងៃនេះ លើវេទិកាក្នុងក្រុមជំនុំរបស់យើងភាគច្រើន ការអធិប្បាយរបស់គ្រូៗគឺផ្តោតទៅលើអ្វីដែល មនុស្សសម្រេចបាននៅលើផែនដី និងភាពចម្រុងចម្រើនលើផ្នែកសម្ភារៈនិយមដូចជា៖ មានផ្ទះច្រើន ឡានច្រើន ជោគជ័យក្នុងការងារ លុយកាក់ សុខភាព និងភាពអរសប្បាយ។ ការអធិប្បាយបែបនេះគឺទាស់ប្រឆាំងនឹងព្រះបន្ទូលផ្ទាល់របស់ព្រះជាម្ចាស់ចាប់តាំងពីកណ្ឌគម្ពីរលោកុប្បត្តិរហូតដល់កណ្ឌគម្ពីរជំណឹងល្អ និងកណ្ឌគម្ពីរសំបុត្រ។ សេចក្តីអធិប្បាយរបស់យើងគួរតែណែនាំឲ្យមនុស្សមានបាបស្រែកហៅរកព្រះនាមរបស់ព្រះអម្ចាស់។ វាគួរតែនាំឲ្យមនុស្សស្រែករកសេចក្តីមេត្តាករុណា និងសេចក្តីសង្គ្រោះតាមរយៈព្រះអម្ចាស់យេស៊ូវគ្រីស្ទ ក្នុងការលន់តួបាប និងការមានជំនឿដោយពឹងផ្អែកលើសេចក្តីសន្យានានារបស់ព្រះជាម្ចាស់ និងការ

សម្លឹងទៅឯកេរ្តិ៍មរតកនៅស្ថានសួគ៌វិញ។

## ទីក្រុងពីរ

កាល នោះ លោក  កាអ៊ីន  កំពុង សាង សង់ ទីក្រុង មួយ (លោកុប្បត្តិ ៤:១៧)។ បើមើលពីក្រៅ លោកអ្នកអាចគិតថា គាត់កំពុងតែមានភាពចម្រុងចម្រើន។ ក្នុងក្រសែភ្នែកលោកីយ៍ នេះ មើលទៅលោក កាអ៊ីន កំពុងតែមមុលទៅមុខ ហើយចង់ សម្រេចបាននូវការងារដ៏អស្ចារ្យៗជាច្រើន។

ដូចយើងរាល់គ្នាដែរ លោក កាអ៊ីន មានអារម្មណ៍ថា គាត់ត្រូវ ការសុវត្ថិភាព។ បន្ទាប់ពីលោក កាអ៊ីន សម្លាប់ប្អូនប្រុសរបស់គាត់ ព្រះជាម្ចាស់បានបណ្ដេញគាត់ចេញពីព្រះវត្តមានទ្រង់ ហើយ បានដាក់បណ្ដាសាឲ្យគាត់រស់នៅបែបជាឈ្លើយ។ ប៉ុន្តែ ដើម្បី ជួយលោក កាអ៊ីន ពេលដែលគាត់មានការភ័យខ្លាចថាខ្លួននឹង ស្លាប់ដូចលោក អេបិល ដោយព្រះគុណព្រះជាម្ចាស់បានដៅទី សម្គាល់លើគាត់សម្រាប់ការពារគាត់។ ប៉ុន្តែ ទោះជាយ៉ាងណា ក្ដី ក៏លោក កាអ៊ីន នៅតែព្យាយាមដោះស្រាយបញ្ហាដោយខ្លួន ឯង។ តើចំណុចនេះប្រាប់យើងអ្វីខ្លះអំពីលោក កាអ៊ីន និងអំពី ទីក្រុងដែលគាត់សាងសង់?

លោក កាអ៊ីន បានព្យាយាមធ្វើការយ៉ាងនឿយហត់ ដើម្បីស្ថាបនាខ្លួនឯងលើផែនដីនេះ។ គាត់បានផ្តោតគំនិត និងកម្លាំងកាយលើជីវិតនៅផែនដីនេះតែប៉ុណ្ណោះ។ គាត់ចង់បានកិត្តិយសសម្រាប់គ្រួសារខ្លួន ហើយថែមទាំងបានដាក់ឈ្មោះទីក្រុងមួយតាមឈ្មោះកូនរបស់គាត់។ ហើយគាត់បានធ្វើការទាំងនោះក្នុងកាលដែលសង្គមកំពុងតែមានការបំផ្លាស់បំប្រែយ៉ាងខ្លាំង។ សូមកត់សម្គាល់អំពីមនុស្សដំបូងគេបង្អស់នានាដែលមានចែងក្នុងខគម្ពីរទាំងនេះ៖ ការធ្វើស្រែចម្ការបែបធារាសាស្ត្រ កំណើតកកើតនៃដូរ្យតន្ត្រី និងគំនូរ ព្រមទាំងវិទ្យាសាស្ត្រនៃការឈានទៅមុខផ្នែកបច្ចេកវិជ្ជា។ សង្គមនោះគឺជាសង្គមរកស៊ី និងសង្គមដែលមានជោគជ័យ។ ប៉ុន្តែ ពួកគាត់កំពុងតែរស់នៅដោយគ្មានព្រះជាម្ចាស់។ លោក កាអ៊ីន បានដើរចេញពីព្រះវត្តមានរបស់ព្រះជាម្ចាស់ ហើយកំពុងតែធ្វើការសម្រាប់តែខ្លួនឯង។

សូម្បីតែសព្វថ្ងៃនេះ ក៏យើងនៅឃើញថាទាំងបុរសទាំងស្ត្រីកំពុងតែតយុទ្ធ និងខិតខំធ្វើការយ៉ាងនឿយហត់ក្នុងការរស់នៅលើផែនដីនេះ។ មនុស្សយើងតែងតែនិយាយមកកាន់ខ្លួនឯងថា *«បើខ្ញុំបានការងារល្អ បើខ្ញុំបានប្រពន្ធ/ប្តីល្អ បើខ្ញុំមានការរស់នៅដោយស្រណុកសុខស្រួល នោះខ្ញុំនឹងសប្បាយចិត្ត និងមាន*

*ការស្កប់ចិត្តជាមិនខាន»*។ នេះគឺជារបៀបរបស់លោក កាអ៊ីន ហើយយើងត្រូវតែមានការប្រុងប្រយ័ត្ន។ សាច់រឿងរបស់លោក កាអ៊ីន បង្ហាញឲ្យយើងឃើញថា ការមានទីក្រុង ឬក៏ផ្ទះដ៏ធំគឺ មិនមែនជាភស្តុតាងដែលថាបុគ្គលម្នាក់នោះត្រូវគ្នាជាមួយនឹង ព្រះជាម្ចាស់ឡើយ។ អ្វីដែលសំខាន់នោះគឺ ការមានទ្រព្យសម្បត្តិ ខាងឯវិញ្ញាណ ដែលកើតឡើងតាមរយៈការបំផ្លាស់បំប្រែយ៉ាង ពេញទីក្នុងដួងចិត្តរបស់យើង។ ព្រះយេស៊ូវបានលើកឡើងថា «ត្រូវតែកើតជាថ្មី» (យ៉ូហាន ៣:៧)។

ទីក្រុងរបស់លោក កាអ៊ីន គឺត្រូវបានសាងសង់ឡើងសម្រាប់ សិរីល្អរបស់មនុស្ស។ យើងឃើញថា ការដែលគាត់ផ្តោតកម្លាំង លើអ្វីដែលមិនចំទីកន្លែង ដើម្បីសង់កេរ្តិ៍ឈ្មោះរបស់គាត់លើផែនដី នេះនៅមានរហូតមកដល់ជំនាន់យើងក្នុងយុគសម័យនៃសម្ភារៈ និយម។ លោកីយ៍នេះបានសន្យាមកកាន់យើងថា យើងនឹងមាន ការស្កប់ស្កល់ បើយើងមានការងារ ទ្រព្យសម្បត្តិ ការកំសាន្ត និង ភាពល្បីល្បាញ។ នេះគឺជាសម្ភារៈដែលទីក្រុងរបស់យើងត្រូវការ ដើម្បីកសាងឡើង។ ហើយសិរីល្អរបស់មនុស្សគឺជាអ្វីដែលបាន ជំរុញឲ្យយើងកសាងវាឡើង។ ប៉ុន្តែ របៀបរបស់លោក កាអ៊ីន នឹង នាំឲ្យមានការបំផ្លាញចោលវិញព្រោះ «បើគ្មានព្រះយេហូវ៉ាសង់

ផ្ទះឡើង នោះពួកជាងដែលសង់ គេធ្វើការជាឥតប្រយោជន៍ទេ បើគ្មានព្រះយេហូវ៉ាថែរក្សាទីក្រុង នោះពួកយាមល្បាតគេចាំយាមជាឥតប្រយោជន៍ដែរ» (ទំនុកតម្កើង ១២៧:១)។

ប៉ុន្តែ ព្រះជាម្ចាស់កំពុងតែសង់ទីក្រុងផ្សេងពីនោះមួយទៀត គឺជាទីក្រុងសម្រាប់សិរីល្អរបស់ទ្រង់។ អស់អ្នកណាដែលស្រឡាញ់ទ្រង់នឹងសម្លឹងទៅមើលទីក្រុងដែលនៅស្ថានសួគ៌មួយនេះ។ យើងអានអំពីវីរបុរសនៃជំនឿថា «គេសង្វាតចង់បានស្រុក១ដ៏ប្រសើរជាង គឺខាងស្ថានសួគ៌វិញ បានជាព្រះទ្រង់គ្មានសេចក្តីខ្មាសដោយគេហៅទ្រង់ជាព្រះនៃគេនោះឡើយ ដ្បិតទ្រង់បានរៀបចំទី-ក្រុង១ឲ្យគេហើយ» (ហេព្រើរ ១១:១៦)។ ធាតុពិតគឺ «ដ្បិតនៅផែនដីនេះ យើងគ្មានក្រុងដែលនៅស្ថិតស្ថេរទេ គឺយើងកំពុងស្វែងរកក្រុងដែលនឹងមកដល់» (ហេព្រើរ ១៣:១៤ គគខ)។ សាវ័កប៉ុល បានសរសេរថា «ឯយើងរាល់គ្នា យើងជាសាសន៍ស្ថានសួគ៌វិញ ក៏នៅចាំព្រះអម្ចាស់យេស៊ូវគ្រីស្ទ ជាព្រះអង្គសង្គ្រោះទ្រង់យាងមកពីស្ថាននោះឯង» (ភីលីព ៣:២០)។

វាជាការដ៏គួរឲ្យសោកស្តាយណាស់ដែលមានគ្រូជាច្រើនបានឈប់អធិប្បាយអំពីទីក្រុងនៅឯស្ថានសួគ៌។ ផ្ទុយទៅវិញពួកគាត់បែរជាបង្វែរភ្នែករបស់យើងឲ្យទៅសម្លឹងមើលទីក្រុងរបស់

លោក កាអ៊ីន ដែលនៅឯផែនដីនេះ។ ពួកគាត់លែងអធិប្បាយអំពីក្តីសង្ឃឹមដ៏ពិតរបស់គ្រីស្ទបរិស័ទ ដែលនោះគឺជា «មរតកដែលមិនចេះពុករលួយ ក៏ឥតសៅហ្មង ហើយមិនដែលស្រពោនឡើយ ជាមរតកដែលបម្រុងទុកឲ្យយើងរាល់គ្នា នៅស្ថានសួគ៌» (១ពេត្រុស ១:៤)។ ពួកគាត់បែរជាជំរុញមនុស្សឲ្យសង្វាតដេញតាមការជោគជ័យ ភាពអរសប្បាយ និងការបំពេញបែបលោកីយ៍ក្នុងជីវិតដ៏ខ្លីនេះ។

ឱ! គ្រូអធិប្បាយអើយ! មានទីក្រុងពីរ។ តើលោកគ្រូកំពុងអធិប្បាយអំពីទីក្រុងមួយណា? ឱ! អ្នកជឿអើយ! តើបងប្អូនកំពុងសង្វាតដេញតាមទីក្រុងមួយណាយ៉ាងអស់ពីចិត្ត?

ទីក្រុងរបស់លោក កាអ៊ីន មិនបាននៅជាប់លាប់ទេ គឺវាបានរលាយបាត់ទៅហើយ។ អ្នកអត្ថាធិប្បាយមួយចំនួនថែមទាំងបានលើកឡើងថាលោក កាអ៊ីន មិនទាំងបានសាងសង់រួចរាល់ផង។ អស់អ្នកណាដែលស្វែងរកការបំពេញនូវអ្វីៗដែលលោកីយ៍នេះមាន គឺនឹងប្រទះការខកចិត្តនៅចុងបញ្ចប់ជាមិនខាន។ ពួកគាត់នឹងឃើញថា ព្រះជាម្ចាស់នឹងបណ្តេញពួកគាត់ចេញពីទ្រង់យ៉ាងអស់កល្បជានិច្ច។

ប៉ុន្តែ គ្រួសាររបស់លោក សេត បានស្រែកហៅរកព្រះនាម

របស់ព្រះជាម្ចាស់។ ពួកគាត់ស្គាល់ពីភាពចម្រុងចម្រើនដ៏ពិត ពួកគាត់បានទទួលជឿលើក្តីសន្យារបស់ព្រះជាម្ចាស់ ហើយថែមទាំងសម្លឹងមើលទៅឯទីក្រុងដែលនៅអស់កល្បជានិច្ច គឺនៅឯស្ថានសួគ៌។ អ្នកជឿដ៏ពិតពឹងផ្អែកលើក្តីសង្ឃឹមនៃជីវិតដ៏អស់កល្បជានិច្ចដែលនៅជាមួយព្រះជាម្ចាស់ ហើយពួកគាត់នឹងមិនមានការខកចិត្តឡើយ។

## ពហុពន្ធភាពគឺមិនមែនជាភាពចម្រុងចម្រើនទេ

សាច់រឿងរបស់លោក កាអ៊ីន និងគ្រួសាររបស់គាត់នៅមានការព្រមានមួយទៀតសម្រាប់យើង។ លោក ឡាមេក[១] (ដែលជាកូនចៅរបស់លោក កាអ៊ីន) គឺជាអ្នកដែលណែនាំឲ្យលោកីយ៍នេះស្គាល់ពីពហុពន្ធភាព (មានន័យថា «ការមានប្រពន្ធ ឬប្តីច្រើន») ដោយបានប្រព្រឹត្តផ្ទាល់។ សព្វថ្ងៃនេះមានមនុស្សខ្លះគិតថា ការមានប្រពន្ធ ឬក៏ប្តីច្រើនគឺជាចំណុចសម្គាល់ពីភាពចម្រុងចម្រើន។ នៅឯប្រទេសអាហ្វ្រិក ការមានប្រពន្ធច្រើនគឺមានការពាក់ព័ន្ធនឹងការមានទ្រព្យសម្បត្តិ អំណាច និងភាពល្បីល្បាញ។ កាលខ្ញុំនៅក្មេង ពេលខ្ញុំឃើញបុរសណាម្នាក់រៀបការ យកប្រពន្ធមួយទៀត

១ លោក ឡាមេក មួយនេះមិនមែនជាលោក ឡាមេក ដែលជាកូនចៅរបស់លោក សេត និងជាឪពុករបស់លោក ណូអេ ទេ។

ខ្ញុំដឹងថាគាត់ទើបតែទទួលបានការឡើងតំណែងនៅកន្លែងធ្វើការ។ គេធ្លាប់និយាយថា បុរសណាដែលមានប្រពន្ធតែមួយគឺប្រៀបដូចជាគាត់មានភ្នែកតែម្ខាងប៉ុណ្ណោះ។ ថ្មីៗនេះ អ្នកដឹកនាំនៅប្រទេសអាហ្វ្រិកម្នាក់ទើបតែរៀបការនឹងប្រពន្ធទីប្រាំរបស់គាត់ ហើយកាលនោះមានការរាំកំសាន្ត និងពិធីជប់លៀង។ យើងក៏ធ្លាប់ឃើញមនុស្សប្រុសជាច្រើននាក់បានបណ្តើរប្រពន្ធជាច្រើនរបស់ខ្លួន ដើម្បីបង្ហាញដល់អ្នកដទៃទៀតពីភាពចម្រុងចម្រើន និងអំណាចរបស់ខ្លួន។ តាមពិតទៅ ថែមទាំងមានគ្រូម្នាក់បានលើកឡើងថា ព្រះជាម្ចាស់បានលេចចេញឲ្យគាត់ឃើញ ហើយបានមានបន្ទូលមកកាន់គាត់ថា ឲ្យទៅយកប្រពន្ធមួយទៀត។ ឥឡូវនេះ គាត់កំពុងតែគាំទ្រការប្រកាន់ខ្ជាប់នឹងពហុពន្ធភាព។

ទោះជាយ៉ាងណាក្តី យោងតាមកណ្ឌគម្ពីរ លោកុប្បត្តិ ៤:១៩ ក៏យើងឃើញថាលោក ឡាមេក (ជាកូនចៅរបស់លោក កាអ៊ីន ដែលមិនកោតខ្លាចព្រះ) គឺជាបុគ្គលដំបូងដែលបានបំផ្លាញច្បាប់អាពាហ៍ពិពាហ៍ ដោយគាត់បាននាំចូលមកនូវការប្រកាន់ខ្ជាប់នឹងពហុពន្ធភាព។ កណ្ឌគម្ពីរ លោកុប្បត្តិ ២:២៤ បង្រៀនយើងយ៉ាងច្បាស់លាស់ថា ដាច់ខាត ត្រូវតែមានតែបុរសម្នាក់ និងស្ត្រីម្នាក់ប៉ុណ្ណោះដែលអាចក្លាយជាសាច់ឈាមតែមួយបាន។ លោក

ឡាមេក បានប្រព្រឹត្តល្មើសទាស់នឹងច្បាប់ដ៏ច្បាស់លាស់ដែលព្រះជាម្ចាស់បានប្រទានមក។ ដោយសារព្រះជាម្ចាស់ជាអង្គដែលបានបង្កើតជីវិតអាពាហ៍ពិពាហ៍រវាងមនុស្សប្រុសម្នាក់ និងមនុស្សស្រីម្នាក់ (ម៉ាថាយ ១៩:៤-៥) នេះមានន័យថា ពហុពន្ធភាពគឺមិនមែនជាសញ្ញាសម្គាល់លើភាពចម្រុងចម្រើនដូចដែលវប្បធម៌ចង់ឲ្យយើងជឿនោះឡើយ វាជាអំពើបាបទេតើ! ប្រសិនបើលោកអ្នកបានរៀបការ បានប្រពន្ធម្នាក់ ព្រះហឫទ័យរបស់ព្រះជាម្ចាស់គឺឲ្យលោកអ្នកមានភាពស្មោះត្រង់ជាមួយនឹងនាងម្នាក់គត់។ ប្រសិនបើលោកអ្នកកំពុងតែគិតថាចង់រៀបការ ខ្ញុំសូមអង្វរលោកអ្នកក្នុងព្រះនាមរបស់ព្រះអម្ចាស់ថា ចូរកុំដើរតាមផ្លូវរបស់លោក ឡាមេក ឲ្យសោះ។

ប្រហែលជាមានអ្នកខ្លះមានប្រពន្ធ ឬក៏ប្តីពីរបីនាក់ហើយ ខ្ញុំចង់សូមអង្វរឲ្យលោកអ្នកចូលទៅកាន់ព្រះអម្ចាស់ក្នុងលក្ខណៈនោះ ដ្បិតព្រះគម្ពីរបានលើកឡើងថា «មនុស្សមានសណ្ឋានជាយ៉ាងណាក្នុងកាលដែលព្រះទ្រង់ហៅ នោះឲ្យប្រព្រឹត្តតាមសណ្ឋាននោះចុះ» (១កូរិនថូស ៧:២០)។ លោកអ្នកមិនគួរបោះបង់ប្រពន្ធនានារបស់ខ្លួនចោលឡើយ។ មានក្រុមជំនុំមួយចំនួនហាមមិនឲ្យបុគ្គលដែលគាំទ្រពហុពន្ធភាពក្លាយជាសមាជិកក្រុម

ជំនុំ និងមិនឲ្យទទួលធ្វើពិធីលៀងព្រះអម្ចាស់។ ការដែលពួកគាត់ធ្វើបែបនោះវាមិនត្រឹមត្រូវទេ។ ប៉ុន្តែ បុគ្គលដែលប្រកាន់ខ្ជាប់នឹងពហុពន្ធភាពមិនអាចក្លាយជាអ្នកដឹកនាំក្នុងក្រុមជំនុំបានឡើយ (១ធីម៉ូថេ ៣:២)។ អស់អ្នកណាដែលបានទទួលសេចក្ដីសង្គ្រោះ ហើយជាសមាជិកក្នុងក្រុមជំនុំមិនគួរបោះបង់អស់អ្នកណាដែលពួកគាត់បានរៀបការជាមួយ មុនដែលពួកគាត់ទទួលបានសេចក្ដីសង្គ្រោះឡើយ ប៉ុន្តែពួកគាត់ក៏មិនត្រូវគាំទ្រការប្រកាន់ខ្ជាប់នឹងពហុពន្ធភាពដែរ។

ពហុពន្ធភាពគឺមិនមែនជាភាពចម្រុងចម្រើនទេ ប៉ុន្តែជាការប្រព្រឹត្តល្មើសនឹងក្រឹត្យវិន័យរបស់ព្រះជាម្ចាស់វិញ ហើយព្រះគម្ពីរក៏បានលើកឡើងពីកម្មផលយ៉ាងច្បាស់ៗផងដែរ។ ប្រពន្ធជាច្រើនរបស់ស្ដេច សាឡូម៉ូន បានបង្វែរចិត្តរបស់គាត់ចេញពីព្រះអម្ចាស់ (១ពង្សាវតាក្សត្រ ១១:៤)។ ពហុពន្ធភាពបានធ្វើឲ្យនាង រេបិកា និងលោក អ៊ីសាក មានទុក្ខកង្វល់ជាច្រើន (លោកុប្បត្តិ ២៦:៣៥) វាបានបង្កឲ្យមានការច្រណែនគ្នារវាងប្រពន្ធ (លោកុប្បត្តិ ៣០:១, ១សាំយូអែល ១:៦) ហើយនិងការឈ្លោះទាស់ទែងគ្នារវាងកូនៗផងដែរ (លោកុប្បត្តិ ៣៧; ពួកចៅហ្វាយ ៩)។ ខ្ញុំកើតចេញពីគ្រួសារដែលប្រកាន់ខ្ជាប់តាមពហុពន្ធ

ភាព ហើយខ្ញុំយល់ពីការនេះយ៉ាងច្បាស់លាស់ណាស់។ ពេលដែលឪពុកក្នុងគ្រួសារណាមួយដែលប្រកាន់ខ្ជាប់នឹងពហុពន្ធភាពស្លាប់ សូម្បីតែមុនយកសពគាត់ទៅកប់ ក៏ការឈ្លោះប្រកែកគ្នាអាចនឹងធ្វើឲ្យគ្រួសារមានការបាក់បែក។ ពហុពន្ធភាពគឺមិនមែនជាភាពចម្រុងចម្រើនឡើយ។

## ចូរកុំច្រណែនអ្នកដែលមិនកោតខ្លាចព្រះជាម្ចាស់

បើយោងតាមស្តង់ដារនាពេលបច្ចុប្បន្ននេះ នោះគេនឹងរាប់លោក ការ៉ុន និងកូនចៅរបស់គាត់ថា ពួកគាត់ពិតជាបានទទួលជោគជ័យមែន ព្រោះពួកគេមាន៖ ដីធ្លី ភាពជឿនលឿន បច្ចេកវិជ្ជា និងការមានប្រពន្ធជាច្រើន។ តក្កនៃដំណឹងល្អដែលសន្យាភាពចម្រុងចម្រើនបានណែនាំឲ្យមនុស្សជាច្រើនសន្មតយ៉ាងខុសឆ្គងថា ការមាននូវអ្វីៗនៅសព្វថ្ងៃនេះគឺស្មើគ្នានឹង (គឺជា) ព្រះពរដូចដែលគ្រួសារលោក ការ៉ុន ទទួលបាន។ ប៉ុន្តែ សូម្បីតែអ្នកជឿដែលមិនព្រមមានមូលដ្ឋានលើទ្រព្យសម្បត្តិនៃលោកីយ៍នេះ ក៏ពួកគាត់នៅមានសេចក្តីល្បួងក្នុងការយកឈ្នះបានដែរ។ ការច្រណែនអ្នកដទៃម្តងហើយម្តងទៀតតែងតែបង្វែរចិត្តយើងចេញពីការសង្វាតដេញតាមទីក្រុងរបស់ព្រះជាម្ចាស់ដោយមាន

ចិត្តគំនិតតែមួយ។

ពេលយើងមើលភាពចម្រុងចម្រើន និងអ្វីៗដែលអស់អ្នកដែលមិនកោតខ្លាចព្រះសម្រេចបាន យើងតែងតែមានចម្ងល់ដូចអ្នកនិពន្ធកណ្ឌគម្ពីរ ទំនុកតម្កើង ៧៣:២-៣ «តែឯជើងទូលបង្គំ បានកន្ធែកចេញហៀបនឹងផុតទីហើយ ជំហាននៃទូលបង្គំបានហៀបនឹងរអិលភ្លាត់ទៅ ដ្បិតទូលបង្គំមានសេចក្តីច្រណែនចំពោះមនុស្សអំនួត ដោយឃើញសេចក្តីចម្រើនរបស់មនុស្សអាក្រក់នោះ»។ បន្ទាប់មក អ្នកនិពន្ធក៏បានលើកឡើងនូវលក្ខណសម្បត្តិមួយចំនួន ដែលដូចគ្នានឹងអ្វីដែលយើងឃើញក្នុងគ្រួសារលោក កាអ៊ីន ដែលឥឡូវនេះគ្រូអធិប្បាយដំណឹងល្អដែលសន្យាភាពចម្រុងចម្រើនកំពុងតែលើកតម្កើង។ គាត់បានសរសេរថាពួកមនុស្សអាក្រក់ហាក់បីដូចជាគ្មានបញ្ហាស្អីសោះ រូបរាងកាយរបស់ពួកគេមានសុខភាពល្អ និងពេញដោយកម្លាំង ពួកគេមានអំនួត ហើយគ្មានអីដែលខ្វាយខ្វល់ ហើយទ្រព្យសម្បត្តិក៏កាន់តែកើនឡើងៗថែមទៀតផង។

ប៉ុន្តែ ខណៈពេលដែលព្រះគម្ពីរលើកឡើងពីរបៀបដែលយើងប្រឈមមុខនឹងការល្បួង ព្រះគម្ពីរក៏បានបើកភ្នែកយើងឲ្យឃើញពីរបៀបតយុទ្ធឈ្នះលើការល្បួងផងដែរ។ ព្រះជាម្ចាស់បានបើក

សម្តែងឲ្យអ្នកនិពន្ធកណ្ឌគម្ពីរទំនុកតម្កើងខាងលើនេះឃើញថា អ្នកមានណាដែលមានអំនួត ហើយមិនចេះគិតគូរពីអ្នកដទៃ គឺឥឡូវនេះកំពុងឈរនៅជ្រោះនៃអន្លង់ដ៏ជ្រៅហើយ។ ការទទួលការបំផ្លាញចោលគឺជាជោគវាសនានៃអ្នកទាំងអស់នោះ (ទំនុកតម្កើង ៧៣:១៧-២០) ហើយយើងគួរតែអាណិតពួកគេ ហើយព្រមានពួកគេ ជាជាងច្រណែន។ ព្រះវត្តមាន និងព្រះប្រាជ្ញាញាណរបស់ព្រះជាម្ចាស់បានផ្លាស់ប្តូរទស្សនៈរបស់អ្នកនិពន្ធកណ្ឌគម្ពីរទំនុកតម្កើងខាងលើនេះ ទាក់ទងនឹងភាពចម្រុងចម្រើនរបស់អស់អ្នកមិនកោតខ្លាចព្រះ។ ដាច់ខាត! យើងត្រូវតែគិតពិចារណា និងរស់នៅដោយរំពឹងលើភាពអស់កល្បជានិច្ច។

ប្រវត្តិសាស្ត្រមិនបានចងចាំពីគ្រួសារលោក កាអ៊ីន ថាពួកគាត់ជាអ្នកថ្វាយបង្គំព្រះជាម្ចាស់នោះទេ ប៉ុន្តែចាំពីភាពចម្រុងចម្រើន និងអ្វីៗដែលពួកគាត់បានសម្រេចឡើងនៅលោកីយ៍នេះ។ ពួកគាត់មិនបានស្គាល់ព្រះជាម្ចាស់ទេ ហើយអ្វីៗដែលពួកគាត់បានសម្រេចឡើងមិនអាចបិទបាំងការបដិសេធរបស់ខ្លួនលើព្រះជាម្ចាស់ដែលពួកគាត់ត្រូវការខ្លាំងជាងគេបានឡើយ។ ពិតណាស់! យើងដឹងហើយថា ការមានសម្ភារៈនិយមគឺមិនមានន័យថាវាអាក្រក់នោះទេ ប៉ុន្តែបើយើងរស់នៅសម្រាប់ភាពចម្រុង

ចម្រើនផ្នែកសម្ភារៈនិយម និងការមានជោគជ័យនៅលើពិភពលោកនេះ នោះមានន័យថា យើងកំពុងតែសាងសង់ផ្ទះរបស់យើងនៅលើដីខ្សាច់ហើយ។ កូនចៅរបស់លោក កាអ៊ុន បានឈរលើដីដ៏រអិល ហើយការថ្កោលទោសគឺជាជោគវាសនារបស់ពួកគាត់។ ពួកគាត់បានគិតថា ខ្លួនបានសម្រេចការងារច្រើនណាស់ ប៉ុន្តែអ្វីៗដែលពួកគាត់បានសាងសង់មិនបាននៅគង់វង្សឡើយ។

ព្រះជាម្ចាស់បានប្រកាសទៅកាន់រាស្ត្ររបស់ទ្រង់ថា «តើឯងស្វែងរកការយ៉ាងធំសម្រាប់ខ្លួនឬ? កុំឡើយ!» (យេរេមា ៤៥:៥)។ ព្រះអង្គបានព្រមានរាស្ត្រអ៊ីស្រាអែលម្តងហើយម្តងទៀតថា កុំឲ្យអួតពីប្រាជ្ញា កម្លាំង និងទ្រព្យសម្បត្តិរបស់ខ្លួនឲ្យសោះ (យេរេមា ៩:២៣)។ ប៉ុន្តែ ទោះជាយ៉ាងណាក្តី ក៏យើងនៅតែឃើញថា គ្រូៗដែលអធិប្បាយភាពចម្រុងចម្រើនចង់ឲ្យយើងសង្វាតដេញតាមរបស់របរទាំងនោះដែរ។ យើងឃើញម្តងហើយម្តងទៀតចំណុចដែលសំខាន់បំផុតក្នុងជីវិតនេះគឺការមានទំនាក់ទំនងដ៏ស្និទ្ធស្នាល និងត្រឹមត្រូវជាមួយនឹងព្រះជាម្ចាស់។ ដូចដែលព្រះជាម្ចាស់បានប្រកាស «ឯអ្នកដែលអួត នោះត្រូវឲ្យគេអួតតែពីសេចក្តីនេះវិញ គឺថាខ្លួនមានយោបល់ ហើយស្គាល់ដល់អញ» (យេរេមា ៩:២៤)។

# ភាពចម្រុងចម្រើនដ៏ពិត

ប៉ុន្តែ តើភាពចម្រុងចម្រើនខាងឯវិញ្ញាណដ៏ពិត ដែលព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យយើងស្វែងរក មានលក្ខណៈបែបដូចម្ដេចទៅ? ក្រោយពីការបង្ហាញយើងពីគំរូដ៏អាក្រក់របស់គ្រួសារលោក កាអ៊ីន កណ្ឌគម្ពីរលោកុប្បត្តិជំពូក៤បានណែនាំឲ្យយើងស្គាល់ផ្លូវដ៏ត្រឹមត្រូវ៖ «ហើយនៅជាន់នោះ គេចាប់តាំងអំពាវនាវដល់ព្រះនាមព្រះយេហូវ៉ា» (លោកុប្បត្តិ ៤:២៦)។ ចំពោះអ្នកជឿនៅជំនាន់ដំបូងៗទាំងនោះ ពួកគាត់បានដាក់ព្រះជាម្ចាស់នៅកន្លែងដែលព្រះអង្គស័ក្តិសមនឹងស្ថិតនៅ គឺគង់នៅចំណុចកណ្តាលនៃជីវិតរបស់ពួកគាត់។ ពួកគាត់បានទុកចិត្ត ស្វែងរក និងថ្វាយបង្គំព្រះជាម្ចាស់។ ហើយព្រះជាម្ចាស់បានបង្កើតយើងមក ដើម្បីឲ្យថ្វាយបង្គំទ្រង់។ ដូចគោលជំនឿគ្រីស្ទានខ្លីជាភាសាខ្មែរបកប្រែពី *Westminster Shorter Catechism* បានលើកឡើងថា «គោលបំណងចម្បងរបស់មនុស្សគឺ ថ្វាយសិរីរុងរឿងដល់ព្រះ និងមានអំណរជាមួយទ្រង់ជារៀងដរាបតទៅ»។[២]

ចាប់តាំងពីកូនចៅរបស់លោក សេត រហូតដល់ជំនាន់គ្រីស្ទបរិស័ទដំបូង រាស្ត្ររបស់ព្រះជាម្ចាស់តែងតែមានការរែកញែកខ្លួនថា ជាអ្នកដែលថ្វាយបង្គំទ្រង់។ រាស្ត្ររបស់ព្រះជាម្ចាស់មាន

២ បកប្រែដោយអង្គការបេសកកម្មទៅកាន់ពិភពលោកប្រចាំកម្ពុជា

ការញែកចេញពីលោកីយ៍ ព្រោះព្រះនាម កិត្តិយស សិរីល្អ និងកេរ្តិ៍ឈ្មោះរបស់ព្រះជាម្ចាស់ផ្តល់អំណរដល់គាត់ជាងអ្វីៗដែលលោកីយ៍នេះមានឲ្យទៅទៀត។ គ្រួសារលោក សេត ថ្វាយបង្គំអង្គដែលតាក់តែងក្តីសន្យា អង្គដែលរក្សាក្តីសន្យា ពោលគឺអង្គដែលបានសន្យាថានឹងចាត់ព្រះសង្គ្រោះឲ្យយាងមក។ សព្វថ្ងៃនេះ គ្រីស្ទបរិស័ទក៏ថ្វាយបង្គំព្រះដ៏ស្មោះត្រង់នេះដែរ ជាព្រះដែលបានបំពេញសេចក្តីសន្យារបស់ទ្រង់ ហើយបានចាត់ព្រះអម្ចាស់យេស៊ូវគ្រីស្ទឲ្យមក។ ពួកគាត់ទទួលជឿលើសេចក្តីសន្យារបស់ព្រះជាម្ចាស់ ហើយសម្លឹងមើលទៅឯការយាងមកវិញរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទដែលពេញដោយក្តីអំណរដ៏ធំធេង ហើយនិងសម្លឹងមើលទៅឯស្ថានសួគ៌ និងផែនដីថ្មី។

ដំណឹងល្អដែលសន្យាភាពចម្រុងចម្រើនបង្វែរមនុស្សយើងចេញពីការយកព្រះជាម្ចាស់ជាចំណុចស្នូលនៃដំណឹងល្អដ៏ពិត។ វាបង្វែរពួកគេចេញពីការផ្តោតលើការសុគតរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទនៅឯភ្នំកាល់វ៉ារី។ វាដកចេញនូវយញ្ញបូជាធួននឹងបាបដែលព្រះយេស៊ូវបានជំនួស ការជាប់ឆ្កាង និងភាពបរិសុទ្ធ។ វាធ្វើឲ្យយើងមើលមិនសូវឃើញនូវក្តីសង្ឃឹមដ៏ធំធេងនៃការយាងមកវិញរបស់ព្រះគ្រីស្ទនាពេលអនាគត និងពេលវេលាដែលនឹង

មកដល់ គឺជាពេលដែលយើងនឹងទៅនៅជាមួយទ្រង់។

មូលហេតុចម្បងរបស់ព្រះជាម្ចាស់ក្នុងការសង្គ្រោះយើងគឺមិនមែន ដើម្បីប្រទានពរដល់យើងផ្នែកសម្ភារៈនិយមនោះទេ ប៉ុន្តែដើម្បីបំផ្លាស់បំប្រែយើងឲ្យក្លាយដូចជារូបអង្គព្រះគ្រីស្ទវិញទេតើ។ សាវ័ក ប៉ុល បានសរសេរថា «កុំឲ្យត្រាប់តាមសម័យនេះឡើយ ចូរឲ្យអ្នករាល់គ្នាបានផ្លាស់ប្រែវិញ ដោយគំនិតបានកែជាថ្មីឡើង» (រ៉ូម ១២:២)។ ក្រុមជំនុំគ្រីស្ទបរិស័ទរាប់សតវត្សតែងតែទទួលស្គាល់ថា យញ្ញបូជាធួននឹងបាប ដែលព្រះអម្ចាស់យេស៊ូវបានសម្រេចនៅលើឈើឆ្កាងនៅឯភ្នំ កាល់វ៉ារី គឺជាអត្ថបទស្នូលនៃសាររបស់គ្រីស្ទបរិស័ទ (អេសាយ ៥៣:៥; យ៉ូហាន ១:២៩; ២កូរិនថូស ៥:២១; ១យ៉ូហាន ៤:១០)។ ប៉ុន្តែ ចំណុចនេះផ្ទុយពីអ្វីដែលយើងឮសព្វថ្ងៃនេះ មានគេថា៖ អត្ថបទស្នូលគឺអំពីមនុស្ស និងអ្វីដែលព្រះជាម្ចាស់អាចធ្វើសម្រាប់ពួកគេ។ សូម្បីតែបទចម្រៀងក៏មានវគ្គបន្ទរ ក៏ស្ទើរតែមានការផ្តោតទៅលើ «សូមព្រះប្រទានពរខ្ញុំ» ផងដែរ។ ដាច់ខាត! យើងត្រូវតែវិលត្រឡប់ទៅរកសារដែលជាស្នូលនៃព្រះគម្ពីរវិញ។ អស់អ្នកណាដែលស្គាល់ព្រះអម្ចាស់ ហើយយកទ្រង់ជាចំណុចស្នូលនៃជីវិតរបស់ពួកគាត់នឹងមានភាពចម្រុងចម្រើនដ៏ពិត។

## ជ្រើសរើសភាពចម្រុងចម្រើនខាងឯវិញ្ញាណ ជាជាងភាពចម្រុងចម្រើនដែលនៅបណ្តោះអាសន្ន

ការស្លាប់ខាងឯជំនឿគឺជាកម្មផលនៃការឱបក្រសោបភាពចម្រុងចម្រើនដ៏ខុសឆ្គង។ បន្ទាប់ពីយើងបានដកព្រះជាម្ចាស់ចេញពីចំណុចស្នូល ហើយដាក់របស់សម្ភារៈនិយមជំនួសទ្រង់វិញ នោះសេចក្តីខុសឆ្គងនានាក៏នឹងជ្រាបចូលភ្លាមៗដែរ។ ជាដំបូង យើងភ្លេចប្រភពនៃព្រះពរ។ ហើយជាបន្ទាប់ យើងភ្លេចធាតុពិតថា សូម្បីតែនៅលើផែនដីនេះ ក៏ព្រះពរខាងឯវិញ្ញាណក៏នៅមានឧត្តមភាពយ៉ាងក្រៃលែងជាងសម្ភារៈនិយមទៅទៀត។ សាវ័ក ប៉ុល បានប្រាប់ឲ្យយើងកែសេចក្តីខុសឆ្គងទាំងនេះ៖ «សូមសរសើរដល់ព្រះដ៏ជាព្រះវរបិតានៃព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នា ដែលទ្រង់បានប្រទានពរមកយើងក្នុងព្រះគ្រីស្ទ ដោយគ្រប់ទាំងព្រះពរខាងព្រលឹងវិញ្ញាណ នៅស្ថានដ៏ខ្ពស់» (អេភេសូរ ១:៣)។ ព្រះពរខាងឯវិញ្ញាណគឺមកពីព្រះជាម្ចាស់ វាមិនមែនមកពីសម្តេចប៉ាប បូជាចារ្យ គ្រូគង្វាល ឬក៏ក្រុមជំនុំណាមួយនោះឡើយ។

គ្រូៗដែលអធិប្បាយដំណឹងល្អដែលសន្យាភាពចម្រុងចម្រើនថែមទាំងចង់ឲ្យយើងទទួលជឿថា ព្រះពរនឹងកើតមានឡើងតាម

រយៈការលាបប្រេង ដួលផ្ងាកក្រោយ ឬក៏ទឹកបរិសុទ្ធ។ មានគ្រូៗមួយចំនួនថែមទាំងហ៊ានលក់អំបោះ និងអំបិល ដោយអះអាងថាពួកគាត់អាចបំបោសអារក្សសាតាំងចេញ ហើយអាចការពារគ្រីស្ទបរិស័ទពីការវាយប្រហារពីពួកវា។ ប៉ុន្តែ ព្រះគម្ពីរបានប្រាប់យើងយ៉ាងច្បាស់ថា ព្រះពររបស់យើងគឺកើតចេញពីព្រះជាម្ចាស់។

ប៉ុន្តែ លោកអ្នកទំនងជាចង់សួរថា តើយើងអាចទទួលបានព្រះពរទាំងនេះដោយរបៀបណា។ តើព្រះជាម្ចាស់ប្រទានព្រះពររបស់ទ្រង់មកកាន់យើងដោយរបៀបណា? ជាថ្មីម្តងទៀតកណ្ឌគម្ពីរ អេភេសូរ ១:៣ បានផ្តល់ចម្លើយដល់យើង។ យើងអាចទទួលបានក្នុង និងតាមរយៈព្រះគ្រីស្ទតែមួយអង្គគត់។ តាមរយៈព្រះគ្រីស្ទ យើងអាចទទួលបានរាល់ព្រះពរពីព្រះវរបិតា។ កុំឲ្យមានគេមកបោកប្រាស់លោកអ្នកឲ្យជឿថា ពួកគេមានអំណាចក្នុងការប្រទានពរដល់អ្នកដទៃដោយខ្លួនឯងឡើយ។

ដូចដែលគ្រួសារលោក សេត និងកូនចៅរបស់គាត់បានផ្តោតចំណាប់អារម្មណ៍លើអ្វីៗខាងឯវិញ្ញាណជាជាងលើការសម្រេចអ្វីមួយឡើងដែលនៅខាងក្រៅ នោះសាវ័ក ប៉ុល ក៏បានអះអាងមកកាន់យើងផងដែរថា ព្រះជាម្ចាស់បានប្រទានពរដល់រាស្ត្ររបស់ទ្រង់ដោយនូវរាល់ព្រះពរខាងឯវិញ្ញាណផងដែរ។ យើង

ហៅព្រះពរនេះថាខាងឯវិញ្ញាណ ព្រោះវាជាព្រះពរដែលមកពីព្រះជាម្ចាស់ ដែលភ្នែកមិនអាចមើលឃើញ។ ព្រះពរទាំងនោះមិនអាស្រ័យជាចម្បងលើកាលៈទេសៈខាងក្រៅដែលនៅជុំវិញយើងលើផែនដីនេះឡើយ។ វាជាព្រះពរទាក់ទងជាមួយអ្វីដែលនៅអស់កល្បជានិច្ច។ សាវ័ក ប៉ុល បានបង្ហាញប្រាប់យើងហើយថាយើងមានព្រះពរទាំងនោះរួចហើយក្នុងព្រះគ្រីស្ទ ដែលព្រះគ្រីស្ទបានយកឈ្នះសម្រាប់រាល់រាស្ត្ររបស់ព្រះជាម្ចាស់ ហើយព្រះពរទាំងនោះមានតម្លៃលើសជាងសម្ភារៈនិយមដែលយើងអាចមាននៅលើលោកនេះទៅទៀត៖

*«តាមដែលទ្រង់បានរើសយើងរាល់គ្នាក្នុងព្រះគ្រីស្ទតាំងពីមុនកំណើតលោកីយ៍មក ប្រយោជន៍ឲ្យយើងរាល់គ្នាបានបរិសុទ្ធ ហើយឥតកន្លែងបន្ទោសបាននៅចំពោះទ្រង់ ដោយសេចក្ដីស្រឡាញ់ ពីព្រោះទ្រង់បានតម្រូវយើងរាល់គ្នាទុកជាមុន សម្រាប់ឲ្យទ្រង់បានទទួលយើងជាកូនចិញ្ចឹម ដោយសារព្រះយេស៊ូវគ្រីស្ទ តាមបំណងព្រះហឫទ័យទ្រង់ ដើម្បីនឹងសរសើរដល់ព្រះគុណដ៏ឧត្ដមរបស់ទ្រង់ ដែលបានផ្ដល់មកយើងរាល់គ្នាទទេ ក្នុងព្រះរាជបុត្រាស្ងួនភ្ងារបស់ទ្រង់ ហើយយើងបានសេចក្ដីប្រោស*

លោះនៅក្នុងព្រះរាជបុត្រានោះ ដោយសារព្រះលោហិតទ្រង់ គឺជាសេចក្តីប្រោសឲ្យរួចពីទោសតាមព្រះគុណដ៏ធ្ងន់ក្រៃលែងនៃទ្រង់ ដែលបានផ្តល់មកយើងជាបរិបូរដោយនូវប្រាជ្ញា នឹងតម្រិះសព្វគ្រប់ ព្រមទាំងសម្តែងឲ្យយើងរាល់គ្នាស្គាល់សេចក្តីអាថ៌កំបាំង នៃព្រះហឫទ័យទ្រង់ តាមគំនិតដែលទ្រង់បានគិតសម្រេច ក្នុងព្រះអង្គទ្រង់ សម្រាប់ការកាន់កាប់ត្រួតត្រា ក្នុងកាលដែលពេលពេញកំណត់បានមកដល់ ដើម្បីនឹងបំព្រួមគ្រប់ទាំងអស់ក្នុងព្រះគ្រីស្ទ ទាំងរបស់នៅស្ថានសួគ៌ នឹងរបស់នៅផែនដីផង ឲ្យរួមគ្នាមកក្នុងទ្រង់ ដែលយើងរាល់គ្នាបានកេរ្តិ៍អាករក្នុងទ្រង់ដែរ ដោយទ្រង់បានតម្រូវយើងទុកជាមុន តាមតម្រិះសម្រេចរបស់ព្រះ ដែលទ្រង់ធ្វើគ្រប់ការទាំងអស់ តាមដែលគាប់ព្រះហឫទ័យទ្រង់ ប្រយោជន៍ឲ្យយើងខ្ញុំ ដែលបានទុកចិត្តជឿដល់ព្រះគ្រីស្ទជាមុនបានសម្រាប់នឹងសរសើរដល់សិរីល្អទ្រង់។

ឯអ្នករាល់គ្នា ក៏បានឮព្រះបន្ទូលនៃសេចក្តីពិត គឺជាដំណឹងល្អពីសេចក្តីសង្គ្រោះរបស់អ្នករាល់គ្នាដោយសារទ្រង់ដែរ ហើយកាលអ្នករាល់គ្នាបានជឿហើយ នោះ

*ទ្រង់ក៏ដៅចំណាំដោយព្រះវិញ្ញាណបរិសុទ្ធ ដែលបានសន្យា ព្រះវិញ្ញាណនោះទ្រង់ជាទីបញ្ចាំចិត្ត ពីដំណើរកេរ្តិ៍អាកររបស់យើងរាល់គ្នាទាល់តែបានលោះរបស់កំណាន់ ដែលទ្រង់បានទិញទុកឲ្យយើងនោះ សម្រាប់ជាសេចក្តីសរសើរដល់សិរីល្អនៃទ្រង់» (អេភេសូរ ១:៤-១៤)។*

សូមសម្គាល់មើលព្រះពរដ៏ល្អខាងឯវិញ្ញាណរបស់គ្រីស្ទបរិស័ទ៖ រើសតាំង តម្រូវទុកជាមុន ស្រឡាញ់ បានទទួលជាកូនចិញ្ចឹម ទទួលយក ប្រោសលោះ សម្តែងឲ្យយើងយល់ អត់ទោសបាប ហើយក៏បានដៅចំណាំយើងដោយព្រះវិញ្ញាណបរិសុទ្ធ ដើម្បីជាទីសម្គាល់នៃការធានាថាយើងនឹងទទួលបានកេរ្តិ៍អាករដែលមកពីទ្រង់។ ទាំងនេះគឺសុទ្ធតែជាព្រះពរដែលនៅអស់កល្បជានិច្ចដែលមិនអាចបំផ្លាញចោលបានឡើយ ហេតុដូច្នេះហើយបានជាវាអាចផ្តល់នូវក្តីអំណរ ការសប្បាយចិត្តដោយស្អាតស្អំ និងសេចក្តីស្កប់ស្កល់ដ៏ជាក់លាក់តទ្បូវនេះលើសជាងព្រះពរបណ្តោះអាសន្ននានា ដែលគ្រូៗដែលអធិប្បាយភាពចម្រុងចម្រើនលើកទឹកចិត្តឲ្យយើងផ្តោតក្តីសង្ឃឹមលើ។

រាស្ត្ររបស់ព្រះជាម្ចាស់មានអំណរ និងភាពស្កប់ស្កល់ ដែល

ភាពលំបាក និងភាពទុក្ខព្រួយ មិនអាចមកបំផ្លាញបាន។ ប្រ-សិនបើលោកអ្នកបានរៀបការហើយ តែគ្មានកូនសោះ ចូរកុំឲ្យគេមើលងាយខ្លួនឡើយ។ លោកអ្នកបានទទួលព្រះពរ ហើយជីវិតអាពាហ៍ពិពាហ៍របស់លោកអ្នកបានពេញបរិបូរហើយ មិនថាមានឬក៏មិនមានកូនចៅនោះទេ។ ប្រសិនបើលោកអ្នកបានកើតជាថ្មី កើតក្នុងព្រះអម្ចាស់ នោះមានន័យថា លោកអ្នកបានទទួលព្រះពរដ៏ល្អៗ មិនថាលោកអ្នករស់នៅក្នុងខ្ទម ឬក៏ក្នុងផ្ទះវីឡាឡើយ។ បុរសម្នាក់ទំនងជារស់នៅក្នុងភាពក្រីក្រអស់មួយជីវិត ប៉ុន្តែគាត់នៅតែល្អប្រសើរជាងអ្នករកស៊ីដែលជាអ្នកមានស្តុកស្តម្ភ ព្រោះទ្រព្យសម្បត្តិរបស់គាត់គឺនៅឯស្ថានសួគ៌ ដែលជាទីកន្លែងដែលកន្លាត និងច្រែះមិនអាចស៊ីបំផ្លាញបាន (ម៉ាថាយ ៦:១៩)។ ស្ត្រីដែលជាគ្រីស្ទបរិស័ទម្នាក់ទំនងជាអាចទ្រាំទ្រនឹងជំងឺណាមួយអស់មួយជីវិតគាត់ តែជំងឺនោះមិនអាចលួចព្រះពររបស់គាត់ដែលមានចែងក្នុងកណ្ឌគម្ពីរអេភេសូរជំពូក១បានឡើយ ហើយគាត់ក៏អាចផ្តោតចិត្តរបស់គាត់ទៅលើសេចក្តីសន្យានៃស្ថានសួគ៌ ដែលជាទីកន្លែងដែលមិនមានការយំសោក ឬក៏ភាពឈឺចាប់ទៀត (វិវរណៈ ២១:៤)។ លោកអ្នកទំនងជាទទួលការបៀតបៀន ប៉ុន្តែព្រះយេស៊ូវបានបង្រៀនថា លោកអ្នកមានពរហើយ ព្រោះនគរ

ស្ថានសួគ៌គឺជារបស់ផងលោកអ្នក (ម៉ាថាយ ៥:១០)។

## ការអធិស្ឋាន និងភាពចម្រុងចម្រើន

យើងបានឃើញម្តងហើយម្តងទៀតពីការដែលព្រះជាម្ចាស់ព្រមានយើងថា កុំឲ្យផ្តោតលើកិត្តិយស និងព្រះពរបណ្តោះអាសន្នដែលនៅបានត្រឹមតែអាយុរបស់យើងនោះឡើយ។ ដូចដែលព្រះអង្គបានចង្អុលយ៉ាងចំៗឲ្យយើងបែរទៅយកព្រះជាម្ចាស់ធ្វើជាចំណុចស្នូល និងព្រះពរដែលនៅអស់កល្បជានិច្ច ដែលព្រះអង្គបានសន្យា ហើយឲ្យដល់យើងក្នុងព្រះយេស៊ូវគ្រីស្ទ។ តើយើងត្រូវរស់នៅរបៀបយ៉ាងដូចម្តេចពេលដែលយើងប្រឈមមុខនឹងការតយុទ្ធបែបនេះទាក់ទងនឹងការស្តាប់បង្គាប់? តើមានសញ្ញាសម្គាល់ដែលនឹងព្រមានយើងពេលដែលយើងបោះបង់ភាពចម្រុងចម្រើនដែលមកពីព្រះជាម្ចាស់ចោល ហើយប្តូរយកភាពចម្រុងចម្រើនជំនួសការថោកទាបរបស់លោកីយ៍នេះដែរឬទេ? យោងតាមព្រះយេស៊ូវ របៀបនៃការអធិស្ឋានរបស់យើងនឹងប្រាប់យើងថាតើយើងឲ្យអភ័យឯកសិទ្ធិលើអ្វី ហើយតើទំនាក់ទំនងរបស់យើងជាមួយនឹងព្រះជាម្ចាស់មានសុខភាពល្អឬទេ។

ដំណឹងល្អដែលសន្យាភាពចម្រុងចម្រើនបានបំផ្លាស់បំប្រែពី

របៀបដែលមនុស្សយើងអធិស្ឋាន។ សព្វថ្ងៃនេះ សេចក្តីអធិស្ឋានភាគច្រើនគឺសុទ្ធតែផ្តោតលើអ្វីៗដែលមាននៅលើផែនដីនេះខ្លាំងជាងខាងឯវិញ្ញាណ លោកអ្នកគ្រាន់តែត្រូវទៅលេងក្រុមជំនុំណាមួយ ហើយស្តាប់នូវអ្វីដែលពួកគាត់ទូលសុំ នោះលោកអ្នកនឹងឃើញថាចំណុចនេះពិត។ ជាទូទៅ ការអធិស្ឋានដែលផ្តោតលើសម្ភារៈនិយមគឺមានមូលដ្ឋានលើខគម្ពីរមួយចំនួនដែលពួកគាត់កាត់ស្រាយខុសបរិបទទាំងស្រុង។ ប្រសិនបើលោកអ្នកអធិស្ឋានទូលសូមព្រះពរខាងឯវិញ្ញាណ នោះឥឡូវនេះលោកអ្នកទំនងជានឹងប្រទះថា សមាជិកមួយចំនួនប្រហែលនឹងចាប់ផ្តើមរអ៊ូរទាំជាមិនខាន។ បើអញ្ចឹង តើយើងគួរអធិស្ឋានយ៉ាងដូចម្តេចទៅ? ក្នុងកណ្ឌគម្ពីរកូឡុស យើងឃើញពីការផ្តោតលើភាពចម្រុងចម្រើនខាងឯវិញ្ញាណក្នុងការអធិស្ឋាន៖

*«ហេតុនោះ ចាប់តាំងពីថ្ងៃ ដែលយើងខ្ញុំឮនិយាយនោះយើងខ្ញុំក៏អធិស្ឋានឲ្យអ្នករាល់គ្នាឥតឈប់ឈរ ហើយទូលសូម ឲ្យអ្នករាល់គ្នាបានស្គាល់ព្រះហឫទ័យទ្រង់សព្វគ្រប់ ដោយគ្រប់ទាំងប្រាជ្ញា នឹងចំណេះខាងឯវិញ្ញាណ ដើម្បីឲ្យបានដើរបែបគួរនឹងព្រះអម្ចាស់ ទាំងគាប់ចិត្តដល់មនុស្សទាំងអស់ ឲ្យបានបង្កើតផល*

*ក្នុងគ្រប់ទាំងការល្អ ហើយឲ្យស្គាល់ព្រះកាន់តែច្បាស់ឡើង ដោយបានគ្រប់ទាំងព្រះចេស្តាចម្រើនកម្លាំង តាមឫទ្ធិបារមីដ៏ឧត្តមរបស់ទ្រង់ ដើម្បីឲ្យបានចេះទ្រាំទ្រ ហើយអត់ធន់គ្រប់យ៉ាងដោយអំណរ ព្រមទាំងអរព្រះគុណដល់ព្រះវរបិតាដែលទ្រង់បានប្រោសឲ្យយើងបានគួរនឹងទទួលចំណែកកេរ្តិ៍អាករ ក្នុងពួកបរិសុទ្ធនៅទីភ្លឺផង ទ្រង់បានប្រោសឲ្យយើងរួចពីអំណាចនៃសេចក្តីងងឹត ហើយផ្លាស់យើងមកក្នុងនគររបស់ព្រះរាជបុត្រាស្ងួនភ្ងានៃទ្រង់ យើងរាល់គ្នាមានសេចក្តីប្រោសលោះក្នុងព្រះរាជបុត្រានោះ គឺជាសេចក្តីផ្ចាច់បាប ដោយសារព្រះលោហិតទ្រង់» (កូឡូស ១:៩-១៤)។*

តើសាវ័ក ប៉ុល បានអធិស្ឋានអ្វីខ្លះសម្រាប់គ្រីស្ទបរិស័ទនៅឯក្រុមជំនុំកូឡូស? សាវ័ក ប៉ុល មិនបានអធិស្ឋានឲ្យពួកគាត់មានទ្រព្យសម្បត្តិផ្នែកសម្ភារៈនិយមឡើយ។ គាត់មិនបានអធិស្ឋានឲ្យពួកគាត់មានជោគជ័យក្នុងការរកស៊ី។ គាត់មិនបានអធិស្ឋានឲ្យពួកគាត់អាចទិញបានផ្ទះថ្មីៗ។ គាត់មិនបានអធិស្ឋានឲ្យពួកគាត់មានសុខភាពល្អរហូត។ គាត់មិនបានអធិស្ឋានឲ្យពួកគាត់

មិនចេះស្លាប់នោះទេ។ តែផ្ទុយទៅវិញ គាត់បានអធិស្ឋានឲ្យព្រះជាម្ចាស់បំពេញពួកគាត់ដោយចំណេះដឹងនៃព្រះហឫទ័យទ្រង់ តាមរយៈប្រាជ្ញា និងការយល់ដឹងខាងឯវិញ្ញាណវិញ។

គាត់បានអធិស្ឋានបែបនោះ ដើម្បីឲ្យពួកគាត់រស់នៅក្នុងលក្ខណៈដែលមានភាពស័ក្តិសម («គួរនឹង») ចំពោះព្រះជាម្ចាស់ ហើយគាប់ព្រះហឫទ័យដល់ទ្រង់ក្នុងគ្រប់របៀប។ ហើយសាវ័កប៉ុល បានបង្ហាញឲ្យយើងឃើញពីរបៀបនៃការរស់នៅដ៏ស័ក្តិសមចំពោះព្រះជាម្ចាស់ ដែលនោះផ្ទុយគ្នាទាំងស្រុងពីអ្វីដែលគ្រូៗដែលអធិប្បាយភាពចម្រុងចម្រើនផ្តោតលើ។ ជីវិតដែលស័ក្តិសមនឹងព្រះជាម្ចាស់គឺជាជីវិតដែលបង្កើតផលផ្លែក្នុងគ្រប់ទាំងការល្អ កើនចំណេះក្នុងការស្គាល់ព្រះជាម្ចាស់ឲ្យកាន់តែច្បាស់ឡើងៗ ពឹងផ្អែកលើព្រះចេស្ដា ដើម្បីស៊ូទ្រាំ ព្រមទាំងអរព្រះគុណដល់ព្រះវរបិតាដោយអំណរ។ តើនេះជារបៀបដែលលោកអ្នកអធិ-ស្ឋានសម្រាប់ខ្លួនឯង និងអ្នកដទៃមែនឬ? ឬក៏ថា ពេលដែលលោកអ្នកអធិស្ឋាន លោកអ្នកគ្រាន់តែផ្តោតលើការឡើងដំណែងមានទ្បាន និងភាពស្រណុកសុខស្រួល? យើងអាច ហើយក៏គួរតែអធិស្ឋានសម្រាប់តម្រូវការរបស់យើងខាងឯរាងកាយ (លូកា ១១:៣) ប៉ុន្តែ ការអធិស្ឋានបែបនោះមិនគួរច្រានចេញ ឬក៏យក

ពេលអធិស្ឋានរបស់យើងច្រើនពេកក្នុងការអធិស្ឋានសម្រាប់តម្រូវការរបស់យើងខាងឯវិញ្ញាណ និងនគររបស់ព្រះជាម្ចាស់ឡើយ (លូកា ១១:២-៤)។ ដាច់ខាត! ពេលដែលយើងអធិស្ឋាន យើងត្រូវតែផ្ដល់អភ័យឯកសិទ្ធិលើព្រះពរខាងឯវិញ្ញាណ។

## សេចក្ដីសន្និដ្ឋាន៖ ចន្លោះបែកគ្នាដ៏ធំ

ចាប់តាំងពីពេលដែលមនុស្សយើងបានធ្លាក់ក្នុងអំពើបាបមកនោះមានចន្លោះបែកគ្នាយ៉ាងធំ៖ អ្នកដែលបដិសេធព្រះជាម្ចាស់ (ដូចលោក កាអ៊ីន) និងអ្នកដែលស្រែកអំពាវនាវរកព្រះនាមព្រះជាម្ចាស់ (ដូចលោក សេត)។ មានចន្លោះរវាងអ្នកដែលប្រមូលទុក និងរស់នៅសម្រាប់ទ្រព្យសម្បត្តិក្នុងជីវិតនេះ និងអ្នកដែលប្រមូលទុកទ្រព្យសម្បត្តិនៅឯស្ថានសួគ៌។ ការប៉ះទង្គិចប្រឆាំងគ្នារវាងក្រុមទាំងពីរនេះ វាមិនជាស្អីថ្មីទេ ប៉ុន្តែខណៈពេលដែលដំណឹងល្អដែលសន្យាភាពចម្រុងចម្រើនសាយភាយចូលក្នុងក្រុមជំនុំយើង ដាច់ខាតយើងត្រូវតែប្រឆាំងនឹងវាដោយប្រើប្រាស់ប្រាជ្ញារបស់ព្រះជាម្ចាស់ដែលបានបង្រៀនយ៉ាងច្បាស់លាស់ក្នុងព្រះគម្ពីរ។

ពេលដែលភាពចម្រុងចម្រើនដ៏ខុសឆ្គងនៃលោកីយ៍នេះ

ប្រជ្រៀតចូលក្នុងជីវិតយើង យើងត្រូវតែបន្តកាន់ឲ្យខ្ជាប់ខ្ជួននូវភាពចម្រុងចម្រើនដ៏ពិតនៃការកោតខ្លាចព្រះ។ ដាច់ខាត! យើងត្រូវតែ*បដិសេធ*ទីក្រុងរបស់លោក កាអ៊ីន ដែលសង់ឡើងសម្រាប់តែសិរីល្អរបស់មនុស្ស ព្រោះនៅថ្ងៃមួយវាក៏នឹងរលាយបាត់ទៅ។ យើងត្រូវធ្វើបែបនេះ *ដើម្បីឲ្យ*យើង*អាចសង្វាតរក*ទីក្រុងដ៏ល្អជាងនោះដែលនៅឯស្ថានសួគ៌វិញ ហើយនៅអស់កល្បជានិច្ចដែលព្រះជាម្ចាស់បានរៀបចំទុកសម្រាប់រាស្ត្ររបស់ទ្រង់។ ជាមួយគ្នាផងដែរ ព្រះជាម្ចាស់ក៏បានត្រាស់ហៅឲ្យយើងបែរចេញពីអំពើបាបនៃការប្រកាន់ខ្ជាប់តាមពហុពន្ធភាព ហើយឲ្យឱបក្រសោបជីវិតអាពាហ៍ពិពាហ៍ក្នុងលក្ខណៈដែលព្រះអង្គបានបង្កើតគឺរវាងបុរសម្នាក់និងស្ត្រីម្នាក់។ ហើយទោះបើពេលខ្លះប្រយោជន៍បណ្តោះអាសន្ននៃទីក្រុងរបស់លោក កាអ៊ីន អាចនាំឲ្យយើងមានភាពច្រណែនក៏ដោយ ក៏ព្រះជាម្ចាស់នៅទាក់ទាញចំណាប់អារម្មណ៍របស់យើង។ ដូច្នេះ ចូរចងចាំពីធាតុពិតៈ វាសនានៃភាពចម្រុងចម្រើនរបស់អស់អ្នកដែលមិនកោតខ្លាចព្រះគឺ ការបំផ្លាញចោល។

អស់អ្នកណាដែលផ្តោតលើព្រះជាម្ចាស់នឹងទទួលបានអំណរនៃភាពចម្រុងចម្រើនដ៏ពិត។ ក្នុងគ្រប់យុគសម័យ យើង

អាចសម្គាល់ថា រាស្ត្ររបស់ព្រះជាម្ចាស់ត្រូវបានញែកចេញ និងទទួលបានព្រះពរតាមរយៈការដែលពួកគាត់ថ្វាយបង្គំព្រះជាម្ចាស់។ ការថ្វាយបង្គំរបស់ពួកគាត់មានពេញទៅដោយការទទួលស្គាល់ថា ព្រះជាម្ចាស់គឺជាប្រភពនៃរាល់គ្រប់ព្រះពរក្នុង និងតាមរយៈព្រះយេស៊ូវគ្រីស្ទ។ ហើយវាកាន់តែមានការស៊ីជម្រៅត្រង់ថា សេចក្តីពិតនៃព្រះពរខាងឯវិញ្ញាណដែលព្រះជាម្ចាស់ប្រទានដល់រាស្ត្ររបស់ទ្រង់ គឺគ្មានអ្នកណា ឬក៏អ្វីមួយអាចមកប៉ះពាល់បានឡើយ។ ហេតុដូច្នេះហើយបានជាសេចក្តីអធិស្ឋានរបស់ពួកគាត់មានការផ្តោតទៅលើសេចក្តីប្រាថ្នាខាងឯវិញ្ញាណ។ ពិតណាស់ យើងរស់នៅក្នុងផែនដីនៃសម្ភារៈនិយម ប៉ុន្តែព្រះជាម្ចាស់បានត្រាស់ហៅឲ្យយើងសង្វាតដេញតាមនូវអ្វីដែលល្អជាងនោះទៅទៀត។

## ជំពូក៣៖

# ជីវិតនៃដំណឹងល្អ

Kenneth Mbugua

«ចូរឲ្យចូលតាមទ្វារចង្អៀត ដ្បិតទ្វារដែលនាំទៅឯសេចក្ដីហិនវិនាស នោះធំ ហើយទូលាយផង ក៏មានមនុស្សជាច្រើនដែលចូលតាមទ្វារនោះ តែឯទ្វារដែលនាំទៅឯជីវិត នោះតូច ហើយចង្អៀតវិញ ក៏មានមនុស្សតិចណាស់ដែលរកផ្លូវនោះឃើញ។ ចូរប្រយ័ត្ននឹងពួកគ្រូក្លែងក្លាយ ដែលគេមកឯអ្នករាល់គ្នា ដោយពាក់រោមចៀមបំប្លែងខ្លួន តែខាងក្នុងរបស់គេ ជាឆ្កែចចកដែលឆ្នក់ស៊ីវិញ អ្នករាល់គ្នានឹងស្គាល់គេបាន ដោយសារផលគេបង្កើត តើដែលបេះផ្លែទំពាំងបាយជូរពីគុម្ពបន្លា ឬផ្លែល្វាពីដំបងយក្សឬទេ ដូច្នេះ អស់ទាំងដើមឈើល្អ តែងមានផ្លែល្អ ឯដើមអាក្រក់ ក៏តែងមានផ្លែអាក្រក់ដែរ ធម្មតាដើមឈើល្អមិនដែលបញ្ចេញផលអាក្រក់បានទេ ហើយដើមដែលអាក្រក់ក៏ពុំអាចនឹងបញ្ចេញផលល្អបានដែរ អស់

*ទាំងដើមឈើណា ដែលមិនកើតផលផ្លែល្អ នោះត្រូវតែកាប់បោះចោលទៅក្នុងភ្លើងចេញ ដូច្នេះ អ្នករាល់គ្នានឹងស្គាល់គេបាន គឺដោយសារផលគេបង្កើត មិនមែនអស់អ្នកណាដែលគ្រាន់តែនិយាយមកខ្ញុំថា ឱព្រះអម្ចាស់ៗអើយ ដែលនឹងចូលទៅក្នុងនគរស្ថានសួគ៌នោះទេ គឺជាអស់អ្នកដែលធ្វើតាមព្រះហឫទ័យនៃព្រះវរបិតា ដែលគង់នៅស្ថានសួគ៌វិញទេតើ» (ម៉ាថាយ ៧:១៣-២១)។*

កាលគេមិនទាន់មានម៉ាស៊ីនប្រើប្រាស់សម្រាប់បញ្ជាក់ថាលុយពិត ឬក្លែងក្លាយ ធនាគារបានបង្រៀនអ្នកធ្វើការឲ្យចេះស្ទាបសាច់លុយពិតដោយប្រើដៃ។ គំនិតដ៏ល្អត្រង់នេះគឺថា ដើម្បីឲ្យស្គាល់អ្វីដែលក្លែងក្លាយគឺដាច់ខាតត្រូវតែស្គាល់នូវអ្វីដែលពិតឲ្យប្រាកដសិន។ យើងមានចិត្តចង់ត្រាប់តាមគំរូនេះ។ តាមរយៈការចំណាយពេលជាមួយនឹងដំណឹងល្អក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ នៅពេលដែលយើងជួបប្រទះនឹងដំណឹងល្អដ៏ខុសឆ្គងនោះយើងនឹងបានដឹងថាវាពិតជាខុសឆ្គងមែន។

យើងនឹងពិនិត្យមើលជីវិតរបស់ព្រះគ្រីស្ទ ពួកសាវ័ក និងជីវប្រវត្តិបុគ្គលមួយចំនួនទៀតក្នុងប្រវត្តិសាស្ត្រក្រុមជំនុំដំបូង ដើម្បី

ពិនិត្យមើលថាតើជីវិតនៃពួកព្យាយុកោរបស់យើងមានភាពស៊ីគ្នាជាមួយនឹងដំណឹងល្អដែលសន្យាភាពចម្រុងចម្រើន និងជីវិតរស់នៅដូចដែលពួកគ្រូៗបែបនោះថាយើងគួរមានដែរឬក៏អត់។ ការធ្វើបែបនេះនឹងជួយយើងក្នុងការត្រៀមខ្លួនដោយមានចំណេះដឹងយ៉ាងច្បាស់ ដើម្បីឲ្យស្គាល់ក្លិននៃដំណឹងល្អដ៏ខុសឆ្គង និងផ្លូវដ៏ខុសឆ្គងរបស់គ្រូៗទាំងនេះបាន។

របៀបរស់នៅរបស់គ្រូៗដែលអធិប្បាយដំណឹងល្អដែលសន្យាភាពចម្រុងចម្រើន គឺពោរពេញទៅដោយភាពសម្បូណ៌ទ្រព្យធន និងភាពខ្ជះខ្ជាយប្រាក់ហួសប្រមាណ។ ហើយពួកគាត់អធិប្បាយថា ព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យគ្រីស្ទបរិស័ទទាំងអស់រស់នៅដូចពួកគាត់ដែរ។ លោកគ្រូ ហ្គោដិន ហ្វី (Gordon Fee) ដែលជាទេវវិទូ និងគ្រូគង្វាលម្នាក់បានពន្យល់ថា ចំណុចខុសឆ្គងមួយនេះកើតមានឡើងដោយសារពួកគាត់កាត់ស្រាយព្រះគម្ពីរក្នុងរបៀបខុសឆ្គង ហើយយើងឃើញយ៉ាងច្បាស់តាមរយៈជីវិតដែលពោរពេញទៅដោយសម្ភារៈនិយម។ ពួកគាត់បានការពារការកាត់ស្រាយដ៏ខុសឆ្គងរបស់ខ្លួនដោយលើកឡើងអំណះអំណាងដ៏ខុសឆ្គងនេះដូចតទៅ៖

*«ព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យកូនៗគ្រប់ៗរូបរបស់ទ្រង់មានភាពចម្រុងចម្រើនខាងឯថវិកា ហើយប្រសិនបើមានគ្រីស្ទបរិស័ទណាម្នាក់កំពុងរស់នៅក្នុងភាពក្រីក្រ នោះមានន័យថា គាត់កំពុងរស់នៅក្រៅព្រះហឫទ័យរបស់ព្រះជាម្ចាស់ហើយ។ ការរស់នៅក្នុងភាពក្រីក្រគឺជាការរស់នៅដូចសាតាំងដែលត្រូវបានចាញ់។ ហើយនៅមានចំណុចមួយទៀតដែលពួកគាត់លាក់ក្នុងអំណះអំណាងនោះ៖ ដោយសារយើងជាកូនៗរបស់ព្រះជាម្ចាស់ (ខ្លះហៅថា "បុត្រាបុត្រីស្ដេច") នោះមានន័យថា យើងគួរតែរស់នៅក្នុងភាពឡូយហ៊ឺហាគ្រប់ពេល—យើងគួរតែមានរបស់ល្អ ហើយស្អាតជាងគេបំផុត ឧ. មានឡានប្រភេទ BMW ជាជាងឡាន Visto ព្រោះមានតែការនេះមួយគត់ដែលអាចនាំមកនូវសិរីល្អដល់ព្រះជាម្ចាស់បាន»។*[១]

តើព្រះគម្ពីរមានការគាំទ្រចំណុចស្នូលនៃដំណឹងល្អដែល

---

១ ដកស្រង់ចេញពីសៀវភៅ The Disease of the Health and Wealth Gospels និពន្ធដោយ៖ លោកគ្រូ Gordon Fee (បោះពុម្ពនៅ Reent College Publishing: Vancouver, ឆ្នាំ២០០៦) ទំព័រ៨។

សន្យាភាពចម្រុងចម្រើនបែបនេះដែរឬទេ? តើព្រះគម្ពីរបាន
បង្រៀនយើងថា ដោយសារយើងជាកូនៗរបស់ព្រះជាម្ចាស់
នោះយើងគួរតែមានរបស់របរល្អៗបំផុតនៅលើលោកនេះមែន
ឬ? តើគំរូនៃព្រះអម្ចាស់របស់យើង និងពួកសាវ័កបានបង្ហាញ
ថាយើងគួរសង្វាតដេញតាមអ្វីក្នុងជីវិតនេះ?

## ព្រះយេស៊ូវគ្រីស្ទ

ព្រះគម្ពីរបានបង្រៀនយើងថា ព្រះយេស៊ូវគ្រីស្ទគឺជាអ្នកមាន
ទ្រព្យសម្បត្តិដ៏ច្រើនម្នាក់ក្នុងចំណោមអ្នកមានផ្សេងៗទៀតនៅ
សម័យកាលទ្រង់។ ព្រះអង្គបានរស់នៅក្នុងវិទ្យាដ៏ធំនៅលើភ្នំដើម
អូលីវ ហើយថែមទាំងមានអ្នកបម្រើជាច្រើនទៀតផង ដើម្បីធ្វើនូវ
រាល់គ្រប់អ្វីៗដែលទ្រង់ចង់ឲ្យពួកគេធ្វើដោយគ្រាន់តែធ្វើសញ្ញា។
ព្រោះព្រះអង្គជាព្រះរាជបុត្រារបស់ព្រះជាម្ចាស់ ដូច្នេះទ្រង់មិន
ដែលស្គាល់ការរងទុក្ខ ឬក៏ការឈឺចាប់ឡើយ ហើយមនុស្សគ្រប់
គ្នាស្រឡាញ់ទ្រង់ ព្រោះព្រះជាម្ចាស់ក៏បានធ្វើឲ្យខ្មាំងសត្រូវរបស់
ទ្រង់ក្លាយជាមិត្តភក្តិរបស់ទ្រង់ផងដែរ។ ពេលដែលព្រះអង្គនៅ
សាលាប្រជុំ ទ្រង់ផ្តោតលើភាពចម្រុងចម្រើនផ្នែកសម្ភារៈនិយម
និងជីវិតដ៏ល្អដែលមនុស្សយើងអាចមានឥឡូវៗនេះ។ ព្រះគម្ពីរ

ក៏បានប្រាប់យើងផងដែរថា ព្រះអង្គបានសន្យាទៅកាន់អស់អ្នកណាដែលដើរតាមទ្រង់ក៏នឹងមានជីវិតដែលគ្មានបញ្ហាដូចជីវិតព្រះអង្គផ្ទាល់។ តើនេះជាការពិតមែនឬ?

កណ្ឌគម្ពីរដំណឹងល្អបានផ្តល់ជាព័ត៌មានដល់យើងថា *នោះផ្ទុយពីធាតុពិតទាំងស្រុង។* ជីវិតរបស់ព្រះគ្រីស្ទគឺពោរពេញទៅដោយការតស៊ូ និងការឈឺចាប់។ យើងនឹងចំណាយពេលខ្លះៗដើម្បីមើលខគម្ពីរដែលពណ៌នាពីជីវិតរបស់ទ្រង់។ ខគម្ពីរទាំងនោះនឹងបង្ហាញជាភស្តុតាងផ្ទាល់អំពីសេចក្តីពិត និងបេសកកម្មរបស់ព្រះយេស៊ូវ។ យើងនឹងព្យាយាមបង្ហាញចំណុចទាំងនេះដល់លោកអ្នក ហើយនាំឲ្យលោកអ្នកស្គាល់សេចក្តីពិតនេះដើម្បីជួយលោកអ្នកក្នុងការត្រៀមខ្លួនប្រៀបធៀបសេចក្តីពិតជាមួយនឹងគំរូ និងសេចក្តីបង្រៀនរបស់គ្រូៗដែលអធិប្បាយដំណឹងល្អដែលសន្យាភាពចម្រុងចម្រើននោះ។

តើព្រះរាជបុត្រានៃព្រះវរបិតាបានរស់នៅយ៉ាងដូចម្តេចនៅលើលោកនេះ ហើយតើការរស់នៅបែបនោះប្រាប់យើងដែលជាអ្នកដើរតាមទ្រង់យ៉ាងដូចម្តេចខ្លះទាក់ទងជាមួយជីវិតរស់នៅរបស់យើង? ក្នុងកណ្ឌគម្ពីរ ម៉ាថាយ ១០:២៤-២៥ ព្រះគ្រីស្ទបានធានាទៅកាន់អស់អ្នកដែលដើរតាមទ្រង់ឲ្យរំពឹងអំពីជីវិត

ខ្លួនក្នុងលក្ខណៈដូចគ្នានឹងទ្រង់៖

*«សិស្សមិនមែនលើសជាងគ្រូទេ ហើយបាវក៏មិនលើសជាងចៅហ្វាយខ្លួនដែរ បើសិស្សបានស្មើនឹងគ្រូ ហើយបាវបានស្មើនឹងចៅហ្វាយ នោះល្មមហើយ បើសិនជាគេហៅម្ចាស់ផ្ទះថា បេលសេប៊ូល នោះចំណង់បើពួកអ្នកនៅផ្ទះនោះទាំងប៉ុន្មាន តើគេនឹងហៅយ៉ាងនោះលើសជាងអម្បាលម៉ានទៅទៀត» (ម៉ាថាយ ១០:២៤-២៥)។*

តាមរយៈការប្រើប្រាស់គោលការណ៍ដ៏ច្បាស់ដែលថា បាវបម្រើមិនលើសជាងចៅហ្វាយខ្លួន នោះព្រះគ្រីស្ទបានបង្ហាញយើងថា ប្រសិនបើចៅហ្វាយរងទុក្ខ នោះបាវបម្រើក៏គួររំពឹងរងទុក្ខបែបដូចហ្នឹងនោះដែរ។ បើគេបានហៅចៅហ្វាយថាជាអារក្ស នោះបាវបម្រើក៏គួររំពឹងថាគេនឹងហៅពួកគាត់ដូចនោះដែរ ហើយអាក្រក់ជាងហ្នឹងទៅទៀត។ ខណៈពេលដែលយើងពិនិត្យមើលជីវិតរបស់ចៅហ្វាយ នោះយើងនឹងឃើញយ៉ាងច្បាស់ថា ចំពោះអ្នកខ្លះដែលហៅខ្លួនថាជាបាវបម្រើរបស់ទ្រង់គឺកំពុងស្វែងរកអ្វី

លើសជាងចៅហ្វាយខ្លួនទៀតហើយ។

តោះ! យើងចាប់ផ្តើមដោយពិនិត្យមើលប្រវត្តិជីវិតរបស់ទ្រង់។ កណ្ឌគម្ពីរលូកាជំពូក២បានផ្តល់ជាព័ត៌មានខ្លះៗអំពីជីវិតឪពុកម្តាយរបស់ព្រះយេស៊ូវក្នុងសង្គមលើផែនដីនេះ។ ពេលដែលពួកគាត់ទៅព្រះវិហារ ពួកគាត់បានថ្វាយដង្វាយសម្រាប់ការបង្កើតកូនប្រុសច្បងរបស់ខ្លួនក្នុងក្រុមគ្រួសារ ដែលដង្វាយនោះគឺសម្រាប់តែអស់អ្នកណាដែលមិនមានសមត្ថភាពក្នុងការថ្វាយសត្វចៀមបាន។

*«លុះដល់កំណត់ កាលត្រូវញែកចេញជាបរិសុទ្ធ តាមក្រឹត្យវិន័យរបស់លោកម៉ូសេ នោះក៏នាំយកព្រះឱរស ទៅឯក្រុងយេរូសាឡិម ដើម្បីថ្វាយដល់ព្រះអម្ចាស់... ហើយនឹងថ្វាយយញ្ញបូជា តាមសេចក្តីដែលបានកត់ទុកក្នុងក្រឹត្យវិន័យរបស់ព្រះអម្ចាស់ គឺថា "លលក១គូ ឬព្រាបជំទើរ"» (លូកា ២:២២, ២៤)។*

ដោយសារនាង ម៉ារា និងលោក យ៉ូសែប មិនមានសមត្ថ-ភាពក្នុងការទិញសត្វចៀមសម្រាប់យញ្ញបូជាដ៏សំខាន់មួយនេះ ដូច្នេះយើងអាចសន្មតយ៉ាងជាក់លាក់ថា ពួកគាត់ក៏មិនមាន

សមត្ថភាពក្នុងការទិញរបស់របរជាច្រើនសម្រាប់ព្រះយេស៊ូវពេលទ្រង់កំពុងធំពេញវ័យដែរ។ ព្រះយេស៊ូវនេះក៏ជាព្រះយេស៊ូវដែលកើតក្នុងស្នូកសត្វដែលមានក្លិនស្អុយ។ ប្រសិនបើព្រះរាជបុត្រារបស់ព្រះជាម្ចាស់អាចធំពេញវ័យបានដោយមិនចាំបាច់មានភាពហ៊ឺហា តើយើងមិនខុសទេឬអី បើយើងអធិប្បាយថា ក្នុងនាមជាបុត្រាបុត្រីរបស់ព្រះជាម្ចាស់ យើងត្រូវតែមានសេចក្តីរំពឹងដោយរស់នៅក្នុងភាពហ៊ឺហានៅលើលោកនេះ? បាវបម្រើមិនលើសពីចៅហ្វាយរបស់ខ្លួនឡើយ។

ប៉ុន្តែ ប្រហែលនោះទាក់ទងតែនឹងពេលដែលព្រះអង្គកំពុងធំធាត់ពេញវ័យទេដឹងមែនឬ? ប្រហែលជាពេលព្រះអង្គធំឡើង ទ្រង់បានចាកចេញពីជីវិតនៃភាពក្រីក្រនៃការរស់នៅជាមួយនឹងគ្រួសាររបស់ទ្រង់ ហើយចេញទៅរស់នៅដោយមានភាពអរសប្បាយ និងហ៊ឺហា។ តើព្រះយេស៊ូវបានបង្ហាញយើងថា ទ្រង់ជាគំរូដើមនៃដំណើររឿងនៃការក្លាយជាអ្នកមានពីអ្នកក្រីក្រ និងដំណើររឿងនៃការចាប់ផ្តើមពីបាតដៃទទេរហូតដល់ភាពចម្រុងចម្រើនផ្នែកសម្ភារៈនិយមមែនឬ? កណ្ឌគម្ពីរលូកាជំពូក៩មិនគាំទ្រគំនិតនេះទេ។ ពេលដែលអាចារ្យម្នាក់នៅជំនាន់នោះស្ម័គ្រចិត្តចង់ក្លាយជាសិស្សរបស់ព្រះគ្រីស្ទ ទ្រង់បានបញ្ជាក់

ពីលក្ខខណ្ឌដូចតទៅ៖ «កញ្ជ្រោងមានរូងវា ហើយសត្វហើរលើអាកាសក៏មានសម្បុកដែរ តែកូនមនុស្សគ្មានកន្លែងណានឹងកើយក្បាលទេ» (លូកា ៩:៥៨)។ ព្រះគ្រីស្ទមិនបានរស់នៅក្នុងវីឡាលើភ្នំដូចដែលអ្នកខ្លះសព្វថ្ងៃនេះចង់គិតថា ទ្រង់បានរស់នៅបែបនោះទ្បើយ។ ព្រះអង្គមានភាពស្កប់ស្កល់នឹងភាពតិចតួចដែលទ្រង់ត្រូវការសម្រាប់ទ្រង់។ ដូចដែលសាវ័ករបស់ទ្រង់បានសរសេរពេលក្រោយមកថា «តែបើមានអាហារទទួលទាន នឹងសំលៀកបំពាក់ នោះក៏ល្មមឲ្យយើងបានស្កប់ចិត្តហើយ» (១ធីម៉ូថេ ៦:៨)។ ប្រសិនបើភាពក្រីក្រគ្រប់គ្រាន់ហើយសម្រាប់ចៅហ្វាយ តើឲ្យបាវបម្រើគួរទាមទារលើសពីហ្នឹងទៀតដែលជាតម្រូវការរបស់ទ្រង់មែនឬ?

នៅចុងបញ្ចប់ ឈើឆ្កាងគឺជាអ្វីដែលផ្តល់អត្ថន័យដល់ជីវិតរបស់ព្រះគ្រីស្ទ។ ព្រះអង្គប្រសូតមក ដើម្បីសុគត។ ព្រះវរបិតាបានគ្រោងជីវិតទ្រង់ទុក ដើម្បីឲ្យមានការរងទុក្ខ។ បើលោកអ្នកព្យាយាមពន្យល់អំពីជីវិតរបស់ព្រះគ្រីស្ទដោយមិនផ្តោតលើការរងទុក្ខដែលព្រះអង្គបានយាងមក ដើម្បីឆ្លងកាត់ជំនួសយើង នោះលោកអ្នកនឹងនៅសល់តែរឿងព្រេងមួយដែលប្រមាថព្រះជាម្ចាស់ជាមិនខាន។ ហោរា អេសាយ បានលើកទំនាយអំពីព្រះមេស្ស៊ី

ដែលបញ្ជាក់ឲ្យយើងឃើញយ៉ាងច្បាស់ពីជីវិតរបស់ព្រះយេស៊ូវគ្រីស្ទក្នុងពាក្យពេចន៍ដូចតទៅនេះ៖

*«ទ្រង់ត្រូវគេមើលងាយ ហើយត្រូវមនុស្សបោះបង់ចោល ទ្រង់ជាមនុស្សទូទុក្ខ ហើយក៏ធ្លាប់ស្គាល់សេចក្តីឈឺចាប់ ទ្រង់ត្រូវគេមើលងាយ ដូចជាអ្នកណាដែលមនុស្សគេចមុខចេញហើយយើងរាល់គ្នាមិនបានរាប់អានទ្រង់សោះ។ ទ្រង់បានទ្រាំទ្រ រងអស់ទាំងសេចក្តីឈឺចាប់របស់យើង ហើយបានទទួលផ្ទុកអស់ទាំងសេចក្តីទុក្ខព្រួយរបស់យើងជាពិត ប៉ុន្តែយើងរាល់គ្នាបានរាប់ទ្រង់ទុកជាអ្នកមានទោសវិញ គឺជាអ្នកដែលព្រះបានវាយជាអ្នកដែលរងវេទនា តែទ្រង់ត្រូវរបួស ដោយព្រោះអំពើរំលងរបស់យើង ក៏ត្រូវវាយជាំ ដោយព្រោះអំពើទុច្ចរិតរបស់យើងទេ ឯការវាយផ្ចាលដែលនាំឲ្យយើងបានជាមេត្រី នោះបានធ្លាក់ទៅលើទ្រង់ ហើយយើងរាល់គ្នាបានប្រោសឲ្យជាដោយសារស្នាមរំពាត់នៅអង្គទ្រង់» (អេសាយ ៥៣:៣-៥)។*

បេសកកម្មរបស់ព្រះយេស៊ូវក្នុងនាមជាព្រះមេស្ស៊ីមានពេញទៅដោយភាពឈឺចាប់ និងការរងទុក្ខ៖ មានគេមើលងាយ បោះបង់ទ្រង់ចោល ទ្រង់ជាមនុស្សទូទុក្ខ បានទ្រាំទ្រ និងរងអស់ទាំងសេចក្ដីឈឺចាប់ បានទទួលផ្ទុកអស់ទាំងសេចក្ដីទុក្ខព្រួយ បានរាប់ទ្រង់ទុកជាអ្នកមានទោស បានវាយ ជាអ្នកដែលរងវេទនា និងត្រូវរបួស។[២] ការត្រាស់ហៅឲ្យដើរតាមព្រះអម្ចាស់មួយនេះមិនមែនជាការដើរលើផ្លូវដ៏ងាយស្រួលទ្បើយ។ លោក អ៊ីសាក វត្តស៍ (Isaac Watts) បានសង្ខេបចំណុចខុសគ្នារវាងដំណើរជីវិតរបស់គ្រីស្ទបរិស័ទ និងការទាមទារដ៏អាត្មានិយមរបស់យើងដូចតទៅ៖ ពេលដែលគាត់សរសេរ «តើខ្ញុំត្រូវការឲ្យមានគេលើកខ្ញុំទៅឯស្ថានសួគ៌នៅលើគ្រែយ៉ាងងាយស្រួលដែលមានពេញទៅដោយផ្កាដោយមិនមានភាពលំបាក ខណៈពេលដែលអ្នកដទៃត្រូវតយុទ្ធ ដើម្បីយកឈ្នះ ហើយទទួលបានរង្វាន់ ព្រមទាំងត្រូវឆ្លងកាត់សមុទ្រដែលពេញដោយឈាមដោយមានភាពលំបាក

២ ប្រសិនបើលោកអ្នកធ្លាប់បានទទួលការបង្រៀនថា ខគម្ពីរទាំងនេះមានន័យថាភាពក្រីក្រ និងការរងទុក្ខរបស់ព្រះគ្រីស្ទបាននាំឲ្យជីវិតរបស់យើងមិនមានការរងទុក្ខ នោះសូមត្រឡប់ទៅអានជំពូក១វិញដែលមានចំណងជើងថា ការយល់ដឹងដ៏ខុសឆ្គងលើព្រះគម្ពីរ។

មែនឬ?»។[៣]

ព្រះអម្ចាស់របស់យើងបានរងទុក្ខសម្រាប់យើង ទ្រង់ក៏បានត្រាស់ហៅយើងឲ្យត្រៀមខ្លួនជាស្រេចក្នុងការរងទុក្ខផងដែរ។ «អ្នកណាដែលមិនផ្ទុកឈើឆ្កាងខ្លួនមកតាមខ្ញុំ នោះក៏ធ្វើជាសិស្សខ្ញុំមិនបានដែរ» (លូកា ១៤:២៧)។ ការដើរតាមព្រះគ្រីស្ទគឺជាការត្រៀមខ្លួនជាស្រេចក្នុងការទទួលយកនូវការឈឺចាប់ និងការរងទុក្ខ។

ខណៈពេលដែលព្រះគ្រីស្ទបានបង្រៀនឲ្យយើងត្រៀមជាស្រេចសម្រាប់ការមានជីវិតដ៏សាមញ្ញ និងពិបាក ព្រះអង្គក៏បានលើកឡើងយ៉ាងច្បាស់លាស់ថា យើងមិនគួរចង់ក្លាយជាអ្នកមានទាល់តែសោះ។ «ចូរប្រយ័ត្ន ហើយខំចៀសពីសេចក្ដីលោភចេញ ដ្បិតជីវិតនៃមនុស្សមិនស្រេចនឹងបានទ្រព្យសម្បត្តិជាបរិបូរទេ» (លូកា ១២:១៥)។ ព្រះយេស៊ូវគ្រីស្ទបានព្រមានថា ការដេញតាមទ្រព្យសម្បត្តិមិនមែនជាការកោតខ្លាចព្រះជាម្ចាស់ទេ ប៉ុន្តែជាគ្រោះថ្នាក់យ៉ាងធំ ដែលយើងត្រូវតែគេចចេញ។ ពេលដែលព្រះអង្គបង្រៀនពួកសិស្សរបស់ទ្រង់អំពីទ្រព្យសម្បត្តិ ទ្រង់មិន

---

៣ ដកស្រង់ចេញពីសៀវភៅទំនុកតម្កើងបរិសុទ្ធដែលមានចំណងជើងជាភាសាអង់គ្លេស *Am I a Soldier of the Cross* និពន្ធដោយលោកគ្រូ Isaac Watts។

បានបង្រៀនពួកគាត់អំពីអាថ៌កំបាំងនៃរបៀបទទួលបានទ្រព្យនោះឡើយ។ ផ្ទុយទៅវិញ ព្រះអង្គបានប្រាប់ឲ្យពួកគាត់បោះបង់ការស្រឡាញ់ទ្រព្យសម្បត្តិចោល។ ប្រសិនបើលោកអ្នកចង់បានព្រះយេស៊ូវ ដាច់ខាតលោកអ្នកត្រូវតែបោះបង់ការលោភលន់ចង់បានលុយកាក់ចោល (លូកា ១៦:១៣)។

ព្រះយេស៊ូវបានរស់នៅយ៉ាងសាមញ្ញ ហើយពេញដោយការបន្ទាបខ្លួន។ ហើយព្រះអង្គក៏បានបង្រៀនយើងឲ្យប្រយ័ត្នក្នុងការធ្លាក់ក្នុងអន្លង់នៃការចង់ក្លាយជាអ្នកមាន។ ព្រះអង្គបានបង្រៀនថារាស្ត្ររបស់ទ្រង់គួររំពឹងថានឹងជួបប្រទះការរងទុក្ខ ហើយមិនគួរវិនិច្ឆ័យជីវិតខ្លួនដោយវាស់វែងនឹងរបស់សម្ភារៈនិយមដែលខ្លួនមានឡើយ។ ឥឡូវនេះ ចូរមើលពីជីវិត និងគោលជំនឿរបស់គ្រូៗដែលអធិប្បាយដំណឹងល្អដែលសន្យាភាពចម្រុងចម្រើនវិញ។ តើពួកគាត់កំពុងអធិប្បាយសាររបស់ព្រះយេស៊ូវមែនឬ? តើរបៀបរស់នៅរបស់ពួកគាត់មានលក្ខណៈដូចជាជីវិតដែលព្រះយេស៊ូវបានរស់នៅ ហើយនិងបានបង្រៀនដែរឬទេ?

# ពួកសាវ័ក

ប្រសិនបើសារនៃដំណឹងល្អដែលសន្យាភាពចម្រុងចម្រើន គឺជាសារដ៏ពិតមែន នោះយើងនឹងរំពឹងឃើញថាអស់អ្នកដែលជាស្មរបន្ទាល់ ទាំងគ្រូអធិប្បាយនៃដំណឹងល្អដំបូងនឹងបង្រៀនអំពីសារនេះច្រើនជាងបុគ្គលណាផ្សេងៗទៀតជាមិនខានហើយ។ សព្វថ្ងៃនេះ អ្នកគាំទ្រដ៏ល្បីល្បាញលើដំណឹងល្អដែលសន្យាភាពចម្រុងចម្រើនសុទ្ធតែរស់នៅក្នុងវិឡា មានឡានឡូយៗរាប់មិនអស់ ហើយថែមទាំងធ្វើដំណើរដោយជិះយន្តហោះផ្ទាល់ខ្លួន។ ចំណែកអស់អ្នកដែលមិនសូវល្បីល្បាញវិញ ពួកគាត់ព្យាយាមឈានទៅដល់កម្រិតនោះ ហើយស្របពេលនោះដែរពួកគាត់ក៏ព្យាយាមបង្ហាញភាពចម្រុងចម្រើនខ្លួនទៀតផង។ ប៉ុន្តែ ចូរយើងពិនិត្យមើលជីវិតរបស់ពួកសាវ័ក។ លោកអ្នកនឹងឃើញពីចំណុចខុសគ្នាយ៉ាងខ្លាំងក្លារហូតដល់វាបង្ហាញថាពួកអស់អ្នកដែលអះអាងខ្លួនថាជាពួកសាវ័កសម្រាប់សម័យនេះ គឺតាមពិតទៅជាគ្រូអធិប្បាយដំណឹងល្អក្លែងក្លាយទេតើ។

គំរូរបស់ពួកសាវ័កបង្ហាញឲ្យយើងឃើញថា ប្រយោជន៍ខាងឯលោកីយ៍នេះមិនសំខាន់ទេ។ ខាងក្រោមនេះជារបៀបដែលសាវ័កប៉ុល បានរៀបរាប់ពីជីវិតរបស់ពួកសាវ័កនានា៖

*«ខ្ញុំស្មានថា ព្រះទ្រង់បានដាក់យើងខ្ញុំ ដែលជាពួក*

*សាវ័ក ឲ្យនៅក្រោយបង្អស់ ហាក់ដូចជាបានតម្រូវឲ្យត្រូវស្លាប់ដែរ ពីព្រោះយើងខ្ញុំបានត្រឡប់ជាទីដែលសម្រាប់ឲ្យលោកីយ៍បានមើលលេង គឺដល់ទាំងពួកទេវតា និងពួកមនុស្សផង យើងខ្ញុំជាមនុស្សល្ងង់ល្ងើដោយយល់ដល់ព្រះគ្រីស្ទ តែអ្នករាល់គ្នាជាអ្នកប្រាជ្ញក្នុងព្រះគ្រីស្ទវិញ យើងខ្ញុំខ្សោយ តែអ្នករាល់គ្នាមានកម្លាំង អ្នករាល់គ្នាមានសេចក្តីរុងរឿង តែយើងខ្ញុំអាប់ឱនកេរ្តិ៍ឈ្មោះវិញ លុះមកដល់ឥឡូវនេះ យើងខ្ញុំត្រូវទាំងឃ្លាន ទាំងស្រេក ហើយនៅអាក្រាត ទាំងត្រូវគេវាយ ហើយក៏ដើរសាត់អណ្តែត យើងខ្ញុំធ្វើការនឿយហត់នឹងដៃយើង កាលណាគេជេរ នោះយើងខ្ញុំឲ្យពរវិញ កាលណាគេបៀតបៀន នោះយើងខ្ញុំទ្រាំទ្រ កាលណាគេប្រមាថ នោះយើងខ្ញុំអង្វរដល់គេ យើងខ្ញុំបានត្រឡប់ដូចជាសំរាមរបស់លោកីយ៍ ហើយដូចជាកម្អែលនៃមនុស្សទាំងអស់ដរាបដល់ឥឡូវនេះ» (១កូរិនថូស ៤:៩-១៣)។*

សាវ័ក ប៉ុល បានសរសេរសារនេះទៅកាន់គ្រីស្ទបរិស័ទដែលបានគិតខ្ពស់ហួសពីគំនិតដែលត្រូវគិតឡើង ដើម្បីស្តីបន្ទោសពួក

គាត់។ គាត់បានលើកឡើងនូវចំណុចខុសគ្នាដ៏មានតម្លៃរវាងអំនួត និងការដែលពួកសាវ័កបន្ទាបខ្លួនក្នុងការកោតខ្លាចព្រះជាម្ចាស់។

ចំពោះសាវ័ក ប៉ុល ការរងទុក្ខគឺជាមូលដ្ឋាននៃការបម្រើព្រះជាម្ចាស់។ សាវ័ក ប៉ុល បានលើកឡើងបួនដងក្នុងសំបុត្រទីពីររបស់គាត់ទៅកាន់លោក ធីម៉ូថេ ដែលជាកូនខាងឯវិញ្ញាណរបស់គាត់ថាឲ្យត្រៀមខ្លួនជាស្រេចក្នុងការរងទុក្ខ។ ជាជាងគេចចេញពីការរងទុក្ខសាវ័ក ប៉ុល បានប្រាប់យើងថា «ចូរទ្រាំទុក្ខលំបាកជាមួយនឹងខ្ញុំ ក្នុងដំណឹងល្អ តាមព្រះចេស្ដានៃព្រះចុះ» (២ធីម៉ូថេ ១:៨)។ ទាក់ទងនឹងការ «ទ្រាំទុក្ខលំបាកជាមួយ» នោះសាវ័ក ប៉ុល បានបញ្ជាក់ពេលក្រោយថា វាជារឿងធម្មតា «ដូចជាទាហានយ៉ាងល្អរបស់ព្រះយេស៊ូវគ្រីស្ទ» (២ធីម៉ូថេ ២:៣)។ ហើយក្រែងលោមានអ្នកខ្លះចង់គេចវេសចេញពីលក្ខណៈដ៏ទូទៅនៃសាររបស់សាវ័ក ប៉ុល គាត់ក៏បានសរសេរយ៉ាងចំៗទៀតថា «ឯអស់អ្នកណាដែលចង់រស់ ដោយគោរពប្រតិបត្តិដល់ព្រះគ្រីស្ទយេស៊ូវ នោះនឹងត្រូវមានសេចក្ដីបៀតបៀនដែរ» (២ធីម៉ូថេ ៣:១២)។

ជីវិតរស់នៅដែលចេះកោតខ្លាចព្រះជាម្ចាស់គឺជាជីវិតរស់នៅដែលចេះឱបក្រសោបការរងទុក្ខ មិនមែនគេចចេញនោះទេ។ សេចក្ដីបង្រៀនរបស់សាវ័ក ប៉ុល គឺផ្ទុយពីការបង្រៀនឲ្យមាន

សុខភាពល្អ និងទ្រព្យសម្បត្តិច្រើនទាំងស្រុង។ សាវ័ក ប៉ុល បានបង្ហាញឲ្យលោក ធីម៉ូថេ និងរម្លឹកដល់យើងថា (ដូចដែលព្រះយេស៊ូវគ្រីស្ទបានធ្វើមុនគាត់) ក្នុងនាមជាគ្រីស្ទបរិស័ទវាជារឿងដ៏ធម្មតាដែលយើងប្រឈមមុខនឹងការបៀតបៀន។ «តែឯអ្នក ចូរឲ្យមានគំនិតនឹងធឹង ក្នុងគ្រប់ការទាំងអស់វិញ ចូរទ្រាំទ្រនឹងសេចក្តីលំបាក ចូរឲ្យអ្នកធ្វើការជាគ្រូផ្សាយដំណឹងល្អចុះ ព្រមទាំងបំពេញការងាររបស់ខ្លួនគ្រប់ជំពូកផង» (២ធីម៉ូថេ ៤:៥)។ ការរងទុក្ខគឺជាចំណុចដ៏ចាំបាច់នៃការធ្វើជាអ្នកដើរតាមព្រះយេស៊ូវគ្រីស្ទ។

ពេលដែលយើងយល់ពីការនេះ នោះយើងនឹងមិនចេះខ្មាសគេក្នុងការរងទុក្ខទេ។ ចូរពិនិត្យមើលការរអ៊ូរទាំរបស់សាវ័ក ប៉ុល ទាក់ទងនឹងការឈឺចាប់៖

*«ប្រាំដងហើយ សាសន៍យូដាវាយខ្ញុំ៤០រំពាត់ខ្វះ១ គេវាយខ្ញុំនឹងដំបង៣ដង គេចោលខ្ញុំនឹងថ្ម១ដង ខ្ញុំត្រូវសំពៅលិច៣ដង ខ្ញុំនៅនាសមុទ្រជ្រៅអស់១ថ្ងៃ១យប់ ខ្ញុំដើរដំណើរជាច្រើន ក៏មានសេចក្តីអន្តរាយនៅទន្លេ អន្តរាយដោយពួកចោរប្លន់ អន្តរាយដោយសាសន៍របស់ខ្ញុំ អន្តរាយដោយសាសន៍ដទៃ ក៏អន្តរាយក្នុងទីក្រុង ក្នុងទីរហោស្ថាន ក្នុងសមុទ្រ ក្នុងពួកបងប្អូនក្លែងក្លាយ*

*ដែរ ត្រូវនឿយហត់ ហើយលំបាក ត្រូវចាំយាមជាញយ ត្រូវស្រេកឃ្លាន ត្រូវអត់ជាញឹកញយ ត្រូវរងា ហើយត្រូវអាក្រាតផង» (២កូរិនថូស ១១:២៤-២៧)។*

ចូរកុំមើលរំលងនូវហេតុផលដែលសាវ័ក ប៉ុល បានលើកឡើងអំពីបទពិសោធន៍ទាំងនេះឲ្យសោះ។ ពេលដែលលោកអ្នកមើលពីបរិបទ នោះលោកអ្នកនឹងឃើញថាសាវ័ក ប៉ុល បានសរសេរចំណុចទាំងនេះទុកជាភស្តុតាងដែលថា គាត់ជាបាវបម្រើរបស់ព្រះគ្រីស្ទ។ ស្នាមរបួសរបស់គាត់គឺជាស្នូរបន្ទាល់ដែលបញ្ជាក់ថា គាត់ជាសាវ័កដ៏ពិតនៃព្រះសង្គ្រោះដែលរងទុក្ខរបស់គាត់។ ពេលដែលគ្រូៗបញ្ជាក់ថា ភាពចម្រុងចម្រើនខាងផ្នែកទ្រព្យសម្បត្តិគឺជាភស្តុតាងនៃភាពស្មោះត្រង់របស់ខ្លួន ចូរគិតពីសាវ័ក ប៉ុល ដែលគាត់បានធ្វើផ្ទុយពីនោះវិញ។ សាវ័ក ប៉ុល បានធ្វើសេចក្តីសន្និដ្ឋានដោយលើកឡើងថា «ហេតុនោះបានជាខ្ញុំអរសប្បាយ ក្នុងកាលដែលមានសេចក្តីកម្សោយ ក្នុងកាលដែលគេត្មះតិះដៀល ក្នុងសេចក្តីលំបាក កាលគេធ្វើទុក្ខបៀតបៀនហើយក្នុងសេចក្តីដែលខ្ញុំត្រូវចង្អៀតចង្អល់ ដោយយល់ដល់ព្រះគ្រីស្ទ ដ្បិតកាលណាខ្ញុំខ្សោយ នោះខ្ញុំមានកម្លាំងយ៉ាងចំណានវិញ។»

(២កូរិនថូស ១២:១០)។ គ្រីស្ទបរិស័ទដែលមានការបន្ទាបខ្លួន នឹងប្រាកដជាបង្ហែរចំណាប់អារម្មណ៍របស់ខ្លួនទៅឯសិរីល្អរបស់ព្រះជាម្ចាស់។ ពួកគាត់មានភាពស្កប់ស្កល់នឹងការរងទុក្ខ ពីព្រោះវាថ្វាយសិរីរុងរឿងទៅដល់តម្លៃនៃព្រះគុណរបស់ព្រះជាម្ចាស់។

តើហេតុអ្វីបានជាព្រះគម្ពីរសញ្ញាថ្មីផ្ដោតយ៉ាងខ្លាំងម្ល៉េះលើការរងទុក្ខ? នៅពេលដែលសាវ័ក ប៉ុល ឆ្លងកាត់ការលំបាក នោះគាត់មិនបានភ្ញាក់ផ្អើលទេ ហើយព្រះជាម្ចាស់ក៏មិនចង់ឲ្យការនោះធ្វើឲ្យយើងភ្ញាក់ផ្អើលផងដែរ។ ប្រសិនបើគ្រីស្ទបរិស័ទយល់ថា ការរងទុក្ខគឺជារឿងធម្មតាទេសម្រាប់គ្រីស្ទបរិស័ទដែលមានការស្មោះត្រង់ នោះការឈឺចាប់នឹងមិនធ្វើឲ្យជំនឿរបស់ពួកគាត់រង្គើឡើយ។ នៅពេលដែលព្រះគ្រីស្ទបានត្រាស់ហៅសាវ័ក ប៉ុល មកកាន់ទ្រង់ផ្ទាល់ ទ្រង់សព្វព្រះហឫទ័យឲ្យគាត់ដឹងពីអ្វីដែលគាត់ត្រូវលះបង់តាំងពីដើមមកម្ល៉េះ៖ «ដ្បិតខ្ញុំនឹងបង្ហាញ ឲ្យគាត់ដឹងជាត្រូវរងទុក្ខលំបាកទាំងអម្បាលម៉ាន ដោយព្រោះឈ្មោះខ្ញុំ» (កិច្ច-ការ ៩:១៦)។ តាមរយៈការពិនិត្យមើលប្រវត្តិរូបនៃជីវិតរបស់ពួកសាវ័ក នោះវានឹងជួយយើងឲ្យចេះត្រៀមខ្លួនក្នុងការប្រឈមមុខនឹងបញ្ហា ហើយដឹងថាព្រះពររបស់ព្រះជាម្ចាស់ក៏មាននៅក្នុងការរងទុក្ខទាំងនោះ។

សូម្បីតែសាវ័ក ប៉ុល ក៏មិនមានការលើកលែងដែរ។ ស្ដេច ហេរ៉ូឌ បានបញ្ជាឲ្យគេសម្លាប់សាវ័ក យ៉ាកុប (កិច្ចការ ១២:២)។ គេបានចាប់សាវ័ក ពេត្រុស ដាក់គុក (កិច្ចការ ១២:៣) ហើយ ប្រវត្តិសាស្ត្រនៃក្រុមជំនុំបានលើកឡើងថា ក្រោយមកគេបាន ឆ្កាងគាត់ (នោះជាការស្លាប់ដ៏វេទនាដែលព្រះគ្រីស្ទបានត្រៀម ទុកសម្រាប់គាត់ សូមមើលកណ្ឌគម្ពីរ យ៉ូហាន ២១:១៨-១៩)។ គេបានវាយពួកសាវ័ក ព្រោះពួកគាត់អធិប្បាយ (កិច្ចការ ៥:៤០-៤១) ហើយគេបានសម្លាប់លោក ស្ទេផាន ដោយចោលនឹងថ្ម (កិច្ចការ ៧:៥៤-៥៨)។ មុនសាវ័ក ប៉ុល បំផ្លាស់បំប្រែចិត្តជឿ គាត់ផ្ទាល់បានញែកខ្លួនថាជាអ្នកដែលចង់វាយប្រហារអស់អ្នក ណាដែលអះអាងទទួលជឿថាព្រះយេស៊ូវជាព្រះអម្ចាស់ (កិច្ច-ការ ៨:៣)។ ពួកសាវ័ក និងគ្រីស្ទបរិស័ទនានានៅជំនាន់ដំបូង បានរងទុក្ខ ហើយបានស្លាប់សម្រាប់ព្រះយេស៊ូវ។

អំណះអំណាងដែលព្រះគម្ពីរបានលើកឡើងអំពីពួកសាវ័ក មិនមានភាពស៊ីសង្វាក់គ្នានឹងសេចក្ដីបង្រៀននៃដំណឹងល្អដែល សន្យាភាពចម្រុងចម្រើននោះទេ។ បាវបម្រើទាំងនេះរបស់ព្រះ គ្រីស្ទ (ដែលលោកីយ៍នេះមិនស័ក្តិសមនឹងពួកគេទេ) មិនបាន រស់នៅក្នុងភាពហ៊ឹហានៅលើផែនដីនេះឡើយ ហើយពួកគាត់

ក៏មិនរំពឹងចង់ក្លាយជាអ្នកមានដែរ។ ពួកគាត់បានដើរតាមព្រះគ្រីស្ទ ដោយដឹងថាការរងទុក្ខ និងការឈឺចាប់គឺមិនមែនជាអ្វីដែលពួកគាត់នឹងទំនងជាប្រទះនោះឡើយ ប៉ុន្តែជាការធានាថាពួកគាត់នឹងជួបប្រទះ។ ហើយចេញពីការធ្វើបែបនោះ ពួកគាត់បានបង្ហាញពីប្រវត្តិនៃជំនឿដែលមានតាំងពីជំនាន់លោក ម៉ូសេ ដែលគាត់ «បានរាប់សេចក្ដីដំនៀលដែលគេតិះដៀលដល់ព្រះគ្រីស្ទ ទុកជាទ្រព្យសម្បត្តិប្រសើរជាងអស់ទាំងរបស់ថ្លៃវិសេសនៅស្រុកអេស៊ីព្ទ ដ្បិតលោកសម្លឹងចំទៅឯរង្វាន់វិញ» (ហេព្រើរ ១១:២៦)។ នៅពេលដែលយើងរងទុក្ខក្នុង និងសម្រាប់ព្រះគ្រីស្ទ នោះវាគឺជាទ្រព្យសម្បត្តិដែលល្អប្រសើរជាងភាពចម្រុងចម្រើន ដែលយើងអាចមាននៅលើលោកនេះទៅទៀត។

## ក្រុមជំនុំដែលទទួលការបៀតបៀន

យើងបានឃើញនូវទុក្ខព្រួយ និងការព្រួយព្រះទ័យរបស់ព្រះអម្ចាស់យើង និងការរងទុក្ខរបស់ពួកសាវ័កដំបូងៗ ខណៈពេលដែលពួកគាត់សង់លើមូលដ្ឋានដែលព្រះគ្រីស្ទបានចាក់គ្រឹះរួចហើយ។ សូមពិចារណាលើគំរូនៃអ្នកបម្រើដ៏ស្មោះត្រង់របស់ព្រះជាម្ចាស់ សូម្បីតែមុនជំនាន់ព្រះគ្រីស្ទ?

*«ពួកស្រីៗបានទទួលមនុស្សស្លាប់របស់ខ្លួនមក ដោយរស់ពីស្លាប់ឡើងវិញ ខ្លះត្រូវគេធ្វើទុក្ខវេទនា ឥត ទទួលការប្រោសលោះឲ្យរួចឡើយ គឺដើម្បីឲ្យបានរស់ ឡើងវិញបែបប្រសើរជាង ខ្លះទៀតត្រូវសេចក្ដីល្បួង ដោយមានគេចំអកឲ្យទាំងវាយនឹងរំពាត់ ក៏ទ្រាំទាំង ជាប់ចំណង នឹងជាប់គុកផង ត្រូវគេចោលនឹងថ្ម ល្បួង ហើយអារបណ្ដាច់ ក៏ត្រូវស្លាប់នឹងដាវ ត្រូវដើររឹមវាម ទាំង ស្លៀកស្បែកចៀម នឹងស្បែកពពែ ត្រូវកំសត់ទុគ៌ត ត្រូវ គេសង្កត់សង្កិនហើយធ្វើបាប ក៏ដើរសាត់ព្រាត់នៅក្នុង ទីរហោស្ថាន ហើយនៅទីភ្នំ ទាំងនៅក្នុងរអាង ហើយ នឹងរូងក្នុងដី លោកីយមិនគួរនឹងពួកអ្នកទាំងនោះទេ» (ហេព្រើរ ១១:៣៥-៣៨)។*

ប៉ុន្តែ តើការរងទុក្ខបែបនេះបានកើតឡើងត្រឹមតែនៅ អតីតកាល ហើយមិនមាននៅសព្វថ្ងៃមែនឬ? តើការទាំងនោះ បានកើតឡើង ដើម្បីឲ្យអ្នកសម័យក្រោយៗអាចមានភាពស្រ-ណុកសុខស្រួលមែនឬ? តើភាពហ៊ឺហា និងភាពងាយស្រួល ជាចំណុចបង្ហាញពីព័ន្ធកិច្ច និងព្រះវត្តមានរបស់ព្រះជាម្ចាស់

មែនឬ? ប្រវត្តិសាស្ត្រក្រុមជំនុំឆ្លើយសំណួរទាំងនោះយ៉ាងច្បាស់លាស់។ ការរងទុក្ខគឺជាចំណុចសម្គាល់នៃការរាលដាលដំណឹងល្អ និងការបន្សុទ្ធគ្រីស្ទបរិស័ទ។

ក្នុងវគ្គនេះ យើងនឹងចំណាយពេលខ្លះៗ ដើម្បីពិនិត្យមើលគំរូអ្នកជឿមួយចំនួនពីប្រវត្តិសាស្ត្រក្រុមជំនុំ ដែលបានបង្ហាញពីព្រះវត្តមានរបស់ព្រះជាម្ចាស់ក្នុងការរងទុក្ខរបស់រាស្ត្រទ្រង់ដោយសារជំនឿរបស់ពួកគេ។ មានប្រភពធនធានជាច្រើនដែលផ្ដល់ព័ត៌មានអំពីគ្រីស្ទបរិស័ទដែលទទួលបានការបៀតបៀនទាំងពីអតីតកាល និងបច្ចុប្បន្នកាល។ យើងនឹងប្រើប្រាស់សៀវភៅ *Foxe's Book of Martyrs* ដែលបានប្រមូលទុកពីប្រវត្តិសាស្ត្រគ្រីស្ទបរិស័ទក្នុងការពិនិត្យមើល។ សូមចូលទៅកាន់គេហទំព័រនានានៃអង្គការមួយចំនួនដែលមានដូចជា Voice of the Martyrs (*www.persecution.com*) and International Christian Concern (*www.persecution.org*) ដើម្បីអានអំពីរឿងរ៉ាវជាច្រើនដែលគ្រីស្ទបរិស័ទកំពុងរងទុក្ខឥឡូវនេះដោយសារជំនឿលើព្រះគ្រីស្ទនៅពេញពិភពលោកនេះ។

មានគ្រីស្ទបរិស័ទដ៏ស្មោះត្រង់ជាច្រើននាក់កំពុងតែស្លាប់ដោយព្រោះព្រះយេស៊ូវគ្រីស្ទ។ ការរស់នៅ និងការស្លាប់របស់បង

ប្អូនប្រុសស្រីទាំងនោះបាននាំមកនូវសិរីល្អដល់ព្រះជាម្ចាស់យ៉ាងខ្លាំង ខណៈពេលដែលពួកគាត់អះអាងពីសេចក្ដីបង្រៀនរបស់សាវ័ក ប៉ុល ថា «ដ្បិតឯខ្ញុំ ដែលខ្ញុំរស់នៅ នោះគឺសម្រាប់ព្រះគ្រីស្ទ ហើយដែលស្លាប់ទៅ នោះជាកំរៃវិញ» (ភីលីព ១:២១)។ ការអធិប្បាយថាគ្រីស្ទបរិស័ទមិនគួររងទុក្ខ គឺជាការមើលងាយដ៏ធ្ងន់ធ្ងរណាស់លើពួកបរិសុទ្ធទាំងនោះ! ការធ្វើបែបនោះគឺជាការលើកឡើងថា ការរងទុក្ខរបស់ពួកសាវ័ក ក្រុមជំនុំដំបូងៗ និងក្រុមជំនុំដែលទទួលការបៀតបៀនគឺគ្មានន័យអ្វីសោះ។ ផ្ទុយពីនោះ គ្រីស្ទបរិស័ទទាំងនោះបានបង្ហាញពីវិញ្ញាណរបស់ព្រះគ្រីស្ទយ៉ាងល្អបំផុត។ ដាច់ខាត! យើងត្រូវតែរៀនពីពួកគាត់។

ចូរយើងចាប់ផ្ដើមពិនិត្យមើលពីជីវិតរបស់ក្រុមជំនុំដំបូងម្នាក់៖ លោកគ្រូ ផូលីខូភ (Polycarp)។ គាត់ជាអ្នកដឹកនាំម្នាក់នៅឯទីក្រុង ស្មឺន៉ា នៅសតវត្សទី២នៃគ.ស.។ ខាងក្រោមនេះគឺជាការរាយរាប់អំពីសេចក្ដីសន្និដ្ឋានទាក់ទងនឹងការកាត់ក្ដីរបស់គាត់ពីអ្នកដឹកនាំប្រទេសរ៉ូម គេបានចោទប្រកាន់ទោសគាត់ដោយសារគាត់ជាអ្នកដើរតាមព្រះគ្រីស្ទ៖

*អ្នកកាត់ក្ដីបានលើកទឹកចិត្តឲ្យគាត់ «ស្បថដោយបដិសេធព្រះគ្រីស្ទ នោះគេនឹងដោះលែងគាត់» ប៉ុន្តែ*

*លោកគ្រូ ផូលីខូភ បានឆ្លើយថា «ខ្ញុំបានបម្រើព្រះអង្គអស់រយៈពេល៨៦ឆ្នាំ ហើយព្រះអង្គមិនដែលធ្វើអ្វីខុសដាក់ខ្ញុំសោះ សូម្បីតែម្ដងក៏គ្មានផង តើឲ្យខ្ញុំប្រមាថព្រះមហាក្សត្ររបស់ខ្ញុំបានដោយរបៀបណាទៅ ដែលទ្រង់ជាព្រះអង្គដែលបានសង្គ្រោះខ្ញុំ?»*។[១]

គ្រីស្ទបរិស័ទដ៏អស្ចារ្យម្នាក់នេះបានចុះចូលយ៉ាងស្ងៀមស្ងាត់ក្នុងការឲ្យគេសម្លាប់គាត់ចោល ជាជាងក្បត់ព្រះគ្រីស្ទ។ ប្រវត្តិសាស្ត្រនៃអាណាចក្ររ៉ូមមានរឿងបែបនេះយ៉ាងច្រើនណាស់។ ឧទាហរណ៍៖ ប្រមាណ៧០ឆ្នាំក្រោយមក នៅប្រទេសរ៉ូមដដែលនោះ មានស្ត្រីម្នាក់ឈ្មោះ ស៊ីសៀលាអា (Cecilia)។ គាត់បានបោះបង់ភាពសុខស្រួលចោលនៃការមានគ្រួសារដែលអ្នកដទៃគោរពរាប់អាន។ គាត់មិនមែនគ្រាន់តែជឿលើព្រះគ្រីស្ទតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងស្មុះស្មាយ៉ាងខ្លាំងក្នុងការនាំអ្នកដទៃមកព្រះអង្គទៀតផង ទោះបើការធ្វើបែបនោះបណ្ដាលឲ្យគេសម្លាប់គាត់ក៏ដោយ។

---

១ ដកស្រង់ចេញពីសៀវភៅ *Foxe's Book of Martyrs* និពន្ធដោយ៖ លោកគ្រូ John Foxe (Peabody: Hendrickson, ឆ្នាំ២០០៤), ទំព័រ១៤។

*គាត់បាននាំឲ្យប្ដី និងប្អូនប្រុសរបស់គាត់ទទួលជឿ ហើយពួកគាត់ក៏ត្រូវបានគេកាត់ក្បាលសម្លាប់ចោលផងដែរ ហើយអ្នកដែលនាំពួកគាត់យកទៅសម្លាប់ក៏បានទទួលជឿផងដែរ ហើយគាត់ក៏បានរងគ្រោះដូចពួកគាត់នោះដែរ។ គេបានដាក់អ្នកស្រីម្នាក់នោះក្នុងខ្ទះទឹកក្ដៅដែលគេកំពុងដាំដោយអាក្រាតអស់យ៉ាងយូរ ហើយបន្ទាប់មកក៏បានយកដាវកាត់ក្បាលគាត់ចោលនៅឆ្នាំ២២២នៃគ.ស.។*[២]

សូម្បីតែនៅទ្វីបអាហ្វ្រិកក៏មានគ្រីស្ទបរិស័ទដ៏ស្មោះត្រង់ដែលបានរងគ្រោះយ៉ាងសាហាវៗដែរ។ «លោកគ្រូ សាទត័រនីនូស៍ (Saturninus) ដែលជាគ្រូគង្វាលនៅស្រុក អែលប៊ីធីណា (Albitina) នៅប្រទេសអាហ្វ្រិក បន្ទាប់ពីពេលដែលគេបានធ្វើបាបគាត់ គេក៏បានបោះគាត់ចូលគុក ទុកឲ្យស្លាប់ព្រោះដាច់បាយ។ ក្រោយមកបន្ទាប់ពីគេបានធ្វើបាបកូនៗទាំងបួនរបស់គាត់ គេក៏បានសម្លាប់ពួកគាត់ដូចគេបានសម្លាប់ឪពុកផងដែរ។»[៣] យើងនៅអាចលើកឧទាហរណ៍ជាច្រើនទៀតដែលរាប់

២ ដូចខាងលើពីទំព័រ១៩។

៣ ដូចខាងលើពីទំព័រ៣៦។

មិនអស់ទាក់ទងនឹងរឿងរ៉ាវរបស់គ្រីស្ទបរិស័ទដែលស្លាប់សម្រាប់ព្រះគ្រីស្ទជាច្រើនឆ្នាំកន្លងទៅនេះនៅលើផែនដីយើងនេះ។ ការសរសេរចុះចេញពីប្រវត្តិសាស្ត្រទាមទារឲ្យយើងមានការឆ្លើយតប។ តើពួកបរិសុទ្ធទាំងនេះខុសមែនឬក្នុងការដែលពួកគាត់រងទុក្ខដោយព្រោះដំណឹងល្អ?

ខណៈពេលដែលលោកអ្នកកំពុងអានសៀវភៅនេះ មានបងប្អូនប្រុសស្រីរបស់គ្រីស្ទបរិស័ទជាច្រើនកំពុងរងទុក្ខដោយទទួលការបៀតបៀន ព្រោះជំនឿរបស់ពួកគាត់លើព្រះគ្រីស្ទ។ ចំពោះគ្រីស្ទបរិស័ទរាប់លាននាក់នៅអាស៊ី ប្រទេសនីហ្សេរីយ៉ា (Nigeria) នៅប្រទេសស៊ូដង់ (Sudan) និងប្រទេសនានាដែលកាន់តាមសាសនាអ៊ីស្លាម ការស្លាប់ដោយសារភាពស្មោះត្រង់លើព្រះគ្រីស្ទគឺជាអ្វីដែលពួកគាត់ប្រឈមមុខយ៉ាងជាក់ស្ដែង។ តាមពិតទៅ ភេរវកម្មដែលចេញពីសាសនាអ៊ីស្លាមបាននាំឲ្យមានមនុស្សជាច្រើនអាចនឹងប្រឈមមុខនឹងការស្លាប់ដោយសារជំនឿលើព្រះគ្រីស្ទនៅទីណាក៏បានលើលោកនេះ។ ចូរនឹកគិតអំពីគ្រីស្ទបរិស័ទដែលគេញែកចេញ ហើយសម្លាប់ចោលយ៉ាងសាហាវនៅឯមហាវិទ្យាល័យ Garissa នៅប្រទេសកេនយ៉ា ដែលទើបតែកើតឡើងថ្មីៗនេះ។ វាធ្វើឲ្យយើងព្រឺរោមខ្លាកៗពេលយើងឮពីបងប្អូន

ប្រុសស្រីដែលមនុស្សអាក្រក់បានបាញ់រះសម្លាប់ចោល ពេលពួកគាត់កំពុងជួបជុំគ្នាអធិស្ឋាន។ ប៉ុន្តែ ខណៈពេលដែលយើងរង់ចាំថ្ងៃដែលរឿងដ៏សាហាវៗបែបនេះលែងមានទៀត ចូរកុំបន្ទាបកិត្តិយសគ្រីស្ទបរិស័ទដែលគេបានសម្លាប់ចោលដោយសារជំនឿ ដោយភ្លេចគិតថា ពួកគាត់បានទទួលរង្វាន់ច្រើនណាស់ដែលរាប់មិនអស់ជាងអ្វីដែលពួកគាត់បានខាតបង់ទៅទៀត។

អ្នកនិពន្ធកណ្ឌគម្ពីរហេព្រើរបានសរសេរអំពីបុរសស្ត្រីបែបនោះដូចតទៅ៖

> *«ពួកអ្នកទាំងនោះបានស្លាប់ក្នុងសេចក្តីជំនឿ ឥតទទួលសេចក្តីដែលបានសន្យាទាំងប៉ុន្មានទេ តែគេបានឃើញពីចំងាយ ហើយក៏ទទួលគំនាប់ដែរ ទាំងយល់ព្រមថា ខ្លួនគេជាអ្នកដទៃ ដែលគ្រាន់តែសំណាក់នៅផែនដីប៉ុណ្ណោះ ពួកអ្នកដែលនិយាយដូច្នោះ នោះសម្តែងច្បាស់ថា គេជាអ្នករកស្រុកសម្រាប់ខ្លួនគេពិត ហើយបើសិនជាគេរឭកស្រុក ដែលគេទើបនឹងចេញមកនោះ នោះគេនឹងមានឱកាសត្រឡប់ទៅវិញបាន តែឥឡូវនេះ គេសង្វាតចង់បានស្រុក១ដ៏ប្រសើរជាង គឺខាងស្ថានសួគ៌វិញ បាន*

*ជាព្រះទ្រង់គ្មានសេចក្ដីខ្មាស ដោយគេហៅទ្រង់ជាព្រះនៃគេនោះឡើយ ដ្បិតទ្រង់បានរៀបចំទីក្រុង១ឲ្យគេហើយ» (ហេព្រើរ ១១:១៣-១៦)។*

តើសេចក្ដីបង្រៀនបែបយ៉ាងម៉េចអាចនឹងត្រៀមមនុស្សធម្មតាឲ្យអាចឈរមាំបែបនោះបាន ហើយឈានដល់ទី បញ្ចប់ដូចនោះបានទៅណ៎? ការអធិប្បាយដំណឹងល្អដែលសន្យាភាពចម្រុងចម្រើនធ្វើឲ្យគ្រីស្ទបរិស័ទមិនអាចពន្យល់អំពីចំណុចស្នូលនៃការរងទុក្ខក្នុងជីវិតអស់អ្នកណាដែលដើរតាមព្រះគ្រីស្ទបានទេ។ វាធ្វើឲ្យបុរសស្ត្រីមិនអាចពន្យល់បាន ហើយថែមទាំងច្រឡំទៀតពេលដែលពួកគាត់ប្រឈមមុខនឹងភាពក្រីក្រ និងភាពឈឺចាប់។ មានតែក្ដីសង្ឃឹមដ៏ពិត និងសិរីល្អនៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទទេទើបអាចបណ្ដាលឲ្យគ្រីស្ទបរិស័ទអាចយល់បានទាក់ទងនឹងការបៀតបៀន និងភាពឈឺចាប់ឥឡូវនេះបាន។ ក្នុងនាមជាអ្នកស្លាប់សម្រាប់ដំណឹងល្អនៅសតវត្សទី២០លោកគ្រូ ជីម អេលាត (Jim Elliot) បានមានប្រសាសន៍ដ៏ល្បីល្បាញថា «បុគ្គលម្នាក់ដែលឲ្យនូវអ្វីដែលគាត់មិនអាចរក្សាទុកបាន ដើម្បីឈោងចាប់យកនូវអ្វីដែលគាត់នឹងមិនអាចបាត់បង់បាន បុគ្គលនោះមិន

មែនជាមនុស្សល្ងីល្ងើទេ»។

## សេចក្តីសន្និដ្ឋាន

សូមពិនិត្យមើលគំរូអំពីព្រះគ្រីស្ទ ពួកសាវ័ក និងគ្រីស្ទបរិស័ទដែលទទួលការរងទុក្ខជាច្រើនសតវត្សនេះ។ បន្ទាប់មក សូមពិនិត្យមើលគំរូ និងសាររបស់គ្រូៗដែលអធិប្បាយដំណឹងល្អដែលសន្យាភាពចម្រុងចម្រើន។ យើងមានដំណឹងល្អដ៏ពិតរបស់ព្រះគ្រីស្ទ និងអ្នកបម្រើមុនៗយើង នោះយើងនឹងអាចស្គាល់ ហើយបដិសេធដំណឹងល្អដ៏ខុសឆ្គងនេះដែលគ្មានតម្លៃទាក់ទងនឹងសុខភាព និងទ្រព្យសម្បត្តិនេះបានជាមិនខាន។

## ជំពូក៤៖

# ការរងទុក្ខ

Kenneth Mbugua

*«ហេតុនោះយើងខ្ញុំមិនណាយចិត្តឡើយ ប៉ុន្តែទោះបើមនុស្សខាងក្រៅរបស់យើងខ្ញុំ កំពុងតែពុករលួយទៅក៏ពិតមែន តែនៅខាងក្នុងកំពុងតែកែប្រែជាថ្មីឡើងរាល់ថ្ងៃជានិច្ចវិញ ដ្បិតសេចក្ដីទុក្ខលំបាកយ៉ាងស្រាលរបស់យើងខ្ញុំ ដែលនៅតែមួយភ្លែតនេះ នោះបង្កើតឲ្យយើងខ្ញុំមានសិរីល្អយ៉ាងធ្ងន់លើសលប់ ដ៏នៅអស់កល្បជានិច្ចវិញ ដោយយើងខ្ញុំមិនរាប់អានរបស់ដែលមើលឃើញឡើយ គឺរាប់អានតែរបស់ដែលមើលមិនឃើញវិញ ដ្បិតរបស់ដែលមើលឃើញនោះស្ថិតស្ថេរមិនយូរប៉ុន្មានទេ តែឯរបស់ដែលមើលមិនឃើញ នោះនៅស្ថិតស្ថេរអស់កល្បជានិច្ចវិញ» (២កូរិនថូស ៤:១៦-១៨)។*

យើងរស់នៅលើផែនដីដែលពោរពេញទៅដោយការរងទុក្ខ។ ការរញ្ជួយដី ខ្យល់ព្យុះសង្ឃរា ភាពរាំងស្ងួត អំណត់អត់ សង្គ្រាមដែលបំផ្លាញជីវិត ផ្ទះសំបែង សង្គម និងជាតិសាសន៍នានា។ បើនិយាយសាច់រឿងផ្ទាល់ៗវិញ តើអ្នកណាមិនធ្លាប់ស្គាល់ការឈឺចាប់ពេលគេបដិសេធយើង ក្បត់យើង ហើយនិងពេលយើងឈ្លោះទាស់ទែងគ្នា? ជាប្រចាំថ្ងៃ យើងតែងតែប្រឈមមុខនឹងការគំរាមកំហែងនៃការរងទុក្ខដែលអាចនឹងកើតឡើងភ្លាមៗ ព្រោះគ្រោះថ្នាក់អាចនាំឲ្យយើងមានការបាត់បង់ និងភាពទុក្ខព្រួយក្នុងមួយរំពេចភ្នែក។ ហើយយើងរស់នៅក្នុងស្ថានភាពដែលពោរពេញទៅដោយជំងឺនៅជុំវិញយើងដែលនាំឲ្យយើងមានការឈឺចាប់ដែលអាចនឹងសម្លាប់យើងបន្តិចម្តងៗ ឬក៏យ៉ាងឆាប់រហ័ស ក៏ដូចជាអស់អ្នកដែលយើងស្រឡាញ់ផងដែរ។ តើនៅមានមន្ទិលសង្ស័យទេក្នុងការគិតថា យើងកំពុងរស់នៅលើផែនដីដែលមានការបាក់បែកនេះ?

ចាប់តាំងពីពេលដែលការរងទុក្ខបានចូលមកក្នុងផែនដីយើង យើងបានព្យាយាមរត់គេចចេញពីវា។ មានការស្វែងរកត្រឹមតែពីរបីយ៉ាងផ្សេងទៀតទេ ដែលមនុស្សយើងចូលចិត្តធ្វើក្រៅពីការគេចចេញពីភាពឈឺចាប់ និងការកាន់តែមានភាពអរសប្បាយ។ យើង

បង្កើតម៉ាស៊ីន និងយុទ្ធសាស្ត្រថ្មីៗដោយមានការសន្យាយ៉ាងចំៗ ថា យើងនឹងមានភាពអរសប្បាយលើសដើម ហើយនិងមិនសូវមានការឈឺចាប់ដូចមុនទេ។ យើងរកការងារល្អៗជាងមុន លុយច្រើនជាងមុន និងសុខភាពល្អជាងមុន។ យើងស្វែងរកទំនាក់ទំនងល្អៗជាងមុន ក្រុមជំនុំ និងគ្រូគង្វាលអស្ចារ្យៗជាងមុន។ ឫសគល់នៃមនុស្សយើងគឺ រវីរវល់ខ្លាំងណាស់ក្នុងការសង្វាតរកក្ដីអរសប្បាយជាងមុន និងការមិនសូវមានភាពឈឺចាប់។ តើព្រះគម្ពីរបានថ្កោលទោសការធ្វើបែបនេះដែរឬទេ? មិនបានថ្កោលទោសទេ ប៉ុន្តែព្រះគម្ពីរបានកែតម្រូវលើការយល់ដឹងនៃការរងទុក្ខរបស់យើង ហើយក៏បានផ្ដល់ដល់យើងថាការរងទុក្ខគឺជាវិថីតែមួយគត់ក្នុងការទទួលបានអំណារ។

មូលហេតុដែលដំណឹងល្អដែលសន្យាភាពចម្រុងចម្រើនមានប្រជាប្រិយភាពគឺដោយសារវាចាក់ចំមូលដ្ឋានដ៏សាមញ្ញនៃសេចក្ដីប៉ងប្រាថ្នារបស់មនុស្សលោក។ ប៉ុន្តែ វាផ្ដល់នូវដំណោះស្រាយលើការរងទុក្ខដែលគ្មានចែងក្នុងព្រះគម្ពីរទាល់តែសោះ ហើយមានការណែនាំដ៏ខុសឆ្គងថែមទៀតផង។ នៅចុងបញ្ចប់ វានាំមកនូវគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរដល់អស់អ្នកដែលដើរតាមវា។ ហើយជាជាងសង្គ្រោះមនុស្ស ដំណោះស្រាយដ៏ខុសឆ្គងនេះបានធ្វើឲ្យ

មនុស្សជាច្រើនបាក់ទឹកចិត្ត មិនអាចមើលឃើញយ៉ាងច្បាស់លាស់ ហើយថែមទាំងមានភាពជូរចត់នឹងព្រះជាម្ចាស់ផ្ទាល់ និងរាស្ត្ររបស់ទ្រង់។ ដំណឹងល្អដែលសន្យាភាពចម្រុងចម្រើនគឺមិនមែនជាដំណោះស្រាយដែលព្រះជាម្ចាស់បានប្រទានមកសម្រាប់ការរងទុក្ខរបស់យើងទេ វាមិនមែនជាដំណឹងល្អដ៏ពិតនោះឡើយ។ នៅក្នុងជំពូកនេះ យើងនឹងចំណាយពេលមើលយ៉ាងចំៗលើអ្វីដែលព្រះជាម្ចាស់បង្រៀនយើងអំពីការរងទុក្ខ និងអំពីរបៀបដែលវាខុសគ្នាពីដំណឹងល្អដែលសន្យាភាពចម្រុងចម្រើនដែលមនុស្សយើងងាយនឹងលង់ក្នុងការបោកប្រាស់របស់វា។

## ការយល់ពីភាពរងទុក្ខ

អ្នកគង្វាលគោនឹងសួរសំណួរដ៏សាមញ្ញៗបីយ៉ាង ពេលដែលពួកគាត់ឃើញសត្វគោធ្លាក់ជាប់ក្នុងប្រឡាយណាមួយ៖ តើសត្វគោនេះបានធ្លាក់ដល់ថ្នាក់ហ្នឹងបែបម៉េចទៅ? តើឲ្យយើងយកវាចេញដោយរបៀបណា? ហើយតើឲ្យយើងធ្វើដូចម្ដេច ដើម្បីរារាំងកុំឲ្យសត្វគោហ្នឹងទៅធ្លាក់ប្រឡាយហ្នឹងម្ដងទៀតបាន? ដូចគ្នាផងដែរ ដើម្បីឲ្យយើងយល់អំពីដំណោះស្រាយដែលព្រះជាម្ចាស់ប្រទានឲ្យយើងទាក់ទងនឹងបញ្ហានៃការរងទុក្ខ យើងក៏

ត្រូវតែយល់ពីមូលហេតុដែលយើងជួបប្រទះការរងទុក្ខ របៀបតែមួយគត់ដែលដោះស្រាយវា និងតើឲ្យយើងធ្វើបែបម៉េច ដើម្បីកុំឲ្យវាកើតឡើងម្តងទៀត។

ធ្លាប់មានពេលមួយ ដែលកាលនោះមិនមានការរងទុក្ខឡើយ ប៉ុន្តែដោយសារអំពើបាប (ជាការដែលយើងបដិសេធព្រះជាម្ចាស់) នោះបាននាំមកនូវភាពឈឺចាប់ឲ្យហូរចូលមកផែនដីនេះ។ ហើយនៅអនាគត ក្នុងពេលវេលាដ៏អស់កល្បជានិច្ចនឹងលែងមានការរងទុក្ខទៀតហើយ។ តើអ្វីទៅនាំឲ្យមានមេត្រីភាពឡើងវិញរវាងការបែកគ្នាមួយនេះ? ព្រះគ្រីស្ទបានយាងមកកាន់ផែនដីនេះ ដើម្បីដោះស្រាយអំពើបាបយើង និងរាល់ផលកម្មនានាតាមរយៈការសុគតលើឈើឆ្កាង ការយកឈ្នះលើសេចក្តីស្លាប់តាមរយៈការរស់ឡើងវិញ ហើយនិងការយាងទៅកាន់ស្ថានសួគ៌វិញ។ ដោយសារព្រះអង្គបានរងទុក្ខខាងឯសាច់ឈាម និងខាងឯវិញ្ញាណនៅលើឈើឆ្កាងជំនួសយើង នោះទ្រង់បានបង់ថ្លៃលោះទារុណកម្មសម្រាប់អំពើបាបយើង ហើយព្រះអង្គថែមទាំងបានទិញយកនូវការប្រោសលោះទាំងស្រុងរបស់យើង និងការស្តារឡើងវិញនូវអ្វីៗដែលទ្រង់បានបង្កើតមកផងដែរ។ ព្រះលោហិតរបស់ទ្រង់បានសម្រេចនូវរាល់តម្រូវការដែល

ចាំបាច់សម្រាប់បង្កើតស្ថានសួគ៌ និងផែនដីថ្មី ដែលនឹងមិនមានការរងទុក្ខទៀតឡើយ (រ៉ូម ៨:១៨-២៥)។

ប្រសិនបើយើងមិនយល់អំពី៖ ១) មូលហេតុដែលមានការរងទុក្ខ ២) អំពីអ្វីដែលព្រះជាម្ចាស់បានធ្វើសម្រាប់វា ៣) និងអំពីអត្ថន័យនៃការនោះសម្រាប់យើង នោះយើងប្រាកដជានឹងងាយធ្លាក់ក្នុងការទទួលយកនូវដំណោះស្រាយដែលខុសឆ្គងនេះជាមិនខាន។ តាមរយៈការបង់ថ្លៃយ៉ាងពេញទី ព្រះជាម្ចាស់បានប្រទានមកយើងនូវដំណោះស្រាយយ៉ាងអស់កល្បជានិច្ចចំពោះបញ្ហានៃអំពើបាបរបស់យើង និងផលកម្មដ៏ឈឺចាប់របស់វា។ ប៉ុន្តែ គ្រូៗដែលអធិប្បាយដំណឹងល្អដែលសន្យាភាពចម្រុងចម្រើនបានបង្ខូចដំណឹងល្អនេះយ៉ាងសៅហ្មង។

## ដើមចមនៃការរងទុក្ខ

ជំពូកដំបូងនៃព្រះគម្ពីរប្រាប់យើងថា ព្រះជាម្ចាស់បានបង្កើតនូវរាល់គ្រប់អ្វីៗចេញពីភាពសូន្យឈឹង។ ព្រះអង្គជាដើមកំណើត ជាអង្គដែលរចនា និងជាអង្គដែលសាងសង់។ ហើយអ្វីដែលព្រះអង្គបានបង្កើតគឺ*ល្អប្រពៃ* (លោកុប្បត្តិ ១:៣១)។ ចំណុចដ៏ល្អប្រពៃពីដើមដំបូងនោះក៏មានបញ្ចូលទាំងមនុស្សលោកដែលព្រះ

ជាម្ចាស់បានបង្កើតផងដែរ។ បុរស និងស្រ្តីបានមានមេត្រីភាពជាមួយនឹងព្រះជាម្ចាស់ ជាមួយគ្នានឹងគ្នា និងជាមួយនឹងគ្រប់អ្វីៗដែលទ្រង់បានបង្កើតមកដែរ។ គ្រប់អ្វីៗនៅល្អ ប៉ុន្តែពេលដែលមនុស្សលោកសម្រេចចិត្តថាព្រះជាម្ចាស់មិនគ្រប់គ្រាន់ ពេលនោះឯងជាពេលដែលលែងនៅល្អទៀតហើយ។

ក្នុងកណ្ឌគម្ពីរលោកុប្បត្តិជំពូក៣ លោក អ័ដាម និងនាង អេវ៉ា មិនបានស្តាប់បង្គាប់ព្រះជាម្ចាស់ទេ។ ព្រះអង្គបានប្រាប់ពួកគាត់ថា «ឯងនឹងស៊ីផ្លែទាំងអស់ក្នុងសួនច្បារនេះបានតាមចិត្ត តែឯត្រង់ដើមដឹងខុសត្រូវ នោះមិនត្រូវឲ្យឯងស៊ីផលឡើយ ដ្បិតនៅថ្ងៃណាដែលឯងស៊ី នោះនឹងត្រូវស្លាប់ជាមិនខាន» (លោកុប្បត្តិ ២:១៦-១៧)។ ព្រះជាម្ចាស់បានព្រមានយ៉ាងច្បាស់លាស់ទៅកាន់លោក អ័ដាម និងនាង អេវ៉ា ថាការរងទុក្ខនឹងប្រាកដជាកើតមានឡើងប្រសិនបើពួកគាត់ជ្រើសរើសបែរចេញពីទ្រង់។ ប៉ុន្តែ ពួកគាត់បានមើលរំលងការព្រមានរបស់ព្រះជាម្ចាស់ ហើយលោតចូលក្នុងអំពើបាប ដោយសារសត្វពស់បានបញ្ចុះបញ្ចូលឲ្យពួកគាត់ជឿថា ពួកគាត់អាចរកឃើញភាពស្កប់ស្កល់បាន ដែលនៅក្រៅពីទំនាក់ទំនងរបស់គាត់ជាមួយនឹងព្រះជាម្ចាស់។

ពួកគាត់បានព្យាយាមឈោងចាប់ថែមទៀត ប៉ុន្តែឃើញថាវា

មានតិចជាងមុន។ ពួកគាត់ព្យាយាមចាប់យកប្រាជ្ញា ប៉ុន្តែឃើញថាវាជាភាពល្ងីល្ងើទៅវិញ។ ហើយពួកគាត់ព្យាយាមស្វែងរកភាពអរសប្បាយ ប៉ុន្តែរកឃើញតែភាពឈឺចាប់ប៉ុណ្ណោះ។ ការរងទុក្ខបានចូលមកដល់ផែនដីយើងពេលដែលមនុស្សយើងព្យាយាមរកភាពអរសប្បាយ និងគោលបំណងក្រៅពីនៅក្នុងព្រះជាម្ចាស់។ ក្រោយពីមនុស្សប្រុស និងមនុស្សស្រីបានប្រព្រឹត្តល្មើសទាស់នឹងក្រឹត្យវិន័យរបស់ព្រះជាម្ចាស់ ស្រាប់តែភ្លាមៗនោះផែនដីរបស់ពួកគាត់ក៏មានការបែកបាក់។ ពួកគាត់ក៏ចាប់ផ្តើមមានភាពភ័យខ្លាច និងភាពអាម៉ាស់ ដែលនោះហើយជាអារម្មណ៍ដ៏ចម្លែកមួយដែលពួកគាត់មិនដែលមានពីមុនៗមក។ នេះឯងជាដើមចមនៃការរងទុក្ខៈ វាបានចូលមកផែនដីតាមរយៈទ្វារនៃអំពើបាប។

លោក អ័ដាម និងនាង អេវ៉ា បានធ្វើឲ្យការប្រកបគ្នាជាមួយនឹងព្រះជាម្ចាស់បាក់បែក ហើយបន្ទាប់មកទ្រង់ក៏បានពន្យល់ពីផលកម្មមួយចំនួនទៅកាន់ពួកគាត់។

> *«ទ្រង់ក៏មានព្រះបន្ទូលទៅស្ត្រីវិញថា អញនឹងចម្រើនឲ្យឯងមានសេចក្តីព្រួយលំបាកជាច្រើនឡើងក្នុងវេលាដែលមានផ្ទៃពោះ ឯងនឹងបង្កើតកូនដោយឈឺចាប់ ចិត្តឯងនឹងប្រាថ្នាខាងឯប្តី ហើយប្តីនឹងត្រួត*

*គ្រាលើឯង រួចទ្រង់ក៏មានព្រះបន្ទូលទៅអ័ដាមថា ដោយព្រោះឯងបានស្តាប់តាមប្រពន្ធឯង ហើយស៊ីផ្លែឈើនោះដែលអញបានហាមមិនឲ្យស៊ីឡើយ នោះដីត្រូវបណ្តាសាដោយព្រោះឯង ឯងត្រូវរកស៊ីពីដីដោយនឿយហត់អស់១ជីវិត ដីនឹងដុះជាបន្លា ហើយនឹងអញ្ចាញឲ្យឯង ឯងត្រូវស៊ីអស់ទាំងតិណជាតិដែលដុះនៅស្រែចំការ ឯងនឹងបានអាហារស៊ីដោយការបែកញើស ដរាបដល់ឯងត្រឡប់ទៅជាដីវិញ ពីព្រោះអញបានយកឯងពីដីមក ដ្បិតឯងជាធូលីដី ក៏ត្រូវត្រឡប់ទៅជាធូលីដីវិញ» (លោកុប្បត្តិ ៣:១៦-១៩)។*

សូមសម្គាល់ពីចរិតលក្ខណៈខុសៗគ្នាជាច្រើនទាក់ទងនឹងការរងទុក្ខ ដែលមានលើកឡើងក្នុងខគម្ពីរទាំងនេះ។ មានភាពឈឺចាប់ខាងឯសាច់ឈាមយ៉ាងខ្លាំង។ ជម្លោះក្នុងទំនាក់ទំនងឈ្លានពានលើភាពជាដៃគូដ៏ធម្មតារវាងមនុស្សប្រុស និងមនុស្សស្រី។ ការងារនៃជីវិតក្លាយជាការងារដ៏លំបាក។ សូម្បីតែដីក៏មានចំណែកជាមួយនឹងភាពពុករលួយរបស់មនុស្ស វាធ្វើបែបនោះដោយតយុទ្ធនឹងភាពខំប្រឹងប្រែងរបស់មនុស្សក្នុងការបង្កើតផល

ផ្លែ។ ហើយអាក្រក់ជាងនោះទៅទៀតគឺ នឹងមានទីបញ្ចប់។ ដោយសារអំពើបាបរបស់មនុស្សបានជាមានសេចក្តីស្លាប់។

តើនឹងមានដំណោះស្រាយបែបណាទៅសម្រាប់បណ្តាសាដ៏ធំធេង និងខ្លាំងក្លាមួយនេះ? បញ្ហាមួយក្នុងចំណោមបញ្ហាជាច្រើននៃដំណោះស្រាយដែលដំណឹងល្អដែលសន្យាភាពចម្រុងចម្រើនគឺ បុព្វហេតុនៃបញ្ហានោះស្រដៀងគ្នាណាស់នឹងដំណោះស្រាយរបស់វា។ លោក អ័ដាម និងនាង អេវ៉ា ខ្វះភាពស្កប់ស្កល់ក្នុងអ្វីដែលពួកគាត់មានក្នុងព្រះជាម្ចាស់ ដូច្នេះហើយបានជាពួកគាត់សង្វាតដេញរកភាពអរសប្បាយក្រៅពីនៅក្នុងទំនាក់ទំនងរបស់ខ្លួនជាមួយនឹងព្រះជាម្ចាស់ និងពីអ្វីៗដែលទ្រង់បានសន្យា។ ដូចគ្នាផងដែរ ដំណឹងល្អដែលសន្យាភាពចម្រុងចម្រើនលើកទឹកចិត្តយើងឲ្យរកព្រះជាម្ចាស់ ដើម្បីឲ្យទទួលបានភាពអរសប្បាយថែមទៀតក្នុងសម្ភារៈនិយម ជាជាងប្រកាសថាការមានព្រះជាម្ចាស់គឺគ្រប់គ្រាន់ហើយ។

ព្រះជាម្ចាស់ផ្ទាល់គឺមិនមែនជាប្រភពនៃភាពអរសប្បាយក្នុងដំណឹងល្អដែលសន្យាភាពចម្រុងចម្រើនទេ តែផ្ទុយពីនោះគឺក្នុងអ្វីៗដែលព្រះជាម្ចាស់អាចប្រទានឲ្យយើង។ ប៉ុន្តែ ដូចដែលលោក អ័ដាម និងនាង អេវ៉ា បានព្យាយាមឈោងចាប់យកភាព

អរសប្បាយ ហើយរកឃើញតែភាពឈឺចាប់ នោះក្តីសន្យាចេញពីដំណឹងល្អដែលសន្យាភាពចម្រុងចម្រើនទាក់ទងនឹងភាពស្កប់ស្កល់គឺមានតែភាពទទេស្អាតវិញទេតើ។ ហេតុអ្វី? ព្រោះវាចង្អុលបង្វែរយើងចេញពីការរកភាពស្កប់ស្កល់ក្នុងព្រះជាម្ចាស់ ដូចដែលអារក្សបានធ្វើទៅកាន់បុរស និងស្រ្តីដំបូងឲ្យចាកចេញពីព្រះជាម្ចាស់។ នៅថ្ងៃនោះ អ្វីដែលពួកគាត់បាត់បង់គឺ ទំនាក់ទំនងជាមួយនឹងព្រះជាម្ចាស់។ ហើយការបែកចេញពីព្រះជាម្ចាស់ គឺជាអត្ថន័យនៃការស្លាប់។ ព្រះយេស៊ូវមានបន្ទូលថា ការផ្សះផ្សាជាមួយនឹងព្រះជាម្ចាស់គឺជាការមានជីវិត (យ៉ូហាន ១៧:៣)។ លោកអ្នកមិនអាចដោះស្រាយបញ្ហានៃការរងទុក្ខតាមរយៈការប្រព្រឹត្តអំពើបាបដែលបង្កឲ្យមានបញ្ហានោះម្តងទៀតឡើយ។

ពេលដែលលោក អ័ដាម និងនាង អេវ៉ា ស្គាល់ភាពឈឺចាប់ពីភាពអាម៉ាស់ ដែលអំពើបាបរបស់ពួកគាត់បាននាំមកចូលផែនដី តើពួកគាត់បានធ្វើអ្វីទាក់ទងនឹងការនោះ? «នោះស្រាប់តែភ្នែករបស់អ្នកទាំង២បានភ្លឺឡើង ហើយគេដឹងថាខ្លួននៅជាអាក្រាត ក៏យកស្លឹកល្វាមកក្លាស់ធ្វើជាប្រដាប់បាំង» (លោកុប្បត្តិ ៣:៧)។ ពួកគាត់បានព្យាយាមបិទបាំងខ្លួនឯងដោយប្រើប្រាស់ដំណោះស្រាយរបស់ខ្លួន។ ហើយនេះឯងគឺជាចំណុចនៃគុណវិបត្តិរបស់

គ្រូៗដែលអធិប្បាយដំណឹងល្អដែលសន្យាភាពចម្រុងចម្រើនៈ ពួកគាត់ផ្តល់ដល់យើងនូវតែដំណោះស្រាយបែបលោកីយ៍។ ពួកគាត់ណែនាំយើងទៅកាន់ក្បាលទឹក និងអាងប្រេះបែកដូចមុនដែលលោកីយ៍នេះកំពុងស្វែងរក៖ ការងារ ផ្ទះសំបែង ទំនាក់ទំនង សុខភាព។ល។ (យេរេមា ២:១៣)។ ពួកគាត់ប្រាប់យើងថា យើងនឹងស្វែងរកក្បាលទឹកដូចគ្នានឹងលោកីយ៍នេះ ប៉ុន្តែយើងនឹងផឹកពីវាតាមរយៈព្រះជាម្ចាស់។

ចូរកុំចាញ់ការបោកបញ្ឆោតឡើយ។ ភាពស្កប់ស្កល់បែបលោកីយ៍ចេញពីដំណឹងល្អដែលសន្យាភាពចម្រុងចម្រើនប្រៀបដូចជាស្លឹកល្វាដែលលោក អ័ដាម និងនាង អេវ៉ា បានយកក្លាស់ធ្វើជាប្រដាប់ប៉ឹងជាបណ្តោះអាសន្ននូវភាពអាម៉ាស់របស់ខ្លួនដែលតាមពិតមិនបានដោះស្រាយឡើយ។ ដំណោះស្រាយរបស់មនុស្សលោកបែបសម្ភារៈនិយមមិនអាចមានលទ្ធភាពក្នុងការដោះស្រាយបញ្ហាដែលការមិនកោតខ្លាចព្រះជាម្ចាស់របស់មនុស្សបានបង្កើតឡើយ។ ដើម្បីឲ្យយើងអាចដោះស្រាយបញ្ហានៃការរងទុក្ខនេះឲ្យបានត្រឹមត្រូវ ដាច់ខាតយើងត្រូវតែដោះស្រាយបញ្ហានៃអំពើបាប និងការបែកបាក់ទំនាក់ទំនងចេញពីព្រះជាម្ចាស់ជាមុនសិន។

សូម្បីតែក្នុងកណ្ឌគម្ពីរលោកុប្បត្តិជំពូក៣ក៏យើងបានឃើញដំណោះស្រាយរបស់ព្រះជាម្ចាស់ចំពោះបញ្ហានៃអំពើបាប និងផលកម្មរបស់វា។ កាលមនុស្សយើងកំពុងតែធ្លាក់ក្នុងអំពើបាបដំណឹងល្អក៏បានផុសចេញឡើងផងដែរ។ ព្រះជាម្ចាស់បានបង្ហាញយើងក្នុងកណ្ឌគម្ពីរលោកុប្បត្តិជំពូក៣ថា មនុស្សយើងត្រូវការយញ្ញបូជាជំនួស និងព្រះសង្គ្រោះម្នាក់ ដើម្បីដោះស្រាយបញ្ហានៃអំពើបាប និងការរងទុក្ខ។ ពេលដែលព្រះជាម្ចាស់ដាក់បណ្ដាសាលើសត្វពស់ ទ្រង់បានមានបន្ទូលថា «អញនឹងធ្វើឲ្យឯង ហើយនិងស្រ្តី គឺទាំងពូជឯង និងពូជនាងមានសេចក្ដីខ្មាំងនឹងគ្នា ពូជនាងនឹងកិនក្បាលឯង ហើយឯងនឹងចឹកកែងជើងគេ» (លោកុប្បត្តិ ៣:១៥)។ តាំងពីជំនាន់ដំបូងៗនៃគ្រីស្ទសាសនា រាស្ត្ររបស់ព្រះជាម្ចាស់បានយល់ពីក្ដីសន្យាទាក់ទងនឹងពូជរបស់នាង អេវ៉ា ដែលនឹងកិនក្បាលសត្វពស់ថា ជាទំនាយដំបូងដែលទាក់ទងនឹងព្រះមេស្ស៊ី។

ប៉ុន្ដែ តើឲ្យមនុស្សយើងទទួលបានសេចក្ដីសង្គ្រោះតាមរយៈព្រះមេស្ស៊ីដោយរបៀបណាទៅណ៎? «នោះព្រះយេហូវ៉ាដ៏ជាព្រះទ្រង់ក៏ធ្វើអាវពីស្បែក ឲ្យអ័ដាម និងប្រពន្ធគាត់ពាក់បិទបាំងកាយ» (លោកុប្បត្តិ ៣:២១)។ មើលទៅហាក់បីដូចជាព្រះ

ជាម្ចាស់បានសម្លាប់សត្វមួយ ដើម្បីយកសត្វនោះធ្វើជាយញ្ញបូជាទុកជាការបិទបាំងភាពខ្មាសរបស់មនុស្សប្រុស និងមនុស្សស្រី ដែលនោះជាលទ្ធផលនៃអំពើបាបរបស់ពួកគាត់។ នៅត្រង់នេះ យើងឃើញជាលើដំបូងអំពីសញ្ញាសម្គាល់នៃគោលការណ៍ចេញពីព្រះគម្ពីរទាក់ទងនឹងបញ្ហានៃអំពើបាបថា វាធំដល់ថ្នាក់វាត្រូវការយញ្ញបូជាធួននឹងបាប (ហេព្រើរ ៩:២២)។ ព្រះជាម្ចាស់នឹងចាត់ព្រះរាជបុត្រារបស់ទ្រង់ឲ្យមកយកកំណើត ហើយរស់នៅក្នុងលក្ខណៈជាមនុស្ស និងសុគតដើម្បីធ្វើជាយញ្ញបូជាជំនួសដោយប្រឈមមុខនឹងសេចក្តីក្រោធរបស់ព្រះជាម្ចាស់ដោយសារអំពើបាបរបស់យើងនៅលើឈើឆ្កាងជំនួសយើង។ នេះឯងជាដំណោះស្រាយរបស់ព្រះជាម្ចាស់ចំពោះបញ្ហានៃអំពើបាប និងរបៀបនេះគឺល្អឥតខ្ចោះ។ នេះគឺជាដំណោះស្រាយតែមួយគត់ដែលអាចនឹងដំណើរការបាន។

ដំណោះស្រាយរបស់ព្រះជាម្ចាស់ពិតជាដោះស្រាយបញ្ហានៃការរងទុក្ខរបស់យើងមែន ពីព្រោះវាចាប់ផ្តើមជាមួយនឹងបុព្វហេតុរបស់វា—អំពើបាប។ ដំណោះស្រាយរបស់យើងជាមួយនឹងការរងទុក្ខគឺមិនមែនអាស្រ័យទៅលើអ្វីៗដែលយើងអាចយកបានពីព្រះជាម្ចាស់នោះទេ ប៉ុន្តែលើភាពផ្សះផ្សាជាមួយនឹងព្រះ

ជាម្ចាស់។ អំណរដ៏ពេញទីគឺកើតចេញពីការប្រកបគ្នាជាមួយនឹង ព្រះជាម្ចាស់ (ទំនុកតម្កើង ១៦:១១)។ នោះឯងជាអ្វីដែលអំពើបាបបានបង្ខូច ហើយក៏ជាអ្វីដែលព្រះគ្រីស្ទបានស្ដារឡើងវិញ។ ប៉ុន្តែ ខណៈពេលដែលយើងរង់ចាំឲ្យការស្ដារឡើងវិញរបស់យើងកើតឡើងចេញយ៉ាងពេញទី ពេលរូបរាងកាយរបស់យើងរស់ពីស្លាប់ឡើងវិញ នៅជំនាន់ដែលនឹងកើតមានឡើង តើឲ្យយើងអាចយល់អំពីផលកម្មនៃអំពើបាបដែលនៅមានជុំវិញយើងលើផែនដីដែលបាក់បែកនេះបានដោយរបៀបណាទៅ?

## ក្ដីសន្យារបស់ព្រះជាម្ចាស់ទាក់ទង នឹងការស្ដារឡើងវិញ

ព្រះជាម្ចាស់បានបង្វែរបណ្ដាសាចេញហើយ។ ព្រះអង្គបានដាក់បណ្ដាសាមនុស្សលោក ព្រោះពួកគេបានបះបោរនឹងទ្រង់ (លោកុប្បត្តិ ៣:១៦-១៩) ហើយបណ្ដាសានោះបានជះឥទ្ធិពលលើរូបរាងកាយយើង ទំនាក់ទំនងយើង ការងាររបស់យើង និងបរិស្ថានរបស់យើង។ ប៉ុន្តែ ផែនការរបស់ព្រះជាម្ចាស់ក្នុងការស្ដារឡើងវិញគឺបានសម្រេចឡើងក្នុងព្រះគ្រីស្ទយ៉ាងពេញទីដូចនឹងបណ្ដាសាអញ្ចឹង។ ផែនការដ៏ល្អឥតខ្ចោះនៃការសង្គ្រោះ និង

ការស្តារឡើងវិញជិតឈានដល់ទីបញ្ចប់ហើយ ហើយជំនឿរបស់យើងក្នុងព្រះជាម្ចាស់ក្នុងការបំពេញវានឹងទ្រទ្រង់យើង សូម្បីតែពេលដែលយើងរងទុក្ខក្នុងជំនាន់ដែលមិនទាន់បានទទួលការសង្គ្រោះ និងពេញដោយការបះបោរក៏ដោយ។

ទីមួយ គ្រីស្ទបរិស័ទដែលកំពុងស្លាប់មានអំណរដោយសាររូបរាងកាយរបស់យើងនឹងទទួលបានការស្តារឡើងវិញនៅអនាគត៖ «ព្រោះ ដូចជាគ្រប់មនុស្សទាំងអស់បានត្រូវស្លាប់ ក្នុងលោកអ័ដាមជាយ៉ាងណា នោះគ្រប់គ្នាក៏នឹងបានប្រោសឲ្យរស់ក្នុងព្រះគ្រីស្ទយ៉ាងនោះដែរ» (១កូរិនថូស ១៥:២២)។ សាវ័កប៉ុល បានសរសេរថែមទៀតអំពីលក្ខណៈនៃរាងកាយដែលនឹងទទួលបានការស្តារឡើងវិញនេះ៖ «សេចក្តីដែលមនុស្សស្លាប់បានរស់ឡើងវិញ នោះក៏បែបដូច្នោះដែរ គេបានកប់ទៅ ជារូបកាយ ដែលពុករលួយ តែរស់ឡើងវិញ ជារូបកាយមិនចេះពុករលួយឡើយ បានកប់ទៅ ទាំងមានសេចក្តីអាប់ឱន តែរស់ឡើងវិញ ទាំងមានសិរីល្អ បានកប់ទៅ ទាំងមានសេចក្តីកម្សោយ តែរស់ឡើងវិញ ទាំងមានព្រះចេស្តា បានកប់ទៅ ជារូបកាយ ខាងសាច់ឈាម តែរស់ឡើង ជារូបកាយខាងវិញ្ញាណវិញ បើមានរូបកាយខាងសាច់ឈាម នោះក៏មានរូបកាយ ខាងវិញ្ញាណដែរ»

(១កូរិនថូស ១៥:៤២-៤៤)។ មុនរូបកាយរបស់យើងទទួលការស្តារឡើងវិញ ព្រះគ្រីស្ទបានធ្វើជាគំរូដំបូងរួចហើយ ហើយក៏បានធានាថាយើងក៏នឹងទទួលបានការរស់ឡើងវិញផងដែរ។ ដូចនឹងព្រះអង្គ ក្នុងការស្លាប់ យើងបោះបង់ភាពបណ្តោះអាសន្នចោល ដើម្បីយកភាពអស់កល្បជានិច្ច។

ទីពីរ ក្នុងព្រះគ្រីស្ទ យើងអាចចាប់ផ្តើមឃើញសញ្ញាសម្គាល់នៃការស្តារឡើងវិញរវាងទំនាក់ទំនងរបស់យើងជាមួយគ្នានឹងគ្នាបាន។ អំពើបាបបានបង្កឲ្យចំណងអាពាហ៍ពិពាហ៍មានភាពអាត្មានិយម និងការច្រណែនគ្នា។ នៅក្នុងគ្រួសារដំបូង សូម្បីតែបងប្រុសក៏បានសម្លាប់ប្អូនប្រុសខ្លួនដោយសារកំហឹងនៃភាពច្រណែនគ្នាទៀតផង។ អំពើបែបៗដូច្នោះបានកើតឡើងតាំងពីពេលនោះរហូតមកដល់ឥឡូវនេះ។ ប៉ុន្តែ ក្នុងព្រះគ្រីស្ទ យើងមានសមត្ថភាព ហើយយើងក៏គួរចាប់ផ្តើមមានការបន្ទាបខ្លួនជាងមានអំនួត ហើយនិងបម្រើគ្នាទៅវិញទៅមក (ភីលីព ២:១-៤)។ ពេលការនេះកើតឡើង វាគឺជាការសម្គាល់អំពីអ្វីៗដែលនឹងមាននៅខាងមុខ។ ព្រះមេស្ស៊ីរបស់យើងគឺជាម្ចាស់នៃ*មេត្រីភាព* ហើយការសោយរាជ្យរបស់ទ្រង់នៅពេលអនាគតនឹងមានលក្ខណៈបែបនោះ (អេសាយ ៩:៦-៧)។ ដូច្នេះ ខណៈពេលដែល

យើងព្យាយាមរស់នៅឥឡូវនេះក្នុងមេត្រីភាព (សន្តិភាព) នៃព្រះសង្គ្រោះរបស់យើង ជាជាងធ្វើតាមចិត្តដែលតែងតែចូលចិត្តឈ្លោះប្រកែកគ្នា ចូរឲ្យយើងកាន់ជាប់នូវសេចក្តីសន្យារបស់ព្រះជាម្ចាស់ដែលរាជ្យនៃមេត្រីភាពរបស់ទ្រង់នឹងមិនមានទីបញ្ចប់ឡើយ។

ក្នុងព្រះគម្ពីរសញ្ញាចាស់ ព្រះជាម្ចាស់បានសន្យាថានឹងមានសន្តិភាពម្តងហើយម្តងទៀត ពេលដែលព្រះអង្គស្តារសម្បត្តិរបស់សាសន៍អ៊ីស្រាអែល។ ឧទាហរណ៍ ខាងក្រោមនេះជាក្តីសន្យារបស់ទ្រង់តាមរយៈហោរា អេម៉ុស៖[៤]

> *«ព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលថា មើល មានថ្ងៃមក ដែលអ្នកភ្ជួររាស់នឹងធ្វើការ ដរាបដល់ជួបនឹងអ្នកច្រូតកាត់ ហើយអ្នកដែលជាន់ផ្លែទំពាំងបាយជូរ នឹងធ្វើការដរាបដល់ជួបនឹងអ្នកដែលសាបព្រោះ នោះភ្នំធំទាំងប៉ុន្មាន នឹងស្រក់ជាទឹកទំពាំងបាយជូរ ហើយអស់ទាំងភ្នំតូចនឹងហូរដែរ អញនឹងនាំពួកអ៊ីស្រាអែល ជារាស្ត្រអញ ដែលជាប់ជាឈ្លើយឲ្យមកវិញ គេនឹងសង់អស់ទាំងទីក្រុងខូចបង់ឡើង ព្រមទាំងអាស្រ័យនៅផង គេ*

៤ ឧទាហរណ៍ផ្សេងៗទៀត៖ ទំនុកតម្កើង ១៤:៧; ៥៣:៦; យេរេមា ៣០:៣; ៣៣:៧; អេសេគាល ៣៩:៣៥; អេម៉ុស ១៩:១៤។

*នឹងដាំចំការទំពាំងបាយជូរ ក៏នឹងផឹកស្រាទំពាំងបាយជូរជាផលពីចំការនោះ គេនឹងដាំច្បារ ហើយស៊ីផលនោះដែរ» (អេម៉ុស ៩:១៣-១៤)។*

មុនការថ្លែងទំនាយនេះ មានសារដែលគួរឲ្យញាក់សាច់ទាក់ទងនឹងការថ្កោលទោស ដូច្នេះសារនេះបានធ្វើឲ្យអ្នកស្តាប់ដំបូងៗមានគំនិតយ៉ាងច្បាស់លាស់ទាក់ទងនឹងរបៀបដែលព្រះជាម្ចាស់នឹងស្តាររាស្ត្ររបស់ទ្រង់ឡើងវិញ។ ប៉ុន្តែ សារនេះក៏សម្រាប់គ្រប់រាស្ត្ររបស់ព្រះជាម្ចាស់នៅក្នុងគ្រប់ពេលវេលាផងដែរ។ ថ្ងៃនៃការស្តារឡើងវិញដ៏ពេញទីមិនទាន់កើតឡើងនៅឡើយទេ។ នៅថ្ងៃណាមួយ ការតយុទ្ធដែលមនុស្សយើងធ្លាប់មាន និងកំពុងតែឆ្លងកាត់ទាក់ទងនឹងការងារនឹងលែងមានទៀតហើយ។ ក្នុងចំណុចដែលមនុស្សយើងធ្លាប់ស្គាល់ទាក់ទងនឹងបរាជ័យ និងការងារមនុស្សយើងនឹងស្គាល់ជោគជ័យ និងអំណរអរសប្បាយវិញ។ នេះគឺជាក្តីសន្យាមួយក្នុងចំណោមក្តីសន្យាជាច្រើនទៀតទាក់ទងនឹងនគរដែលនឹងត្រូវមកដល់។ នៅពេលដែលអ្វីមួយដែលយើងព្យាយាមធ្វើនៅលើផែនដីនេះបរាជ័យ នោះចូរឲ្យយើងចងចាំថា ការព្យាយាមរបស់យើងគឺជាការបណ្តោះអាសន្នទេ ប៉ុន្តែ

នៅពេលអនាគតការបំពេញអំណរដែលនឹងកើតមានឡើងនឹងមិនចេះមានទីបញ្ចប់ឡើយ។

ជាចំណែកមួយនៃផែនការរបស់ព្រះជាម្ចាស់សម្រាប់ការសង្គ្រោះ៖ អ្វីៗទាំងអស់ដែលព្រះអង្គបានបង្កើតមកនឹងទទួលបានការស្តារឡើងវិញចេញពីភាពដ៏ពុករលួយដែលវាកំពុងមាន។ ផែនដីនេះនឹងទទួលបានការស្តារឡើងវិញដល់កម្រិតថាភាពស្រស់ស្អាតរបស់វានឹងស្អាតលើសភាពបរិសុទ្ធដំបូងរបស់វាទៅទៀត។ ហើយនេះជារបៀបរបស់ព្រះជាម្ចាស់ត្រង់ថា ការស្តារនូវអ្វីៗដែលព្រះអង្គបានបង្កើតឡើងវិញនឹងកើតឡើងចេញពីសេចក្តីសង្គ្រោះ និងសេរីភាពរបស់រាស្ត្រព្រះជាម្ចាស់ក្នុងព្រះគ្រីស្ទ។

*«ខ្ញុំរាប់អស់ទាំងសេចក្តីទុក្ខលំបាកនៅជាន់នេះ ថាជាសេចក្តីមិនគួរប្រៀបផ្ទឹមនឹងសិរីល្អ ដែលនឹងបើកសម្តែងមកឲ្យយើងរាល់គ្នាឃើញនោះទេ ដ្បិតសេចក្តីទន្ទឹងរបស់ជីវិតទាំងឡាយ នោះរង់ចាំតែពួកកូនរបស់ព្រះលេចមកឲ្យឃើញប៉ុណ្ណោះទេ ពីព្រោះជីវិតទាំងឡាយបានត្រូវចុះចូលនឹងសេចក្តីឥតប្រយោជន៍ តែមិនមែនដោយស្ម័គ្រពីចិត្ត គឺដោយព្រោះព្រះអង្គ ដែលទ្រង់បញ្ចុះ*

*បញ្ចូលវិញ ដោយសង្ឃឹមថា ជីវិតទាំងនោះឯង នឹងបាន រួចពីចំណងនៃសេចក្ដីពុករលួយ ឲ្យបានសេរីភាពនៃសិរី ល្អរបស់ពួកកូនព្រះវិញ» (រ៉ូម ៨:១៩-២១)។*

តើហេតុអ្វីបានជាព្រះគម្ពីរមានខជាច្រើនម្ល៉េះស្ដីពីសេចក្ដីសន្យារបស់ព្រះជាម្ចាស់ទាក់ទងនឹងការស្ដារឡើងវិញ និងការធ្វើឲ្យមានភាពល្អឥតខ្ចោះចំពោះរូបរាងកាយ ទំនាក់ទំនង ការងារ និងបរិស្ថានរបស់យើង? ព្រោះព្រះអង្គជ្រាបថាយើងត្រូវការក្ដីសង្ឃឹមដ៏ឥតរង្គើនេះ ហើយសញ្ញាសម្គាល់ដែលយើងឃើញឥឡូវៗនេះ ដើម្បីទ្រទ្រង់យើងក្នុងភាពពុករលួយ និងអំពើបាបដែលនៅមានជុំវិញយើង។ ដំណោះស្រាយរបស់ព្រះជាម្ចាស់ចំពោះការតយុទ្ធរបស់យើងជាមួយការរងទុក្ខគឺជាដំណោះស្រាយដ៏ពិតតែមួយគត់ ហើយក៏នឹងនៅអស់កល្បជានិច្ច។ ខណៈពេលដែលយើងបន្តទ្រាំទ្រការរងទុក្ខម្ដងហើយម្ដងទៀតដោយមានភាពស្មោះត្រង់ នោះយើងនឹងចាប់ផ្ដើមដកពិសោធន៍នឹងព្រះពរដែលជារបស់យើងដែលយើងនឹងទទួលបាននៅជំនាន់ដែលនឹងកើតឡើង។ ក្នុងនគររបស់ព្រះគ្រីស្ទដែលនឹងកើតមានឡើង យើងនឹងរស់នៅយ៉ាងអស់កល្បជានិច្ចក្នុងព្រះពរ និងសិរីល្អរបស់

ទ្រង់។ ដំណោះស្រាយរបស់ព្រះជាម្ចាស់គឺមិនមែនជាដំណោះស្រាយសុខស្រួលតែបណ្ដោះអាសន្ននោះទេ ប៉ុន្តែជាផែនការដ៏អស់កល្បជានិច្ចដែលទ្រង់បានរៀបចំចាប់តាំងពីពេលមុនមានពេលវេលាមកម៉្លេះ។ រាស្ត្ររបស់ព្រះជាម្ចាស់អាចឃើញទ្រង់បន្តធ្វើតាមផែនការរបស់ទ្រង់ ហើយដឹងថាទ្រង់នឹងបំពេញការនោះ។ នៅពេលអនាគត រាស្ត្ររបស់ព្រះអង្គ និងលោកីយ៍ទាំងមូលនឹងទទួលបានការស្ដារឡើងវិញយ៉ាងពេញទី។

## ព្រឹត្តិការណ៍ដែលបានកើតឡើងហើយ តែមិនទាន់មកដល់

ដូចដែលលោកអ្នកអាចមើលឃើញ សេចក្ដីសន្យារបស់ព្រះជាម្ចាស់ចំពោះរាស្ត្ររបស់ទ្រង់គឺជាព្រឹត្តិការណ៍ដែលកើតឡើងក្នុងបច្ចុប្បន្នកាល និងអនាគតកាលក្នុងពេលតែមួយ។ គ្រូៗដែលអធិប្បាយដំណឹងល្អដែលសន្យាភាពចម្រុងចម្រើនប្រើប្រាស់ខគម្ពីរមួយចំនួនខាងលើនេះជា «ភស្តុតាង» ថាគ្រីស្ទបរិស័ទអាចទទួលបានរបស់របរទាំងនោះឥឡូវនេះបាន។ ចំណុចខុសឆ្គងនៃការអធិប្បាយរបស់ពួកគាត់គឺមិនមែនលើអ្វីដែលគ្រីស្ទបរិស័ទនឹងទទួលបាននោះទេ ប៉ុន្តែគឺលើពេលវេលាដែលគ្រីស្ទបរិស័ទ

នឹងទទួលវា។ ពួកគាត់បានផ្លាស់ប្ដូរការកំណត់ពេលវេលារបស់ព្រះជាម្ចាស់ ហើយការធ្វើបែបនោះបានបង្ខូចផែនការនៃការស្ដារឡើងវិញរបស់ទ្រង់។

ពេលដែលសាវ័ក ប៉ុល សរសេរទៅកាន់ក្រុមជំនុំកូរិនថូស គាត់បានស្ដីបន្ទោសពួកគេ ព្រោះពួកគេមានការយល់ដឹងមិនត្រឹមត្រូវទាក់ទងនឹងព្រះពរនានាក្នុងព្រះគ្រីស្ទ។ «អ្នករាល់គ្នាឆ្អែតហើយ ក៏ជាអ្នកមានផង កាលឥតពីយើងខ្ញុំ នោះអ្នករាល់គ្នាបានសោយរាជ្យឡើង ហើយខ្ញុំក៏សុខចិត្តឲ្យអ្នករាល់គ្នាបានសោយរាជ្យដែរ ដើម្បីឲ្យយើងខ្ញុំបានសោយរាជ្យជាមួយគ្នា» (១កូរិន-ថូស ៤:៨)។ សាវ័ក ប៉ុល បានលើកឡើងពីចំណុចខុសគ្នារវាងពួកគាត់ដោយលើកឡើងពីឥរិយាបថដែលពេញដោយអំនួតរបស់ពួកគាត់មកប្រៀបធៀបនឹងការបន្ទាបខ្លួន និងភាពក្រីក្ររបស់ពួកសាវ័ក។ គ្រីស្ទបរិស័ទនៅឯក្រុមជំនុំកូរិនថូសបង្ហាញពីឥរិយាបថដោយថា ព្រះពរទាំងនោះដែលព្រះជាម្ចាស់បានសន្យាសម្រាប់អនាគតនៅគ្រានៃថ្ងៃមេឃ នឹងផែនដីថ្មីហាក់បីដូចជាបានក្លាយជាព្រះពររបស់ពួកគាត់រួចអស់បាត់ទៅហើយ។

ប្រសិនបើលោកអ្នកនៅក្នុងព្រះគ្រីស្ទ  នោះមានន័យថារាល់ក្ដីសន្យារបស់ព្រះជាម្ចាស់គឺជារបស់លោកអ្នកក្នុងព្រះអង្គ

(២កូរិនថូស ១:២០)។ ប៉ុន្តែ ខណៈពេលដែលយើងរស់នៅក្នុងចន្លោះរវាងការយាងមកលើកទី១ និងលើកទី២របស់ព្រះយេស៊ូវគ្រីស្ទ យើងនៅបន្តរង់ចាំឲ្យផែនការរបស់ព្រះជាម្ចាស់កើតឡើងយ៉ាងពេញលេញ ព្រមទាំងព្រះពរដ៏ពេញទីនៃការនៅក្នុងព្រះគ្រីស្ទ។ ពេលដែលសាវ័ក ប៉ុល សរសេរអំពីសិរីល្អដែលជារបស់យើងនៅក្នុងព្រះគ្រីស្ទ គាត់កំពុងសម្លឹងមើលទៅឯអនាគត។ គាត់បានបង្រៀនក្រុមជំនុំរ៉ូមថា «ទុក្ខលំបាកពេលបច្ចុប្បន្ននេះជាសេចក្ដីដែលមិនស័ក្ដិសមយកទៅប្រៀបផ្ទឹមជាមួយសិរីរុងរឿងនៅពេលខាងមុខ ដែលព្រះជាម្ចាស់នឹងបើកសម្ដែងឲ្យយើងឃើញនោះទេ» (រ៉ូម ៨:១៨ គគខ)។ ក្រែងលោយើងអានរំលងពីពេលវេលានៃអនាគត ដែលសាវ័ក ប៉ុល បានលើកឡើង គាត់បានសរសេរបញ្ជាក់បន្ថែមទៀតថា «ដ្បិតយើងបានសង្គ្រោះរួច ដោយសេចក្ដីសង្ឃឹម តែសេចក្ដីសង្ឃឹមដែលមើលឃើញ នោះមិនឈ្មោះថាជាសេចក្ដីសង្ឃឹមទេ ដ្បិតរបស់អ្វីដែលអ្នកណាមើលឃើញហើយ នោះនឹងសង្ឃឹមចង់បានធ្វើអ្វីទៀត តែបើយើងសង្ឃឹមនឹងបានអ្វី ដែលមើលមិនឃើញវិញ នោះយើងនឹងរង់ចាំនៅដោយអំណត់» (រ៉ូម ៨:២៤-២៥)។ ជាការពិតណាស់ ក្នុងព្រះគ្រីស្ទយើងនឹងលែងរងទុក្ខទៀតហើយ។ ប៉ុន្តែ យើងនឹងទទួលបាន

ព្រះពរនោះនាគ្រាចុងក្រោយនៃជំនាន់នេះ និងពេលដែលព្រះជាម្ចាស់បំពេញសម្រេចផែនការរបស់ទ្រង់។

ក្នុងលោកីយ៍នេះគ្មានដំណោះស្រាយដ៏ធំឯណាទៀតទេ សម្រាប់ការរងទុក្ខរបស់យើង។ ប៉ុន្តែ ក៏គ្មានចំណុចជំទាស់គ្នារវាងការរងទុក្ខរបស់យើងឥឡូវនេះ នឹងការដែលព្រះជាម្ចាស់ធានាថាទ្រង់នឹងលែងឲ្យយើងមានការរងទុក្ខផងដែរនៅពេលអនាគត។

> *«ហេតុនោះយើងខ្ញុំមិនណាយចិត្តឡើយ ប៉ុន្តែ ទោះបើមនុស្សខាងក្រៅរបស់យើងខ្ញុំ កំពុងតែពុករលួយទៅក៏ពិតមែន តែនៅខាងក្នុងកំពុងតែកែប្រែជាថ្មីឡើងរាល់ថ្ងៃជានិច្ចវិញ ដ្បិតសេចក្ដីទុក្ខលំបាកយ៉ាងស្រាលរបស់យើងខ្ញុំ ដែលនៅតែមួយភ្លែតនេះ នោះបង្កើតឲ្យយើងខ្ញុំមានសិរីល្អយ៉ាងធ្ងន់លើសលប់ ដ៏នៅអស់កល្បជានិច្ចវិញ ដោយយើងខ្ញុំមិនរាប់អានរបស់ដែលមើលឃើញឡើយ គឺរាប់អានតែរបស់ដែលមើលមិនឃើញវិញ ដ្បិតរបស់ដែលមើលឃើញ នោះស្ថិតស្ថេរមិនយូរប៉ុន្មានទេ តែឯរបស់ដែលមើលមិនឃើញ នោះនៅស្ថិតស្ថេរអស់កល្បជានិច្ចវិញ» (២កូរិនថូស ៤:១៦-១៨)។*

មូលហេតុដែលរាស្ត្ររបស់ព្រះជាម្ចាស់ទ្រាំទ្រការរងទុក្ខលើផែនដីនេះគឺព្រោះពួកគាត់កាន់ក្តីសង្ឃឹមយ៉ាងជាប់ដែលព្រះជាម្ចាស់បានដាក់ក្នុងពួកគាត់។ ឥឡូវនេះ ព្រះជាម្ចាស់បានរាប់ពួកគាត់ជាសុចរិត បានទទួលសេចក្តីសង្គ្រោះ ហើយថែមទាំងប្រទានពរដល់ពួកគាត់ទៀតផង។ ហើយទំនុកចិត្តបែបហ្នឹងធ្វើឲ្យពួកគាត់អាចមានអំណរក្នុងការរងទុក្ខ ព្រោះពួកគាត់ដឹងថាព្រះជាម្ចាស់នឹងបំបាត់ការរងទុក្ខរបស់ពួកគាត់ឆាប់ៗនេះ។ ព្រះពរនានារបស់ព្រះជាម្ចាស់ដែលមានឥឡូវនេះផ្តល់ជាទំនុកចិត្តធានាដល់យើងថា យើងនឹងទទួលបាននូវព្រះពរដ៏ល្អៗជាងហ្នឹងទៅទៀតដែលយើងមិនទាន់ទទួលបាននៅឡើយ។

## ផែនការរបស់ព្រះជាម្ចាស់សម្រាប់ការរងទុក្ខ

ដូច្នេះ យើងឃើញហើយថា ព្រះគម្ពីរនិយាយទាស់ប្រឆាំងម្តងហើយម្តងទៀតនឹងអំណះអំណាងរបស់គ្រូៗដែលអធិប្បាយដំណឹងល្អដែលសន្យាភាពចម្រុងចម្រើនថា ព្រះជាម្ចាស់មិនដែលមានព្រះហឫទ័យចង់ឲ្យយើងរងទុក្ខឡើយ។ ដាច់ខាត! យើងមិនគួរឲ្យមនុស្សយើងមានការភ័យខ្លាច និងមន្ទិលសង្ស័យដោយសារការរងទុក្ខ ព្រោះគ្រូគង្វាលរបស់ពួកគាត់មិនបានជួយពួកគាត់ក្នុង

ការយល់អំពីការរងទុក្ខ។ គ្រីស្ទបរិស័ទមិនចាំបាច់ខ្លាចការរងទុក្ខទេ មិនមែនគ្រាន់តែដោយសារវាមានទីបញ្ចប់ប៉ុណ្ណោះនោះទេ ប៉ុន្តែដោយសារព្រះជាម្ចាស់មានអធិបតេយ្យភាពលើវា ហើយក៏ប្រើប្រាស់វា ដើម្បីប្រទានពរដល់បុត្រាបុត្រីរបស់ទ្រង់ផងដែរ។

យើងនឹងចំណាយពេលមើលពីចំណុចនេះថែមទៀតក្នុងជំពូកក្រោយៗ។ ប៉ុន្តែសម្រាប់ឥឡូវនេះ ចូរយើងចំណាយពេលខ្លះៗមើលពីមូលហេតុមួយចំនួនសិនថា ហេតុអ្វីបានជាការរងទុក្ខមិនគ្រាន់តែជាការបណ្ដោះអាសន្ន ប៉ុន្តែជាព្រះពរផងដែរ។ ទី១ ព្រះជាម្ចាស់ចម្រើនជំនឿរបស់យើងក្នុងការរងទុក្ខ។ សាវ័កពេត្រុស បានផ្ដោតលើការនេះពេលដែលគាត់ពន្យល់ពីអនាគតទាក់ទងនឹងរាស្ត្ររបស់ព្រះជាម្ចាស់៖

*«សូមសរសើរដល់ព្រះដ៏ជាព្រះវរបិតានៃព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នា ដែលទ្រង់បានបង្កើតយើងឡើងជាថ្មី តាមសេចក្តីមេត្តាករុណាដ៏ធំរបស់ទ្រង់ ដើម្បីឲ្យយើងរាល់គ្នាបានសេចក្តីសង្ឃឹមដ៏រស់ ដោយសារព្រះយេស៊ូវគ្រីស្ទ ទ្រង់រស់ពីស្លាប់ឡើងវិញ ហើយឲ្យយើងបានមរតក ដែលមិនចេះពុករលួយក៏ឥតសៅហ្មង ហើយមិនដែលស្រពោនឡើយ ជាមរតក*

*ដែលបម្រុងទុកឲ្យយើងរាល់គ្នានៅស្ថានសួគ៌ គឺឲ្យយើងរាល់គ្នា ដែលព្រះចេស្ដានៃព្រះកំពុងតែថែរក្សា ដោយសារជំនឿ សម្រាប់ឲ្យបានសេចក្ដីសង្គ្រោះ ដែលប្រុងប្រៀបនឹងសម្ដែងមកនៅជាន់ក្រោយបង្អស់នោះ អ្នករាល់គ្នាក៏មានសេចក្ដីអំណរជាខ្លាំង ក្នុងសេចក្ដីសង្គ្រោះនោះ ទោះបើសព្វថ្ងៃនេះត្រូវរងទុក្ខព្រួយជាយូរបន្តិច ដោយកើតមានសេចក្ដីល្បួងផ្សេងៗក៏ដោយ ដើម្បីឲ្យការសាកលជំនឿនៃអ្នករាល់គ្នា ដ៏វិសេសជាងមាសដែលតែងតែខូច ទោះបើបានសាកនឹងភ្លើងក៏ដោយ នោះបានឃើញសម្រាប់ជាសេចក្ដីសរសើរ កេរ្តិ៍ឈ្មោះ និងសិរីល្អ ក្នុងកាលដែលព្រះយេស៊ូវគ្រីស្ទទ្រង់លេចមក» (១ពេត្រុស ១:៣-៧)។*

តើលោកអ្នកបានឃើញហើយឬនៅថាឥរិយាបថដែលចេះតែចង់បានអ្វីៗឥឡូវនេះនៃដំណឹងល្អដែលសន្យាភាពចម្រុងចម្រើនតាមពិតទៅជាការបដិសេធប្រាជ្ញានៃផែនការដ៏ល្អលើសការនោះទៅទៀតរបស់ព្រះជាម្ចាស់? ខណៈពេលដែលយើងស៊ូទ្រាំក្នុងការរងទុក្ខ ដោយសម្លឹងមើលទៅឯអនាគត តាមពិតទៅវាជួយ

ចម្រើនជំនឿរបស់យើងក្នុងរបៀបមួយដែលនឹងថ្វាយសិរីល្អដល់ព្រះជាម្ចាស់យ៉ាងជាប់លាប់។

គ្រីស្ទបរិស័ទក៏មិនអាចរួចចេញពីការរងទុក្ខដែរ។ ពួកគាត់នឹងប្រាកដជាជួបប្រទះ ហើយក៏គួរមាន*អំណរ*ក្នុងវាដែរ។ ចូរកត់សម្គាល់ពីអ្វីដែលសាវ័ក ពេត្រុស បន្តសរសេរៈ

> *«ពួកស្ងួនភ្ងាអើយ កុំឲ្យមានប្លែកក្នុងចិត្ត ដោយភ្លើងដ៏ក្តៅក្រហាយ ដែលកំពុងតែល្បងអ្នករាល់គ្នា ទុកដូចជាកើតមានសេចក្តីចំឡែកនោះឡើយ ត្រូវអរសប្បាយវិញ ដោយព្រោះមានចំណែកក្នុងការរងទុក្ខរបស់ព្រះគ្រីស្ទ ដើម្បីឲ្យអ្នករាល់គ្នាបានត្រេកអររីករាយជាខ្លាំង ក្នុងកាលដែលសិរីល្អទ្រង់លេចមក បើសិនជាគេតិះដៀលអ្នករាល់គ្នា ដោយព្រោះព្រះគ្រីស្ទ នោះមានពរហើយ ពីព្រោះព្រះវិញ្ញាណដ៏មានសិរីល្អ គឺជាព្រះវិញ្ញាណនៃព្រះ ទ្រង់សណ្ឋិតលើអ្នករាល់គ្នាហើយ» (១ពេត្រុស ៤:១២-១៤)។*

ដូចដែលសាវ័ក ប៉ុល បានយល់ថា ការរួមចំណែកក្នុងការរងទុក្ខរបស់ព្រះយេស៊ូវគ្រីស្ទគឺជាការរួមចំណែកជាមួយនឹងការ

មានព្រះជន្មរស់ឡើងវិញ និងសិរីល្អរបស់ទ្រង់ផងដែរ (ភីលីព ៣:១០)។ នេះឯងជាអ្វីដែលព្រះយេស៊ូវបានបង្រៀននៅឯសេចក្ដីអធិប្បាយលើភ្នំ (ម៉ាថាយ ៥:១០-១២) ហើយពេលក្រោយពួកសិស្សរបស់ទ្រង់បានយកសេចក្ដីអធិប្បាយនោះទៅអនុវត្ត។ បន្ទាប់ពីពេលមានគេវាយពួកគាត់នឹងរំពាត់ ដោយសារពួកគាត់អធិប្បាយដំណឹងល្អ ពួកគាត់បានចាកចេញ «ដោយអរសប្បាយ ពីព្រោះព្រះបានរាប់ជាអ្នកគួរនឹងទ្រាំសេចក្ដីដំនៀលដោយព្រោះព្រះនាមទ្រង់» (កិច្ចការ ៥:៤១)។ ការរួចផុតចេញពីការរងទុក្ខនាពេលបច្ចុប្បន្ននេះ គឺជាសារដ៏ក្លែងក្លាយដែលបង្វែរគ្រីស្ទបរិស័ទចេញពីផែនការ និងព្រះពររបស់ព្រះជាម្ចាស់។ ជាជាងដើរតាមដំណឹងល្អដែលសន្យាភាពចម្រុងចម្រើន យើងគួរតែគ្រាប់តាមព្រះបន្ទូលព្រះជាម្ចាស់ដែលលើកទឹកចិត្តថា «បងប្អូនអើយ កាលណាអ្នករាល់គ្នាមានសេចក្ដីល្បួងផ្សេងៗ នោះត្រូវរាប់ជាសេចក្ដីអំណរសព្វគ្រប់វិញ ដោយដឹងថា ការល្បងលមើលជំនឿនៃអ្នករាល់គ្នា នោះនាំបង្កើតឲ្យមានសេចក្ដីខ្ជាប់ខ្ជួន ចូរទុកឲ្យសេចក្ដីខ្ជាប់ខ្ជួននោះ បានធ្វើការឲ្យសម្រេចពេញលេញចុះ ដើម្បីឲ្យអ្នករាល់គ្នាបានគ្រប់លក្ខណ៍ ហើយពេញខ្នាតឥតខ្វះអ្វីឡើយ» (យ៉ាកុប ១:២-៤)។

ពេលដែលគ្រូអធិប្បាយបានបង្រៀនពីភាពចម្រុងចម្រើនប្រ-កាសថា ព្រះជាម្ចាស់មិនដែលមានព្រះហឫទ័យចង់ឲ្យលោកអ្នករងទុក្ខទេ នោះមានន័យថា ពួកគាត់បានបន្ទាបបន្ថោកនូវរាល់គ្រប់អ្វីៗដែលព្រះជាម្ចាស់អាចធ្វើក្នុងជីវិតរបស់លោកអ្នកតាមរយៈការឈឺចាប់ហើយ។ ព្រះអង្គគ្រប់គ្រងលើការរងទុក្ខដ៏បណ្ដោះអាសន្នរបស់យើងលើផែនដីនេះ ហើយព្រះអង្គក៏ប្រើប្រាស់វាសម្រាប់ចម្រើនជំនឿរបស់យើងផងដែរ។ ការរងទុក្ខនេះក៏ជាចំណែកនៃផែនការដ៏ល្អរបស់ទ្រង់សម្រាប់យើង ដែលព្រះអង្គបានប្រាប់ឲ្យយើងមានអំណរក្នុងវាផងដែរ។ ពេលយើងរងទុក្ខសម្រាប់ព្រះជាម្ចាស់ នោះមានន័យថា យើងបង្ហាញពីការប្រកបគ្នា និងការរួបរួមជាមួយនឹងព្រះគ្រីស្ទយេស៊ូវ។ នេះគឺពិតជាការដែលនាំឲ្យមានអំណរ និងជាដំណឹងល្អដែលនាំឲ្យមានមូលដ្ឋាននៃក្ដីសង្ឃឹមដ៏ជាក់លាក់មែន។

## សេចក្ដីសន្និដ្ឋាន

យើងមានការរងទុក្ខនៅលើផែនដីនេះដោយសារអំពើបាប។ ពេលយើងយល់ពីការនេះហើយ ដាច់ខាតយើងមិនត្រូវស្វែងរកដំណោះស្រាយសម្រាប់ការរងទុក្ខដែលគេចចេញពីឫសគល់

វាទៀយ។ ព្រះជាម្ចាស់មានផែនការក្នុងការសង្គ្រោះ ដែលព្រះអង្គដោះស្រាយបញ្ហានៃអំពើបាប និងផលកម្មដ៏ឈឺចាប់របស់វាដ៏អស់កល្បជានិច្ច។ ពេលដែលព្រះយេស៊ូវគ្រីស្ទរងទុក្ខនៅលើឈើឆ្កាង ព្រះអង្គបានយកទារុណកម្មដែលយើងសមនឹងទទួលសម្រាប់អំពើបាបរបស់យើង ដើម្បីកុំឲ្យយើងរងទុក្ខយ៉ាងអស់កល្បជានិច្ចនៅក្នុងស្ថាននរក។

ព្រះជាម្ចាស់បានបង្វែរបណ្ដាសាចេញ ហើយបានប្ដូរវានឹងការស្ដារឡើងវិញ។ ឥឡូវនេះ យើងអាចឃើញសញ្ញាសម្គាល់មួយចំនួននៃការស្ដារឡើងវិញ ប៉ុន្តែវានឹងមិនឈានដល់ទីបញ្ចប់នៅឡើយទេ រហូតទាល់តែព្រះយេស៊ូវយាងត្រឡប់មកវិញ ហើយធ្វើឲ្យជំនាន់នេះឈានដល់ទីបញ្ចប់ ហើយនាំចូលមកនូវជំនាន់ថ្មី។ ទំនុកចិត្តរបស់យើងក្នុងព្រះគ្រីស្ទដោយជឿថា ព្រះជាម្ចាស់នឹងដកចេញនូវការរងទុក្ខជាអចិន្ត្រៃយ៍ ផ្ដល់នូវក្ដីសង្ឃឹមដល់យើងសូម្បីតែពេលដែលយើងប្រឈមមុខនឹងការឈឺចាប់ក៏ដោយ។ តាមពិតទៅ យើងថែមទាំងអាចមានអំណរក្នុងការរងទុក្ខ ព្រោះវាចម្រើនជំនឿរបស់យើង ហើយបង្កើនការរួបរួមគ្នារបស់យើងជាមួយនឹងព្រះយេស៊ូវគ្រីស្ទ។ ការរងទុក្ខឥឡូវនេះគឺជាចំណែកមួយនៃផែនការរបស់ព្រះជាម្ចាស់ ខណៈពេលដែលទ្រង់នាំយើងឲ្យ

ឈានចូលទៅដល់ចំណុចបញ្ចប់នៃព័ន្ធកិច្ចរបស់ទ្រង់ទាក់ទង នឹងការស្តារឡើងវិញ ដែលនៅពេលនោះការរងទុក្ខរបស់យើង នឹងឈានដល់ទីបញ្ចប់។ នេះគឺជាព្រះប្រាជ្ញារបស់ព្រះជាម្ចាស់ ហើយក៏ជាដំណឹងល្អដ៏នៅអស់កល្បជានិច្ចផងដែរ។

## ជំពូក៥៖

# ដំណឹងល្អដ៏ពិត

Conrad Mbewe

*«ពាក្យនេះគួរជឿ ហើយគួរទទួលគ្រប់យ៉ាង គឺថា ព្រះគ្រីស្ទយេស៊ូវទ្រង់បានយាងមកក្នុងលោកីយ៍ ដើម្បីនឹងជួយសង្គ្រោះមនុស្សមានបាប ដែលខ្ញុំនេះជាលេខ១ក្នុងពួកគេ» (១ធីម៉ូថេ ១:១៥)។*

ការសាយភាយនៃគ្រីស្ទសាសនាគឺជាមហាអច្ឆរិយមួយក្នុងចំណោមអច្ឆរិយនៃពិភពលោកនេះ។ តាមរយៈការប្រឆាំងទាស់នឹងអំណាច និងការបៀតបៀនមួយចំនួន ជំនឿគ្រីស្ទសាសនាក៏បាន ហើយក៏កំពុងនៅតែបន្តសាយភាយនៅលើផែនដីនេះ ដោយនាំមកនូវការរួបរួមនៃគ្រប់ជាតិសាសន៍ និងវប្បធម៌។ សាសនាជាច្រើនមានចលនានៃការចាប់ផ្ដើមក្នុងប្រវត្តិសាស្រ្ត ហើយក៏បានឈានដល់ទីបញ្ចប់ផងដែរ។ លោក កាម៉ាលាល បានរំពឹងថាការនោះក៏នឹងកើតឡើងចំពោះគ្រីស្ទសាសនាផងដែរ នៅពេល

ដែលគាត់ផ្តល់ប្រឹក្សាទៅកាន់ពួកសាន់ហេឌ្រិន (“Sanhedrin” កិច្ចការ ៥:៣៤-៣៩)។

ប៉ុន្តែ ចំណែកឯជំនឿគ្រីស្ទសាសនាវិញ ដែលនៅពេលមុនជាជំនឿរបស់មនុស្សតែប៉ុន្មាននាក់ប៉ុណ្ណោះនៅក្រុងយេរូសាឡឹម និងយូដា ឥឡូវមានគេស្រឡាញ់ និងប្រកាសជាច្រើនតាំងពីទ្វីបអាហ្វ្រិកដល់កូរ៉េដល់អាម៉េរិកខាងត្បូង។ ហើយការនេះនៅតែបន្តកើតឡើងទោះបើគ្រីស្ទបរិស័ទប្រឈមមុខនឹងការប្រឆាំងដ៏សាហាវៗយង់ឃ្នងតាំងពីសតវត្សទី១រហូតមកដល់ទី២១ក៏ដោយ។ ជាពិសេសបេសកជន និងគ្រូអធិប្បាយជាច្រើនបានស៊ូប្តូរជីវិត ដើម្បីផ្សាយនូវដំណឹងដែលពួកគាត់ដឹងយ៉ាងសាមញ្ញថាជា*ដំណឹងល្អ*។ ប្រាកដណាស់ គួរតែមានអ្នកសួរថា «ហេតុអ្វីបានជាដូច្នោះ? តើអ្វីទៅដែលជាសាំងសម្រាប់បញ្ឆេះធ្វើឲ្យមានចលនានេះកើតឡើងដោយមិនអាចមានការទប់ស្កាត់បាន ទោះបើមានមនុស្សជាច្រើនព្យាយាមបញ្ឈប់ចលនានោះក៏ដោយ?»។

ពិតណាស់ ដំណឹងល្អគឺជាចំណុចស្នូល។ ក្នុងនាមជាគ្រីស្ទបរិស័ទ យើងដឹងថាយើងមានដំណឹងដ៏ល្អបំផុត ដំណឹងដ៏សំខាន់បំផុត និងដំណឹងដែលផ្តល់ជាអំណរដ៏ខ្លាំងបំផុតក្នុងចក្រវាលនេះ៖ «ព្រះគ្រីស្ទយេស៊ូវទ្រង់បានយាងមកក្នុងលោកីយ៍ ដើម្បី

នឹងជួយសង្គ្រោះមនុស្សមានបាប» (១ធីម៉ូថេ ១:១៥)។ សារនៃសេចក្តីសង្គ្រោះរបស់យើងតាមរយៈព្រះយេស៊ូវគ្រីស្ទគឺជាដំណឹងល្អ ហើយយើងមិនត្រូវ ព្រមទាំងមិនអាចទុកដំណឹងនេះសម្រាប់តែខ្លួនឯងបានឡើយ។

លើសពីនោះទៅទៀត ដើម្បីប្រយោជន៍របស់យើង និងប្រយោជន៍របស់អស់អ្នកដែលមិនទាន់ជឿ ដាច់ខាតយើងមិនហ៊ានមើលរំលងដំណឹងល្អដ៏ពិតនេះបានឡើយ។ គឺនៅក្នុងព្រះគ្រីស្ទផ្ទាល់ដែលយើងទទួលបានការរម្លឹកថាតើអ្វីទៅធ្វើឲ្យដំណឹងនេះល្អម្ល៉េះ៖ អត្តសញ្ញាណ ចំណាប់អារម្មណ៍ និងការថ្លែងអន្តរាគមន៍របស់ទ្រង់។

## អត្តសញ្ញាណនៃព្រះសង្គ្រោះ

សាររបស់គ្រីស្ទបរិស័ទគឺជាសារដ៏ល្អបំផុតនៅក្នុងចក្រវាលនេះ។ ទីមួយ ព្រោះ*អត្តសញ្ញាណ*នៃព្រះសង្គ្រោះ។ ព្រះយេស៊ូវបានមានបន្ទូលថា «ខ្ញុំជាផ្លូវ ជាសេចក្តីពិត ហើយជាជីវិត បើមិនមកតាមខ្ញុំ នោះគ្មានអ្នកណាទៅឯព្រះវរបិតាបានឡើយ» (យ៉ូហាន ១៤:៦)។ មិនមែនតាមរយៈលោក មហាម៉ាត់ ឬព្រះពុទ្ធ ឬស្ត្រីព្រហ្មចារីនាងម៉ារា ឬក៏អ្នកដឹកនាំសាសនាណាម្នាក់ឡើយ សូម្បី

តែអ្នកដឹកនាំក្នុងគ្រីស្ទសាសនា។ ហើយក៏មិនតាមរយៈវិញ្ញាណក្ខន្ធដូនតាណាមួយឡើយ ប៉ុន្តែគឺតាមតែរយៈព្រះយេស៊ូវគ្រីស្ទមួយអង្គគត់ទើបយើងអាចគេចផុតចេញពីអំពើបាប និងស្ថាននរក ហើយទទួលបានព្រះគុណ និងស្ថានសួគ៌វិញ។ ប៉ុន្តែ តើព្រះយេស៊ូវម្នាក់នេះជានរណាដែលហ៊ានអះអាងយ៉ាងសម្បើមម្ល៉េះ?

ទីមួយ ព្រះអង្គគឺជា*ព្រះមេស្ស៊ី* (ព្រះគ្រីស្ទ) ដែលពួកហោរាក្នុងព្រះគម្ពីរសញ្ញាចាស់បានរៀបរាប់ និងសរសេរសំដៅលើ—ជាក្តីសង្ឃឹមសម្រាប់សាសន៍អ៊ីស្រាអែល និងពិភពលោកទាំងមូល។ សូមកត់សម្គាល់មើលពីការពណ៌នាអំពីអំណាច និងឫទ្ធិបារមីដ៏ពិសេសរបស់ព្រះមេស្ស៊ីក្នុងកណ្ឌគម្ពីរទំនុកតម្កើងជំពូក២ និង៤៥។ ស្របគ្នាផងដែរកណ្ឌគម្ពីរ លោកុប្បត្តិ ៤៩:១០ ក៏បានលើកឡើងដែរថា ព្រះអង្គនឹងប្រសូតចេញពីកុលសម្ព័ន្ធនៃសាសន៍យូដាក្នុងប្រទេសអ៊ីស្រាអែល។ ក្នុងកណ្ឌគម្ពីរ អេសាយ ៧:១៤ យើងអានអំពីអាថ៌កំបាំងដែលថាទ្រង់នឹងប្រសូតពីនាងក្រមុំព្រហ្មចារីម្នាក់ ហើយកណ្ឌគម្ពីរ មីកា ៥:២ បានប្រាប់យើងពីទីតាំងចំៗនៃកន្លែងប្រសូត គឺនៅភូមិបេថ្លេហិម។ ហើយក្នុងខគម្ពីរជាច្រើនយើងក៏ឃើញផងដែរថា ព្រះមេស្ស៊ីនេះគឺជាពូជពង្សវង្សាម្នាក់នៃគ្រួសារស្តេច ដាវីឌ (អេសាយ ១១)។ ល្អលើសនោះទៅ

ទៀតកណ្ឌគម្ពីរអេសាយជំពូក៥៣បានប្រាប់យើងថា ព្រះអង្គនឹងរងទុក្ខយ៉ាងពិបាក សុគតជំនួសយើង ហើយក៏នឹងមានព្រះជន្មរស់ពីសុគតឡើងវិញផងដែរ។ មានតែបុគ្គលម្នាក់គត់ក្នុងប្រវត្តិសាស្ត្រដែលបានបំពេញរាល់គ្រប់ទំនាយទាំងនោះ ដែលត្រូវបានសរសេរឡើងរាប់រយឆ្នាំមុនដែលត្រូវបំពេញ។ គឺព្រះយេស៊ូវគ្រីស្ទ។

អ្នកនិពន្ធកណ្ឌដំណឹងល្អនៅក្នុងព្រះគម្ពីរសញ្ញាថ្មីមិនចង់ឲ្យលោកអ្នកមើលរំលងចំណុចសំខាន់នេះឡើយ។ ដូចដែលសាវ័ក ម៉ាថាយ បានសរសេរឡើងម្តងហើយម្តងទៀតអំពីកាលដែលព្រះយេស៊ូវគង់នៅលើផែនដី «ការទាំងនោះកើតមក ដើម្បីឲ្យបានសម្រេចសេចក្តី ដែលព្រះអម្ចាស់ទ្រង់មានបន្ទូល ដោយសារហោរា» (ម៉ាថាយ ១:២២; ២:១៧; ២១:៤។ល។)។ ពិតជាអស្ចារ្យមែន! មានពេលមួយ ព្រះយេស៊ូវបានក្រោកឈរនៅក្នុងសាលាប្រជុំ បន្ទាប់មកបានអានចេញពីកណ្ឌគម្ពីរហោរាអេសាយ ហើយក៏បានប្រកាសថាតាមពិតទៅបទគម្ពីរនោះគឺកំពុងនិយាយអំពីទ្រង់ផ្ទាល់ (លូកា ៤:១៦-២១)។

សូមនឹកស្រមៃទៅមើលថា តើអ្នកស្តាប់មានការភ្ញាក់ផ្អើលប៉ុណ្ណាទៅ! មានពេលមួយទៀត ព្រះយេស៊ូវបានស្តីឲ្យពួកសិស្សរបស់ទ្រង់ដោយសារពួកគាត់មិនបានមើលឃើញពីអ្វីដែលព្រះ

គម្ពីរសញ្ញាចាស់បានមានបន្ទូលអំពីទ្រង់ រួមមានទាំងចំណុចដែលថាទ្រង់នឹងរងទុក្ខ សុគត ហើយនឹងមានព្រះជន្មរស់ពីស្លាប់ឡើងវិញ (លូកា ២៤:២៥-២៧; ៤៤-៤៧)។ នេះក៏ជាព្រះយេស៊ូវដែលសាវ័ក ប៉ុល បាននិយាយសំដៅទៅកាន់ពេលដែលគាត់លើកឡើងថា «ព្រះគ្រីស្ទយេស៊ូវទ្រង់បានយាងមកក្នុងលោកីយ៍ដើម្បីនឹងជួយសង្គ្រោះមនុស្សមានបាប» (១ធីម៉ូថេ ១:១៥)។ ទ្រង់នេះឯងគឺជាបុគ្គលដែលមនុស្សម្នាកំពុងតែប្រកាសនៅលើផែនដីនេះ។

កុំមើលរំលងចំណុចសំខាន់នៃពាក្យទាំងប្រាំនោះ៖ *បានយាងមកក្នុងលោកីយ៍។* ផ្ទុយពីព្រះមេស្ស៊ីក្លែងក្លាយនានា និងអ្នកដឹកនាំផ្សេងៗដែលធ្វើឲ្យយើងខកចិត្ត ដោយសារពួកគាត់សន្យាជាច្រើន ប៉ុន្តែអាចបំពេញបានតែបន្តិចបន្តួច ឯព្រះយេស៊ូវវិញព្រះអង្គមិនមែនកើតចេញពីភពផែនដីនេះទេ។ ព្រះយេស៊ូវគ្រីស្ទមួយអង្គនេះដែលព្រះគម្ពីរបានរៀបរាប់ គឺមិនមែនគ្រាន់តែជាមនុស្សដ៏ខ្ពង់ខ្ពស់ប៉ុណ្ណោះទេ ប៉ុន្តែក៏ជាព្រះផងដែរ។ ព្រះអង្គគឺជាអង្គដែលបានយាងមកយកកំណើត ជាបុគ្គលទីពីរនៃព្រះត្រៃឯកដែលពេញដោយព្រះពរ ពោលគឺជាព្រះរាជបុត្រារបស់ព្រះជាម្ចាស់។

រាល់គ្រប់កណ្ឌដំណឹងល្អ (ម៉ាថាយ ម៉ាកុស លូកា និង

យ៉ូហាន) បានលើកឡើងអំពីសារនេះ ហើយសាវ័ក យ៉ូហាន ក៏បានចាប់ផ្ដើមកណ្ឌគម្ពីររបស់គាត់ដោយប្រើប្រាស់ពាក្យពេចន៍ ដូចតទៅនេះ៖

*«កាលដើមដំបូងមានព្រះបន្ទូល ព្រះបន្ទូលក៏គង់នៅជាមួយនឹងព្រះ ហើយព្រះបន្ទូលនោះឯងជាព្រះ ទ្រង់គង់នៅជាមួយនឹងព្រះ តាំងអំពីដើមមក គ្រប់របស់ទាំងអស់បានកើតមកដោយសារទ្រង់ ហើយក្នុងបណ្ដារបស់ដែលបានបង្កើតមកទាំងប៉ុន្មាន នោះគ្មានអ្វីណាមួយកើតមកក្រៅពីទ្រង់ឡើយ...ព្រះបន្ទូលក៏ត្រឡប់ជាសាច់ឈាម ហើយបានស្នាក់នៅជាមួយនឹងយើងរាល់គ្នា យើងរាល់គ្នាបានឃើញសិរីល្អទ្រង់ គឺជាសិរីល្អនៃព្រះរាជបុត្រាតែ១ ដែលមកពីព្រះវរបិតា មានពេញជាព្រះគុណ នឹងសេចក្ដីពិត» (យ៉ូហាន ១:១-៣; ១៤)។*

នៅទីបញ្ចប់នៃជីវិតរបស់ព្រះយេស៊ូវនៅលើផែនដី យើងឃើញយ៉ាងច្បាស់លាស់ថាទ្រង់គឺជាព្រះរាជបុត្រារបស់ព្រះជាម្ចាស់។ មុនព្រះអង្គប្រសូត ទេវតាមួយរូបបានប្រាប់នាង ម៉ារា ថាបុត្រ

ដែលនឹងសម្រាលពីនាងគឺជាព្រះរាជបុត្រារបស់ព្រះជាម្ចាស់ (លូកា ១:៣៥)។ ហើយនៅទីបញ្ចប់នៃជីវិតរបស់ទ្រង់ នាពេលព្រះអង្គដកដង្ហើមចុងក្រោយ ហើយសុគតនៅលើឈើឆ្កាង ទាហានដែលឈរនៅទីនោះក៏បានឃើញការសុគតរបស់ព្រះអង្គដែរ គាត់បានលន់តួថា៖ «នេះពិតជាព្រះរាជបុត្រានៃព្រះមែន» (ម៉ាថាយ ២៧:៥៤)។ ក្រែងលោយើងមើលរំលងចំណុចនេះ ព្រះវរបិតាបានប្រកាសពីរដងចេញពីស្ថានសួគ៌ថា ព្រះយេស៊ូវគឺជាព្រះរាជបុត្រារបស់ទ្រង់ (ម៉ាថាយ ៣:១៧; ១៧:៥)។

ហេតុអ្វីបានជាអត្តសញ្ញាណរបស់ព្រះយេស៊ូវគ្រីស្ទគឺជាដំណឹងដ៏ល្អម្ល៉េះ? មិនថាបញ្ហានៃអំពើបាបរបស់លោកអ្នកធំប៉ុណ្ណាក៏ដោយ ក៏ព្រះដ៏មានពេញដោយសព្វានុភាពបានយាងមកលោកីយ៍នេះ ដើម្បីប្រោសលោះលោកអ្នកដែរ។ ប្រសិនបើព្រះយេស៊ូវគ្រាន់តែជាមនុស្សធម្មតា នោះយើងប្រាកដនឹងជាគ្មានសង្ឃឹមឡើយ ព្រោះអ្នករំដោះបែបនោះមិនមានអំណាចគ្រប់គ្រាន់ទេ គាត់នឹងនៅមានអំពើបាបផ្ទាល់ខ្លួន បរាជ័យ និងភាពខ្សោយមួយចំនួនដែលគាត់ត្រូវយកឈ្នះជាមុនសិនទើបគាត់អាច*ព្យាយាម*សង្គ្រោះយើងចេញពីអំពើបាបរបស់យើង។ ប៉ុន្តែ ព្រះគ្រីស្ទទ្រង់បរិសុទ្ធ គ្មានបាប ហើយក៏ថែមទាំងមានរាល់

គ្រប់សិទ្ធិអំណាចក្នុងនាមជាព្រះរាជបុត្រារបស់ព្រះជាម្ចាស់ទៅទៀត។ តើមានអ្វីមួយពិបាកខ្លាំងពេកសម្រាប់ព្រះអង្គមែនឬ? (លូកា ១៨:២៧)។ ព្រះអង្គដែលបង្កើតចក្រវាលដ៏មហិមានេះចេញពីភាពទទេសូន្យស្អាត ហើយទ្រទ្រង់វាដោយប្រើប្រាស់ព្រះហស្តដ៏ពេញដោយឫទ្ធិចេស្តា។ តើព្រះអង្គនេះអាចបរាជ័យក្នុងការដោះស្រាយបញ្ហាច្រវាក់នៃអំពើបាបរបស់យើងដែលធ្វើឲ្យយើងជាទាសកររបស់វាមិនបានទេឬអី? ទេ! ព្រះអង្គមិនអាចបរាជ័យបានឡើយ។ ពេលដែលព្រះអង្គឮសម្រែករបស់លោកអ្នក ហើយទ្រង់ចាប់ផ្តើមធ្វើការ នោះច្រវាក់ដ៏ខ្លាំងបំផុតនៃអំពើបាបនឹងរបូតចេញលឿនជាងសម្បុកពីងពាងឆេះពេលត្រូវភ្លើងទៅទៀត។ ចូរសរសើរតម្កើងព្រះអង្គ!

## ចំណាប់អារម្មណ៍នៃព្រះសង្គ្រោះ

ទីពីរ ចំណុចមួយទៀតដែលធ្វើឲ្យសារនៃគ្រីស្ទបរិស័ទជាសារដែលល្អបំផុតគឺ៖ *ចំណាប់អារម្មណ៍*នៃព្រះសង្គ្រោះ។ ដូចដែលយើងបានលើកឡើងម្តងរួចទៅហើយថាសាវ័ក ប៉ុល បាននិពន្ធក្រោមការដឹកនាំរបស់ព្រះវិញ្ញាណថា «ព្រះគ្រីស្ទយេស៊ូវទ្រង់បានយាងមកក្នុងលោកីយ៍ ដើម្បីនឹងជួយសង្គ្រោះ*មនុស្សមានបាប*»

(១ធីម៉ូថេ ១:១៥)។ នេះមិនគ្រាន់តែជាដំណឹងដ៏ល្អប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាដំណឹងដ៏គួរឲ្យញ័ររន្ធត់ផងដែរ។

សតិសម្បជញ្ញៈរបស់យើងប្រាប់ថា ព្រះជាម្ចាស់ទ្រង់បរិសុទ្ធ ដូច្នេះ តើធ្វើឲ្យព្រះរាជបុត្រារបស់ព្រះជាម្ចាស់យាងមកកាន់ផែនដី ដើម្បីស្វែងរកការប្រកបគ្នាជាមួយនឹង*មនុស្សមានបាប*បានយ៉ាងដូចម្ដេច? នោះឯងជាអ្វីដែលធ្វើឲ្យពួកផារិស៊ីមានការភាន់ច្រឡំ។ ពួកគាត់រំពឹងឲ្យព្រះយេស៊ូវ (ទោះបើពួកគាត់បានគិតថាទ្រង់គ្រាន់តែជាគ្រូបង្រៀនម្នាក់តែប៉ុណ្ណោះ) រារាំងពួកមនុស្សមានបាបចេញ ប៉ុន្តែការដែលព្រះអង្គព្យាយាមស្វែងរក ហើយនិងស្វាគមន៍ពួកមនុស្សមានបាបធ្វើឲ្យពួកផារិស៊ីមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង។ «អស់ទាំងអ្នកយកពន្ធ និងអ្នកមានបាប គេក៏ចូលមកជិត ដើម្បីស្ដាប់ទ្រង់ នោះពួកផារិស៊ី និងពួកអាចារ្យគេឌុកដាន់ថា អ្នកនេះទទួលមនុស្សបាប ហើយក៏ស៊ីជាមួយនឹងគេផង» (លូកា ១៥:១-២)។ ទោះជាយ៉ាងណាក្ដី ក៏ព្រះយេស៊ូវមិនបានសូមការអភ័យទោសពីពួកគាត់ដែរទាក់ទងនឹងការនេះ។ ប៉ុន្តែ ផ្ទុយទៅវិញព្រះអង្គបានឆ្លើយថា «ពួកអ្នកជាមិនត្រូវការនឹងគ្រូពេទ្យទេ ត្រូវការតែពួកអ្នកដែលឈឺប៉ុណ្ណោះ ខ្ញុំមិនបានមកហៅពួកមនុស្សសុចរិតទេ គឺមកហៅតែមនុស្សមានបាប ឲ្យគេប្រែចិត្ត

វិញទេតើ» (លូកា ៥:៣១-៣២)។

ចំណាប់អារម្មណ៍របស់ព្រះយេស៊ូវក្នុងការសង្គ្រោះមនុស្សមានបាបគឺជាការដ៏គួរឲ្យភ្ញាក់ផ្អើលខ្លាំងណាស់ ព្រោះពេលណាដែលយើងប្រព្រឹត្តអំពើបាប គឺក្រឹត្យវិន័យរបស់ព្រះជាម្ចាស់ទេដែលយើងបានធ្វើរំលង។ ព្រះអង្គគឺជាអង្គដែលយើងធ្វើឲ្យខកព្រះទ័យ។ តើលោកអ្នកធ្លាប់ឮអំពីបុគ្គលម្នាក់ដែលធ្វើឲ្យបុគ្គលណាម្នាក់ទៀតខកចិត្ត ហើយបុគ្គលដែលគេបានធ្វើឲ្យខកចិត្តនេះចេញទៅរកបុគ្គលដែលធ្វើឲ្យគាត់ខកចិត្ត ដើម្បីនឹងប្រទានពរដល់គាត់ដែរឬទេ? កាលខ្ញុំនៅជំទង់ ខ្ញុំបានធ្វើជាមេរំខានជាច្រើនដងជាមួយនឹងអ្នកដទៃ។ ជាលទ្ធផល ពេលណាដែលខ្ញុំបានឃើញប៉ូលិស ជារឿយៗខ្ញុំតែងតែចាប់ផ្ដើមមានអារម្មណ៍ភ័យខ្លាច។ សតិសម្បជញ្ញៈរបស់ខ្ញុំបានធ្វើឲ្យខ្ញុំគិតថា ប៉ូលិសនោះកំពុងតែស្វែងរកចាប់ខ្ញុំ ដូច្នេះខ្ញុំក៏តែងតែស្វែងរកផ្លូវគេចកុំឲ្យប៉ូលិសឃើញខ្ញុំ។ នេះឯងជារបៀបដែលសតិសម្បជញ្ញៈរបស់យើងគួរគិតពេលដែលយើងគិតអំពីការដែលព្រះរាជបុត្រារបស់ព្រះជាម្ចាស់បានយាងមកផែនដី។ យើងដឹងហើយថាយើងស័ក្តិសមនឹងទទួលទារុណកម្មពីព្រះអង្គសម្រាប់នូវរាល់អំពើបាបដែលយើងបានប្រព្រឹត្ត*ទាស់នឹងទ្រង់*។ ទោះជាយ៉ាងណាក្ដី ក៏វាពិតជា

ការដ៏អស្ចារ្យមែនដែលព្រះយេស៊ូវគ្រីស្ទបានយាងមកផែនដី ដើម្បីនឹងសង្គ្រោះមនុស្សមានបាបឲ្យចេញរួចពីបាប មិនមែនមកដាក់ទោសពួកគាត់ឡើយ (យ៉ូហាន ៣:១៧)។

ចូរឲ្យសេចក្តីពិតនេះជ្រាបចូលទៅក្នុងចិត្តរបស់លោកអ្នក។ ព្រះយេស៊ូវមិនបានយាងមក ដើម្បីសង្គ្រោះមនុស្សសុចរិតឡើយ។ ព្រះអង្គបានយាងមក ដើម្បីសង្គ្រោះមនុស្សមានបាប។ មូលហេតុដែលព្រះជាម្ចាស់អាចមានចំណាប់អារម្មណ៍នឹងរឿងរ៉ាវទាក់ទងនឹងមនុស្សមានបាបគឺ ព្រោះទ្រង់មានសេចក្តីមេត្តាករុណា សេចក្តីស្រឡាញ់ ហើយព្រះអង្គក៏*ពេញដោយព្រះគុណ*ផងដែរ។ ព្រះគុណមានឋានៈខ្ពស់ជាងសេចក្តីមេត្តាករុណាមួយកាំ។ ព្រះគុណគឺជាសេចក្តីមេត្តាករុណាដែលបុគ្គលដែលជាអ្នកគេត្រូវបានគេធ្វើឲ្យខកចិត្តបង្ហាញទៅកាន់ភាគីដែលធ្វើឲ្យបុគ្គលម្នាក់នោះខកចិត្ត។ ឧទាហរណ៍៖ ប្រសិនបើខ្ញុំឃើញមនុស្សមួយហ្វូងកំពុងតែវាយដំច្រំធាក់លោកអ្នក ហើយខ្ញុំបានជួយសង្គ្រោះលោកអ្នកចេញពីកំហឹងរបស់ពួកគេ នោះលោកអ្នកនឹងរាប់ការនោះថាជាសេចក្តីមេត្តាករុណា។ វាជាសេចក្តីជ្រះថ្លានៃភាពជាមនុស្សដែលជំរុញឲ្យខ្ញុំជួយលោកអ្នកគេចចេញពីកណ្តាប់ដៃនៃហ្វូងមនុស្សដែលកំពុងវាយលោកអ្នក។ ប៉ុន្តែ ចូរនឹកស្រមៃទៅមើលថា ប្រសិន

បើប៉ុន្មានថ្ងៃមុនរឿងរ៉ាវដ៏គួរឲ្យខ្លោចចិត្តនេះកើតឡើង លោកអ្នកបានមកកាន់ផ្ទះខ្ញុំ ហើយបានវាយបង្ខូចផ្ទះខ្ញុំបែកអស់រលីង។ បន្ទាប់មក ពេលក្រោយខ្ញុំឃើញហ្វូងមនុស្សវាយលោកអ្នក នោះវាជារឿងធម្មតាទេដែលលោកអ្នកនឹងរំពឹងឲ្យខ្ញុំរួមដៃក្នុងការវាយលោកអ្នកដែរ។ ប៉ុន្តែ ប្រសិនបើខ្ញុំជួយសង្គ្រោះលោកអ្នក ហើយថែមទាំងជូនលោកអ្នកទៅពេទ្យណាមួយជិតហ្នឹង ហើយបង់ថ្លៃព្យាបាលឲ្យផងដែរ នេះជាការលើសជាងសេចក្តីមេត្តាករុណាទៅទៀត។ វាជាព្រះគុណ។

ព្រះជាម្ចាស់មានពេញទៅដោយព្រះគុណទៅកាន់មនុស្សមានបាប  សូម្បីតែមនុស្សដែលមានបាបដ៏ធ្ងន់ធ្ងរក៏ដោយ។ សាវ័ក ប៉ុល បានលើកខ្លួនគាត់ជាឧទាហរណ៍ទាក់ទងនឹងប្រភេទមនុស្សដែលព្រះយេស៊ូវគ្រីស្ទសង្គ្រោះ៖ «ព្រះគ្រីស្ទយេស៊ូវទ្រង់បានយាងមកក្នុងលោកីយ៍ ដើម្បីនឹងជួយសង្គ្រោះមនុស្សមានបាប *ដែលខ្ញុំនេះជាលេខ១ក្នុងពួកគេ*» (១ធីម៉ូថេ ១:១៥)។ សាវ័ក ប៉ុល កំពុងតែទទូចប្រាប់យើងថាគាត់ជាមនុស្សដែលមានបាបលើសគេ។ មុនសាវ័ក ប៉ុល បំផ្លាស់បំប្រែចិត្តហើយទទួលជឿលើព្រះគ្រីស្ទ គាត់ជាបុគ្គលម្នាក់ដែលមើលងាយមើលថោកហើយនិយាយអាក្រក់ៗជាច្រើនទាស់នឹងព្រះយេស៊ូវគ្រីស្ទដែល

ជាព្រះរាជបុត្រារបស់ព្រះជាម្ចាស់។ គាត់បានធ្វើឲ្យគ្រីស្ទបរិស័ទជាច្រើនរងទុក្ខដោយសារជំនឿរបស់ពួកគេនៅលើព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ តាមពិតទៅ គាត់កំពុងតែធ្វើដំណើរទៅកាន់ទីក្រុងដាម៉ាស ដើម្បីប្រមូលគ្រីស្ទបរិស័ទបន្ថែមទៀតយកមកធ្វើបាប និងដាក់គុក អំឡុងពេលនោះឯងគឺជាពេលដែលគាត់បានបំផ្លាស់បំប្រែចិត្តហើយទទួលជឿ។

ការនេះធ្វើឲ្យសាវ័ក ប៉ុល ក្លាយជាគំរូដ៏ចម្បងម្នាក់នៃចំណាប់អារម្មណ៍របស់ព្រះសង្គ្រោះយើង។ «ដោយហេតុនោះបានជាទ្រង់អាណិតមេត្តាដល់ខ្ញុំ ដើម្បីឲ្យព្រះយេស៊ូវគ្រីស្ទបានសម្តែងចេញគ្រប់ទាំងសេចក្តីអត់ធន់របស់ទ្រង់ក្នុងខ្លួនខ្ញុំ ដែលជាអ្នកលេខ១នោះ ឲ្យខ្ញុំបានធ្វើជាក្បួនដល់ពួកអ្នក ដែលនឹងជឿដល់ទ្រង់ ប្រយោជន៍ឲ្យគេបានជីវិតអស់កល្បជានិច្ច» (១ធីម៉ូថេ ១:១៦)។ ការបង្ហាញសេចក្តីមេត្តាករុណាទៅកាន់មនុស្សដែលមានបាបលើសគេ គឺជាការដែលព្រះជាម្ចាស់ចង់លើកទឹកចិត្តកុំឲ្យមនុស្សមានបាបផ្សេងៗទៀតរត់គេចចេញពីទ្រង់ ប៉ុន្តែឲ្យពួកគាត់ទូលសុំនូវភាពអាណិតអាសូរដូចនោះដែរ។ ក្នុងព្រះគ្រីស្ទ ប្រសិនបើព្រះជាម្ចាស់អាចអត់ទោសបាបមនុស្សដែលមានបាបយ៉ាងធ្ងន់ធ្ងរដូចជាសាវ័ក ប៉ុល បាន នោះព្រះអង្គក៏អាចអត់ទោសបាបមនុស្សដូច

ជាលោកអ្នក និងខ្ញុំបានដែរ។

នោះទំនងជាបញ្ហារបស់លោកអ្នក។ ក្នុងជម្រៅចិត្តរបស់លោកអ្នក លោកអ្នកដឹងហើយថាតម្រូវការធំបំផុតរបស់លោកអ្នកមិនមែនជាការមានលុយកាក់ច្រើនជាងមុន ឬក៏រាងកាយដែលមានសុខភាពល្អនោះទេ។ លោកអ្នកបានប្រព្រឹត្តអំពើបាបយ៉ាងសាហាវៗទាស់នឹងព្រះជាម្ចាស់ ហើយលោកអ្នកក៏កំពុងតែគេចចេញពីចំណុចដ៏ពិតនោះ។ ទំនងជាលោកអ្នកបានរម្លូតកូនមួយនៅក្នុងផ្ទៃ ហើយសតិសម្បជញ្ញៈរបស់លោកអ្នកកំពុងតែស្រែកដាក់លោកអ្នកក្នុងភាពស្ងៀមស្ងាត់នៃវិញ្ញាណរបស់លោកអ្នក។ ទំនងលោកអ្នកបានរស់នៅក្នុងជីវិតមួយដែលមានពេញទៅដោយការរួមភេទដោយអសីលធម៌ ហើយលោកអ្នកដឹងថាព្រះជាម្ចាស់ជ្រាបនូវរាល់ការនោះទាំងស្រុងដោយសារព្រះអង្គមើលឃើញនូវគ្រប់អ្វីៗទាំងអស់ដែលបានប្រព្រឹត្តឡើងក្នុងទីលាក់កំបាំង។ ទំនងជាលោកអ្នកបានរស់នៅដោយបោកប្រាស់អ្នកដទៃ ហើយឥឡូវនេះវាបានត្រឡប់មកលងលោកអ្នកវិញ ខណៈពេលដែលលោកអ្នកសម្លឹងមើលនូវរាល់ទ្រព្យសម្បត្តិទាំងអស់ដែលលោកអ្នកបានលួចពីគេក្នុងរបៀបខុសឆ្គងដោយគ្មានការស្តាប់ចិត្ត។

លោកអ្នកទំនងជាសួរខ្លួនឯងថា *«តើឲ្យព្រះជាម្ចាស់អត់*

*ទោសបាបនេះបានដោយរបៀបណាទៅ?»*។ នោះឯងជាបញ្ហាដ៏ចម្បងរបស់លោកអ្នក។ ទោះជាយ៉ាងណាក្តីដំណឹងល្អនៃជំនឿគ្រីស្ទបរិស័ទគឺថា ព្រះជាម្ចាស់មានចំណាប់អារម្មណ៍លើលោកអ្នក។ ព្រះអង្គបានចាត់ព្រះរាជបុត្រារបស់ទ្រង់ឲ្យមកកាន់លោកីយ៍ មិនមែនដើម្បីថ្កោលទោសលោកីយ៍ទេ ប៉ុន្តែដើម្បីឲ្យលោកីយ៍អាចនឹងទទួលបានសេចក្តីសង្គ្រោះតាមរយៈទ្រង់ (យ៉ូហាន ៣:១៧)។ ចូរជឿចុះ! ព្រះអង្គមានចំណាប់អារម្មណ៍ក្នុងការសង្គ្រោះលោកអ្នក។ នេះឯងជាមូលហេតុដែលធ្វើឲ្យដំណឹងនេះជាដំណឹងដ៏ល្អ។ តាមពិតទៅ វាល្អពេកហើយសឹងតែថាវាមិនពិតផង។ នៅមានសង្ឃឹមនៅឡើយសម្រាប់លោកអ្នកមិនថាអំពើបាបរបស់លោកអ្នកមានពេញដោយគំនុំក៏ដោយ។ ទោះបើលោកអ្នកស័ក្តិសមនឹងទៅស្ថាននរកក៏ដោយ ក៏លោកអ្នកផ្ទាល់នៅតែអាចទៅរស់នៅឯស្ថានសួគ៌ដ៏អស់កល្បជានិច្ចបានដែរ។

## ការថ្លែងអន្តរាគមន៍នៃព្រះសង្គ្រោះ

ជាចុងក្រោយ មូលហេតុដែលសារនៃគ្រីស្ទបរិស័ទជាដំណឹងដ៏ល្អបំផុតក្នុងចក្រវាលគឺ ពីព្រោះព្រះសង្គ្រោះ*ចុះថ្លែងអន្តរាគមន៍*។ «ព្រះគ្រីស្ទយេស៊ូវទ្រង់បានយាងមកក្នុងលោកីយ៍ ដើម្បីនឹងជួយ

សង្គ្រោះមនុស្សមានបាប» (១ធីម៉ូថេ ១:១៥)។ បើបុគ្គលណាម្នាក់ត្រូវតែទទួលការសង្គ្រោះ នោះមានន័យថា គាត់កំពុងស្ថិតនៅក្នុងការមានបញ្ហា ឬក៏មិនអាចសង្គ្រោះខ្លួនឯងបានហើយ។ ចំពោះបុគ្គលណាម្នាក់ដែលត្រូវការការសង្គ្រោះ មិនអាចជួយខ្លួនឯងបាន ឬក៏មិនអាចផ្លាស់ប្តូរកាលៈទេសៈរបស់គាត់បាន ចំពោះបុគ្គលនោះបើគ្មានអ្នកមកជួយរំដោះទេ នោះគាត់នឹងប្រឈមមុខនឹងវាសនាខ្លួនជាមិនខាន។

ជាទូទៅ ពេលដែលយើងគិតអំពីការជួយសង្គ្រោះ យើងទំនងជាស្រមៃគិតពីក្រុមទាហានដែលត្រូវបានគេចាត់ឲ្យចូលក្នុងទឹកដីដ៏ជ្រៅនៃខ្មាំងសត្រូវ ដើម្បីសង្គ្រោះចំណាប់ខ្មាំង ឬក៏គិតពីឧទ្ធម្ភាគចក្រដែលនាំអ្នកជំនាញហែលទឹកទៅកាន់តំបន់សមុទ្រដែលមានព្យុះសង្ឃរាយ៉ាងខ្លាំង ដើម្បីស្រង់យកអស់អ្នករងគ្រោះពីការលិចនាវា។ ទំនងលោកអ្នកគិតអំពីយន្តហោះអង្គការសហប្រជាជាតិដែលយកស្បៀងទៅកាន់តំបន់ដែលប្រឈមមុខនឹងអំណត់អត់ ក៏ដូចជាថ្នាំពេទ្យបំប៉នខ្លះៗទៅកាន់គ្រួសារដែលដាច់បាយ។ ក្នុងកាលៈទេសៈនីមួយៗ អស់អ្នកដែលទទួលជំនួយគឺសុទ្ធតែជាអស់អ្នកដែលមិនអាចជួយខ្លួនឯងបានទេ។ វាមិនអាចទៅរួចបានឡើយ។ ប្រសិនបើមិនមានអ្នកផ្សេងមកជួយ

សង្គ្រោះពួកគាត់ នោះពួកគាត់នឹងវិនាសជាមិនខាន។

ព្រះយេស៊ូវបានចុះថ្លែងអន្តរាគមន៍បែបនោះ។ ប៉ុន្តែ ចំណុចគ្រោះថ្នាក់នេះមិនមែនសម្រាប់តែអស់អ្នកដែលបានសម្លាប់អ្នកដទៃ ឬក៏សម្រាប់តែចោរនោះទ្បើយ ដ្បិតយើងទាំងអស់គ្នាត្រូវការការសង្គ្រោះចេញពីអំពើបាបខ្លួន។ ចាប់តាំងពីចំណុចផ្តើមនៃប្រវត្តិសាស្ត្រ លោក អ័ដាម និងនាង អេវ៉ា ដែលជាឪពុកម្តាយដំបូងរបស់យើង បានប្រព្រឹត្តបាបទាស់នឹងព្រះជាម្ចាស់ដោយបរិភោគផ្លែឈើពីដើមដែលព្រះជាម្ចាស់បានហាមពួកគាត់កុំឲ្យហូប (លោកុប្បត្តិ ៣)។ ការបះបោរដ៏អាត្មានិយមនេះទាស់នឹងព្រះជាម្ចាស់បានបណ្តាលឲ្យមានផលកម្មដែលធ្លាក់មកដល់កូនចៅគ្រប់ៗរូបរបស់ពួកគាត់ ដែលនោះមានរួមទាំងលោកអ្នកហើយនិងខ្ញុំ។ តាមធម្មជាតិ ចាប់តាំងពីពេលនោះមក យើងទាំងអស់គ្នាសុទ្ធតែជាមនុស្សមានបាប។

ដូចនឹងលោក អ័ដាម និងនាង អេវ៉ា យើងទាំងអស់គ្នាបានប្រព្រឹត្តអំពើបាប ហើយ «ឈ្នួលរបស់អំពើបាប នោះជាសេចក្តីស្លាប់» (រ៉ូម ៦:២៣)។ តើព្រះយេស៊ូវបានសង្គ្រោះលោកអ្នកចេញពីកម្មផលនៃនិស្ស័យអំពើបាប និងអំពើបាបរបស់លោកអ្នកហើយឬនៅ? ប្រសិនបើមិនទាន់ទេ នោះលោកអ្នកនៅត្រូវ

បង់ថ្លៃឈ្នួលនោះដោយខ្លួនឯង។ នេះឯងជាមូលហេតុដែលព្រះគម្ពីរបានចែងថា «តែត្រង់ពួកខ្លាច ពួកមិនជឿ ពួកគួរខ្ពើម ពួកកាប់សម្លាប់គេ ពួកកំផិត ពួកមន្តអាគម ពួកថ្វាយបង្គំរូបព្រះ ហើយគ្រប់ទាំងមនុស្សកំភូត គេនឹងមានចំណែក នៅក្នុងបឹងដែលឆេះជាភ្លើងនឹងស្ពាន់ធ័រ គឺជាសេចក្ដីស្លាប់ទី២វិញ» (វិវរណៈ ២១:៨)។ រាល់គ្រប់មនុស្សដែលប្រព្រឹត្តបាបដែលមិនទាន់ទទួលបានសេចក្ដីសង្គ្រោះនឹងត្រូវចំណាយពេលវេលាដ៏នៅអស់កល្បជានិច្ចនៅក្នុងបឹងភ្លើងនេះ។

ជាអចិន្ត្រៃយ៍ អស់អ្នកណាដែលមិនបានផ្សះផ្សាជាមួយនឹងព្រះជាម្ចាស់ នោះចំពោះពួកគាត់ ស្ថាននរកគឺជាទីកន្លែងនៃការដាច់ចេញពីព្រះអង្គ។ យើងជាមនុស្សអាត្មានិយមចាប់តាំងពីពេលដែលយើងកើតមកម្ល៉េះ ហើយស្ថិតក្រោមទាសករនៃការរស់នៅបែបអសីលធម៌ ហើយយើងក៏ស្លាប់ខាងឯវិញ្ញាណផងដែរ។ សាវ័ក ប៉ុល បានសរសេរទៅកាន់អស់អ្នកដែលបានទទួលជីវិតឡើងវិញតាមរយៈព្រះគ្រីស្ទថា «ពីដើម អ្នករាល់គ្នាក៏ស្លាប់ក្នុងការរំលង ហើយក្នុងអំពើបាបដែរ ជាការដែលអ្នករាល់គ្នាបានប្រព្រឹត្តតាមរបៀបលោកីយ៍នេះ...យើងរាល់គ្នាទាំងអស់ក៏បានប្រព្រឹត្តក្នុងពួកនោះពីដើមដែរ ដោយសេចក្ដីប៉ងប្រាថ្នារបស់សាច់ឈាមយើង

ទាំងប្រព្រឹត្តសេចក្តីដែលសាច់ឈាម នឹងគំនិតយើងចង់បានផង ហើយតាមកំណើតយើង នោះយើងជាមនុស្សជាប់ក្នុងសេចក្តីខ្ញាល់ ដូចជាមនុស្សឯទៀតដែរ» (អេភេសូរ ២:១-៣)។ គឺក្នុងលក្ខណៈនៃអំពើបាបបែបនេះឯងដែលធ្វើឲ្យយើងត្រូវការមានព្រះសង្គ្រោះយ៉ាងខ្លាំង។

យើង*មិនអាច*សង្គ្រោះខ្លួនឯងបានឡើយ។ បើយើងគ្រាន់តែត្រូវការមានសុខភាពល្អ ឬក៏ការមានលុយកាក់ជាច្រើនក្នុងកុងធនាគារ នោះយើងមិនចាំបាច់ត្រូវមានព្រះសង្គ្រោះទេ។ ជារឿយៗ គ្រូៗអាចបង្រៀនច្បាប់រស់នៅដ៏ល្អស្អាតស្អំ និងរបៀបរកស៊ីបាន ហើយតាមរយៈការផ្តល់ប្រឹក្សា អ្នកដែលទទួលបានចំណេះដឹងអាចនឹងគេចចេញពីជំងឺ ហើយអ្នកក្រអាចក្លាយជាអ្នកមាន។ តើលោកអ្នកគិតថា ភាពក្រីក្រ និងការឈឺថ្កាត់តម្រូវឲ្យមានបេសកកម្មជួយសង្គ្រោះដែលត្រូវមានយញ្ញបូជាពីព្រះរាជបុត្រារបស់ព្រះជាម្ចាស់មែនឬ? ទេ! យើងត្រូវការការចុះថ្លែងអន្តរាគមន៍ពីព្រះអង្គសង្គ្រោះ ព្រោះបើគ្មានការនោះទេ នោះយើងនឹងនៅស្លាប់យ៉ាងអស់កល្បជានិច្ចជាមិនខាន។

តើព្រះយេស៊ូវបានចុះថ្លែងអន្តរាគមន៍ ដើម្បីសង្គ្រោះយើងចេញពីកាលៈទេសៈដ៏គ្មានសង្ឃឹមនេះបានដោយរបៀបណា?

គឺតាមរយៈជីវិតដែលគ្មានបាប ការសុគតលើឈើឆ្កាងជំនួសយើង និងការមានជ័យជម្នះលើសេចក្តីស្លាប់ដោយមានព្រះជន្មរស់ឡើងវិញ។ នេះឯងជាភាពឧត្តុង្គឧត្តមរបស់ដំណឹងល្អនៃជំនឿរបស់គ្រីស្ទបរិស័ទ។ «ដ្បិតកាលយើងនៅខ្សោយនៅឡើយ លុះដល់កំណត់ហើយ នោះព្រះគ្រីស្ទទ្រង់បានសុគតជំនួសមនុស្សទមិឡល្មើស» (រ៉ូម ៥:៦)។ ព្រះយេស៊ូវ ដែលជាព្រះរាជបុត្រារបស់ព្រះជាម្ចាស់ បានយាងមកកាន់លោកីយ៍នេះដោយគ្មានបាបទាល់តែសោះ ហើយព្រះអង្គក៏បានស្តាប់បង្គាប់ព្រះវរបិតាយ៉ាងល្អឥតខ្ចោះផងដែរ។ សេចក្តីស្លាប់គ្មានអំណាចលើទ្រង់ឡើយ។ ប៉ុន្តែ បន្ទាប់មកព្រះអង្គបានទទួលយកបំណុលកម្មរបស់យើងដាក់លើទ្រង់ផ្ទាល់ បានយកពិរុទ្ធភាពរបស់យើង ហើយសុគតជំនួសយើងនៅលើឈើឆ្កាង។ នោះព្រះគម្ពីរបានលើកឡើងថា «ដ្បិតឯព្រះអង្គដែលមិនបានស្គាល់បាបសោះ នោះព្រះទ្រង់បានធ្វើឲ្យត្រឡប់ជាតួបាប ជំនួសយើងរាល់គ្នាវិញ ដើម្បីឲ្យយើងរាល់គ្នាបានត្រឡប់ទៅជាសេចក្តីសុចរិតរបស់ព្រះដោយនូវព្រះអង្គនោះឯង» (២កូរិនថូស ៥:២១)។ ដើម្បីបង្ហាញថាព្រះជាម្ចាស់ស្កប់ព្រះទ័យយ៉ាងពេញទីចំពោះការសុគតរបស់ព្រះគ្រីស្ទជំនួសយើង បីថ្ងៃក្រោយមក ទ្រង់បានប្រោសព្រះយេស៊ូវឲ្យរស់ពី

សុគតឡើងវិញ។ ដូច្នេះ ចំពោះអស់អ្នកដែលទទួលជឿលើព្រះយេស៊ូវ ទោះបើពួកគាត់ស្លាប់ក៏ដោយ ក៏ពួកគាត់នឹងរស់ឡើងវិញ ហើយនឹងទៅនៅជាមួយព្រះជាម្ចាស់យ៉ាងអស់កល្បជានិច្ចដែរ។ បំណុលរបស់ពួកគាត់ត្រូវបានបង់ថ្លៃដាច់ដោយការសុគតរបស់ព្រះគ្រីស្ទនៅលើឈើឆ្កាង។

ប៉ុន្តែ ព្រះជាម្ចាស់មិនបានបញ្ចប់បេសកកម្មរបស់ទ្រង់នៅត្រឹមនេះទេ។ ពេលដែលព្រះយេស៊ូវបានមានព្រះជន្មរស់ពីសុគតឡើងវិញ ព្រះអង្គបានយាងទៅកាន់ព្រះវរបិតានៅឯស្ថានសួគ៌ ហើយក៏បានចាត់ព្រះវិញ្ញាណបរិសុទ្ធឲ្យមកធ្វើជាអ្នកជំនួយ និងជាទីប្រឹក្សាដល់រាស្ត្ររបស់ទ្រង់។ ព្រះវិញ្ញាណបរិសុទ្ធយាងចូលទៅកាន់ដួងចិត្តរបស់យើង ហើយនាំឲ្យយើងមានជីវិតខាងឯវិញ្ញាណ ផ្តល់នូវការប្រកបគ្នាជាមួយនឹងព្រះជាម្ចាស់ ហើយប្រទានអំណាចដល់យើងក្នុងការបដិសេធខ្លួនឯង ហើយឲ្យស្រឡាញ់អ្នកដទៃ និងស្រឡាញ់ព្រះជាម្ចាស់ ក៏ដូចជាស្តាប់តាមបង្គាប់ទ្រង់ផងដែរ។

ហេតុដូច្នេះហើយបានជាដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទគឺជា «ព្រះចេស្តានៃព្រះសម្រាប់នឹងជួយសង្គ្រោះដល់អស់អ្នកណាដែលជឿ» (រ៉ូម ១:១៦)។ ដំណឹងល្អនេះបំផ្លាស់បំប្រែជីវិតយើងមិនមែនចេញពីក្រៅចូលក្នុងដូចដែលគ្រូៗខុសឆ្គងអះអាងនោះ

ឡើយ ប៉ុន្តែពីក្នុងចេញក្រៅ ដើម្បីត្រៀមពួកគាត់សម្រាប់ជីវិតដ៏នៅអស់កល្បជានិច្ចក្នុងព្រះវត្តមានរបស់ព្រះជាម្ចាស់។ សាវ័កប៉ុល មានការភ្ញាក់ផ្អើលយ៉ាងខ្លាំងនឹងការបំផ្លាស់បំប្រែបែបនេះក្នុងក្រុមជំនុំអ្នកជឿនៅឯទីក្រុងកូរិនថូស។ «តើមិនដឹងថា ពួកមនុស្សទុច្ចរិតមិនដែលបានគ្រងនគរព្រះទុកជាមរតកទេឬអី កុំឲ្យច្រឡំឡើយ ដ្បិតពួកមនុស្សកំផិត ពួកថ្វាយបង្គំរូបព្រះ ពួកសហាយស្មន់ ពួកអ្នកសម្រេចកិច្ចដោយខ្លួនឯង ពួកលេងកូនជឹង ពួកចោរ ពួកមនុស្សលោភ ពួកប្រមឹក ពួកត្មះតិះដៀល នឹងពួកប្លន់កំហែង នោះមិនដែលបានគ្រងនគរព្រះទុកជាមរតកឡើយ» (១កូរិនថូស ៦:៩-១០)។ មកដល់ខគម្ពីរនេះ ស្តាប់ទៅហាក់បីដូចជាដំណឹងដ៏អាក្រក់ណាស់ ប៉ុន្តែវាជាដំណឹងដ៏ល្អបំផុត៖ «ឯពួកអ្នករាល់គ្នាខ្លះ ពីដើមក៏ជាមនុស្សយ៉ាងដូច្នោះដែរ តែបានលាងស្អាតហើយ ក៏បានញែកជាបរិសុទ្ធ ហើយរាប់ជាសុចរិតផង ដោយនូវព្រះនាមព្រះអម្ចាស់យេស៊ូវ និងព្រះវិញ្ញាណរបស់ព្រះនៃយើងរាល់គ្នា» (១កូរិនថូស ៦:១១)។

នេះគឺជាដំណឹងល្អ ដែលស័ក្តិសមនឹងទទួលយកបានយ៉ាងពេញទី។ នេះឯងជាចំណុចដែលធ្វើឲ្យជំនឿគ្រីស្ទបរិស័ទជាជំនឿដែលមិនអាចបញ្ឈប់ចលនានៃបេសកកម្មបានឡើយ។ យើង

មានដំណឹងដ៏ល្អបំផុតក្នុងចក្រវាលនេះ៖ «ព្រះគ្រីស្ទយេស៊ូវទ្រង់បានយាងមកក្នុងលោកីយ៍ ដើម្បីនឹងជួយសង្គ្រោះមនុស្សមានបាប» (១ធីម៉ូថេ ១:១៥)។ ព្រះជាម្ចាស់ផ្ទាល់បានយាងមកដើម្បីសង្គ្រោះយើង។ ដូច្នេះ វាមិនសំខាន់ទេត្រង់ថាលោកអ្នកកំពុងជាប់ជាទាសករនៃអំពើបាបដ៏ខ្លាំងប៉ុណ្ណានោះទេ។ បើលោកអ្នកទទួលស្គាល់ថាខ្លួនគ្មានសង្ឃឹមទេក្នុងកាលៈទេសៈនេះ ហើយអំពាវនាវទៅកាន់ព្រះយេស៊ូវគ្រីស្ទ សូមឲ្យទ្រង់សង្គ្រោះលោកអ្នកនោះព្រះអង្គនឹងសង្គ្រោះលោកអ្នកជាមិនខាន។ ព្រះអង្គនឹងលាងសម្អាតអំពើបាបរបស់លោកអ្នកចោល ហើយក៏នឹងបំផ្លាស់បំប្រែដួងចិត្ត ដើម្បីឲ្យលោកអ្នកចាប់ផ្ដើមរស់នៅក្នុងបែបជីវិតដែលលោកអ្នកមិនធ្លាប់មានលទ្ធភាពរស់នៅពីមុនមក។ ហេតុដូច្នេះលោកអ្នកអាចសម្លឹងមើលទៅឯសេចក្ដីស្លាប់ចំនឹងមុខ ដោយមិនភ័យខ្លាច ពីព្រោះទ្រនិចនៃសេចក្ដីស្លាប់ត្រូវបានដកចេញហើយក្នុងការសុគតរបស់ព្រះយេស៊ូវដែលជាព្រះសង្គ្រោះរបស់លោកអ្នក។ ឥឡូវនេះ អ្វីដែលសេចក្ដីស្លាប់អាចធ្វើបានគឺនាំយកលោកអ្នកឲ្យទៅរស់នៅជាមួយនឹងទ្រង់នៅឯស្ថានសួគ៌។ សរុបសេចក្ដីទៅ នេះប្រៀបដូចជាបុគ្គលម្នាក់ដែលត្រូវបានគេបំបរបង់ចោលនៅលើកោះ បន្ទាប់មកបានឃើញឧទ្ធម្ភាគចក្រហោះលើ

ក្បាលគាត់ ចូរអំពាវនាវទៅកាន់ព្រះយេស៊ូវគ្រីស្ទ ហើយអនុ-ញ្ញាតឲ្យទ្រង់ជួយសង្គ្រោះលោកអ្នកចេញពីសេចក្តីស្លាប់។ ព្រះអង្គអាចធ្វើការនេះបាននៅថ្ងៃនេះ!

## ជំពូក៦៖

# ព្រះពរនៃដំណឹងល្អដ៏ពិត

Michael Otieno Maura

*«ដូច្នេះ ដែលយើងរាល់គ្នាបានរាប់ជាសុចរិត ដោយការជឿ នោះឈ្មោះថាយើងបានមេត្រីនឹងព្រះ ដោយសារព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នាហើយ ក៏ដោយសារទ្រង់ យើងមានផ្លូវចូលក្នុងព្រះគុណនេះ ជាទីដែលយើងកំពុងឈរនៅដោយជំនឿ ហើយយើងអួតពីសេចក្តីសង្ឃឹមដល់សិរីល្អនៃព្រះផង មិនតែប៉ុណ្ណោះសោត យើងនៅតែអួតក្នុងកាលដែលមានទុក្ខលំបាកដែរ ដោយដឹងថា សេចក្តីទុក្ខលំបាកបង្កើតឲ្យមានសេចក្តីទ្រាំទ្រ សេចក្តីទ្រាំទ្របង្កើតឲ្យមានសេចក្តីសាំុថ្មឹក សេចក្តីសាំុថ្មឹកបង្កើតឲ្យមានសេចក្តីសង្ឃឹម ឯសេចក្តីសង្ឃឹមក៏មិនដែលនាំឲ្យមានសេចក្តីខ្មាសឡើយ ពីព្រោះសេចក្តីស្រឡាញ់របស់ព្រះ បានផ្សាយមកសព្វក្នុងចិត្តយើងរាល់គ្នា ដោយសារព្រះវិញ្ញាណបរិសុទ្ធ ដែលព្រះបានប្រទានមកយើងហើយ»។ (រ៉ូម ៥:១-៥)*

មានចំណុចមួយចំនួនដែលមិនគួរចាកឆ្ងាយពីគំនិតរបស់គ្រីស្ទបរិស័ទ។ ចំណុចមួយក្នុងចំណោមចំណុចនានាគឺ ព្រះពរនៃដំណឹងល្អ។ នេះគឺជាប្រធានបទដ៏អស្ចារ្យមួយមែន! ចំណុចនេះជំរុញចិត្តយើង លើកទឹកចិត្តយើង បន្ទាបខ្លួនយើង ហើយជួយឲ្យយើងមានការយល់ដឹងដ៏ត្រឹមត្រូវទាក់ទងនឹងបទពិសោធន៍ក្នុងជីវិត។ ការចងចាំអំពីព្រះពរដែលយើងមានក្នុងព្រះជាម្ចាស់នឹងជួយឲ្យយើងមានទស្សនៈដ៏ត្រឹមត្រូវអំពីទ្រង់។ វាបានផ្តល់កម្លាំងចិត្តដល់យើងក្នុងការរស់នៅសម្រាប់សិរីល្អ និងព្រះកិត្តិយសរបស់ព្រះជាម្ចាស់ក្នុងជីវិតនេះ។ ប៉ុន្តែ ក្នុងប្រទេសយើងសព្វថ្ងៃនេះ អ្នកខ្លះមិនមានគំនិតត្រឹមត្រូវទេទាក់ទងនឹងព្រះពរ។

ខ្ញុំបានអធិប្បាយជាច្រើនឆ្នាំនៅភូមិ ម៉ាសៃ (Massai)។ ហើយឥឡូវនេះ ខ្ញុំបានមកអធិប្បាយនៅទីក្រុង ណៃរ៉ូប៊ី (Nairobi)។ មានមនុស្សជាច្រើនប្រាប់ខ្ញុំថា ខ្ញុំពិតជាមានពរមែន ព្រោះខ្ញុំបានរើចេញពីតំបន់ជនបទមកនៅទីក្រុងធំ។ មានគ្រីស្ទបរិស័ទជាច្រើនដែលយល់ដឹងយ៉ាងខុសឆ្គងបែបនេះទាក់ទងនឹងព្រះពរ ព្រោះពួកគាត់ផ្តោតចិត្តគំនិតលើអត្ថប្រយោជន៍បែបលោកីយ៍ និងភាពអរសប្បាយដែលមិននៅគង់វង្ស។ ព្រះជាម្ចាស់ជ្រាបពីដួងចិត្តរបស់យើង ហើយក៏បានព្រមាន និងកែតម្រង់យើងអំពី

ចំណុចខុសឆ្គងនេះក្នុងព្រះគម្ពីរផងដែរ។

សាវ័ក ប៉ុល បានសរសេរទៅកាន់គ្រីស្ទបរិស័ទដែលរស់នៅក្នុងចំណោមទីក្រុងមួយដ៏អស្ចារ្យ ហើយមានអំណាចយ៉ាងខ្លាំងនៅសម័យបុរាណ—គឺទីក្រុងរ៉ូម។ នៅជុំវិញពួកគាត់ ពួកគាត់បានឃើញអ្នកដទៃសរសើរនិងអួតពីទ្រព្យសម្បត្តិ អំណាច និងឋានៈរបស់ខ្លួន។ ប៉ុន្តែសាវ័ក ប៉ុល គ្មានចំណាប់អារម្មណ៍លើចំណុចទាំងនោះទេ។ គាត់ផ្តោតលើដំណឹងល្អ។ ក្នុងកណ្ឌគម្ពីរ រ៉ូម ១:១៦ គាត់បានពណ៌នាអំពីដំណឹងល្អថា ដំណឹងល្អ៖ «ជាព្រះចេស្តានៃព្រះសម្រាប់នឹងជួយសង្គ្រោះដល់អស់អ្នកណាដែលជឿ»។ ហើយមិនគ្រាន់តែប៉ុណ្ណោះនោះទេ «ដ្បិតសេចក្តីសុចរិតនៃព្រះបានសម្តែងមកក្នុងដំណឹងល្អនោះ...ដូចមានសេចក្តីចែងទុកមកថា "មនុស្សសុចរិតនឹងរស់នៅ ដោយអាងជំនឿ"» (រ៉ូម ១:១៧)។

ប៉ុន្តែ ដើម្បីឲ្យយើងយល់អំពីអំណាច និងព្រះគុណនៃដំណឹងល្អ ដាច់ខាតយើងត្រូវតែទទួលស្គាល់កាលៈទេសៈដ៏ពិតរបស់យើង។ ដូច្នេះហើយបានជានៅក្នុងខ៨ សាវ័ក ប៉ុល បានប្រកាសថា «សេចក្តីក្រោធរបស់ព្រះបានសម្តែងមកពីស្ថានសួគ៌ទាស់នឹងគ្រប់ទាំងសេចក្តីទមិឡល្មើស និងសេចក្តីទុច្ចរិតរបស់មនុស្ស» (រ៉ូម ១:១៨)។ ព័ត៌មាននេះទាក់ទងនឹងយើងទាំងអស់

គ្នា ពីព្រោះក្នុងកណ្ឌគម្ពីររ៉ូមជំពូក២ សាវ័ក ប៉ុល បានលើកឡើងយ៉ាងច្បាស់លាស់ថា*លោកីយ៍ទាំងមូល*មានទោសនៅចំពោះព្រះភក្ត្រព្រះជាម្ចាស់។

ដំណឹងអាក្រក់ជួយយើងក្នុងការត្រៀមខ្លួន ដើម្បីទទួលយកដំណឹងល្អ។ ក្នុងកណ្ឌគម្ពីររ៉ូមជំពូក៣ ចាប់ពីខ២១ យើងអាចមើលឃើញពីចំណុចដ៏អស្ចារ្យនៃការរាប់ជាសុចរិតតាមរយៈជំនឿ គឺថាយើងមិនអាចមានទំនាក់ទំនងដ៏ត្រឹមត្រូវតាមរយៈអ្វីដែលយើងធ្វើនោះទេ ប៉ុន្តែ យើងអាចមានទំនាក់ទំនងដ៏ត្រឹមត្រូវជាមួយនឹងព្រះជាម្ចាស់វិញតាមតែរយៈជំនឿក្នុងព្រះអម្ចាស់យេស៊ូវគ្រីស្ទមួយអង្គគត់ប៉ុណ្ណោះ។

នេះមិនមែនជាគំនិតថ្មីនោះទេ។ ក្នុងកណ្ឌគម្ពីររ៉ូមជំពូក៤ យើងឃើញមានគំរូអំពីមនុស្សពីរនាក់ដែលទទួលបានការរាប់ជាសុចរិត គឺមានទំនាក់ទំនងជាមួយនឹងព្រះជាម្ចាស់តាមរយៈជំនឿក្នុងទ្រង់។ ទាំងលោក អ័ប្រាហាំ និងស្តេច ដាវីឌ គឺទទួលបានការរាប់ជាសុចរិតតាមរយៈជំនឿតែមួយគត់។ នេះគឺជារបៀបដែលព្រះជាម្ចាស់តែងតែធ្វើការ។

ពេលដែលសាវ័ក ប៉ុល សរសេរកណ្ឌគម្ពីររ៉ូមជំពូក៥ គាត់បានចាប់ផ្តើមដោយប្រើពាក្យ «*ដូច្នេះ*» ព្រោះគាត់មិនចង់ឲ្យ

យើងមើលរំលងនូវអ្វីដែលគាត់កំពុងបង្រៀន។ បន្ទាប់ពីគាត់បានរៀបរាប់អំពីជំនឿរបស់លោក អ័ប្រាហាំ សាវ័ក ប៉ុល បានបន្តសរសេរថា «*ដូច្នេះ* ដែលយើងរាល់គ្នាបានរាប់ជាសុចរិត ដោយការជឿ នោះឈ្មោះថាយើងបានមេត្រីនឹងព្រះ ដោយសារព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នាហើយ» (រ៉ូម ៥:១)។ សាវ័ក ប៉ុល ចង់ឲ្យយើងឃើញថានេះជារបៀបដែលព្រះជាម្ចាស់*សង្គ្រោះ*។ ការរាប់ជាសុចរិតដោយជំនឿគឺជាសេចក្ដីបង្រៀនដែលមានចែងក្នុងព្រះគម្ពីរ។

ដូច្នេះ សូមអនុញ្ញាតឲ្យខ្ញុំពន្យល់ឲ្យបានច្បាស់ថា តើការរាប់ជាសុចរិតដោយជំនឿមានន័យយ៉ាងដូចម្ដេច។ ការរាប់ជាសុច-រិតដោយជំនឿគឺជាសកម្មភាពនៃព្រះគុណដ៏ឥតគិតថ្លៃពីព្រះជាម្ចាស់។ ព្រះជាម្ចាស់បានចាប់ផ្ដើមដោយអង្គទ្រង់ផ្ទាល់ក្នុងការអត់ទោស និងអភ័យទោសនូវរាល់អំពើបាបរបស់យើង ហើយប្រកាសថាយើងសុចរិតក្នុងព្រះនេត្ររបស់ទ្រង់ដោយសារសេចក្ដីសុចរិតរបស់ព្រះគ្រីស្ទដែលទ្រង់បានដាក់លើយើង។ ហើយយើងអាចទទួលបានអំណោយទាននេះបានតាមតែរយៈជំនឿក្នុងព័ន្ធកិច្ចដែលព្រះអម្ចាស់យេស៊ូវគ្រីស្ទបានសម្រេចតែមួយគត់។ នេះឯងគឺជាការរាប់ជាសុចរិតដោយជំនឿ។

មនុស្សយើងពិតជាមានការដ៏ពិបាកណាស់ក្នុងការទទួលស្គាល់ថា ខ្លួនមិនមែនជាអ្នកគ្រប់គ្រងលើជីវិតខ្លួនឯងផ្ទាល់។ បុគ្គលគ្រប់ៗរូបតែងតែចង់ជឿថាខ្លួនជាវីរបុរសក្នុងដំណើររឿងខ្លួន។ ប៉ុន្តែ ព្រះជាម្ចាស់ប្រទានការរាប់ជាសុចរិតដោយឥតគិតថ្លៃ យើងមិនអាចធ្វើអ្វីមួយ ដើម្បីទទួលបានភាពសុចរិតបានឡើយ។ ចូរនឹកចាំពីចំណុចដែលលោកគ្រូ ម៉ាទីន លូសើរ (Martin Luther) បានរកឃើញម្ដងទៀត ពេលដែលគាត់អានកណ្ឌគម្ពីរ រ៉ូម១:១៧ «មនុស្សសុចរិតនឹងរស់នៅ ដោយអាងជំនឿ»។ ការរកឃើញមួយនេះបានបំផ្លាស់បំប្រែជីវិតគាត់។ ព្រះវិញ្ញាណបរិសុទ្ធបានបើកសម្ដែងឲ្យចិត្តគំនិតគាត់ឃើញ ហើយភ្លាមៗនោះគាត់ដែលជាអ្នកខំយ៉ាងស្វះស្វែងក្នុងការទទួលបានសេចក្ដីសង្គ្រោះក៏បានយល់ឃើញថា ការរាប់ជាសុចរិតគឺដោយសារជំនឿ។

តើយើងកំពុងអធិប្បាយសេចក្ដីពិតនេះដែរឬទេ? តើយើងទទួលបានសេរីភាពតាមរយៈសារដែលថាយើងបានជាសុចរិតដោយជំនឿ ឬក៏យើងនៅគិតថា យើងអាចទទួលបានការរាប់ជាសុចរិតតាមរយៈអ្វីមួយដែលយើងធ្វើនៅឡើយ? តើយើងឱបក្រសោបការរាប់ជាសុចរិតដោយជំនឿយ៉ាងអស់ពីចិត្ត និងកម្លាំងយើងហើយឬនៅ? យើងត្រូវការមនុស្សដែលហ៊ានចេញ

ទៅ ហើយប្រកាសប្រាប់លោកីយ៍នេះឲ្យដឹងថា ព្រះជាម្ចាស់រាប់នរណាម្នាក់ជាសុចរិតតាមរយៈជំនឿ។

## ព្រះពរទី១៖ មេត្រីភាពជាមួយនឹងព្រះជាម្ចាស់

បន្ទាប់ពីសាវ័ក ប៉ុល បានពន្យល់ការរាប់ជាសុចរិតដោយសារជំនឿ នោះគាត់បានបង្រៀនអំពីអត្ថប្រយោជន៍ និងព្រះពរដែលការរាប់ជាសុចរិតផ្តល់ជូនទៅកាន់ក្រុមជំនុំរ៉ូម។ ជំពូកនេះនឹងរៀបរាប់អំពីព្រះពរនានានៃដំណឹងល្អដែលការរាប់ជាសុច-រិតដោយជំនឿនាំមកជូន។ ក្នុងខដំបូងនៃកណ្ឌគម្ពីររ៉ូមជំពូក៥ យើងអាចឃើញពីព្រះពរទី១៖ «ដូច្នេះ ដែលយើងរាល់គ្នាបានរាប់ជាសុចរិត ដោយការជឿ នោះឈ្មោះថាយើងបាន*មេត្រីនឹង*ព្រះដោយសារព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នាហើយ»។

ចូរនឹកចាំអំពីចំណុចដែលយើងបានឃើញក្នុងកណ្ឌគម្ពីរ រ៉ូម ១:១៨ ត្រង់ចំណុចថាលោកីយ៍ទាំងមូលមានពេញទៅដោយពិរុទ្ធភាព។ មានតែព្រះជាម្ចាស់មួយអង្គគត់ទើបអាចដោះស្រាយបញ្ហានេះបាន។ «តែឯព្រះ ទ្រង់សម្តែងសេចក្តីស្រឡាញ់របស់ទ្រង់ដល់យើងរាល់គ្នាឲ្យឃើញច្បាស់ ដោយព្រះគ្រីស្ទបានសុគត

ជំនួសយើងរាល់គ្នា នោះគឺក្នុងកាលដែលយើងនៅមានបាបនៅឡើយផង» (រ៉ូម ៥:៨)។ នេះគឺជាអំណាច និងគោលបំណងនៃការសុគតរបស់ព្រះគ្រីស្ទ៖ «ដ្បិតកាលយើងជាខ្មាំងសត្រូវ...យើងបានជាមេត្រីនឹងព្រះវិញទៅហើយ» (រ៉ូម ៥:១០)។ សាវ័ក ប៉ុលមិនមែនគ្រាន់តែកំពុងលើកឡើងជាគោលអំពីសន្តិភាពដែលមាននៅខាងក្នុង ដែលជាបទពិសោធន៍ ឬក៏អារម្មណ៍ប៉ុណ្ណោះនោះទេ។ ប៉ុន្តែ សន្តិភាពនេះគឺអំពីទំនាក់ទំនងដ៏បាក់បែកជាមួយនឹងព្រះជាម្ចាស់ដែលទ្រង់បានផ្សះផ្សាឡើងវិញទេតើ។

មនុស្សមានបាបគឺជាខ្មាំងសត្រូវរបស់ព្រះជាម្ចាស់។ បើគ្មានជំនឿក្នុងព្រះយេស៊ូវគ្រីស្ទទេ នោះយើងនៅតែកំពុងធ្វើសង្គ្រាមទាស់នឹងព្រះជាម្ចាស់នៅឡើយ។ ហេតុអ្វី? ព្រះជាម្ចាស់គឺបរិសុទ្ធហើយសុចរិត ប៉ុន្តែយើងបានបដិសេធសេចក្ដីសុចរិតរបស់ទ្រង់។ ព្រះជាម្ចាស់មានភាពឧដុង្គឧត្ដមខ្ពស់លើសអ្វីៗទាំងអស់ ហើយទ្រង់គង់ក្នុងភាពបរិសុទ្ធ ប៉ុន្តែយើងបានជ្រើសរើសទាស់ប្រឆាំងនឹងភាពបរិសុទ្ធរបស់ទ្រង់ដោយផ្ដោតលើភាពអាត្មានិយមនៃអំពើបាបផ្ទាល់ខ្លួន។ ការផ្ដោតលើភាពអាត្មានិយមរបស់យើងនឹងមិនអាចនាំយើងទៅកាន់ស្ថានសួគ៌បានទេ ពីព្រោះព្រះជាម្ចាស់មិនតម្រូវអ្វីក្រៅពីសេចក្ដីសុចរិតឡើយ។ ហើយគ្មាននរណាម្នាក់ក្នុង

ចំណោមយើងដែលសុចរិតទេ (រ៉ូម ៣:៩-១៨, ២៣)។

ដូច្នេះ ការរាប់ជាសុចរិតនេះ យើងត្រូវការ ដើម្បីឲ្យយើងអាចនឹងមានមេត្រីភាពជាមួយនឹងព្រះជាម្ចាស់បាន។ យើងទាំងអស់គ្នាមានពេញទៅដោយអំពើបាបដោយសារភាពជាមនុស្សរបស់យើងបានប្រែប្រួលចេញពីលក្ខណៈត្រឹមត្រូវ។ អំពើបាបរបស់លោក អ័ដាម ក៏បានធ្លាក់មកលើយើងផងដែរ យើងគឺជាកូនចៅរបស់គាត់ ដែលមិនបានស្តាប់បង្គាប់ព្រះជាម្ចាស់ ហើយក៏បាននាំចូលមកនូវអំពើបាបមកកាន់មនុស្សលោកយើងផងដែរ។ ហេតុដូច្នេះហើយបានជាយើងធ្វើសង្គ្រាមទាស់នឹងព្រះអង្គចាប់តាំងពីកំណើតមកម្ល៉េះ។ ទ្រង់បរិសុទ្ធ ហើយក៏តម្រូវឲ្យមានភាពបរិសុទ្ធដែរ ប៉ុន្តែយើងទេដែលខ្វះនូវភាពបរិសុទ្ធនោះ។

បើយើងវិភាគដោយស្មោះត្រង់ទៅ នោះយើងនឹងសន្មតថានិស្ស័យរបស់យើងគឺពុករលួយ។ អារម្មណ៍ ការយល់ដឹង ពាក្យពេចន៍ និងទង្វើរបស់យើងសុទ្ធតែជាចំណុចដែលខណ្ឌយើងចេញពីព្រះជាម្ចាស់។ យើងមិនអាចមានទំនាក់ទំនងដ៏ល្អជាមួយនឹងព្រះជាម្ចាស់ដោយចេញពីការខិតខំដោយខ្លួនឯងនោះឡើយ។ យើងមិនគ្រាន់តែមានអំពើបាបដោយសារលោក អ័ដាម ប៉ុណ្ណោះទេ តែយើងក៏បានប្រព្រឹត្តបាបដោយខ្លួនឯងផ្ទាល់ដែរ ហើយមាន

បំណងប្រាថ្នាចង់បានអំពើបាបទៀតផង។ ហើយព្រះជាម្ចាស់ប្រឆាំងនឹងមនុស្សមានបាប ពីព្រោះទ្រង់គឺជាព្រះដ៏សុចរិត។

ដូច្នេះ តើលោកអ្នកយល់ហើយឬនៅត្រង់ថា ការមានមេត្រីភាពជាមួយនឹងព្រះជាម្ចាស់គឺជាព្រះពរដ៏អស្ចារ្យ? ចំណុចនេះគួរធ្វើឲ្យយើងរំភើបដែលថាមនុស្សមានបាបត្រូវបានថ្កោលទោសគ្មានសង្ឃឹម ហើយសមនឹងទទួលការកាត់ទោសដោយយុត្តិធម៌ ប៉ុន្តែឥឡូវនេះ អាចមានមេត្រីភាពជាមួយនឹងព្រះជាម្ចាស់បាន។ បើព្រះជាម្ចាស់បានរាប់លោកអ្នកជាសុចរិតដោយសារជំនឿ នោះមានន័យថា លោកអ្នកមានការផ្សះផ្សាវិញជាមួយនឹងទ្រង់ ហើយលោកអ្នកស្ថិតក្រោមចំណុចនៃសន្តិភាពជាមួយនឹងព្រះអាទិកររបស់ខ្លួនហើយ។ នេះគឺជាអ្វីដែលយើងគួរតែលើកឡើងជារៀងរាល់ថ្ងៃអាទិត្យ៖ មនុស្សយើងអាចមានមេត្រីភាពជាមួយនឹងព្រះជាម្ចាស់បាន។ គ្រីស្ទបរិស័ទលែងស្ថិតក្នុងសណ្ឋាននៃការធ្វើសង្គ្រាមទាស់នឹងព្រះជាម្ចាស់ទៀតហើយ។ ឥឡូវនេះ យើងនៅខាងព្រះជាម្ចាស់វិញ។

តើផលកម្មនៃការមានមេត្រីភាពជាមួយនឹងព្រះជាម្ចាស់នឹងប៉ះពាល់ជីវិតយើងយ៉ាងដូចម្តេចទៅ? ទីមួយ យើងមិនចាំបាច់មានមន្ទិលសង្ស័យអំពីទំនាក់ទំនងរបស់យើងជាមួយនឹងព្រះ

ជាម្ចាស់ទៀតឡើយ។ ទារុណកម្មដែលត្រូវធ្លាក់មកលើយើង បានធ្លាក់ទៅលើអ្នកដែលជំនួសយើងនៅលើឈើឆ្កាងនៃភ្នំកាល់វ៉ារីរួចហើយ។ ហើយសេចក្តីសុចរិតរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទបានយកមកដាក់លើយើង។ ពេលដែលព្រះជាម្ចាស់ទតមើលយើង ទ្រង់លែងឃើញយើងទៀតហើយ តែទ្រង់ឃើញសេចក្តីសុចរិតរបស់ព្រះរាជបុត្រាទ្រង់ ហើយយើងក៏សុចរិតក្នុងព្រះនេត្រទ្រង់ផងដែរ។

ខ្ញុំមានកូនស្រីម្នាក់ដែលឥឡូវគាត់កំពុងរៀននៅសាលាបឋមសិក្សា។ ពេលដែលខ្ញុំបានវិក្កយបត្របង់លុយ នោះខ្ញុំនឹងទៅសាលាគាត់ ហើយខ្ញុំបង់លុយឲ្យនាយកសាលា។ ដូច្នេះ ពេលដែលមាននរណាម្នាក់សួរក្នុងថ្នាក់ថា មាននរណាខ្លះបានបង់លុយហើយ នោះកូនស្រីខ្ញុំនឹងលើកដៃ ទោះបើគាត់មិនបានឲ្យលុយនោះក៏ដោយ។ លុយនោះជាលុយរបស់ខ្ញុំ ប៉ុន្តែគេបានរាប់នាងថាបានបង់លុយហើយ។ នេះឯងគឺជាអ្វីដែលព្រះជាម្ចាស់បានប្រព្រឹត្តសម្រាប់យើងក្នុងព្រះគ្រីស្ទ។ ដូច្នេះ ពេលដែលអារក្សសាតាំងរម្លឹកយើងអំពីអំពើបាបរបស់យើង ហើយធ្វើឲ្យយើងមានមន្ទិលសង្ស័យនឹងទំនាក់ទំនងរបស់យើងជាមួយព្រះជាម្ចាស់ ឥឡូវយើងមានចម្លើយ។ យើងទទួលបានសេចក្តីសុចរិតរបស់

ព្រះជាម្ចាស់បានតាមរយៈព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ យើងមាន
សន្តិភាពជាមួយទ្រង់បានតាមរយៈព្រះយេស៊ូវ។

ដូច្នេះ មេត្រីភាពដែលព្រះយេស៊ូវគ្រីស្ទបាននាំមករវាងយើង
និងព្រះជាម្ចាស់ ក៏បាននាំសន្តិភាពមកកាន់ក្នុងចិត្តរបស់យើង
ផងដែរ។ សតិសម្បជញ្ញៈលែងខណ្ឌយើងចេញពីព្រះជាម្ចាស់
ទៀតហើយ។ ពេលដែលយើងទទួលបានការរាប់ជាសុចរិត
ហើយសេចក្តីសុចរិតរបស់ព្រះគ្រីស្ទបានដាក់លើយើង នោះ
សតិសម្បជញ្ញៈរបស់យើងលែងថ្កោលទោសយើងទៀតហើយ។
សេចក្តីយុត្តិធម៌របស់ព្រះជាម្ចាស់បានស្កប់ស្កល់ក្នុងការសុគត
របស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទជំនួសយើង។ សាតាំងអាចចោទ
យើងបាន ប៉ុន្តែវាមិនអាចថ្កោលទោសយើងទៀតទេ ព្រោះព្រះ
ជាម្ចាស់ផ្ទាល់បានរាប់យើងជាសុចរិតហើយ។

តើយើងកំពុងបង្រៀនសេចក្តីពិតនេះដែរឬទេ? ខ្ញុំចាំអំពីបុរស
វ័យជំទង់ម្នាក់ដែលបានមករកខ្ញុំប៉ុន្មានឆ្នាំមុន ហើយប្រាប់ខ្ញុំថា
«លោកគ្រូ! ខ្ញុំបានភ្លាត់ស្នៀតម្តងទៀតយប់មិញ។» ហើយខ្ញុំបាន
សួរគាត់ថា «ហេតុអ្វី?»។ គាត់បានប្រាប់ខ្ញុំថា «ខ្ញុំបានយល់សប្តិ
ថាខ្ញុំស្រវឹង ដូច្នេះឥឡូវនេះខ្ញុំបានបាត់បង់សេចក្តីសង្គ្រោះរបស់ខ្ញុំ
ហើយ។»។ ការនេះកើតឡើង ព្រោះយើងមិនបានបង្រៀនពីមូល

ដ្ឋាននៃសេចក្ដីពិតទាក់ទងនឹងសេចក្ដីសង្គ្រោះថា *វាមិនអាស្រ័យលើយើងឡើយ*។ ការរាប់ជាសុចរិតមិនអាស្រ័យលើអ្វីដែលយើងធ្វើនោះទេ វាអាស្រ័យលើអ្វីដែលព្រះអម្ចាស់យេស៊ូវគ្រីស្ទបានធ្វើ និងលើសេចក្ដីសុចរិតរបស់ទ្រង់។ មានមនុស្សជាច្រើនខ្វល់ខ្វាយអំពីសេចក្ដីសង្គ្រោះរបស់ខ្លួន ហើយពួកគាត់ត្រូវការឲ្យយើងចេញទៅ ហើយប្រាប់ពួកគាត់ថា ប្រសិនបើព្រះជាម្ចាស់រាប់ពួកគាត់ថាជាសុចរិតដោយជំនឿក្នុងព្រះគ្រីស្ទយេស៊ូវ នោះមានន័យថាពួកគាត់មានសន្តិភាពដ៏នៅអស់កល្បជានិច្ចជាមួយនឹងព្រះជាម្ចាស់ហើយ។ «ហេតុនោះ នៅជាន់នេះ អ្នកណាដែលនៅក្នុងព្រះគ្រីស្ទយេស៊ូវ នោះ*គ្មានទោសសោះ*» (រ៉ូម ៨:១)។

## ផ្លូវតែមួយគត់ទៅកាន់សន្តិភាពជាមួយនឹងព្រះជាម្ចាស់

នោះឯងជាព្រះពរទី១៖ «ដូច្នេះ ដែលយើងរាល់គ្នាបានរាប់ជាសុចរិត ដោយការជឿ នោះឈ្មោះថាយើងបាន*មេត្រីនឹងព្រះ* ដោយសារព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នាហើយ» (រ៉ូម ៥:១)។ មុនបន្តទៅលើព្រះពរបន្តបន្ទាប់ ខ្ញុំចង់ផ្តោតលើពាក្យ «*ដោយសារ*» ជាមុនសិន។

មានមនុស្សមួយចំនួនគិត ហើយប្រព្រឹត្តទង្វើហាក់បីដូចជា

ខ្លួនអាចមានមេត្រីភាពជាមួយព្រះជាម្ចាស់ក្នុងរបៀបណាមួយផ្សេងទៀតអញ្ចឹង។ ប៉ុន្តែ សាវ័ក ប៉ុល បានសរសេរយ៉ាងច្បាស់ថាមេត្រីភាពជាមួយនឹងព្រះជាម្ចាស់កើតឡើងបានតែ*ដោយសារ [ឬក៏តាមរយៈ] ព្រះយេស៊ូវគ្រីស្ទ*មួយប៉ុណ្ណោះ។ មានតែព្រះអង្គមួយគត់ដែលជាតួអង្គសម្របសម្រួលរវាងមនុស្ស និងព្រះជាម្ចាស់។ គ្មានផ្លូវណាផ្សេងទៀតទៅកាន់ព្រះពរនៃមេត្រីភាពដ៏អស្ចារ្យនេះជាមួយនឹងព្រះជាម្ចាស់ឡើយ។ វាត្រូវតែកើតឡើងតាមរយៈព្រះយេស៊ូវគ្រីស្ទ។

នៅតំបន់ខ្ញុំរស់នៅ យើងមានប៉ុស្តិ៍ប្រៃសណីយ៍ដ៏តូចមួយ។ ខ្ញុំនៅភូមិមួយដែលមានឈ្មោះថាអ៊ូហ្គានចា (Ugunja)។ ប្រសិនបើលោកអ្នកសរសេរសំបុត្រមកយើង លោកអ្នកត្រូវសរសេរដូចតទៅ៖ ប្រអប់សំបុត្រលេខ១៣ ភូមិអ៊ូហ្គានចា *តាមរយៈ*ទីក្រុងស៊ីយ៉ា (Siaya)។ ដើម្បីឲ្យសំបុត្រនោះមកដល់យើង គឺវាត្រូវឆ្លងកាត់តាមរយៈទីក្រុងស៊ីយ៉ាជាមុនសិន។ ហើយមេត្រីភាពនេះជាមួយនឹងព្រះជាម្ចាស់ គឺតាមរយៈព្រះយេស៊ូវគ្រីស្ទ។ គ្មានផ្លូវណាផ្សេងទៀតឡើយ។ គឺព្រះអម្ចាស់យេស៊ូវគ្រីស្ទទេតើដែលបានរស់នៅជីវិតយ៉ាងល្អឥតខ្ចោះ។ ហើយជីវិតដ៏ល្អឥតខ្ចោះនេះបានបំពេញក្រឹត្យវិន័យជំនួសយើង។ មានតែព្រះអម្ចាស់យេស៊ូវគ្រីស្ទ

មួយអង្គគត់ដែលបានរស់នៅដោយគ្មានបាប។

មានតែព្រះយេស៊ូវគ្រីស្ទមួយអង្គប៉ុណ្ណោះដែលបានថ្វាយយញ្ញបូជាធួននឹងបាបជំនួសយើងតាមរយៈព្រះលោហិតដ៏មានតម្លៃរបស់ទ្រង់។ ហេតុដូច្នេះហើយបានជាការមានមេត្រីភាពជាមួយនឹងព្រះជាម្ចាស់គឺកើតឡើងតាមតែរយៈព្រះយេស៊ូវគ្រីស្ទមួយអង្គប៉ុណ្ណោះ។ តើយើងកំពុងប្រាប់មនុស្សអំពីសេចក្ដីពិតនេះជារៀងរាល់ថ្ងៃអាទិត្យដែរឬទេ? តើជីវិតរស់នៅជាប្រចាំថ្ងៃរបស់យើងបង្ហាញ៖ យើងជឿថាមេត្រីភាពនេះជាមួយព្រះជាម្ចាស់គឺមានតែតាមរយៈព្រះអម្ចាស់យេស៊ូវគ្រីស្ទដែរឬទេ?

លោកអ្នកទំនងជាអាចទទួលការចាក់ប្រេងតាំងលើក្បាលឬក៏លើជើង ឬក៏អាចហែលទឹកក្នុងអាងមួយណាក៏បាន ប៉ុន្តែការនោះនឹងមិនអាចនាំមកនូវមេត្រីភាពជាមួយនឹងព្រះជាម្ចាស់បានឡើយ។ មិនបានទេ! នោះគឺជាការងាររបស់សាសនានៃពួកក្លែងក្លាយ ហើយដាច់ខាតយើងត្រូវតែបោះវាចោល។ ដាច់ខាត! យើងត្រូវតែចេញទៅ ហើយប្រាប់មនុស្សម្នាថា៖ លោកអ្នកអាចមានមេត្រីភាពជាមួយនឹងព្រះជាម្ចាស់បានតាមរយៈព្រះយេស៊ូវគ្រីស្ទ និងតាមរយៈទ្រង់តែមួយគត់។

កណ្ឌគម្ពីរ ១កូរិនថូស ១:៣០-៣១ គឺជាខគម្ពីរមួយដែលខ្ញុំ

ចូលចិត្តយ៉ាងខ្លាំងក្នុងចំណោមខគម្ពីរផ្សេងៗ ដែលលើកឡើងអំពីភាពគ្រប់គ្រាន់របស់ព្រះគ្រីស្ទសម្រាប់អ្វីៗទាំងអស់៖ «តែដោយសារព្រះ នោះអ្នករាល់គ្នានៅក្នុងព្រះគ្រីស្ទយេស៊ូវ ដែលទ្រង់បានតាំងឡើង ទុកជាប្រាជ្ញាដែលមកពីព្រះ ហើយជាសេចក្តីសុចរិត សេចក្តីបរិសុទ្ធ នឹងសេចក្តីប្រោសលោះដល់យើងផង ដើម្បីឲ្យបានត្រូវនឹងសេចក្តីដែលចែងទុកមកថា "អ្នកណាដែលអួត ត្រូវអួតតែពីព្រះអម្ចាស់ប៉ុណ្ណោះ"»។

ដូចនឹងបុរសដែលជាអ្នកមានម្នាក់ក្នុងកណ្តាដំណឹងល្អ មានមនុស្សមួយចំនួនចាកចេញដោយមានការព្រួយចិត្ត ពេលដែលយើងអធិប្បាយអំពីព្រះពរនានាដែលនៅអស់កល្បជានិច្ចនៃដំណឹងល្អ។ ប៉ុន្តែ មេត្រីភាពជាមួយនឹងព្រះជាម្ចាស់គឺមិនកើតឡើងតាមរយៈទ្រព្យ ឬសម្បត្តិសម្ភារៈនោះទេ។ ចូរនឹកគិតអំពីអស់អ្នកដែលកំពុងអធិប្បាយដំណឹងល្អនៅតំបន់ជនបទនៃទឹកដីនេះ។ គ្រូគង្វាលទាំងនោះដែលកំពុងធ្វើការដោយទាំងគ្មានស្បែកជើង ឬក៏គ្មានកង់ជិះ គឺពួកគាត់នោះឯងដែលមានព្រះពរដ៏មហិមា។ ពួកគាត់មានមេត្រីភាពជាមួយនឹងព្រះជាម្ចាស់ ហើយក៏កំពុងប្រកាសអំពីមេត្រីភាពនេះតាមរយៈព្រះយេស៊ូវគ្រីស្ទផងដែរ។ នេះឯងគឺជាអ្វីដែលយើងត្រូវជឿ។

## ព្រះពរទី២៖ មានផ្លូវចូលទៅកាន់ព្រះជាម្ចាស់

យើងឃើញអំពីព្រះពរបន្ទាប់ក្នុងខ២នៃកណ្ឌគម្ពីររ៉ូមជំពូក៥៖ «ក៏ដោយសារ [តាមរយៈ] ទ្រង់ យើង*មានផ្លូវចូល*ក្នុងព្រះគុណនេះ ជាទីដែលយើងកំពុងឈរនៅ*ដោយជំនឿ* ហើយយើងអួតពីសេចក្តីសង្ឃឹមដល់សិរីល្អនៃព្រះផង»។ ឥឡូវនេះ ដោយសារព្រះជាម្ចាស់បានរាប់យើងជាសុចរិត ហើយយើងមានមេត្រីភាពជាមួយនឹងព្រះជាម្ចាស់ នោះយើងក៏*មានផ្លូវចូលទៅកាន់ព្រះជាម្ចាស់*ផងដែរ។ ទោះបើយើងមិនសមនឹងទទួលបានក៏ដោយ ក៏យើងមានផ្លូវចូលទៅកាន់បល្ល័ង្កនៃព្រះគុណដែលឥឡូវយើងកំពុងឈរប្រឈមមុខ។

ពីមុន យើងធ្លាប់ជាអ្នកបះបោរដែលមិនអាចចូលទៅកាន់ព្រះវត្តមានរបស់ព្រះជាម្ចាស់បាន។ សូមអនុញ្ញាតឲ្យខ្ញុំលើកឡើងនូវឧទាហរណ៍មួយ។ នៅឆ្នាំ១៩៩២ កាលប្រទេសកេនយ៉ា (Kenya) កំពុងបោះឆ្នោត កាលលោកប្រធានាធិបតីម្នាក់ឈ្មោះលោក មួយ៍ (President Moi) ជាអ្នកដឹកនាំ មានមនុស្សជាច្រើនបានចាកចោលគណបក្សខ្លួន ហើយទៅចូលរួមជាមួយនឹងគានូ (KANU ដែលជាគណបក្សរបស់លោក មួយ៍)។ ពួកចាកចោលបក្សទាំងនេះមកពីតំបន់ជនបទទៅកាន់ផ្ទះរដ្ឋ (the State

House) ហើយមានគេនាំពួកគាត់ចូលទៅកាន់សភានៃប្រធានា-ធិបតី។ ពួកគាត់សប្បាយក្នុងការទទួលទានចំណីអាហារនៅទីនោះ ហើយថែមទាំងបានជួបនឹងប្រធានាធិបតីទៀត។ ហើយលោកប្រធានាធិបតីក៏ថែមទាំងចេញទៅឃោសនារកសន្លឹកឆ្នោតជាមួយនឹងពួកគាត់ទៀតផង។ កាលមុនពួកគាត់គឺជាអ្នកទាស់ប្រឆាំងនឹងលោកប្រធានាធិបតី ប៉ុន្តែឥឡូវនេះមានផ្លូវចូល ហើយផ្លូវចូលនោះមានយ៉ាងហូរហៀរទៅក្នុងផ្ទះរដ្ឋ។

ដូចគ្នានោះដែរ យើងម្នាក់ៗធ្លាប់ជាអ្នកបះបោរទាស់នឹងព្រះជាម្ចាស់។ ប៉ុន្តែ ព្រះយេស៊ូវគ្រីស្ទបាននាំយើងទៅកាន់ព្រះជាម្ចាស់ផ្ទាល់ ដោយសារព្រះអង្គបានរាប់យើងជាសុចរិតតាមរយៈជំនឿ។ ហើយឥឡូវនេះ យើងមានផ្លូវចូលទៅ។ ព្រះយេស៊ូវបាននាំយើងចូលទៅកាន់ព្រះវត្តមានរបស់ព្រះជាម្ចាស់។ ការដែលទ្រង់រាប់យើងជាសុចរិតនាំឲ្យយើងមានសន្តិភាព និងទំនុកចិត្តនៅចំពោះព្រះជាម្ចាស់របស់យើង។

ព្រះវត្តមានរបស់ព្រះជាម្ចាស់មានសារៈសំខាន់ចំពោះរាស្ត្ររបស់ទ្រង់តាំងពីយូរយារណាស់មកហើយ។ ចូលនឹកចាំថា ព្រះវិហារនៅសម័យព្រះគម្ពីរសញ្ញាចាស់ក៏ជាទីសម្គាល់មួយនៃព្រះវត្តមានរបស់ព្រះជាម្ចាស់ទៅកាន់រាស្ត្ររបស់ទ្រង់ផងដែរ។ ប៉ុន្តែ

សូម្បីតែព្រះវិហារក៏មានការបែងចែកជាបីដែរៈ ទីបរិសុទ្ធបំផុត កន្លែងបរិសុទ្ធ និងទីលានខាងក្រៅ។ នៅឯទីបរិសុទ្ធបំផុតមាន បល្ល័ង្កនៃសេចក្តីមេត្តាករុណា ហើយមានតែសម្តេចសង្ឃមួយគត់ ដែលអាចចូលទៅកាន់ទីកន្លែងនោះបាន ហើយគាត់បានធ្វើការ នោះមួយឆ្នាំតែមួយដងគត់ប៉ុណ្ណោះ ដើម្បីថ្វាយយញ្ញបូជាសម្រាប់ អំពើបាបពួករាស្ត្រ។ ប៉ុន្តែ សម្រាប់ឯយញ្ញបូជារបស់យើងវិញ គឺ ត្រូវបានធ្វើឡើងតែម្តងសម្រាប់រាល់ពេល។ ហេតុដូច្នេះបានជា ឥឡូវនេះព្រះអម្ចាស់យេស៊ូវគ្រីស្ទនាំយើងចូលទៅក្នុងព្រះវត្តមាន របស់ព្រះដ៏ខ្ពស់បំផុត។ យើងមានផ្លូវចូលទៅកាន់ព្រះជាម្ចាស់។

ក្នុងកណ្ឌគម្ពីរ ហេព្រើរ ៤:១៤-១៦ អ្នកនិពន្ធបានសង្ខេប សេចក្តីពិតនេះបានយ៉ាងល្អៈ

> *«ដូច្នេះ ដែលមានសម្តេចសង្ឃយ៉ាងធំ១អង្គ ដែល ទ្រង់បានយាងកាត់អស់ទាំងជាន់ស្ថានសួគ៌ គឺព្រះ យេស៊ូវជាព្រះរាជបុត្រានៃព្រះ នោះត្រូវតែឲ្យយើងមាន ចិត្តដាច់ស្រេទ្បះនឹងជឿតាមចុះ ដ្បិតសម្តេចសង្ឃនៃយើង ទ្រង់មិនមែនមិនអាចនឹងអាណិតអាសូរ ដល់សេចក្តី កម្សោយរបស់យើងរាល់គ្នានោះទេ ព្រោះទ្រង់បានត្រូវ*

*សេចក្តីល្បួងគ្រប់យ៉ាង ដូចជាយើងរាល់គ្នាដែរ តែឥត ធ្វើបាបឡើយ ដូច្នេះ ត្រូវឲ្យយើងរាល់គ្នា មកដល់បល្ល័ង្ក នៃព្រះគុណដោយក្លាហាន ដើម្បីនឹងទទួលសេចក្តីមេត្តា ហើយរកបានព្រះគុណសម្រាប់នឹងជួយដល់ពេលត្រូវ ការចុះ»។*

អ្វីដែលយើងមានក្នុងព្រះយេស៊ូវគ្រីស្ទគឺល្អប្រសើរជាងអ្វី ដែលពួកបរិសុទ្ធក្នុងព្រះគម្ពីរសញ្ញាចាស់មានទៅទៀត។ ក្នុង ព្រះអម្ចាស់យេស៊ូវគ្រីស្ទ លោកអ្នកមានសម្តេចសង្ឃដែលប្រ-ទានផ្លូវចូលដល់លោកអ្នកទៅកាន់ព្រះជាម្ចាស់។ ដូច្នេះហើយ បានជាឥឡូវនេះ លោកអ្នកអាចចូលទៅកាន់បល្ល័ង្កនៃព្រះគុណ ដោយមានភាពក្លាហាន។ តាមរយៈព្រះយេស៊ូវគ្រីស្ទ យើងបាន ទទួលផ្លូវចូល ហេតុដូច្នេះយើងទៅដោយមានទំនុកចិត្ត។ នេះគឺ ជាព្រះពរដ៏អស្ចារ្យមួយ។

ប៉ុន្តែ ដាច់ខាត! យើងមិនត្រូវមានគំនិតខុសឆ្គងអំពីទំនុកចិត្ត នេះដែលយើងអាច ហើយគួរមានក្នុងព្រះយេស៊ូវឡើយ។ ព្រះ ជាម្ចាស់ជាភ្លើងដែលឆេះបន្សុស។ យើងមិនហ៊ានមានការរញ៉េ រញ៉ៃជាមួយនឹងព្រះជាម្ចាស់ឡើយ។ ក្នុងព្រះគម្ពីរ យើងឃើញ

ពីអ្វីដែលកើតឡើងចំពោះអស់អ្នកដែលមើលងាយព្រះជាម្ចាស់ និងមិនអើពើពីទ្រង់។ ព្រះអង្គបរិសុទ្ធ ហើយខុសប្លែកពីមនុស្សបាប ហើយទ្រង់ទាមទារឲ្យយើងគោរពដល់ទ្រង់។ ពេលដែលយើងចូលទៅកាន់ទ្រង់ យើងមិនមែនទៅដើម្បីឈ្លោះប្រកែក ឬក៏ទាមទារអ្វីពីទ្រង់ឡើយ។

ទំនុកចិត្តនេះគឺជាចំណេះដឹងរបស់យើងដែលគ្មានមន្ទិលសង្ស័យ៖ ព្រះគ្រីស្ទជាអង្គដែលរៀបចំផ្លូវចូលមួយនេះ ហើយយើងទទួលបានតាមរយៈជំនឿ។ ព្រះជាម្ចាស់បានសម្រេចការនោះ ហើយវាចប់សព្វគ្រប់អស់ហើយ។ វាប្រៀបដូចជា មានគេអញ្ជើញលោកអ្នកឲ្យទៅចូលរួមពិធីរៀបការ ហើយបើមានគេសួរលោកអ្នកនៅច្រកផ្លូវចូលថាហេតុអ្វីបានជាគេគួរអនុញ្ញាតឲ្យលោកអ្នកចូល នោះលោកអ្នកនឹងបង្ហាញសំបុត្រអញ្ជើញ។ គេបានអញ្ជើញលោកអ្នកហើយ ដូច្នេះលោកអ្នកមិនគួរមានការពិបាកចិត្តឡើយ។ ព្រះអម្ចាស់យេស៊ូវគ្រីស្ទបានអញ្ជើញលោកអ្នក ហើយក៏បានប្រទានសេចក្តីសុចរិតរបស់ទ្រង់ដល់យើងផងដែរ។ យើងមិនមែនចូលទៅកាន់ទ្រង់ដោយមានទំនុកចិត្តដោយពឹងលើអ្វីដែលយើងបានធ្វើនោះទេ ប៉ុន្តែ យើងចូលដោយមានទំនុកចិត្ត ពីព្រោះព្រះអង្គបានលាងសម្អាតយើងដោយព្រះ

លោហិតទ្រង់ ហើយក៏បានប្រទានសេចក្តីសុចរិតរបស់ទ្រង់ដល់យើងផងដែរ។ វាគឺជាទំនុកចិត្តដែលមានមូលដ្ឋានលើអ្វីដែលព្រះអម្ចាស់យេស៊ូវគ្រីស្ទបានសម្រេចជំនួសយើង។

ទោះបើតាមពិតទៅយើងមានផ្លូវចូលទៅកាន់ព្រះជាម្ចាស់ក៏ដោយ ក៏នៅមានក្រុមជំនុំ និងគ្រូអធិប្បាយមួយចំនួនព្យាយាមដាក់រនាំងឃាំងរវាងគ្រីស្ទបរិស័ទ និងព្រះជាម្ចាស់ដែរ។ យើងមិនត្រូវការសង្ឃណាម្នាក់ ដើម្បីនាំផ្លូវយើងទៅកាន់ព្រះជាម្ចាស់ទៀតទេ។ ប៉ុន្តែ តាមពិតទៅគឺមិនមែនគ្រាន់តែសង្ឃកាតូលិកទេដែលលើកខ្លួនថា ជាអ្នកយាមទ្វារចូលទៅបល្ល័ង្កនៃព្រះគុណ។ យើងក៏មានក្រុមជំនុំជាច្រើនទៀតដែលបានធ្លាក់ក្នុងសេចក្តីល្បួងនៃការបង្កើតក្រុមខុសឆ្គងដោយពឹងលើបុគ្គលិកលក្ខណៈ។ ពួកគេថា មានតែគ្រូគង្វាលម្នាក់គត់ដែលអាចអធិស្ឋានសម្រាប់លោកអ្នកបាន។ មានតែគាត់ម្នាក់គត់ដែលអាចប្រទានពរដល់លោកអ្នក។ ពួកគាត់គិតថា ប្រសិនបើគ្រូគង្វាលរបស់គាត់បានចេញដំណើរកំសាន្ត ហើយគាត់ត្រូវការការអធិស្ឋាន នោះគាត់ត្រូវតែទូរស័ព្ទទៅកាន់គ្រូគង្វាល ហើយសូមឲ្យគ្រូគង្វាលអធិស្ឋានសម្រាប់គាត់។ គ្រីស្ទបរិស័ទត្រូវតែទទួលការបង្រៀនថា ខ្លួនមានផ្លូវចូលទៅកាន់ព្រះជាម្ចាស់តាមរយៈព្រះគ្រីស្ទ។

ក្នុងវប្បធម៌មួយចំនួនរបស់យើង យើងសាំហើយក្នុងការឲ្យអ្នកដ៏ទៃធ្វើជាអ្នកតំណាងយើង អ្នកដែលឈរវាងយើង និងវិញ្ញាណនានា។ ប៉ុន្តែ នេះមិនមែនជាផលផ្លែនៃដំណឹងល្អទ្បើយ។ អ្នកជឿនីមួយៗក្នុងព្រះអម្ចាស់យេស៊ូវគ្រីស្ទសុទ្ធតែបានទទួលផ្លូវចូលទៅកាន់ព្រះជាម្ចាស់រួចហើយ។ ហើយការនេះកើតឡើងគឺមិនមែនដោយសារទង្វើរបស់យើង តាមរយៈលុយកាក់ដែលយើងឲ្យ តាមរយៈកម្លាំងយើង តាមរយៈសមត្ថភាពរបស់យើង ឬក៏ប្រវត្តិរបស់យើងឡើយ។ យើងទទួលបានព្រះពរនៃការមានផ្លូវចូលទៅកាន់ព្រះជាម្ចាស់ដ៏អស្ចារ្យនេះ គឺដោយសារតែព្រះជាម្ចាស់បានប្រកាសថាយើងសុចរិតដោយពឹងលើអំពើល្អរបស់ព្រះរាជបុត្រាទ្រង់។

## ព្រះពរទី៣៖ ក្ដីអំណរពីក្ដីសង្ឃឹមនៃសិរីល្អរបស់ព្រះជាម្ចាស់

ប៉ុន្តែ នៅមានព្រះពរជាច្រើនទៀតនៅអនាគតដែលយើងមិនទាន់ទទួលបាននៅឡើយ។ មេត្រីភាពជាមួយព្រះជាម្ចាស់ និងផ្លូវចូលទៅកាន់ព្រះជាម្ចាស់ក្នុងព្រះគ្រីស្ទយេស៊ូវប្រទាននូវ*អំណរ*ដល់យើងដោយសារក្ដីសង្ឃឹមដែលវាផ្ដល់ឲ្យយើង។ តោះ! នាំគ្នា

មើលកណ្ឌគម្ពីរ រ៉ូម ៥:២ ម្ដងទៀត «ក៏ដោយសារ [តាមរយៈ] ទ្រង់ យើងមានផ្លូវចូលក្នុងព្រះគុណនេះ ជាទីដែលយើងកំពុងឈរនៅដោយជំនឿ ហើយ*យើងអួតពីសេចក្ដីសង្ឃឹមដល់សិរីល្អនៃព្រះផង*»។

យើងក៏អាចប្រែពាក្យ «*អួត*» ត្រង់នេះថាជាពាក្យ «*អំណរ*» ផងដែរ ហើយបើយើងផ្គុំពាក្យទាំងពីរនេះជាមួយគ្នា នោះយើងនឹងយល់អត្ថន័យរបស់សាវ័ក ប៉ុល។ អ្វីដែលគាត់កំពុងនិយាយគឺអំពីទំនុកចិត្តដែលពោរពេញទៅដោយភាពស្រស់ស្អាត។[១] ពេលដែលយើងដឹងថាអ្វីមួយមានតម្លៃ—ដូចជា បុគ្គល អំណោយទាន ឬទ្រព្យ—គឺជាកម្មសិទ្ធិយើង នោះអំណរ*គឺជា*បទពិសោធន៍របស់យើង។ ក្នុងព្រះយេស៊ូវ យើងមានការធានានៃការអះអាងលើអ្វីៗដែលល្អបំផុត។ យើងមានអំណរក្នុងក្ដីសង្ឃឹមនៃសិរីល្អរបស់ព្រះជាម្ចាស់។ សាវ័ក ប៉ុល បានប្រាប់ក្រុមជំនុំរ៉ូមឲ្យចងចាំថា៖ លោកអ័ប្រាហាំ ត្រូវបានរាប់ជាសុចរិតដោយសារជំនឿ។ ស្ដេច ដាវីឌ ត្រូវបានរាប់ជាសុចរិតដោយសារជំនឿ។ ហើយព័ន្ធកិច្ចនៃការធួននឹងបាបរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទនៅលើភ្នំកាល់វ៉ារីបាន

១ ដកស្រង់ចេញពីសៀវភៅ *The Bible Knowledge Word Study: Acts-Ephesians* និពន្ធដោយ៖ លោកគ្រូ Darrell Bock (Colorado Springs: Cook, ឆ្នាំ២០០៦), ទំព័រ១៥២)។

ប្រទាននូវមេត្រីភាពដល់យើងជាមួយនឹងព្រះជាម្ចាស់។ ហើយក៏បានផ្តល់ដល់យើងនូវផ្លូវចូលផងដែរ។ ហើយដោយសារការនេះ ឥឡូវយើងអាចមានអំណរក្នុងក្តីសង្ឃឹមនៃការមានចំណែកក្នុងសិរីល្អរបស់ព្រះជាម្ចាស់បាន។

ប៉ុន្តែ ដូចដែលយើងត្រូវមានការប្រុងប្រយ័ត្នក្នុងការផ្តល់អត្ថន័យលើពាក្យ *«ព្រះពរ»* យើងក៏ត្រូវប្រយ័ត្នដែរលើពាក្យ *«អំណរ»* និង *«អរ»* ព្រោះសព្វថ្ងៃនេះមានការប្រើប្រាស់ពាក្យទាំងនេះក្នុងលក្ខណៈខុសឆ្គង។ អំណរនេះដែលយើងកំពុងរៀបរាប់គឺមិនសំដៅទៅលើលទ្ធផលនៃអ្វីដែលយើងទទួលបាននៅខាងក្រៅនោះឡើយ។ វាជាអំណរដែលកើតឡើងចេញពីលទ្ធ-ផលនៃការរាប់ជាសុចរិតដោយសារជំនឿក្នុងព្រះគ្រីស្ទយេស៊ូវ។ សំឡេង និងសំណើចគឺមិនមែនជាអ្វីដែលផ្តល់អត្ថន័យលើអំណរទេ។ ខ្ញុំធ្លាប់បានឃើញមនុស្សសើចពេញមួយយប់ ហើយពួកគាត់បានអះអាងថា នោះគឺជាអំណរនៃព្រះអម្ចាស់។ ប៉ុន្តែ នោះគឺមិនមែនជាអំណរនៃព្រះអម្ចាស់ទេ។ អំណរដែលសាវ័ក ប៉ុលប្រាប់យើងគឺទាក់ទងនឹងការពេញចិត្តនឹងភាពស្ថិតស្ថេរនៃព្រះពរដ៏នៅអស់កល្បជានិច្ច។ យើងដឹងយ៉ាងប្រាកដថាយើងនឹងមានចំណែកក្នុងសិរីល្អរបស់ព្រះជាម្ចាស់។

នេះមិនមែនជាក្ដីសង្ឃឹមដែលមិនច្បាស់លាស់នោះទេ ដូចជាការសង្ឃឹមថានឹងទទួលបានការងារដ៏ល្អមួយ ឬក៏ផ្ទះដ៏ស្អាតមួយនៅអនាគតនោះឡើយ។ នេះគឺជាការដឹងយ៉ាងប្រាកដថា នៅថ្ងៃមួយយើងនឹងឃើញសិរីល្អរបស់ព្រះជាម្ចាស់ដែលទ្រង់បានរាប់យើងជាសុចរិត។ យើងដឹងថា ទ្រង់បានសង្គ្រោះយើង បានរំដោះយើង ហើយយើងក៏នឹងមានចំណែកក្នុងសិរីល្អរបស់ទ្រង់ផងដែរ ដោយគ្មានមន្ទិលសង្ស័យ សូម្បីតែមួយសរសៃសក់ក៏គ្មានផង។ កណ្ឌគម្ពីរ កូឡូស ១:២៧ បានចែងថា «ព្រះគ្រីស្ទគង់នៅក្នុងបងប្អូន ព្រះអង្គប្រទានឲ្យបងប្អូនមានសង្ឃឹមថា នឹងបានទទួលសិរីរុងរឿងរបស់ព្រះអង្គ» (គខប)។ ប្រសិនបើលោកអ្នកមានព្រះអម្ចាស់យេស៊ូវគ្រីស្ទក្នុងលោកអ្នក នោះលោកអ្នកអាចមានសង្ឃឹមនៃសិរីល្អ។

ហើយយើងក៏មិនមានសង្ឃឹមលើអ្វីដែលមិនទាន់មានឡើងនៅឡើយដែរ។ ព្រះជាម្ចាស់មិនមែនកំពុងបោកប្រាស់យើងនោះទេ។ ព្រះអង្គមានសិរីល្អតាំងពីណាពីណើមកម្ល៉េះសម្រាប់គ្រប់ពេល ហើយសិរីល្អនេះក៏បានទ្រទ្រង់ផែនដីនេះផងដែរ។ នឹងមានថ្ងៃមួយដែលសិរីល្អរបស់ព្រះជាម្ចាស់នឹងគ្របលើផែនដីនេះ ហើយយើងក៏នឹងមានចំណែកក្នុងហ្នឹងផងដែរ។ បើលោកអ្នក

ធ្លាប់មើលល្ខោននៅកន្លែងគេសម្ដែង នោះលោកអ្នកដឹងហើយ ថាគេមានវាំងនននៅលើឆាក។ មុនគេចាប់ផ្ដើមសម្ដែងល្ខោន គេតែងតែបិទវាំងនន។ ប៉ុន្ដែ តួសម្ដែងបានទៅត្រៀមខ្លួននៅទី នោះរួចទៅហើយ ហើយអ្នកទស្សនាក៏បានត្រៀមខ្លួនក្នុងការចាំ គេបើកវាំងននផងដែរ។ ពេលដែលគេបើកវាំងនន នោះលោក អ្នកនឹងមើលឃើញអ្វីៗដែលមាននៅទីនោះហើយស្រេច។ សិរី ល្អរបស់ព្រះជាម្ចាស់មាននៅក្នុងព្រះវត្ដមានរបស់ទ្រង់ ហើយថ្ងៃ មួយអស់អ្នកដែលត្រូវបានរាប់ជាសុចរិតដោយសារជំនឿនឹងមិន គ្រាន់តែមើលឃើញប៉ុណ្ណោះទេ ប៉ុន្ដែពួកគាត់ក៏នឹងមានចំណែក ក្នុងសិរីល្អនោះដែរ។

តើលោកអ្នកលែងមានចំណាប់អារម្មណ៍នឹងសិរីល្អរបស់ ព្រះជាម្ចាស់ហើយមែនឬ? លោកីយ៍នេះព្យាយាមពង្វក់ស្មារ-តីយើងដោយឲ្យយើងចង់ប្រព្រឹត្ដបាប ហើយមានអ្នកខ្លះចង់ប្ដូរ សិរីល្អរបស់ព្រះជាម្ចាស់ជាមួយនឹងអ្វីដែលពួកគាត់អាចទទួល បាននៅទីនេះ និងឥឡូវនេះ។ ប៉ុន្ដែ យើងមាននូវអ្វីដែលមាន តម្លៃជាងមាស ប្រាក់ ឬក៏អ្វីណាមួយផ្សេងទៀតដែលលោកីយ៍ នេះអាចនឹងឲ្យយើងទៅទៀត។ យើងមានក្ដីសង្ឃឹមនៃសិរីល្អ របស់ព្រះជាម្ចាស់។ លោកអ្នកមិនអាចរកព្រះពរនេះបានក្រៅពី

ក្នុងដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទឡើយ។

ព្រះអម្ចាស់យេស៊ូវរបស់យើងជ្រាបហើយថា ការរួមចំណែកក្នុងសិរីល្អរបស់ព្រះជាម្ចាស់គឺជាព្រះពរដែលគ្មានការប្រៀបធៀបបានទេ។ ព្រះអង្គសព្វព្រះហឫទ័យចង់ឲ្យយើងមានចំណែកក្នុងសិរីល្អរបស់ព្រះជាម្ចាស់ ទ្រង់បានអធិស្ឋានថា «ឱព្រះវរបិតាអើយ ឯពួកអ្នកដែលទ្រង់ប្រទានមកទូលបង្គំ នោះទូលបង្គំចង់ឲ្យគេនៅជាមួយនឹងទូលបង្គំ ក្នុងកន្លែងដែលទូលបង្គំនៅដែរ ដើម្បីឲ្យបានឃើញសិរីល្អដែលទ្រង់បានប្រទានមកទូលបង្គំ ដ្បិតទ្រង់បានស្រឡាញ់ទូលបង្គំ តាំងតែពីមុនកំណើតលោកីយ៍រៀងមក» (យ៉ូហាន ១៧:២៤)។ គ្រីស្ទបរិស័ទមានក្តីសង្ឃឹមយ៉ាងជាក់លាក់នៃការរួមចំណែកក្នុងសិរីល្អរបស់ព្រះជាម្ចាស់។ ហើយក្តីសង្ឃឹមនេះផ្តល់នូវអំណរដល់ពួកគាត់។

## ព្រះពរទី៤៖ ក្តីអំណរក្នុងទុក្ខលំបាក

លោកីយ៍នេះសន្យាមកយើងនូវអ្វីៗដែលនឹងលិចបាត់ទៅវិញ ហើយក៏នឹងបែកជាធូលីដី។ ព្រះពរដែលយើងមានក្នុងដំណឹងល្អនឹងនៅយ៉ាងគង់វង្ស។ ហេតុដូច្នេះ ព្រះពរមួយទៀតដែលយើងមាន គឺត្រង់ថា ទោះបើយើងប្រឈមមុខនឹងទុក្ខលំបាកក៏យើង

នៅអាចមានអំណរបានផងដែរ។ «មិនតែប៉ុណ្ណោះសោត *យើងនៅតែអួតក្នុងកាលដែលមានទុក្ខលំបាកដែរ* ដោយដឹងថា សេចក្ដីទុក្ខលំបាកបង្កើតឲ្យមានសេចក្ដីទ្រាំទ្រ» (រ៉ូម ៥:៣)។ យើងអាចមានក្ដីអរសប្បាយក្នុងទុក្ខលំបាករបស់យើង។ នេះគឺជាព្រះពរដ៏ចម្លែកមែន!

បើលោកអ្នកអធិប្បាយពីចំណុចនេះនៅព្រះវិហារមួយចំនួន អ្នកស្ដាប់នឹងចាប់ផ្ដើមមានអារម្មណ៍ស្រងេះស្រងោច។ ធ្លាប់មានព្រះវិហារមួយនៅទីក្រុងណៃរ៉ូប៊ី (Nairobi) ដែលមានទង់ជ័យថា «បញ្ឈប់ទុក្ខលំបាក—តាមរយៈការចូលរួមជាមួយនឹងព្រះវិហារសកលនៃព្រះគ្រីស្ទ (Universal Church of Christ)»។ ព្រះគម្ពីរមិនបានសន្យាការនេះនោះទេ ប៉ុន្តែបានលើកឡើងថា យើងអាចមានអំណរក្នុងទុក្ខលំបាករបស់យើង។ តើយើងគួរដកខគម្ពីរនេះចេញមែនឬ? ទេ! យើងគួរឱនក្បាល ហើយអរព្រះគុណព្រះជាម្ចាស់។ ចំពោះអស់អ្នកដែលព្រះជាម្ចាស់បានរាប់ជាសុចរិត ទោះបើពួកគាត់កំពុងតែប្រឈមមុខនឹងការបៀតបៀនក៏ដោយ ក៏ពួកគាត់នៅអាច ហើយក៏នៅមានអំណរបានដែរ។ តើឲ្យការនេះកើតឡើងយ៉ាងដូចម្ដេចបានទៅ?

ជាដំបូង ការរងទុក្ខគឺជាយានដ៏សំខាន់មួយសម្រាប់ការញែក

ជាបរិសុទ្ធរបស់យើង។ យើងអាចមានអំណរក្នុងទុក្ខលំបាកបាន ព្រោះទុក្ខលំបាកបង្កើតឲ្យមានសេចក្តីទ្រាំទ្រ។ (ក៏មានទុក្ខលំបាកមិនល្អដែរ៖ បើខ្ញុំទទួលទារុណកម្មមកពីខ្ញុំលួចគេ នោះមិនមែនសម្រាប់សិរីល្អរបស់ព្រះជាម្ចាស់ទេ ហើយក៏មិនមែនជាទុក្ខលំបាកបែបគ្រីស្ទបរិស័ទផងដែរ។) ពេលដែលគ្រីស្ទបរិស័ទជួបទុក្ខលំបាកដោយសារយើងទុកចិត្តលើព្រះអម្ចាស់យេស៊ូវគ្រីស្ទ នោះព្រះជាម្ចាស់ប្រើប្រាស់ការនោះ ដើម្បីពង្រឹងជំនឿរបស់យើង។ តើមានគេធ្លាប់សើចចំអកដាក់លោកអ្នកដោយសារជំនឿរបស់លោកអ្នកដែរឬទេ? ពេលដែលយើងនៅបន្តឱបក្រសោបព្រះគ្រីស្ទក្នុងកាលៈទេសៈបែបហ្នឹង នោះព្រះជាម្ចាស់នឹងពង្រឹងការឱបក្រសោបរបស់យើងលើទ្រង់ឲ្យកាន់តែរឹងមាំឡើងៗថែមទៀត។ ហើយពេលវាកើតឡើងម្តងទៀតនៅពេលក្រោយ យើងនឹងកាន់តែឱបក្រសោបខ្លាំងជាងមុនថែមទៀត។ ទុក្ខលំបាកបង្កើតឲ្យមានសេចក្តីទ្រាំទ្រក្នុងជំនឿ។

ហើយលើសពីនេះទៅទៀតសាវ័ក ប៉ុល ក៏បានប្រាប់យើងថា សេចក្តីទ្រាំទ្របង្កើតឲ្យមានសេចក្តីសាំុថ្មក។ គ្រីស្ទបរិស័ទដ៏ស្មោះត្រង់គឺជាបុគ្គលដែលបានឆ្លងកាត់ទុក្ខលំបាក ហើយចេញពីការនោះទទួលបានការហ្វឹកហាត់ នឹងការផ្លាស់ប្រែតាម

រយៈទុក្ខលំបាកនោះ។ ចូរនឹកចាំអំពីបទពិសោធន៍របស់ស្តេច ដាវីឌ និងអំពីរបៀបដែលការនោះបានបណ្តុះបណ្តាលលក្ខណសម្បត្តិរបស់ទ្រង់។ ពេលដែលស្តេច សូល សួរគាត់ថាតើគាត់មានលទ្ធភាពក្នុងការទៅច្បាំងជាមួយនឹងយក្ស កូលីយ៉ាត គាត់បានត្រៀមចម្លើយរួចស្រេចហើយ។ គាត់ធ្លាប់មើលថែសត្វចៀមរបស់ឪពុកគាត់ ហើយពេលណាសត្វតោ ឬក៏សត្វខ្លាឃ្មុំមករកស៊ីសត្វចៀម គាត់តែងតែសម្លាប់ពួកវាចោល។ គាត់ធ្លាប់បានដកពិសោធន៍ក្នុងរបៀបដែលព្រះជាម្ចាស់បានជួយគាត់ ពេលដែលគាត់ប្រឈមមុខនឹងការគំរាមកំហែង ហើយការនោះបានកសាងលក្ខណសម្បត្តិរបស់គាត់។ ដូច្នេះគាត់អាចលើកឡើងថា «ឯព្រះយេហូវ៉ា ជាព្រះដែលបានជួយទូលបង្គំ ឲ្យរួចពីក្រចកសិង្ហនឹងខ្លាឃ្មុំ ទ្រង់ក៏នឹងជួយឲ្យរួចពីកណ្តាប់ដៃសាសន៍ភីលីស្ទីននោះដែរ» (១សាំយូអែល ១៧:៣៧)។ ទុក្ខលំបាកបង្កើតឲ្យមានសេចក្តីទ្រាំទ្រ។

យើងក៏អាចមានអំណរក្នុងទុក្ខលំបាកបានដែរ ព្រោះវាបង្ហាញអំពីអំណាចរបស់ព្រះជាម្ចាស់។ លោកគ្រូ ម៉ាទីន ប៊ូសេ ដែលជាគ្រូខ្ញុំម្នាក់ គាត់ធ្លាប់បានលើកឡើងអំពីគំរូនៃបេសកជនម្នាក់ដែលបានចេញទៅប្រកាសដំណឹងល្អនៅកន្លែងមួយ ហើយនៅទីនោះ

គាត់មិនបានឃើញផលផ្លែអស់រយៈពេលយ៉ាងយូរឆ្នាំ។ ហើយបន្ទាប់មក កូនម្នាក់របស់គាត់បានឈឺ ហើយមិនយូរមិនឆាប់ គាត់ក៏ស្លាប់ទៅ។ ក្នុងនាមជាកូនរបស់ព្រះជាម្ចាស់ បេសកជនម្នាក់នេះមិនបានរងទុក្ខ ឬក៏កាន់ទុក្ខបែបដូចលោកីយ៍នេះធ្វើឡើយ (១ថែសាឡូនីច ៤:១៣)។ អ្នកនៅទីនោះក៏បានកត់សម្គាល់ពីការនោះ។ ពួកគេបានឃើញអំពីរបៀបដែលគាត់បានឆ្លើយតបនឹងជំងឺ និងការស្លាប់របស់កូនគាត់ ហើយពួកគេក៏មានការងឿងឆ្ងល់ថា តើហេតុអ្វីបានជាគាត់មានការខុសប្លែកពីអ្នកដទៃ។ ហើយនៅថ្ងៃបន្ទាប់ ពួកគេក៏ចាប់ផ្ដើមមកផ្ទះគាត់។ របៀបដែលគ្រីស្ទបរិស័ទឆ្លងកាត់ទុក្ខលំបាកនឹងបើកសម្ដែងឲ្យអ្នកដទៃឃើញអំណាចរបស់ព្រះជាម្ចាស់។ លោកីយ៍នេះអាចឃើញអំណាច និងព្រះគុណរបស់ព្រះជាម្ចាស់ក្នុងជីវិតរបស់យើង ហើយការនោះទាញពួកគេទៅកាន់ព្រះអង្គសង្គ្រោះរបស់យើង។

ការរងទុក្ខក៏ត្រៀមយើងឲ្យព្រះអង្គអាចប្រើយើងនៅអនាគតផងដែរ។ តើលោកអ្នកអាចនឹកស្រមៃអំពីគ្រូណាម្នាក់ដែលគ្មានសន្ដានចិត្តបានដែរឬទេ? ពេលខ្លះគ្រូៗក៏ត្រូវការរងទុក្ខផងដែរ ដើម្បីអត្ថប្រយោជន៍អ្នកដទៃ។ ពេលដែលយើងមានបទពិសោធន៍ក្នុងការរងទុក្ខ យើងអាចកាន់តែមានសន្ដានចិត្តជាមួយ និងចេះ

បម្រើអស់អ្នកដែលកំពុងរងទុក្ខដែរ។

លើសពីនោះ ព័ន្ធកិច្ចនៃគ្រីស្ទបរិស័ទដែលកំពុងរងទុក្ខក៏មានអំណាចយ៉ាងខ្លាំងក្នុងការលើកទឹកចិត្តព្រលឹងវិញ្ញាណយើងផងដែរ។ ដាច់ខាត! ខ្ញុំត្រូវតែលើកឡើងអំពីលោកគ្រូ ចន ខារីធា (John Nkarithia) នៅស្រុក ម៉ៃធេនី-ម៉ារូ (Maithene-Meru)។ គាត់បានឆ្លងកាត់ការរងទុក្ខ និងជំងឺជាច្រើន ហើយគាត់បានថ្វាយសិរីល្អដល់ព្រះជាម្ចាស់តាមរយៈការនោះ។ បើលោកអ្នកបានទៅលេងគាត់ នោះលោកអ្នកទំនងជាគិតថា លោកអ្នកនឹងលើកទឹកចិត្តគាត់ ប៉ុន្តែលោកអ្នកគឺជាបុគ្គលដែលចាកចេញពីទីនោះដោយទទួលបានការលើកទឹកចិត្តពីគាត់វិញទេ។ តាមពិតទៅ មុនគាត់ស្លាប់ គាត់ថែមទាំងបានអធិស្ឋានសម្រាប់ខ្ញុំ ឲ្យចេញទៅប្រកាសដំណឹងល្អ។ យើងថ្វាយសិរីល្អដល់ព្រះជាម្ចាស់ក្នុងការរងទុក្ខរបស់យើង ពេលដែលយើងប្រើប្រាស់វា ដើម្បីបង្រៀនអ្នកដទៃ។

សូមរៀបចំមនុស្សឲ្យត្រៀមខ្លួនជាស្រេចក្នុងការស្លាប់។ កុំគ្រាន់តែអធិស្ឋានឲ្យពួកគេទទួលបានការព្យាបាលឡើយ។ ចូរអធិស្ឋាន ហើយត្រៀមពួកគាត់សម្រាប់សិរីល្អ។ ខ្ញុំបានអានកណ្ឌគម្ពីរ រ៉ូម ៨:១៨-៣៩ ទៅកាន់លោកគ្រូ ចន ខារីធា៖ «ខ្ញុំរាប់អស់ទាំងសេចក្ដីទុក្ខលំបាកនៅជាន់នេះថា ជាសេចក្ដីមិនគួរប្រៀបផ្ទឹម

នឹងសិរីល្អ ដែលនឹងបើកសម្ដែងមកឲ្យយើងរាល់គ្នាឃើញនោះទេ»។ ពេលវេលាបានមកដល់ហើយក្នុងការឲ្យយើងដឹង ដូចដែលលោកគ្រូម្នាក់នោះដឹងថា យើងអាចមានអំណរក្នុងការរងទុក្ខរបស់យើងបាន។

ហើយក្ដីសង្ឃឹមដែលទ្រទ្រង់យើង និងញែកយើងជាបរិសុទ្ធនឹងមិនធ្វើឲ្យយើងខកចិត្តឡើយ។ ក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ត្រូវបានចាក់ចូលមកក្នុងដួងចិត្តយើង។ យើងមានក្ដីសង្ឃឹមដ៏ពិតប្រាកដ។ តាមពិតទៅសាវ័ក ប៉ុល បានសរសេរទៅកាន់លោក ធីម៉ូថេ ថា «ព្រះយេស៊ូវគ្រីស្ទដ៏ជាទីសង្ឃឹមនៃយើងរាល់គ្នា» (១ធីម៉ូថេ ១:១)។ ព្រះយេស៊ូវគឺជាក្ដីសង្ឃឹមរបស់យើង។ ក្ដីសង្ឃឹមដែលនៅក្នុងព្រះអម្ចាស់យេស៊ូវគ្រីស្ទគ្មានការខកចិត្តឡើយ។

## សេចក្ដីសន្និដ្ឋាន

លោកអ្នកឃើញព្រះត្រៃឯកក្នុងព្រះពរនានានៃដំណឹងល្អ។ ព្រះវរបិតាបានចាត់ព្រះរាជបុត្រាឲ្យមកទទួលទារុណកម្មដែលយើងសមនឹងទទួលណាស់ ដើម្បីឲ្យយើងអាចនឹងមានមេត្រីភាពជាមួយព្រះជាម្ចាស់ ហើយនិងផ្លូវចូលទៅកាន់ទ្រង់បាន។

ហើយព្រះអង្គក៏បានចាក់ក្ដីស្រឡាញ់ ក្ដីអំណរ និងក្ដីសង្ឃឹមក្នុងចិត្តយើងតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ដែលទ្រង់បានប្រទានមកយើង។ អំណរនៃក្ដីសង្ឃឹមនៃសិរីល្អរបស់ព្រះជាម្ចាស់ទ្រទ្រង់យើង ទោះបើក្នុងការរងទុក្ខ ដែលការនោះនឹងនាំយើងឲ្យកាន់តែស្និទ្ធស្នាលជាមួយទ្រង់ ហើយពង្រឹងជំនឿរបស់យើងក៏ដោយ។

ទាំងនេះគឺជាព្រះពរមួយចំនួនក្នុងដំណើងល្អនៃការរាប់ជាបរិសុទ្ធតាមរយៈជំនឿក្នុងព្រះយេស៊ូវ។ តើយើងបង្រៀនអំពីព្រះពរទាំងនេះដែរឬទេ? តើយើងកំពុងនិយាយគ្នាអំពីព្រះពរទាំងនេះដែរឬទេ? តើយើងស្គាល់អំណរនៃព្រះពរទាំងនេះដែរឬទេ? ចូរអរព្រះគុណនូវក្ដីស្រឡាញ់ដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ដែលព្រះអង្គបានចាក់មកកាន់ដួងចិត្តយើង យើងមានពរព្រោះយើងមានមេត្រីភាព សុវត្ថិភាព ក្ដីសង្ឃឹម និងក្ដីអំណរដែលនឹងនៅអស់កល្បជានិច្ច។

### សេចក្ដីបន្ថែមទី១៖

# ការអំពាវនាវ១២ចំណុចចំពោះគ្រូៗដែលបង្រៀនភាពចម្រុងចម្រើន

John Piper

## កុំធ្វើឲ្យស្ថានសួគ៌ពិបាកជាងហ្នឹង

ព្រះយេស៊ូវបានមានបន្ទូលថា «ដែលមនុស្សអ្នកមានចូលទៅក្នុងនគរព្រះ នោះពិបាកណាស់»។ ពួកសិស្សនឹកស្ញើចយ៉ាងខ្លាំង ហើយអស់អ្នកដែលបង្កចលនា «ចម្រុងចម្រើន» ក៏គួរនឹកស្ញើចដែរ។ ហើយព្រះយេស៊ូវក៏កាន់តែធ្វើឲ្យពួកគាត់ងឿងស្ញើចថែមទៀតដោយបានលើកឡើងថា «ពួកអ្នកដែលជាប់ចិត្តនឹងទ្រព្យសម្បត្តិ នោះនឹងចូលទៅក្នុងនគរព្រះពិបាកណាស់ បើសត្វអូដ្ឋនឹងចូលតាមប្រហោងម្ជុល នោះងាយជាជាងអ្នកមានចូល

ទៅក្នុងនគរព្រះវិញ»។ ពួកគាត់បានឆ្លើយតបដោយមិនជឿ៖ «ចុះបើដូច្នេះ តើអ្នកណាអាចនឹងបានសង្គ្រោះ?»។ ព្រះយេស៊ូវមានបន្ទូលថា «ការនោះមនុស្សលោកធ្វើពុំកើតទេ តែព្រះទ្រង់ធ្វើកើត ដ្បិតព្រះទ្រង់អាចនឹងធ្វើកើតទាំងអស់បាន» (ម៉ាកុស ១០:២៣-២៧)។

នេះមានន័យថា ការនឹកស្មើចរបស់ពួកគាត់គឺជាការត្រឹមត្រូវ។ សត្វអូដ្ឋមិនអាចចូលតាមរន្ធម្ជុលបានឡើយ។ នេះមិនមែនជាការប្រៀបប្រដូចអំពីអ្វីដែលត្រូវការខិតខំយ៉ាងខ្លាំង ឬក៏ការលះបង់ដ៏ខ្លាំងក្លាដែរ។ វាមិនអាចទៅរួចទេ។ យើងដឹងការនេះ ព្រោះព្រះយេស៊ូវបានប្រាប់ថា *ធ្វើពុំកើតទេ!* នោះគឺជាព្រះបន្ទូលរបស់ទ្រង់ មិនមែនរបស់យើងឡើយ។ «ការនោះមនុស្សលោកធ្វើពុំកើតទេ»។ អ្វីដែលព្រះយេស៊ូវកំពុងបង្រៀនគឺ តម្រូវការឲ្យមានដួងចិត្តដែលផ្លាស់ប្រែគឺជាអ្វីដែលមនុស្សយើងមិនអាចធ្វើបានដោយខ្លួនឯង។ ដាច់ខាត! ព្រះជាម្ចាស់ត្រូវតែធ្វើការនោះ—«តែព្រះទ្រង់ធ្វើកើត»។

យើងមិនអាចធ្វើឲ្យខ្លួនឯងលែងឲ្យតម្លៃលើលុយកាក់ខ្ពស់ជាងព្រះជាម្ចាស់បានឡើយ។ ប៉ុន្តែ ព្រះជាម្ចាស់អាចធ្វើការនេះបាន។ នេះគឺជាដំណឹងល្អ។ ហើយនេះក៏គួរតែជាផ្នែកមួយនៃ

សារដែលគ្រូៗដែលអធិប្បាយពីភាពចម្រុងចម្រើនប្រកាសមុន ពួកគាត់ទៅបញ្ចុះបញ្ចូលឲ្យអ្នកស្ដាប់ក្លាយដូចជាសត្វអូដ្ឋសិន។ តើហេតុអ្វីបានជាគ្រូអធិប្បាយចង់ប្រកាសដំណឹងល្អដែលលើកទឹកចិត្តឲ្យចង់ក្លាយជាអ្នកមាន ដែលការធ្វើបែបនោះបញ្ជាក់អំពីធាតុពិតរបស់ពួកគេថា មិនសមនឹងទទួលនគរព្រះជាម្ចាស់?

## សង្គ្រោះមនុស្សចេញពីអត្តឃាតកម្ម

សាវ័ក ប៉ុល បានព្រមានប្រឆាំងនឹង*ការចង់*ក្លាយជាអ្នកមាន។ ហើយជាការកាត់ស្រាយ គាត់ក៏ព្រមានប្រឆាំងនឹងគ្រូៗដែលកូរឲ្យមានចិត្តចង់ក្លាយជាអ្នកមាន ជាជាងជួយឲ្យអ្នកស្ដាប់បោះបង់វាចោល។ គាត់បានព្រមានថា៖

> *«ឯពួកអ្នកដែលចង់ធ្វើជាអ្នកស្ដុកស្ដម្ភ នោះនឹងធ្លាក់ទៅក្នុងសេចក្ដីល្បួង នឹងអន្ទាក់ ហើយក្នុងបំណងជាច្រើន ដែលឆ្កួតផ្ដាស ហើយធ្វើទុក្ខដល់ខ្លួន ក៏ពន្លិចមនុស្សទៅក្នុងសេចក្ដីហិនវិនាសនឹងសេចក្ដីអន្តរធានវិញ ដ្បិតការដែលស្រឡាញ់ប្រាក់ នោះហើយជាមេឫសនៃសេចក្ដីអាក្រក់គ្រប់យ៉ាង ដែលអ្នកខ្លះបានឈោងតាម ហើយត្រូវល្បួងលោមឲ្យឃ្លាតចេញពីជំនឿ ទាំង*

*ចាក់ទំលុះខ្លួនគេ ដោយសេចក្ដីព្រួយលំបាកជាច្រើន» (១ធីម៉ូថេ ៦:៩-១០)។*

នេះគឺជាពាក្យពេចន៍ដ៏ធ្ងន់ធ្ងរ ប៉ុន្តែវាហាក់បីដូចជាមិនពុមានសោះក្នុងការអធិប្បាយនៃដំណឹងល្អដែលសន្យាភាពចម្រុងចម្រើន។ វាគ្មានអ្វីខុសទេដែលអ្នកក្រចង់មានភាពចម្រុងចម្រើនខ្លះៗ ដើម្បីអាចមាននូវអ្វីៗដែលពួកគាត់ត្រូវការ ហើយអាចមានចិត្តសប្បុរស ហើយប្រើប្រាស់ពេលវេលា និងកម្លាំងក្នុងការធ្វើអ្វីដែលលើកតម្កើងព្រះគ្រីស្ទ ជាជាងឲ្យខ្លួនរួចតែមួយគ្រាៗសិន។ វាមិនខុសទេក្នុងការសូមឲ្យព្រះគ្រីស្ទជួយក្នុងការនេះ។ ព្រះអង្គខ្វល់អំពីតម្រូវការរបស់យើង (ម៉ាថាយ ៦:៣៣)។

ប៉ុន្តែ យើងទាំងអស់គ្នា—អ្នកក្រ និងអ្នកមាន—សុទ្ធតែស្ថិតនៅក្រោមគ្រោះថ្នាក់តតឈប់ឈរនៃការដែលដាក់ក្ដីស្រឡាញ់ (១យ៉ូហាន ២:១៥-១៦) និងក្ដីសង្ឃឹមរបស់យើង (១ធីម៉ូថេ ៦:១៧) លើទ្រព្យសម្បត្តិជាជាងលើព្រះគ្រីស្ទ។ ការ «ចង់ធ្វើជាអ្នកស្ដុកស្ដម្ភ» នេះគឺខ្លាំងណាស់ ហើយក៏ជាការនាំឲ្យធ្វើអត្ត-ឃាតកម្មផងដែរ ហេតុដូច្នេះហើយបានជាសាវ័ក ប៉ុល ប្រើប្រាស់ពាក្យយ៉ាងខ្លាំងៗក្នុងការព្រមានយើង។ សេចក្ដីអំពាវនាវរបស់ខ្ញុំ

គឺ សូមឲ្យគ្រូៗដែលអធិប្បាយភាពចម្រុងចម្រើនធ្វើដូចនោះដែរ។

## ការព្រមានប្រឆាំងនឹងការវិនិយោគដ៏ទន់ខ្សោយ

ព្រះយេស៊ូវព្រមានទាស់នឹងការព្យាយាមប្រមូលទ្រព្យសម្បត្តិទុកលើផែនដីនេះ ដែលតាមរយៈការនេះព្រះអង្គកំពុងប្រាប់យើងឲ្យធ្វើជា*អ្នកដែលឲ្យ*ជាង*អ្នកដែលទុក*។ «កុំឲ្យប្រមូលទ្រព្យសម្បត្តិ ទុកសម្រាប់ខ្លួន នៅផែនដី ជាកន្លែងដែលមានកន្លាត នឹងច្រែះស៊ីបំផ្លាញ ហើយចោរទំលុះប្លន់នោះឡើយ ត្រូវប្រមូលទ្រព្យសម្បត្តិ ទុកសម្រាប់ខ្លួន នៅឯស្ថានសួគ៌វិញ ដែលជាកន្លែងគ្មានកន្លាត ឬច្រែះស៊ីបំផ្លាញឡើយ ក៏គ្មានចោរទំលុះ ឬប្លន់ផង» (ម៉ាថាយ ៦:១៩-២០)។

ពិតណាស់ យើងទាំងអស់គ្នាបានទុកនូវអ្វីខ្លះៗ។ ព្រះយេស៊ូវបានសន្មតការនោះ។ ព្រះអង្គមិនរំពឹងថា (លើកលែងតែកាលៈទេសៈដ៏ខ្លាំងមួយចំនួន) ការឲ្យរបស់យើងនឹងត្រូវឈានដល់ថ្នាក់ថា យើងនឹងលែងមានលទ្ធភាពក្នុងការឲ្យទៀតនោះឡើយ។ ទំនងនឹងមានថ្ងៃមួយដែលយើងនឹងស្លាប់ជំនួសនរណាម្នាក់ ហើយយើងនឹងលែងមានលទ្ធភាពក្នុងការឲ្យទៀត។ ប៉ុន្តែ ជាទូទៅព្រះយេស៊ូវរំពឹងឲ្យយើងរស់នៅក្នុងរបៀបមួយដែលមានគំរូនៃ

ការបន្តធ្វើការ រកលុយ ហើយរស់នៅដោយសាមញ្ញៗ និងបន្តឲ្យ។

ប៉ុន្តែ ដោយសារយើងងាយធ្លាក់ក្នុងអន្លង់នៃការលោភលន់ ហេតុដូច្នេះហើយបានជាព្រះយេស៊ូវជ្រាបថាទ្រង់ត្រូវតែព្រមាន យើងឲ្យប្រឆាំងនឹងការ «ប្រមូលទ្រព្យសម្បត្តិទុកសម្រាប់ខ្លួននៅផែនដី»។ មើលទៅវាហាក់បីដូចជាបានចំណេញ ប៉ុន្តែវានឹងគ្រាន់តែនាំទៅកាន់ការបាត់បង់ប៉ុណ្ណោះ («កន្លាត ឬច្រែះស៊ីបំផ្លាញទ្បើយ ក៏គ្មានចោរទំលុះ ឬប្លន់ផង»)។ សេចក្តីអំពាវនាវរបស់ខ្ញុំគឺ សូមឲ្យសេចក្តីព្រមានរបស់ព្រះយេស៊ូវបានឮខ្ទរយ៉ាងខ្លាំងនៅក្នុងមាត់របស់គ្រូៗដែលអធិប្បាយភាពចម្រុងចម្រើនផង។

## ចូរចម្រើនការឲ្យ

ការក្លាយជាអ្នកមានគឺមិនមែនជាមូលហេតុនៃការធ្វើការនោះទេ។ សាវ័ក ប៉ុល បានលើកឡើងថា យើងមិនគួរលួចគេឡើយ។ ចំណុចផ្ទុយពីនេះគឺ យើងត្រូវខំធ្វើការឲ្យខ្លាំងជាមួយនឹងដៃយើង។ ប៉ុន្តែ ចំណុចចម្បងគឺមិនមែនគ្រាន់តែធ្វើការ ដើម្បីប្រមូល ឬក៏សូម្បីតែដើម្បី*មាន*នោះដែរ។ គោលបំណងគឺ «ដើម្បីឲ្យ*មានអ្វីនឹងចែក*»។

កណ្ឌគម្ពីរ អេភេសូរ ៤:៨ បានចែងថា «អ្នកណាដែលធ្លាប់

លួច ត្រូវឈប់លួចទៅ ស៊ូឲ្យអ្នកនោះទ្រាំនឿយហត់ជាជាង ទាំងធ្វើការល្អដោយដៃខ្លួនវិញ *ដើម្បីឲ្យមានអ្វីនឹងចែកដល់អ្នកណាដែលត្រូវការផង*»។ នេះមិនមែនជាហេតុផលដែលយើងយកមកប្រើប្រាស់ ដើម្បីក្លាយជាអ្នកមាន ឬដើម្បីឲ្យយើងអាចកាន់តែចេះឲ្យនោះទេ។ តែជាការត្រាស់ហៅឲ្យយើងរកថែមទៀត ដើម្បីឲ្យយើងអាចកាន់តែចេះឲ្យថែមទៀតទេតើ។ គ្មានមូលហេតុណាដែលគួរបណ្តាលឲ្យបុគ្គលណាម្នាក់ដែលកាន់តែរកស៊ីមានបានក៏គួរកាន់តែរស់នៅក្នុងលក្ខណៈដែលកាន់តែហ៊ឺហាៗជាងមុននោះទេ។ សាវ័ក ប៉ុល ទំនងនឹងលើកឡើងថា ចូរឲ្យយើងមានការរិះថាំក្នុងការចាយវាយរបស់យើងចុះ ហើយចេះឲ្យនូវរាល់អ្វីៗទាំងអស់ទៀត។

ខ្ញុំមិនអាចសន្មតថា លោកអ្នកគួរ «ចំណាយ» ប៉ុណ្ណានោះទេ។ ប៉ុន្តែ ក្នុងរាល់ខគម្ពីរដែលយើងកំពុងតែមើលក្នុងជំពូកនេះទាំងអស់សុទ្ធតែជំរុញចិត្តឲ្យយើងរស់នៅដោយសាមញ្ញៗ ហើយឲ្យយើងកាន់តែមានចិត្តសប្បុរសក្នុងការកាន់តែឲ្យថែមទៀត មិនមែនឲ្យយើងកាន់តែប្រមូលទ្រព្យសម្បត្តិទុកនោះឡើយ។ ពេលដែលព្រះយេស៊ូវមានបន្ទូលថា «ចូរលក់របស់ដែលអ្នករាល់គ្នាមានទាំងប៉ុន្មាន ហើយចែកឲ្យទៅជាទានចុះ» (លូកា ១២:៣៣)

ទ្រង់ហាក់បីដូចជាកំពុងនិយាយបញ្ឆិតបញ្ឆៀងថា ពួកសិស្ស មិនមែនជាអ្នកមានដល់ថ្នាក់អាចឲ្យចេញពីការសល់នោះទេ។ តែហាក់បីដូចជា ពួកគាត់មានតិចណាស់ ដល់ថ្នាក់ត្រូវលក់អ្វីមួយ ដើម្បីអាចលទ្ធភាពឲ្យនូវអ្វីមួយបាន។

តើហេតុអ្វីបានជាគ្រូអធិប្បាយចង់លើកទឹកចិត្តអ្នកស្តាប់ឲ្យគិតថា ពួកគាត់គួរមានទ្រព្យសម្បត្តិ ដើម្បីឲ្យខ្លួនអាចក្លាយជាអ្នកឲ្យដ៏សប្បុរស? ហេតុអ្វីបានជាមិនលើកទឹកចិត្តឲ្យពួកគាត់បន្តរស់នៅដោយសាមញ្ញៗ ហើយធ្វើជាអ្នកឲ្យដោយសប្បុរសទៅវិញ? តើការនេះនឹងមិនបន្ថែមលើទីបន្ទាល់នៃការឲ្យរបស់ពួកគាត់ថា ព្រះគ្រីស្ទគឺជាទ្រព្យសម្បត្តិរបស់ពួកគាត់ មិនមែនអ្វីៗដែលពួកគាត់មាននោះទេ?

## ថែរក្សាជំនឿលើព្រះជាម្ចាស់

មូលហេតុដែលអ្នកនិពន្ធកណ្ឌគម្ពីរហេព្រើរប្រាប់ឲ្យយើងចេះស្កប់ចិត្តនឹងអ្វីដែលយើងមានគឺ ព្រោះចំណុចផ្ទុយសន្មតថា យើងមានជំនឿតិចក្នុងក្តីសន្យានានារបស់ព្រះជាម្ចាស់។ គាត់បានសរសេរថា «ចូរឲ្យកិរិយាដែលអ្នករាល់គ្នាប្រព្រឹត្ត បានឥតលោភឡើយ ឲ្យស្កប់ចិត្តនឹងរបស់ដែលមានហើយប៉ុណ្ណោះ

ចុះ ដ្បិតទ្រង់មានបន្ទូលថា "អញនឹងមិនចាកចេញពីឯង ក៏មិនបោះបង់ចោលឯងឡើយ" បានជាយើងរាល់គ្នាអាចនឹងនិយាយដោយក្លាហានថា "ខ្ញុំមិនព្រមខ្លាចឡើយព្រោះព្រះអម្ចាស់ទ្រង់ជាជំនួយខ្ញុំ តើមនុស្សនឹងធ្វើដល់ខ្ញុំជាយ៉ាងណាបាន?"។» (ហេព្រើរ ១៣:៥-៦)។

មួយវិញសោត យើងអាចទុកចិត្តក្នុងព្រះអង្គឲ្យធ្វើជាអ្នកជួយយើង។ ទ្រង់នឹងផ្គត់ផ្គង់ និងការពារ។ ក្នុងអត្ថន័យបែបនេះ មានកម្រិតនៃភាពចម្រុងចម្រើនមួយដែលទ្រង់នឹងឲ្យដល់យើង។ «ឯព្រះវរបិតានៃអ្នករាល់គ្នា ដែលគង់នៅស្ថានសួគ៌ ទ្រង់ជ្រាបហើយថាអ្នករាល់គ្នាត្រូវការនឹងរបស់ទាំងនោះដែរ» (ម៉ាថាយ ៦:៣២)។ ប៉ុន្តែ ម្យ៉ាងវិញទៀត ពេលដែលខគម្ពីរនេះលើកឡើងថា «ចូរឲ្យកិរិយាដែលអ្នករាល់គ្នាប្រព្រឹត្ត បានឥតលោភឡើយ ឲ្យស្កប់ចិត្តនឹងរបស់ដែលមានហើយប៉ុណ្ណោះចុះ» គឺ*ព្រោះ*ព្រះជាម្ចាស់បានសន្យាថាទ្រង់នឹងមិនចាកចេញចោលយើងឡើយ។ ដាច់ខាត! នេះត្រូវតែមានន័យថា យើងមានការងាយស្រួលណាស់ក្នុងការចាកចេញពីការទុកចិត្តលើព្រះជាម្ចាស់សម្រាប់*តម្រូវការ*យើងទៅកាន់ការប្រើព្រះជាម្ចាស់សម្រាប់អ្វីៗដែលយើងចង់បានវិញ។

បន្ទាត់រវាង «សូមឲ្យព្រះជាម្ចាស់ជួយខ្ញុំផង» និង «សូមព្រះ

ជាម្ចាស់ជួយឲ្យខ្ញុំក្លាយជាអ្នកមាន» គឺជាបន្ទាត់ពិត ហើយអ្នកនិពន្ធកណ្ឌគម្ពីរហេព្រើរមិនចង់ឲ្យយើងឆ្លងកាត់បន្ទាត់នេះទេ។ គ្រូអធិប្បាយគួរជួយអ្នកស្ដាប់របស់គាត់ចងចាំ និងឃើញខ្សែបន្ទាត់នោះ ជាជាងនិយាយហាក់បីដូចជាវាមិននៅទីនោះសោះ។

## កាត់គ្រោះថ្នាក់នៃការឈ្លក់ចោល

ព្រះយេស៊ូវបានព្រមានថា ដំណឹងល្អដែលជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលទ្រង់សព្វព្រះហឫទ័យប្រើប្រាស់សម្រាប់ឲ្យជីវិតដល់យើង ឯទ្រព្យសម្បត្តិវិញអាចច្របាច់កយើងរហូតដល់ស្លាប់បានដែរ។ ព្រះអង្គមានបន្ទូលថា វាប្រៀបដូចជាគ្រាប់ពូជមួយដែលដុះឡើងនៅក្នុងចំណោមបន្លា៖ «គឺអស់អ្នកដែលបានឮ រួចចេញទៅ នោះសេចក្ដីខ្វល់ខ្វាយ នឹងទ្រព្យសម្បត្តិ ហើយនិងសេចក្ដីស្រើបស្រាលនៅជីវិតនេះ ក៏ចូលមកខ្ទប់ជិត មិនឲ្យបង្កើតជាផលផ្លែ» (លូកា ៨:១៤)។

គ្រូៗដែលអធិប្បាយភាពចម្រុងចម្រើនគួរតែព្រមានអ្នកស្ដាប់ថា មានភាពចម្រុងចម្រើនផ្នែកហិរញ្ញវត្ថុមួយបែបដែលអាចនឹងច្របាច់កពួកគាត់រហូតដល់ស្លាប់ខាងឯវិញ្ញាណបាន។ តើហេតុអ្វីបានជាយើងចង់លើកទឹកចិត្តឲ្យអ្នកស្ដាប់សង្វាតដេញចាប់នូវ

អ្វីដែលព្រះយេស៊ូវបានព្រមានថាអាចនឹងធ្វើឲ្យពួកគាត់មិនអាចបង្កើតផលផ្លែបាន?

## ចូររក្សាទុកនូវអំបិល និងពន្លឺ

តើអ្វីទៅធ្វើឲ្យគ្រីស្ទបរិស័ទជាអំបិលនៃផែនដី និងជាពន្លឺនៃលោកីយ៍? មិនមែនទ្រព្យសម្បត្តិទេ។ ការចង់បានទ្រព្យសម្បត្តិ និងការសង្វាតដេញតាមទ្រព្យសម្បត្តិមានរសជាតិ និងរូបភាពដូចលោកីយ៍នេះ។ ការប្រាថ្នាចង់ក្លាយជាអ្នកមានធ្វើឲ្យយើង*ដូចជា*លោកីយ៍ មិនមែនខុសពីនោះឡើយ។ នៅក្នុងចំណុចដែលយើងគួរមានរសជាតិខុសពីគេ យើងបែរជាមានការលោយទ្បំនៃការច្រ-ណែនដូចដែលលោកីយ៍មានទៅវិញ។ ក្នុងលក្ខណៈនេះ យើងមិនបានឲ្យអ្វីទៅកាន់លោកីយ៍ដែលខុសពីអ្វីដែលវាបានទទួលជឿរួចទៅហើយនោះទេ។

ចំណុចគ្រោះថ្នាក់ដ៏ធំបំផុតនៃការអធិប្បាយភាពចម្រុងចម្រើន គឺថា បុគ្គលនោះមិនចាំបាច់មានការបំផ្លាស់បំប្រែខាងឯព្រលឹងវិញ្ញាណ ដើម្បីឱបក្រសោបវាទេ បុគ្គលម្នាក់នោះគ្រាន់តែត្រូវការមានចិត្តលោភលន់តែប៉ុណ្ណោះ។ ការយកនាមព្រះយេស៊ូវមកប្រើប្រាស់សម្រាប់ឲ្យក្លាយជាអ្នកមានគឺមិនមែនជាអំបិលនៃផែនដី

និងជាពន្លឺនៃលោកីយ៍ទេ។ តាមរយៈការនេះ លោកីយ៍នឹងគ្រាន់តែឃើញការឆ្លុះមុខវាវិញ។ ហើយបើពួកគេមាន «ការបំផ្លាស់» បែបនោះ នោះមានន័យថា ពួកគេមិនបានបំផ្លាស់បំប្រែយ៉ាងពិតប្រា-កដទេ ប៉ុន្តែគ្រាន់តែបានដាក់ឈ្មោះថ្មីលើជីវិតចាស់តែប៉ុណ្ណោះ។

បរិបទនៃព្រះបន្ទូលរបស់ព្រះយេស៊ូវបង្ហាញថា ទ្រង់បានបង្ហាញពីធាតុពិតនៃអំបិល និងពន្លឺ។ វាជាការមានអំណរក្នុងការស្ម័គ្រចិត្តរងទុក្ខសម្រាប់ព្រះគ្រីស្ទ។ ខាងក្រោមនេះគឺជាអ្វីដែលព្រះយេស៊ូវបានមានបន្ទូល៖

*«អ្នករាល់គ្នាមានពរ ក្នុងកាលដែលគេជេរ បៀតបៀន ហើយនិយាយបង្ខុសគ្រប់ទាំងសេចក្ដីអាក្រក់ ពីអ្នករាល់គ្នា ដោយព្រោះខ្ញុំ ចូរមានចិត្តអំណរ ហើយរីករាយជាខ្លាំងចុះ ដ្បិតអ្នករាល់គ្នាមានរង្វាន់ជាធំនៅឯស្ថានសួគ៌ ពីព្រោះគេក៏បានធ្វើទុក្ខដល់ពួកហោរា ដែលនៅមុនអ្នករាល់គ្នា បែបដូច្នេះដែរ។ អ្នករាល់គ្នាជាអំបិលនៃផែនដី បើអំបិលបាត់ជាតិប្រៃហើយ នោះតើនឹងយកអ្វី ដើម្បីធ្វើឲ្យប្រៃឡើងវិញបាន ជារបស់គ្មានប្រយោជន៍ទៀតសោះ មានតែបោះបង់ចោលទៅក្រៅ ឲ្យមនុស្សដើរជាន់ប៉ុណ្ណោះ អ្នករាល់គ្នាជាពន្លឺនៃលោកីយ៍ ឯទីក្រុង*

*ណាដែលនៅលើភ្នំ នោះលោកមិនកំបាំងទេ» (ម៉ាថាយ ៥:១១-១៤)។*

ការដែលយើងស្រឡាញ់ទ្រព្យសម្បត្តិដូចដែលលោកីយ៍ស្រឡាញ់គឺមិនមែនជាចំណុចដែលនឹងនាំឲ្យពួកគេ*ភ្លក់រសជាតិ*អំបិល និងឃើញពន្លឺរបស់ព្រះគ្រីស្ទក្នុងយើងឡើយ។ ផ្ទុយពីនោះវិញ ការភ្លក់ និងការឃើញកើតមានឡើងពេលដែលគ្រីស្ទបរិស័ទស្ម័គ្រចិត្ត និងមានលទ្ធភាពស្រឡាញ់អស់អ្នកដែលកំពុងឆ្លងកាត់ទុក្ខលំបាក ហើយខណៈពេលនោះក៏នៅមានអំណរពីព្រោះរង្វាន់របស់ពួកគាត់គឺនៅឯស្ថានសួគ៌។ «*ចូរមានចិត្តអំណរ* ហើយរីករាយជាខ្លាំងចុះ [ក្នុងភាពលំបាក]...អ្នករាល់គ្នាជាអំបិលនៃផែនដី»។ រសជាតិប្រៃគឺជាការភ្លក់អំណរក្នុងទុក្ខលំបាក។ នេះគឺជាជីវិត*ដ៏ប្លែក*ពីគេដែលលោកីយ៍អាចភ្លក់ថាខុសគ្នាបាន។

មនុស្សយើងមិនអាចយល់ពីជីវិតបែបនេះបានឡើយ។ វាជាជីវិតអធិធម្មជាតិ។ ប៉ុន្តែ ការទាក់ទាញមនុស្សដោយសន្យាភាពចម្រុងចម្រើនវាគ្រាន់តែជារឿងធម្មតាទេ។ វាមិនមែនជាសាររបស់ព្រះយេស៊ូវនោះទេ។ វាក៏មិនមែនជាអ្វីដែលទ្រង់សុគតសម្រាប់បំពេញសម្រេចដែរ។

# កុំលាក់តម្លៃ

ចំណុចខ្វះខាតមួយចេញពីការអធិប្បាយភាពចម្រុងចម្រើនគឺត្រង់ចំណុចពិតថា ព្រះគម្ពីរសញ្ញាថ្មីផ្តោតយ៉ាងខ្លាំងលើតម្រូវការនៃការរងទុក្ខ ជាជាងលើចំណុចនៃការចម្រុងចម្រើនផ្នែកសម្ភារៈនិយម។

ព្រះយេស៊ូវបានមានបន្ទូលថា «ចូរនឹកចាំពីពាក្យដែលខ្ញុំបានប្រាប់រួចហើយថា បាវមិនមែនធំជាងចៅហ្វាយទេ បើគេបានបៀតបៀនដល់ខ្ញុំ នោះគេនឹងបៀតបៀនដល់អ្នករាល់គ្នា ហើយបើគេបានកាន់តាមពាក្យខ្ញុំ នោះគេនឹងកាន់តាមពាក្យរបស់អ្នករាល់គ្នាដែរ» (យ៉ូហាន ១៥:២០)។ ឬក៏ជាថ្មីម្តងទៀត ទ្រង់បានលើកឡើងថា «បើសិនជាគេហៅម្ចាស់ផ្ទះថា បេលសេប៊ូល នោះចំណង់បើពួកអ្នកនៅផ្ទះនោះទាំងប៉ុន្មាន តើគេ*នឹងហៅយ៉ាងនោះលើសជាងអម្បាលម៉ានទៅទៀត*» (ម៉ាថាយ ១០:២៥)។

កាលសាវ័ក ប៉ុល ចេញដំណើរបេសកកម្ម គាត់បានរម្លឹកអ្នកជឿថ្មីថ្មោងថា «ត្រូវតែទ្រាំរងទុក្ខវេទនាជាច្រើន ទើបនឹងចូលទៅក្នុងនគរព្រះបាន» (កិច្ចការ ១៤:២២)។ ហើយគាត់បានប្រាប់អ្នកជឿនៅឯទីក្រុងរ៉ូមថា ការរងទុក្ខគឺជាផ្នែកមួយនៃការទទួលបានមរតកដ៏នៅអស់កល្បជានិច្ចបាន៖

*«ហើយព្រះវិញ្ញាណទ្រង់ក៏ធ្វើបន្ទាល់នឹងវិញ្ញាណយើងថា យើងជាកូនរបស់ព្រះ បើសិនណាជាកូនព្រះហើយ នោះយើងក៏បានគ្រងមរតកដែរ គឺជាអ្នកគ្រងមរតកនៃព្រះជាមួយនឹងព្រះគ្រីស្ទផង ឲ្យតែយើងទទួលរងទុក្ខជាមួយនឹងទ្រង់ចុះ ដើម្បីឲ្យបានដំកើងឡើងជាមួយនឹងទ្រង់ដែរ។ ខ្ញុំរាប់អស់ទាំងសេចក្តីទុក្ខលំបាកនៅជាន់នេះថា ជាសេចក្តីមិនគួរប្រៀបផ្ទឹមនឹងសិរីល្អ ដែលនឹងបើកសម្តែងមកឲ្យយើងរាល់គ្នាឃើញនោះទេ» (រ៉ូម ៨:១៦-១៨)។*

សាវ័ក ពេត្រុស ក៏បានលើកឡើងផងដែរថា ការរងទុក្ខគឺជារឿងធម្មតាក្នុងការទទួលបានព្រះពរដ៏នៅអស់កល្បជានិច្ចរបស់ព្រះជាម្ចាស់៖

*«ពួកស្ងួនភ្ងាអើយ កុំឲ្យមានប្លែកក្នុងចិត្ត ដោយភ្លើងដ៏ក្តៅក្រហាយ ដែលកំពុងតែល្បងអ្នករាល់គ្នា ទុកដូចជាកើតមានសេចក្តីចំឡែកនោះឡើយ ត្រូវអរសប្បាយវិញ ដោយព្រោះមានចំណែកក្នុងការរងទុក្ខរបស់ព្រះគ្រីស្ទ ដើម្បីឲ្យអ្នករាល់គ្នាបានត្រេកអររីករាយជាខ្លាំង ក្នុង*

*កាលដែលសិរីល្អទ្រង់លេចមក បើសិនជាគេតិះដៀល អ្នករាល់គ្នា ដោយព្រោះព្រះគ្រីស្ទ នោះមានពរហើយ ពីព្រោះព្រះវិញ្ញាណដ៏មានសិរីល្អ គឺជាព្រះវិញ្ញាណនៃ ព្រះ ទ្រង់សណ្ឋិតលើអ្នករាល់គ្នាហើយ» (១ពេត្រុស ៤:១២-១៤)។*

ការរងទុក្ខគឺជាការលះបង់ដ៏ធម្មតាទេនៃការកោតខ្លាចព្រះជាម្ចាស់។ «ឯអស់អ្នកណាដែលចង់រស់ ដោយគោរពប្រតិបត្តិដល់ព្រះគ្រីស្ទយេស៊ូវ នោះនឹងត្រូវមានសេចក្តីបៀតបៀនដែរ» (២ធីម៉ូថេ ៣:១២)។ ខ្ញុំដឹងថាពាក្យពេចន៍លើការរងទុក្ខផ្លាស់ពីនេះទៅនោះរវាងអត្ថន័យនៃការរងទុក្ខជាទូទៅដែលជាលទ្ធផលនៃការធ្លាក់ក្នុងអំពើបាប (រ៉ូម ៨:១៨-២៥) និងលើអត្ថន័យដ៏ចំៗដោយសារមនុស្សយើងជាអ្នកជំទាស់។ ប៉ុន្តែ បើទាក់ទងទៅនឹងគោលបំណងរបស់ព្រះជាម្ចាស់ក្នុងការរងទុក្ខរបស់យើង វាគ្មានចំណុចខុសគ្នាដ៏សម្បើមអម្បាលម៉ាននោះទេ។

គ្រូៗដែលអធិប្បាយភាពចម្រុងចម្រើនគួរតែលើកឡើងអំពីចំណុចសំខាន់នៃអ្វីដែលព្រះយេស៊ូវ និងពួកសាវ័កបានបង្រៀនទាក់ទងនឹងការរងទុក្ខ ថាវាគឺជាអ្វីដែលចាំបាច់។ ដាច់ខាត!

សាវ័ក ប៉ុល បានមានប្រសាសន៍ថា វាត្រូវតែកើតឡើង (កិច្ច-ការ ១៤:២២) ហើយបើយើងមិនប្រាប់អ្នកជឿថ្មីៗតាំងពីដើមមក នោះមានន័យថា យើងនាំឲ្យពួកគាត់ស្ថិតនៅក្នុងគ្រោះថ្នាក់ហើយ។ សូម្បីតែព្រះយេស៊ូវក៏បានលើកឡើងអំពីចំណុចនេះតាំងពីមុនមានការទទួលជឿ ដើម្បីឲ្យអស់អ្នកដែលទំនងនឹងបើកចិត្តទទួលជឿទាំងនោះយល់អំពីការលះបង់ជាមុនសិន «ដូច្នេះ អស់អ្នកណាក្នុងពួកអ្នករាល់គ្នា ដែលមិនលះអាល័យពីរបស់ទ្រព្យខ្លួនទាំងអស់ នោះធ្វើជាសិស្សខ្ញុំមិនបានទេ» (លូកា ១៤:៣៣)។

## ចូរគាំទ្រតម្លៃនៃការរងទុក្ខ

ព្រះគម្ពីរសញ្ញាថ្មីមិនគ្រាន់តែលើកឡើងយ៉ាងច្បាស់ៗថា ការរងទុក្ខគឺជាចំណុចចាំបាច់សម្រាប់អ្នកដើរតាមព្រះគ្រីស្ទប៉ុណ្ណោះទេ ប៉ុន្តែក៏បានពន្យល់យ៉ាងពេញទីអំពីមូលហេតុថា ហេតុអ្វីបានជាវាដូច្នោះ ហើយអ្វីទៅជាគោលបំណងរបស់ព្រះជាម្ចាស់ក្នុងការនោះ។ គោលបំណងទាំងនោះគឺសំខាន់ណាស់សម្រាប់ឲ្យអ្នកជឿបានយល់ដឹង។ ព្រះជាម្ចាស់បានបើកសម្ដែង ដើម្បីជួយឲ្យយើងយល់អំពីមូលហេតុដែលយើងរងទុក្ខ ហើយដើម្បីបន្សុទ្ធយើងដូចមាសនៅក្នុងភ្លើង។

ក្នុងជំពូកនៃការរងទុក្ខក្នុងសៀវភៅជាភាសាអង់គ្លេស *Let the Nations Be Glad* ខ្ញុំបានរៀបរាប់អំពីគោលបំណងទាំងនោះ។ ត្រង់នេះខ្ញុំនឹងគ្រាន់តែលើកឡើងត្រួសៗ ហើយនិយាយទៅកាន់គ្រូៗដែលអធិប្បាយភាពចម្រុងចម្រើនដូចតទៅ៖ សូមលើកឡើងនូវសេចក្ដីបង្រៀនដែលមានក្នុងព្រះគម្ពីរក្នុងសាររបស់លោកអ្នកផង។ អ្នកជឿថ្មីៗត្រូវតែដឹងអំពីមូលហេតុដែលព្រះជាម្ចាស់គ្រោងការរងទុក្ខសម្រាប់ពួកគេ។

១. ការរងទុក្ខជួយឲ្យចម្រើនជំនឿ និងភាពបរិសុទ្ធ។
២. ការរងទុក្ខចម្រើនភាពអរសប្បាយរបស់យើងក្នុងព្រះជាម្ចាស់។
៣. ការរងទុក្ខគឺជាការលះបង់នៃការធ្វើឲ្យអ្នកដទៃក្លាហានឡើង។
៤. ការរងទុក្ខបំពេញនូវអ្វីដែលការឈឺចាប់របស់ព្រះគ្រីស្ទខ្វះខាត។
៥. ការរងទុក្ខធ្វើឲ្យអ្នកជឿត្រាប់តាមបញ្ញត្តិរបស់ទ្រង់ឲ្យចេញទៅបង្កើតសិស្ស។
៦. ការរងទុក្ខបង្ហាញឲ្យឃើញភាពឧដុង្គឧត្ដមរបស់ព្រះគ្រីស្ទ។

## ចូរបង្ហាត់ឲ្យពួកគាត់ចេញទៅ

ការដែលព្រះគ្រីស្ទបានយាងមកកាន់លោកីយ៍នេះបាននាំឲ្យមានការបំផ្លាស់បំប្រែផ្នែកមូលដ្ឋាន។ រហូតមកដល់ពេលនោះ ព្រះជាម្ចាស់បានផ្ដោតតែលើព័ន្ធកិច្ចនៃការសង្គ្រោះសាសន៍អ៊ីស្រាអែល ហើយមានតែម្ដងម្កាលប៉ុណ្ណោះដែលព្រះអង្គបានផ្ដោតទៅលើសាសន៍ដទៃៗទៀត។ សាវ័ក ប៉ុល បានមានប្រសាសន៍ថា «ក្នុងកាលជំនាន់មនុស្សពីបុរាណ នោះទ្រង់បានអនុញ្ញាតឲ្យគ្រប់ទាំងសាសន៍ដើរតាមផ្លូវរបស់គេរៀងខ្លួន» (កិច្ចការ ១៤:១៦)។ គាត់បានហៅពេលវេលានោះថាជា «គ្រាខ្លៅល្ងង់»។ «ពីដើម ព្រះទ្រង់បានទតរំលងគ្រាខ្លៅល្ងង់មែន តែឥឡូវនេះ ទ្រង់ត្រាស់បង្គាប់ដល់មនុស្សទាំងអស់ នៅគ្រប់អន្លើឲ្យប្រែចិត្តវិញ» (កិច្ចការ ១៧:៣០)។ ឥឡូវនេះ ព្រះជាម្ចាស់បានប្ដូរការផ្ដោតពីសាសន៍អ៊ីស្រាអែលទៅកាន់សាសន៍ដទៃ។ ព្រះយេស៊ូវបានមានបន្ទូលថា «នគរព្រះនឹងត្រូវហូតចេញពីអ្នករាល់គ្នា [អ៊ីស្រាអែល] ប្រគល់ទៅឲ្យសាសន៍១ទៀត ដែលគេនឹងបង្កើតផល [អ្នកដើរតាមព្រះមេស្ស៊ី] របស់នគរនោះ» (ម៉ាថាយ ២១:៤៣)។ ការមានចិត្តរឹងបានធ្លាក់មកលើសាសន៍អ៊ីស្រាអែលរហូតទាល់តែចំនួននៃសាសន៍នានាបានចូលមក (រ៉ូម ១១:២៥)។

ចំណុចខុសគ្នាដ៏ចម្បងមួយរវាងពេលវេលាទាំងពីរនេះគឺ ក្នុងព្រះគម្ពីរសញ្ញាចាស់ ព្រះជាម្ចាស់បានថ្វាយសិរីល្អដល់ទ្រង់ផ្ទាល់ជាចម្បងតាមរយៈការដែលទ្រង់ប្រទានពរដល់សាសន៍អ៊ីស្រា-អែល ដើម្បីឲ្យសាសន៍នានាឃើញ ហើយដឹងថា ព្រះយេហូវ៉ាទ្រង់ជាព្រះ។ «សូមឲ្យ [ព្រះជាម្ចាស់] សម្រេចតាមសេចក្តីត្រឹមត្រូវចំពោះយើង...ពួកអ៊ីស្រាអែលជារាស្ត្ររបស់ទ្រង់ផង តាមត្រូវការរាល់តែថ្ងៃ *ប្រយោជន៍ឲ្យអស់ទាំងសាសន៍នៅផែនដី បានដឹងថា ព្រះយេហូវ៉ាទ្រង់ជាព្រះ*ឥតមានព្រះឯណាទៀតសោះឡើយ» (១ពង្សាវតារក្សត្រ ៨:៥៩-៦០)។ នៅគ្រានោះ ព្រះជាម្ចាស់មិនទាន់បានចាត់ឲ្យសាសន៍អ៊ីស្រាអែលចេញទៅធ្វើ «មហាបេសក-កម្ម» ដើម្បីនាំសាសន៍នានានៅឡើយទេ ប៉ុន្តែព្រះអង្គបានបំពាក់សិរីល្អលើពួកគេ ដើម្បីឲ្យសាសន៍ដទៃឃើញចំណុចអស្ចារ្យរបស់សាសន៍អ៊ីស្រាអែល ហើយមករកសាសន៍អ៊ីស្រាអែល។

ដូច្នេះ ពេលដែលស្តេច សាឡូម៉ូន សង់ព្រះវិហាររបស់ព្រះអម្ចាស់ គឺវាស្អាតណាស់ហើយបានស្រោបមាសជាច្រើនផង។

> *«ឯខាងក្នុងទីបរិសុទ្ធបំផុត នោះមានបណ្តោយ២០ហត្ថ នឹងទទឹង២០ហត្ថ ហើយកំពស់២០ហត្ថដែរ ទ្រង់ស្រោបទីនោះដោយមាសសុទ្ធ ហើយអាសនាដែលធ្វើពី*

*ឈើតាត្រៅក៏ស្រោបដូច្នោះដែរ ដូច្នេះ សាឡូម៉ូន បានស្រោបប៉ែកខាងក្នុងនៃព្រះវិហារដោយមាសសុទ្ធ ហើយទ្រង់សន្ធឹងច្រវាក់មាស ខាំងពីមុខទីបរិសុទ្ធបំផុត ដែលបានស្រោបមាសដែរ» (១ពង្សាវតារក្សត្រ ៦:២០-២១)។*

ហើយពេលទ្រង់ដាក់គ្រឿងសង្ហារិម វាក៏មានមាសយ៉ាងច្រើនដែរ។

*«រួចមក សាឡូម៉ូន ក៏ធ្វើគ្រប់អស់ទាំងគ្រឿងប្រដាប់ដែលនៅក្នុងព្រះវិហារនៃព្រះយេហូវ៉ា គឺជាអាសនាមាស តុមាសសម្រាប់ដាក់នំបុ័ងតាំងទុក ជើងចង្កៀងមាសសុទ្ធទាំងប៉ុន្មាន ៥ខាងស្តាំ ៥ខាងឆ្វេង នៅមុខទីបរិសុទ្ធបំផុត ព្រមទាំងផ្កា ចង្កៀង នឹងឃ្នាបប្រឆេះធ្វើពីមាស ហើយទាំងឆ្នាំង ដង្កៀប ចានគោម កូនចាន នឹងពានធ្វើពីមាសសុទ្ធទាំងអស់ ក៏ធ្វើត្រចៀកទ្វារមាសសម្រាប់ទ្វារនៃព្រះវិហារខាងក្នុង គឺជាទ្វារនៃទីបរិសុទ្ធបំផុត ហើយសម្រាប់ទ្វារព្រះវិហារខាងក្រៅដែរ» (១ពង្សាវតារក្សត្រ ៧:៤៨-៥០)។*

ស្ដេច សាឡូម៉ូន បានចំណាយពេលប្រាំពីរឆ្នាំក្នុងការសាងសង់ព្រះវិហាររបស់ព្រះជាម្ចាស់។ បន្ទាប់មក ទ្រង់បានចំណាយពេលដប់បីឆ្នាំក្នុងការសង់ព្រះដំណាក់របស់ទ្រង់ (១ពង្សាវតារក្សត្រ ៦:៣៨-៧:១)។ ហើយដំណាក់នោះក៏ស្អាតដែរដោយមានមាសជាច្រើន និងត្បូងថ្មថ្លៃៗ (១ពង្សាវតារក្សត្រ ៧; ១០)។

បន្ទាប់មក ពេលដែលគេបានសាងសង់រួចហើយកណ្ឌគម្ពីរពង្សាវតារក្សត្រទី១ជំពូក១០បានលើកឡើងអំពីភាពស្ដុកស្ដម្ភខណៈពេលដែលមហាក្សត្រីស្រុកសេបា (ដែលតំណាងឲ្យពួជសាសន៍នានា) បានឃើញសិរីល្អនៃព្រះវិហាររបស់ព្រះជាម្ចាស់ និងព្រះដំណាក់របស់ស្ដេច សាឡូម៉ូន។ ពេលដែលមហាក្សត្រីឃើញ «នោះព្រះនាងក៏ភាំងស្មារតី» (១ពង្សាវតារក្សត្រ ១០:៥)។ នាងបានមានប្រសាសន៍ថា «សូមឲ្យព្រះយេហូវ៉ាជាព្រះនៃទ្រង់បានប្រកបដោយព្រះពរ ជាព្រះដែលសព្វព្រះហឫទ័យនឹងទ្រង់ដើម្បីនឹងតាំងឡើងលើបល្ល័ង្ករាជ្យនៃសាសន៍អ៊ីស្រាអែល គឺដោយព្រោះព្រះយេហូវ៉ា ទ្រង់ស្រឡាញ់សាសន៍អ៊ីស្រាអែលអស់កល្បជានិច្ចបានជាតាំងទ្រង់ឡើងឲ្យធ្វើជាស្ដេចលើគេ» (១ពង្សាវតារក្សត្រ ១០:៩)។

និយាយម្យ៉ាងទៀតទៅ លំនាំក្នុងព្រះគម្ពីរសញ្ញាចាស់គឺ

ជា*សាសនានៃការចូរមកមើល*។ រាស្ត្ររបស់ព្រះជាម្ចាស់មានលំនៅដ៏ជាក់លាក់នៅលើផែនដីនេះ។ មានព្រះវិហារដ៏ជាក់លាក់ មានស្តេចគ្រប់គ្រងលើរាស្ត្ររបស់ទ្រង់ រដ្ឋាភិបាលដែលគ្រប់គ្រងជនជាតិផ្ទាល់ខ្លួន ពលទាហានលើផែនដីនេះដែលចេញទៅធ្វើសង្គ្រាមរបស់ព្រះជាម្ចាស់ ហើយនិងក្រុមពួកសង្ឃ ដើម្បីថ្វាយយញ្ញបូជាសម្រាប់អំពើបាប។

ការយាងមករបស់ព្រះគ្រីស្ទបានបំផ្លាស់បំប្រែនូវចំណុចទាំងអស់នេះ។ ឥឡូវនេះ គ្មានលំនៅដ៏ជាក់លាក់នៅលើផែនដីទៀតឡើយ (យ៉ូហាន ៤:២០-២៤) ព្រះយេស៊ូវបានយកតំណាងជំនួសព្រះវិហារ ពួកសង្ឃ និងយញ្ញបូជា (យ៉ូហាន ២:១៩ និងហេព្រើរ ៩:២៥-២៦) គ្មានរដ្ឋាភិបាលនៃគ្រីស្ទសាសនា ដើម្បីគ្រប់គ្រងឡើយ ពីព្រោះនគររបស់ព្រះគ្រីស្ទគឺមិនមែននៅលើផែនដីនេះទេ (យ៉ូហាន ១៨:៣៦)។ ហើយយើងក៏មិនធ្វើសង្គ្រាមលើផែនដីនេះដោយប្រើរទេះសេះចម្បាំង ឬក៏គ្រាប់បែក និងគ្រាប់កាំភ្លើងឡើយ ប៉ុន្តែយើងច្បាំងសង្គ្រាមខាងឯវិញ្ញាណដោយប្រើព្រះបន្ទូល និងព្រះវិញ្ញាណវិញ (អេភេសូរ ៦:១២-១៨ និង២កូរិន-ថូស ១០:៣-៥)។

ចំណុចទាំងអស់នេះគាំទ្រការបំផ្លាស់បំប្រែដ៏ធំបំផុតក្នុង

បេសកកម្ម។ ព្រះគម្ពីរសញ្ញាថ្មីមិនបើកបង្ហាញអំពីសាសនាឲ្យចូរមកមើលទៀតទេ ប៉ុន្តែអំពីសាសនាឲ្យចេញទៅប្រាប់។ «នោះព្រះយេស៊ូវក៏យាងមកជិតពួកគេមានបន្ទូលថា៖ "ខ្ញុំបានទទួលសិទ្ធិអំណាចទាំងអស់ ទាំងនៅស្ថានសួគ៌ និងនៅផែនដី ដូច្នេះចូរទៅបង្កើតសិស្សពីគ្រប់ជនជាតិ ហើយធ្វើពិធីជ្រមុជទឹកឲ្យពួកគេនៅក្នុងព្រះនាមព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ ហើយបង្រៀនពួកគេឲ្យកាន់តាមសេចក្ដីទាំងប៉ុន្មានដែលខ្ញុំបានបង្គាប់ដល់អ្នករាល់គ្នា ហើយមើល៍ ខ្ញុំនៅជាមួយអ្នករាល់គ្នាគ្រប់ពេលវេលារហូតដល់អស់កល្ប"» (ម៉ាថាយ ២៨:១៨-២០ គគខ)។

ការអនុវត្តនៃចំណុចនេះគឺសំខាន់ណាស់ទាក់ទងនឹងរបៀបដែលយើងរស់នៅ និងរបៀបដែលយើងគិតអំពីលុយកាក់ និងរបៀបរស់នៅ។ ចំណុចដ៏ចម្បងមួយក្នុងចំណុចនានាគឺត្រង់ថាយើងគឺជា «ពួកប្រទេសក្រៅ ហើយដូចជាពួកអ្នកដែលគ្រាន់តែសំណាក់នៅ» លើផែនដីនេះ (១ពេត្រុស ២:១១)។ យើងមិនប្រើប្រាស់លោកីយ៍នេះហាក់បីដូចវាជាផ្ទះដើមរបស់យើងនោះទេ។ «ឯយើងរាល់គ្នា យើងជាសាសន៍ស្ថានសួគ៌វិញ ក៏នៅចាំព្រះអម្ចាស់យេស៊ូវគ្រីស្ទ ជាព្រះអង្គសង្គ្រោះ ទ្រង់យាងមកពី

ស្ថាននោះឯង» (ភីលីព ៣:២០)។

ចំណុចនេះនាំឲ្យយើងរស់នៅក្នុងរបៀបដែលត្រូវធ្វើសង្គ្រាម។ នេះមានន័យថា យើងមិនប្រមូលទ្រព្យសម្បត្តិ ដើម្បីបង្ហាញលោកីយ៍ថា ព្រះជាម្ចាស់យើងអាចធ្វើឲ្យយើងក្លាយជាអ្នកមានយ៉ាងខ្លាំងនោះទេ។ យើងខំធ្វើការយ៉ាងហត់ ហើយព្យាយាមតតាំងឲ្យម៉ឺងម៉ាត់សម្រាប់ការលះបង់ ដើម្បីផ្សាយដំណឹងល្អទៅកាន់ទីបំផុតនៃផែនដី។ យើងព្យាយាមផ្គត់ផ្គង់ឲ្យអស់ពីសមត្ថភាពក្នុងការតស៊ូនឹងសង្គ្រាម មិនមែនដើម្បីភាពស្រណុកសុខស្រួលនៅឯផ្ទះនោះទេ។ យើងចិញ្ចឹមកូនៗយើងឲ្យពួកគាត់យល់ពីការរងទុក្ខដែលពួកគាត់ត្រូវឆ្លងកាត់ ដើម្បីសម្រេចបេសកកម្ម។

ដូច្នេះ បើគ្រូៗដែលអធិប្បាយភាពចម្រុងចម្រើនសួរខ្ញុំពីក្តីសន្យាទាក់ទងនឹងទ្រព្យសម្បត្តិសម្រាប់ពួករាស្ត្រដ៏ស្មោះត្រង់ក្នុងព្រះគម្ពីរសញ្ញាចាស់ នោះចម្លើយរបស់ខ្ញុំគឺ៖ សូមអានព្រះគម្ពីរសញ្ញាថ្មីដោយយកចិត្តទុកដាក់ ហើយសូមពិនិត្យមើលថាតើលោកអ្នកឃើញការផ្តោតដូចគ្នាដែរឬទេ។ លោកអ្នកនឹងមិនឃើញទ្បើយ។ ហើយមូលហេតុគឺថា មានការបំផ្លាស់បំប្រែយ៉ាងខ្លាំង។

«ដ្បិតយើងរាល់គ្នាមិនបានយកអ្វី ចូលមកក្នុងលោកីយ៍

នេះទេ ហើយច្បាស់ជាយើងពុំអាចនឹងយកអ្វីចេញទៅវិញបាន ដែរ តែបើមានអាហារទទួលទាន នឹងសំលៀកបំពាក់ នោះក៏ ល្មមឲ្យយើងបានស្កប់ចិត្តហើយ» (១ធីម៉ូថេ ៦:៧-៨)។ ហេតុ អ្វី? ពីព្រោះការត្រាស់ហៅឲ្យដើរតាមព្រះយេស៊ូវគឺជាការត្រាស់ ហៅ «ឲ្យអ្នកទ្រាំទ្រទុក្ខលំបាក ដូចជាទាហានយ៉ាងល្អរបស់ព្រះ យេស៊ូវគ្រីស្ទចុះ» (២ធីម៉ូថេ ២:៣)។ ព្រះគម្ពីរសញ្ញាថ្មីមិនបាន ផ្តោតលើទ្រព្យសម្បត្តិ ដើម្បីធ្វើជានុយឲ្យយើងធ្លាក់ក្នុងអំពើបាប ទេ ប៉ុន្តែការលះបង់ ដើម្បីនាំយើងចាកចេញវិញ។

អំណោះអំណាងមួយដែលព្រះជាម្ចាស់បានគ្រោងទុកក្នុងការ វែកញែកចំណុចខុសគ្នារវាងផ្នត់គំនិតនៃការមកមើលក្នុងព្រះគម្ពីរ សញ្ញាចាស់ និងការចេញទៅប្រាប់ក្នុងព្រះគម្ពីរសញ្ញាថ្មី គឺត្រង់ ចំណុចខុសគ្នារវាងភាសានៃព្រះគម្ពីរសញ្ញាចាស់ និងព្រះគម្ពីរ សញ្ញាថ្មី។ ហេប្រ៊ូគឺជាភាសានៃព្រះគម្ពីរសញ្ញាចាស់ ហើយគ្មាន ជាតិសាសន៍ណាប្រើប្រាស់ភាសាហ្នឹងនៅសម័យបុរាណក្រៅពី សាសន៍អ៊ីស្រាអែលនោះទេ ហើយនោះជាភាសាមួយដែលមាន តែពួកគាត់ប្រើប្រាស់ប៉ុណ្ណោះ។ នេះជាចំណុចខុសគ្នាយ៉ាងខ្លាំង ជាមួយនឹងភាសាក្រិក ដែលជាភាសាព្រះគម្ពីរសញ្ញាថ្មី ដែលនោះ ក៏ជាភាសាប្រើប្រាស់សម្រាប់រកស៊ីនៅសម័យរ៉ូមផងដែរ។ សរុប

សេចក្តីទៅ ទាំងភាសានៃព្រះគម្ពីរសញ្ញាចាស់ និងព្រះគម្ពីរសញ្ញាថ្មីបានលើកឡើងអំពីចំណុចខុសគ្នាក្នុងបេសកកម្ម។ ភាសាហេប្រ៊ូមិនមែនជាភាសាងាយប្រើប្រាស់សម្រាប់បេសកកម្មទៅកាន់អ្នកនៅសម័យបុរាណទេ។ ឯភាសាក្រិកវិញគឺជាភាសាដ៏ងាយជាងសម្រាប់បេសកកម្មទៅកាន់អស់អ្នកនៅសម័យរ៉ូម។

## ញែកខ្លួនចេញពីអ្នកក្លែងបន្លំ

សាវ័ក ប៉ុល បានធ្វើជាគំរូតាមរយៈការដែលគាត់ប្រុងប្រយ័ត្នយ៉ាងខ្លាំងក្នុងការបង្ហាញថា គាត់មិនបានធ្វើព័ន្ធកិច្ច ដើម្បីលុយនោះឡើយ។ គាត់បានមានប្រសាសន៍ថា អ្នកបម្រើព័ន្ធកិច្ចមានសិទ្ធិក្នុងការរកលុយ ដើម្បីចិញ្ចឹមខ្លួនចេញពីព័ន្ធកិច្ច ប៉ុន្តែ បន្ទាប់មក ដើម្បីបង្ហាញយើងអំពីគ្រោះថ្នាក់ក្នុងការនោះ គាត់បានបដិសេធក្នុងការប្រើប្រាស់សិទ្ធិនោះទាំងស្រុង។

*«ដ្បិតមានសេចក្តីចែងទុកមក ក្នុងក្រឹត្យវិន័យលោកម៉ូសេ ថា "កុំឲ្យឃ្លុំមាត់របស់គោ ដែលបញ្ជាន់ស្រូវឡើយ "...ឬទ្រង់មានបន្ទូលដូច្នោះចំពោះដល់យើងរាល់គ្នាដែរ គឺដោយព្រោះតែយើងរាល់គ្នាហើយ បានជាសេចក្តីនោះបានចែងទុកមក ដើម្បីឲ្យអ្នកណាដែលភ្ជួររាស់ បានភ្ជួរ*

*រាស់ដោយសង្ឃឹម ហើយអ្នកណាដែលបញ្ជាន់ដោយសង្ឃឹម នោះនឹងបានតាមសេចក្ដីសង្ឃឹមនោះឯង បើសិនជាយើងខ្ញុំបានសាបព្រោះរបស់ខាងព្រលឹងវិញ្ញាណនៅក្នុងពួកអ្នករាល់គ្នា ហើយច្រូតបានរបស់អ្នករាល់គ្នាខាងសាច់ឈាមវិញ នោះតើច្រើនហួសពេកឬអី បើអ្នកឯទៀតមានអំណាចនោះលើអ្នករាល់គ្នា នោះតើយើងខ្ញុំមិនត្រូវមានលើសជាងគេទៅទៀតទេឬអី ប៉ុន្តែ យើងខ្ញុំមិនបានប្រើអំណាចនោះទេ យើងខ្ញុំបានទ្រទ្រង់ទាំងអស់វិញ ដើម្បីមិនឲ្យដំណឹងល្អនៃព្រះគ្រីស្ទត្រូវបង្អាក់ឡើយ» (១កូរិនថូស ៩:៩-១២)។*

បើនិយាយម្យ៉ាងវិញទៀត គាត់បានបោះបង់សិទ្ធិដ៏ត្រឹមត្រូវចោល ដើម្បីកុំឲ្យមានគេគិតថាលុយកាក់គឺជាចំណុចជំរុញឲ្យគាត់ធ្វើព័ន្ធកិច្ច។ គាត់មិនចង់បានលុយពីអ្នកដែលទទួលជឿដោយសារគាត់នោះទេ «ដ្បិតយើងខ្ញុំមិនដែលប្រើពាក្យបញ្ចើចដូចជាអ្នករាល់គ្នាដឹងស្រាប់ ឬប្រព្រឹត្តដោយចិត្តលោភឡើយ សឹងមានព្រះទ្រង់ជាសាក្សីហើយ» (១ថែស្សាឡូនីច ២:៥)។

គាត់ពេញចិត្តក្នុងការធ្វើការនឹងដៃរបស់គាត់ផ្ទាល់ ជាជាងឲ្យ

គេគិតថា គាត់កំពុងធ្វើជាអ្នកក្លែងបន្លំលក់ដំណឹងល្អ៖

*«ខ្ញុំមិនដែលលោភចង់បានប្រាក់មាស ឬសំលៀកបំពាក់របស់អ្នកណាឡើយ អ្នករាល់គ្នាដឹងហើយថា ដៃខ្ញុំនេះបានផ្គត់ផ្គង់គ្រប់របស់ ដែលខ្ញុំត្រូវការ ព្រមទាំងពួកអ្នកដែលនៅជាមួយផង ខ្ញុំបានបង្ហាញអ្នករាល់គ្នាដោយគ្រប់ការទាំងអស់ថា គួរឲ្យខំធ្វើការដូច្នោះ ដើម្បីឲ្យបានជួយដល់ពួកអ្នកខ្សោយ ហើយនឹងនឹកចាំពីព្រះបន្ទូលនៃព្រះអម្ចាស់យេស៊ូវ ដែលទ្រង់មានបន្ទូលថា ដែលឲ្យនោះបានពរជាជាងទទួល» (កិច្ចការ ២០:៣៣-៣៥)។*

គាត់ដឹងថាមានអ្នកខ្លះបានធ្វើជាអ្នកក្លែងបន្លំព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដោយបានស្មានថា «គោរពប្រតិបត្តិព្រះជាម្ចាស់ជាមធ្យោបាយរកទ្រព្យសម្បត្តិ» (១ធីម៉ូថេ ៦:៥-៦ គខប)។ ប៉ុន្តែគាត់បានបដិសេធក្នុងការធ្វើនូវអ្វីដែលនឹងអាចដាក់គាត់ក្នុងចំណាត់ថ្នាក់ហ្នឹង៖ «ដ្បិតយើងមិនមែន*រកចំណេញពីព្រះបន្ទូលរបស់ព្រះ* ដូចមនុស្សជាច្រើននោះឡើយ តែក្នុងព្រះគ្រីស្ទ យើងនិយាយក្នុងនាមជាមនុស្សស្មោះត្រង់ ជាមនុស្សដែលព្រះបាន

ចាត់ឲ្យមក នៅចំពោះព្រះអង្គ» (២កូរិនថូស ២:២-១៧ គកស)។

មានគ្រូៗដែលអធិប្បាយភាពចម្រុងចម្រើនជាច្រើននាក់មិនគ្រាន់តែបង្ហាញថា «យើងមិនមែនរកចំណេញពីព្រះបន្ទូល» ហើយបានធ្វើជា «គោរពប្រតិបត្តិព្រះជាម្ចាស់ជាមធ្យោបាយរកទ្រព្យសម្បត្តិ» ប៉ុន្តែពួកគាត់ក៏បង្កើតទេវវិទ្យាដ៏ក្លែងក្លាយ ដើម្បីអះអាងថាការដែលពួកគាត់បង្ហាញទ្រព្យសម្បត្តិដ៏ស្ដុកស្ដម្ភរបស់ពួកគាត់គឺជារឿងត្រឹមត្រូវ។ សាវ័ក ប៉ុល បានធ្វើយ៉ាងនោះផ្ទុយស្រឡះទាំងស្រុង។

## យកព្រះគ្រីស្ទជាកម្រៃ

ចំណុចដែលខ្ញុំបារម្ភខ្លាំងជាងគេបំផុតទាក់ទងនឹងឥទ្ធិពលនៃចលនានៃភាពចម្រុងចម្រើនគឺ វាធ្វើឲ្យព្រះគ្រីស្ទទៅជាតូចដោយមិនយកទ្រង់ជាចំណុចចាំបាច់ និងមិនសូវជាការស្កប់ចិត្តជាងអំណោយទានរបស់ទ្រង់។ ព្រះគ្រីស្ទនឹងមិនទទួលភាពឧដុង្គឧត្ដមយ៉ាងខ្លាំងតាមរយៈការដែលព្រះអង្គធ្វើជាអ្នកឲ្យទ្រព្យសម្បត្តិនោះឡើយ។ ព្រះអង្គនឹងទទួលបានភាពឧដុង្គឧត្ដមយ៉ាងខ្លាំងតាមរយៈការដែលទ្រង់ប្រទានការស្កប់ស្កល់ដល់អស់អ្នកដែលលះបង់ ដើម្បីស្រឡាញ់អ្នកដទៃក្នុងព័ន្ធកិច្ចនៃដំណឹងល្អ។

នៅពេលដែលយើងលើកព្រះគ្រីស្ទថាជាអង្គដែលធ្វើឲ្យយើងក្លាយជាអ្នកមាន នោះមានន័យថា យើងកំពុងថ្វាយសិរីល្អដល់ទ្រព្យសម្បត្តិ ហើយព្រះគ្រីស្ទក្លាយជាឈ្នាន់នៃអ្វីដែលយើងចង់បាន ដែលមានដូចជា៖ សុខភាព ទ្រព្យសម្បត្តិ និងភាពចម្រុងចម្រើនជាដើម។ ប៉ុន្តែ ពេលដែលយើងលើកព្រះគ្រីស្ទថា ជាអង្គដែលធ្វើឲ្យព្រលឹងវិញ្ញាណយើងបានស្កប់ស្កល់អស់កល្បជានិច្ច ហើយសូម្បីតែក្នុងពេលដែលគ្មានសុខភាពល្អ ទ្រព្យសម្បត្តិ និងភាពចម្រុងចម្រើន នោះព្រះគ្រីស្ទនឹងទទួលបានភាពឧដុង្គឧត្តមលើសជាងអំណោយទានទាំងអស់នោះទៅទៀត។

យើងឃើញចំណុចនេះក្នុងកណ្ឌគម្ពីរ ភីលីព ១:២០-២១។ សាវ័ក ប៉ុល បានមានប្រសាសន៍ថា «តាមសេចក្តីដែលខ្ញុំទន្ទឹងចាំ ហើយសង្ឃឹមអស់ពីចិត្តថា...គឺឲ្យតែខ្ញុំបានតម្កើងព្រះគ្រីស្ទក្នុងរូបកាយខ្ញុំវិញ ដោយចិត្តក្លាហានគ្រប់ជំពូក ក្នុងពេលឥឡូវនេះចុះ ដូចជាពីដើមរៀងមកដែរ ទោះរស់ឬស្លាប់ក្តី ដ្បិតឯខ្ញុំ ដែលខ្ញុំរស់នៅ នោះគឺសម្រាប់ព្រះគ្រីស្ទទេ ហើយដែលស្លាប់ទៅ នោះជាកម្រៃវិញ»។ ការដែលយើងតម្កើងព្រះគ្រីស្ទកើតឡើងពេលដែលយើងយកទ្រង់ទុកជាទ្រព្យរហូតដល់ថ្នាក់ថា ការដែលយើងស្លាប់គឺជា*កម្រៃ*។ ពីព្រោះការស្លាប់មានន័យថា «ចេញទៅនៅជាមួយនឹង

ព្រះគ្រីស្ទ» (ភីលីព ១:២៣)។

នេះជាចំណុចដែលការអធិប្បាយភាពចម្រុងចម្រើនបានមើលរំលង។ ព្រះគម្ពីរសញ្ញាថ្មីផ្ដោតលើសិរីល្អរបស់ព្រះគ្រីស្ទ មិនមែនលើសិរីល្អនៃអំណោយទានរបស់ទ្រង់ទេ។ ដើម្បីធ្វើឲ្យចំណុចនេះកាន់តែច្បាស់ឡើង ព្រះគម្ពីរក៏បានដាក់ជីវិតជាគ្រីស្ទបរិស័ទទាំងមូលក្រោមទង់ជាតិនៃការលះកាត់ចិត្តខ្លួនឯងចោលដោយមានអំណរដែរ។ «កាលទ្រង់បានហៅហ្វូងមនុស្ស នឹងពួកសិស្សមកនោះក៏មានបន្ទូលទៅគេថា អ្នកណាដែលចង់មកតាមខ្ញុំ ត្រូវឲ្យអ្នកនោះ*លះកាត់ចិត្តខ្លួនឯងចោល*ទាំងផ្ទុកឈើឆ្កាងខ្លួនមកតាមខ្ញុំចុះ» (ម៉ាកុស ៨:៣៤)។ «ខ្ញុំបានជាប់ឆ្កាងជាមួយនឹងព្រះគ្រីស្ទ» (កាឡាទី ២:២០)។

ប៉ុន្តែ ទោះបើការលះកាត់ចិត្តខ្លួនឯងចោលគឺជាវិថីដ៏ពិបាកដែលនាំឲ្យមានជីវិតក៏ដោយ (ម៉ាថាយ ៧:១៤) ក៏វាជាវិថីដែលនាំឲ្យមានអំណរដ៏ខ្លាំងបំផុត បើប្រៀបធៀបនឹងវិថីនានា។ «នគរស្ថានសួគ៌ក៏ប្រៀបដូចជាកំណប់កប់ទុកក្នុងចំការ ដែលកាលណាមនុស្សម្នាក់បានឃើញ នោះក៏លាក់ទុក រួចចេញទៅ លក់របស់ទ្រព្យខ្លួនទាំងអស់*ដោយអំណរ* ដើម្បីនឹងទិញចំការនោះ» (ម៉ាថាយ ១៣:៤៤)។ ព្រះយេស៊ូវមានបន្ទូលថា ការដែលរក

ឃើញទ្រង់គឺប្រៀបដូចជាកំណប់ដែលធ្វើឲ្យយើង*មានអំណរ*យ៉ាងខ្លាំងក្នុងការបោះបង់នូវទ្រព្យសម្បត្តិនានាចោល។ «រួចចេញទៅ លក់របស់ទ្រព្យខ្លួនទាំងអស់*ដោយអំណរ* ដើម្បីនឹងទិញចំការនោះ»។

ខ្ញុំមិនចង់ឲ្យគ្រូៗដែលអធិប្បាយភាពចម្រុងចម្រើនឈប់នាំអ្នកស្តាប់ឲ្យមានអំណរដ៏ពេញទីនោះទេ។ ផ្ទុយពីនោះវិញ ខ្ញុំសូមទទូចអង្វរឲ្យពួកគាត់ឈប់លើកទឹកចិត្តអ្នកស្តាប់ឲ្យស្វែងរកអំណរខ្លួនក្នុងរបស់សម្ភារៈនិយម។ អំណរដែលព្រះគ្រីស្ទចង់ផ្តល់ឲ្យគឺធំសម្បើមណាស់ ហើយនៅយ៉ាងយូរអង្វែងដល់ថ្នាក់ថាវាអាចធ្វើឲ្យយើងនៅមានអំណរទោះបើយើងបាត់បង់ភាពចម្រុងចម្រើនក៏ដោយ។ «ដ្បិតអ្នករាល់គ្នាមានចិត្តអាណិតអាសូរ ដល់ពួកអ្នកដែលជាប់ចំណង ក៏ទ្រាំឲ្យមនុស្សប្លន់យករបស់ទ្រព្យខ្លួន*ដោយអំណរ ដោយដឹងថា ខ្លួនមានទ្រព្យសម្បត្តិ ដែលប្រសើរជាង ហើយក៏នៅជាប់លាប់ផង នៅឯស្ថានសួគ៌*» (ហេព្រើរ ១០:៣៤)។ ការអស្ចារ្យដែលគ្រូៗដែលអធិប្បាយភាពចម្រុងចម្រើនគួរស្វែងរកគឺ ព្រះគុណក្នុងការមានអំណរពេលបាត់បង់ភាពចម្រុងចម្រើន។ នោះឯងគឺជាអំបិលនៃផែនដី និងពន្លឺនៃលោកីយ៍។ ការនេះនឹងបង្ហាញភាពឧដុង្គឧត្តមដ៏មានតម្លៃបំផុត

របស់ព្រះគ្រីស្ទ។

## សេចក្ដីបន្ថែមទី២៖

# លុយ

Wayne Grudem

ជាមូលដ្ឋាន ការមានលុយកាក់គឺជាការល្អ ហើយផ្ដល់ឱកាសជាច្រើនក្នុងការថ្វាយសិរីល្អទៅកាន់ព្រះជាម្ចាស់ ប៉ុន្តែវាក៏នាំឲ្យមានសេចក្ដីល្បួងជាច្រើននឹងអំពើបាបផងដែរ។

មានពេលខ្លះមនុស្សមួយចំនួនគិតថា «លុយជាឫសនៃអំពើអាក្រក់គ្រប់បែបយ៉ាង» ប៉ុន្តែព្រះគម្ពីរមិនបានលើកឡើងយ៉ាងដូច្នោះទេ។ សាវ័ក ប៉ុល មានប្រសាសន៍ក្នុងកណ្ឌគម្ពីរ ១ធីម៉ូថេ ៦:១០ ថា «ការស្រឡាញ់លុយជាឫសនៃអំពើអាក្រក់គ្រប់បែបយ៉ាង» ប៉ុន្តែត្រង់នេះគាត់កំពុងនិយាយអំពី «ការស្រឡាញ់លុយ» មិនមែនអំពីលុយតែឯងនោះឡើយ (គគខ)។

តាមពិតទៅ ជាមូលដ្ឋាន ការមានលុយកាក់គឺជាការល្អទេតើ ព្រោះវាជាការច្នៃប្រឌិតរបស់មនុស្សយើង ដែលញែកយើងចេញពីសត្វ ហើយធ្វើឲ្យយើងអាចគ្រប់គ្រងផែនដីនេះតាមរយៈការដែលយើងបង្កើតរបស់ល្អៗចេញពីផែនដី និងសេវាកម្មមួយ

ចំនួន ដើម្បីនាំមកនូវអត្ថប្រយោជន៍ដល់អ្នកដទៃ។ លុយកាក់ធ្វើឲ្យមនុស្សយើងអាចបង្កើតផលផ្លែបាន ហើយអាចមានអំណរនឹងផលផ្លែដែលយើងបង្កើតនោះរាប់លានដងដែលយើងអាចធ្វើបាន ជាជាងបើយើងគ្មានលុយកាក់ ដែលនោះនឹងបណ្តាលឲ្យយើងនៅតថ្លៃគ្នារហូត។

បើគ្មានលុយទេ នោះខ្ញុំមានតែរបស់មួយគត់ក្នុងការដោះដូរ គឺសៀវភៅរបស់ខ្ញុំ។ ខ្ញុំនឹងគ្រាន់តែមានសៀវភៅ *Systematic Theology*[១] រាប់រយក្បាល ប៉ុន្តែបើសិនជាលោកីយ៍នេះគ្មានលុយកាក់ ខ្ញុំនឹងមិនទាំងដឹងផងដែរថា តើមួយក្បាលអាចមានតម្លៃប៉ុន្មានទៅនឹងនំប៉ុងមួយដើម ឬក៏អាវពីរ ឬក៏កង់មួយ ឬក៏ឡានមួយផង។ ហើយអ្នកលក់គ្រឿងគ្រៅធ្វើម្ហូបទំនងជាទាំងមិនមានចំណាប់អារម្មណ៍ក្នុងការអានសៀវភៅរបស់ខ្ញុំផង ដូច្នេះគាត់ក៏នឹងមិនទំនងប្តូរម្ហូបមួយកន្ត្រកនឹងសៀវភៅខ្ញុំមួយរយក្បាលផង! ហើយមិនយូរមិនឆាប់ អ្នកដោះដូរដែលធ្លាប់ទទួលសៀវភៅរបស់ខ្ញុំក៏នឹងលែងចង់បានមួយក្បាលទៀត ឬក៏បីក្បាលទៀត ដែលនោះនឹងធ្វើឲ្យខ្ញុំនៅសល់សៀវភៅយ៉ាងរាប់គំនរ ហើយគ្មាន

១ Wayne Grudem, *Systematic Theology: An Introduction to Biblical Doctrine* (Leicester: InterVarsity, ឆ្នាំ១៩៩៤; Grand Rapids: Zondervan, ឆ្នាំ១៩៩៤)។

លទ្ធភាពក្នុងការរកអ្នកដែលចង់ដោះដូរអ្វីមួយនឹងខ្ញុំ។ បើគ្មានលុយកាក់ នោះមិនយូរមិនឆាប់ខ្ញុំនឹងត្រូវបង្ខំខ្លួនក្នុងការត្រឡប់ទៅដាំនេះដាំនោះវិញ ដើម្បីចិញ្ចឹមជីវិត ហើយនឹងត្រូវចិញ្ចឹមគោនិងមាន់ ហើយទំនងម្តងម្កាលទៅប្តូរយកស៊ុត។ ហើយលោកអ្នកក៏ត្រូវធ្វើដូច្នោះដែរ ជាមួយនឹងអ្វីដែលលោកអ្នកអាចធ្វើបាន។

ប៉ុន្តែ មានតែលុយកាក់មួយប៉ុណ្ណោះដែលគ្រប់គ្នាពេញចិត្តនឹងដោះដូរទំនិញជាមួយ ពីព្រោះមានតែវាមួយទេដែលអ្នកដទៃផ្សេងទៀតនឹងដោះដូរទំនិញជាមួយ។ ដោយមានប្រព័ន្ធលុយកាក់ ភ្លាមៗនោះខ្ញុំក៏ស្រាប់តែដឹងថា តើសៀវភៅរបស់ខ្ញុំមួយក្បាលមានតម្លៃប៉ុណ្ណា។ គឺ៤០ដុល្លារមួយក្បាល ព្រោះនោះគឺជាតម្លៃដែលមនុស្សរាប់ពាន់នាក់បានសម្រេចថា ពួកគេពេញចិត្តនឹងបង់ថ្លៃសម្រាប់វា។

លុយក៏មានផ្ទុកនូវតម្លៃនៃអ្វីមួយរហូតដល់ខ្ញុំសម្រេចចិត្តចាយវាយលើអ្វីមួយទៀត។ ពេលដែលខ្ញុំទទួលបាន៤០ដុល្លារ លុយនោះមានតម្លៃជាបណ្តោះអាសន្នសម្រាប់សៀវភៅខ្ញុំរហូតដល់ខ្ញុំអាចទៅផ្សារ ហើយប្រាប់អ្នកលក់គ្រឿងគ្រៅធ្វើម្ហូបថា ខ្ញុំចង់ដោះដូរ៤០ដុល្លារនោះសម្រាប់គ្រឿងគ្រៅម្ហូបខ្លះៗ។ អ្នកលក់គ្រឿងធ្វើម្ហូបដែលពីមុនមិនចង់ដោះដូរគ្រឿងម្ហូបជាមួយនឹងសៀវភៅ

ទេវវិទ្យា ឥឡូវនេះគាត់ចង់ទទួលលុយ៤០ដុល្លាររបស់ខ្ញុំយ៉ាងខ្លាំងណាស់ ពីព្រោះគាត់ដឹងថាគាត់អាចដោះដូរលុយនោះសម្រាប់អ្វីមួយផ្សេងទៀតក្នុងលោកីយ៍នេះដែលគាត់ចង់បាន ដែលមានតម្លៃ៤០ដុល្លារដូចគ្នានោះ។

សរុបសេចក្តីទៅ លុយកាក់គឺគ្រាន់តែជាសម្ភារៈឲ្យយើងប្រើប្រាស់ប៉ុណ្ណោះ ហើយយើងអាចអរព្រះគុណព្រះជាម្ចាស់បានយ៉ាងត្រឹមត្រូវ ដែលក្នុងព្រះប្រាជ្ញារបស់ទ្រង់ ព្រះអង្គបានគ្រោងឲ្យយើងច្នៃប្រឌិតលុយ ហើយប្រើវា។ វាគ្រាន់តែជា «យានមួយនៃការដោះដូរ» ប៉ុណ្ណោះ អ្វីដែលធ្វើឲ្យការដោះដូរអ្វីមួយផ្សេងទៀតបានដោយស្ម័គ្រចិត្ត។ វាគ្រាន់តែជាគ្រឿងប្រើប្រាស់មួយ...ដែលត្រូវបានបង្កើតឡើងស្របច្បាប់ក្នុងការដោះដូរគ្រឿងប្រើប្រាស់មួយផ្សេងទៀតដែលស្មើគ្នា ដែលមានដូចជារបស់របរអ្វីមួយសេវាកម្ម ហើយគេបានប្រើប្រាស់វាទុកជារង្វាស់នៃការប្រៀបធៀបតម្លៃនៅក្នុងទីផ្សារ។[២]

លុយធ្វើឲ្យមានការដោះដូរគ្នាដោយស្ម័គ្រចិត្តមានភាពយុត្តិធម៌ មិនសូវខ្ជះខ្ជាយ និងទូលំទូលាយ។ លើផែនដីនេះ យើងត្រូវការលុយកាក់ ដើម្បីឲ្យយើងអាចធ្វើជាអ្នកគ្រប់គ្រងផែនដីនេះ

---

២ *The American Heritage Dictionary of the English Language* (Boston: Houghton Mifflin, ឆ្នាំ១៩៩២), ទំព័រ១១៦៦។

ឲ្យបានល្អ ហើយឲ្យយើងថ្វាយសិរីល្អដល់ព្រះតាមរយៈការប្រើប្រាស់វាដោយប្រើប្រាជ្ញា។

ប្រសិនបើលុយវាអាក្រក់ដោយឯងៗ នោះព្រះជាម្ចាស់នឹងមិនមានវានោះទេ។ ប៉ុន្តែ ទ្រង់បានមានបន្ទូលថា «អស់ទាំងប្រាក់ជារបស់ផងអញ ហើយមាសទាំងប៉ុន្មានក៏ជារបស់អញដែរ» (ហាកាយ ២:៨)។

ព្រះអង្គគឺជាម្ចាស់នៃរាល់គ្រប់អ្វីៗ ហើយទ្រង់បានផ្តល់វាឲ្យមកយើងក្នុងនាមយើងជាអ្នកត្រួតត្រា ដើម្បីឲ្យយើងអាចថ្វាយសិរីល្អដល់ទ្រង់តាមរយៈវាបាន។

លុយកាក់ផ្តល់នូវឱកាសជាច្រើនក្នុងការថ្វាយសិរីល្អទៅកាន់ព្រះជាម្ចាស់៖ ១) តាមរយៈការវិនិយោគ និងការពង្រីកការត្រួតត្រារបស់យើង ហើយតាមរយៈការធ្វើបែបនោះគឺយើងកំពុងត្រាប់តាមអធិបតេយ្យភាព និងប្រាជ្ញារបស់ព្រះជាម្ចាស់។ ២) តាមរយៈការផ្គត់ផ្គង់តម្រូវការរបស់យើង បង្ហាញថាយើងកំពុងត្រាប់តាមព្រះជាម្ចាស់ត្រង់ថាទ្រង់ឯករាជ្យ។ ៣) តាមរយៈការឲ្យដល់អ្នកដទៃគឺយើងកំពុងត្រាប់តាមក្តីមេត្តាករុណា និងក្តីស្រឡាញ់របស់ព្រះជាម្ចាស់។ ៤) ឬក៏តាមរយៈការថ្វាយទៅកាន់ក្រុមជំនុំ និងការផ្សាយដំណឹងល្អ គឺយើងកំពុងតែនាំអ្នកដទៃ

ចូលមកកាន់នគរព្រះ។

ប៉ុន្តែ ដោយសារលុយមានអំណាច និងតម្លៃយ៉ាងខ្លាំង នោះមានន័យថា យើងក៏មានទំនួលខុសត្រូវយ៉ាងធ្ងន់ធ្ងរផងដែរ ហើយវាជាតំណាងនៃសេចក្តីល្បួងដ៏ឥតឈប់ឈរទៅកាន់អំពើបាប។ លោកអ្នកអាចជាប់អន្ទាក់ក្នុងការស្រេទឡាញ់លុយ (១ធីម៉ូថេ ៦:១០) ហើយវាក៏អាចបង្វែរចិត្តយើងចេញពីព្រះជាម្ចាស់បានផងដែរ។ ព្រះយេស៊ូវបានព្រមានថា «អ្នករាល់គ្នាពុំអាចនឹងគោរពដល់ព្រះ និងទ្រព្យសម្បត្តិផងបានទេ» (ម៉ាថាយ ៥:២៤) ហើយព្រះអង្គក៏បានព្រមានទាស់នឹងការប្រមូលច្រើនពេក ដល់ថ្នាក់ថាយើងលាក់ទុកលើសពីតម្រូវការ ហើយមិនប្រើប្រាស់វាសម្រាប់ការល្អៗ៖

> *«កុំឲ្យប្រមូលទ្រព្យសម្បត្តិទុកសម្រាប់ខ្លួននៅផែនដី ជាកន្លែងដែលមានកន្លាត និងច្រែះស៊ីបំផ្លាញ ហើយចោរទំលុះប្លន់នោះឡើយ ត្រូវប្រមូលទ្រព្យសម្បត្តិទុកសម្រាប់ខ្លួននៅឯស្ថានសួគ៌វិញដែលជាកន្លែងគ្មានកន្លាត ឬច្រែះស៊ីបំផ្លាញឡើយ ក៏គ្មានចោរទំលុះ ឬប្លន់ផង ពីព្រោះសម្បត្តិទ្រព្យរបស់អ្នកស្ថិតនៅកន្លែងណា នោះចិត្តអ្នកក៏នឹងនៅកន្លែងនោះដែរ» (ម៉ាថាយ ៦:១៩-២១)។*

ប៉ុន្តែ ការធ្វើឲ្យអ្វីមួយដែលល្អរមួលខុចពីធាតុដើមមិនគួរធ្វើឲ្យយើងគិតថា របស់នោះឯងផ្ទាល់គឺអាក្រក់នោះឡើយ។ ដោយឯងៗ លុយវាល្អទេ ហើយក៏ផ្តល់នូវឱកាសជាច្រើនដល់យើងក្នុងការថ្វាយសិរីល្អទៅកាន់ព្រះជាម្ចាស់ផងដែរ។

## សេចក្ដីបន្ថែមទី៣៖

# គ្រូៗដែលបង្រៀនភាពចម្រុងចម្រើន

គោលបំណងរបស់យើងក្នុងសៀវភៅនេះគឺ៖ លើកឡើងអំពីគោលការណ៍ចម្បងៗ និងគំនិតនានានៃសេចក្ដីបង្រៀនពីភាពចម្រុងចម្រើន ជាជាងប្រកែកគ្នាជាមួយនឹងពួកគ្រូៗទាំងនោះដោយផ្ទាល់។ ប៉ុន្ដែ យើងក៏បាននឹកគិតដល់អស់អ្នកដែលជះឥទ្ធិពលជាច្រើនអ្នកផងដែរ។ ពួកគាត់បានបង្រៀន និងផ្សព្វផ្សាយដំណឹងល្អដែលសន្យាភាពចម្រុងចម្រើន ក្នុងរបៀបខុសៗគ្នា និងផ្សេងៗគ្នា។

យើងចង់រាយឈ្មោះគ្រូៗដែលជះឥទ្ធិពលបែបដូចខាងលើនោះមួយចំនួន៖ លោក យ៉ូសែប ព្រីនស៍ (Joseph Prince), លោក ដឹនកិន វិលាមស៍ (Duncan Williams), លោក បេនសិន អេយដាហូសា (Benson Idahosa), លោក ដេវីឌ អូយីដេពូ (David Oyedepo, founder of Winners Chapel [អ្នកបង្កើតសមាគមអ្នកឈ្នះ]), លោក ចន ព្រេស៍ (John Praise),

លោក ខិននេធ & លោកស្រី គ្លរីយា ខូពឡេនដ៍ (Kenneth & Gloria Copeland), លោក ខិននេធ ហាហ្គិន (Kenneth Hagin), លោកស្រី ម៉ារីឡាន ហិកគីយ៍ (Marilyn Hickey), លោក ម៉ររីស ស៊ីរូឡូ (Morris Cerullo), លោក ចន អេវ៉ានសីនី (John Avanzini), លោក រូបបើរត៍ ធៀលតូន (Robert Tilton), លោក បិននី ហិន (Benny Hinn), លោក ឆាលស៍ ខេបស៍ (Charles Capps), លោក យូល អូស្ទិន (Joel Osteen) និងលោក ធី. ឌី. ចេកស៍ (T.D. Jakes)។

ទោះជាយ៉ាងណាក្ដី លើសពីអ្វីៗទាំងអស់ យើងចង់លើកទឹកចិត្តឲ្យអ្នកអានល្បងលសេចក្ដីអធិប្បាយដែលពួកគាត់ឮ ដោយយកមកផ្ទៀងផ្ទាត់ជាមួយនឹងព្រះគម្ពីរ។ យើងសង្ឃឹមថា សៀវភៅនេះបានជួយដល់លោកអ្នកក្នុងការឈរមាំក្នុងដំណឹងល្អដ៏ពិតប្រាកដ។

## សេចក្ដីបន្ថែមទី៤៖

# ឯកសារបន្ថែម៖ សៀវភៅនានាដែលនិយាយពីការបង្រៀននៃភាពចម្រុងចម្រើន

ទាក់ទងនឹងប្រធានបទមួយនេះ យើងឃើញថាមិនសូវមានសៀវភៅច្រើនប៉ុន្មានទេ ពេលដែលយើងគិតពីការជះឥទ្ធិពលដែលវាមានលើក្រុមជំនុំនៅជុំវិញពិភពលោកនេះ។ យើងចង់លើកទឹកចិត្តឲ្យពួកគ្រូគង្វាល និងទេវវិទូសរសេរទប់ទល់នឹងសេចក្ដីបង្រៀនដ៏ខុសឆ្គងនេះ។

ខាងក្រោមនេះគឺជាសៀវភៅដ៏មានតម្លៃមួយចំនួនសម្រាប់ការអានបន្ថែម៖

**Adeleye, Femi *Preachers of a Different Gospel* (Hippo Books, ឆ្នាំ២០១១)។**

អ្នកនិពន្ធម្នាក់នេះដែលមកពីប្រទេសនីហ្សេរីយ៉ាព្យាយាមល្បងលអំណះអំណាងនៃដំណឹងល្អដែលសន្យាភាពចម្រុង

ចម្រើន ហើយក៏បានបំភ្លឺនូវរបៀបដែលវាខុសនឹងព្រះគម្ពីរ។ សៀវភៅរបស់គាត់គឺជាការព្រមានអំពីកលល្បិចនៃរបៀបដែលសេចក្តីបង្រៀនដ៏ខុសឆ្គងនេះបានវាយលុកចូលក្នុងព្រះវិហារ។

**Fee, Gordon** ***The Disease of the Health and Wealth Gospels*** **(Vancouver: Regent College, ឆ្នាំ២០០៦)។**

ក្នុងនាមជាគ្រូផ្នែកប្រវត្តិសាស្ត្រព្រះគម្ពីរសញ្ញាថ្មី លោកគ្រូម្នាក់នេះបានកាត់ស្រាយយ៉ាងចំៗដោយផ្តល់គំនិតរិះគន់លើប្រធានបទដែលគ្រីស្ទបរិស័ទនិយាយទាក់ទងនឹងសុខភាព ទ្រព្យសម្បត្តិ និងភាពចម្រុងចម្រើន។ កូនសៀវភៅមួយនេះជួយចង្អុលឲ្យអ្នកអានឈរលើសេចក្តីបង្រៀនដ៏ស្មោះត្រង់ក្នុងព្រះគម្ពីរ។

**Hanegraaf, Hank** ***Christianity in Crisis: The 21st Century*** **(Nashville: Thomas Nelson, ឆ្នាំ២០០៩)។**

សៀវភៅនេះគឺជាកំណែលើសៀវភៅដ៏មានឥទ្ធិពលមួយទៀតដែលគាត់បានចេញបោះពុម្ពនៅឆ្នាំ១៩៩៣។ គាត់បានព្យាយាមផ្តល់នូវព័ត៌មានយ៉ាងលម្អិតថែមទៀត ហើយគាត់ក៏បានបើកបង្ហាញនូវសេចក្តីខុសឆ្គងនានាដ៏ចម្បងៗនៃគ្រីស្ទសាសនានាពេលបច្ចុប្បន្ននេះ។ គាត់ក៏បានផ្តល់នូវចម្លើយចេញពីព្រះគម្ពីរលើចំណុចនីមួយៗផងដែរ។

**Jones, David & Russell Woodbridge** ***Health, Wealth & Happiness*** **(Grand Rapids: Kregel ឆ្នាំ២០១១)។**

អ្នកនិពន្ធទាំងពីរនេះបានត្រឡប់ទៅកាន់ព្រះគម្ពីរវិញ ហើយបានផ្តល់នូវការយល់ដឹងដ៏ពិតៗក្នុងព្រះគម្ពីរទាក់ទងនឹងទ្រព្យសម្បត្តិ ភាពក្រីក្រ ការរងទុក្ខ និងការឲ្យ។ ពួកគាត់បានលើកឡើងនូវសេចក្តីខុសឆ្គងដ៏ធំៗប្រាំពីរយ៉ាងដែលចលនានៃដំណឹងល្អដែលសន្យាភាពចម្រុងចម្រើនបានបង្កឡើង។ សៀវភៅនេះលើកទឹកចិត្តឲ្យអ្នកអានរកឃើញជាថ្មីម្តងទៀតនូវដំណឹងល្អដ៏ពិតរបស់ព្រះយេស៊ូវ។

**McConnell, Dan** ***A Different Gospel: Updated Edition*** **(Peabody: Hendrickson, ឆ្នាំ១៩៩៥)។**

អមជាមួយដួងចិត្តដែលជាគ្រូគង្វាល និងផ្នែកជាអ្នកសិក្សា អ្នកនិពន្ធម្នាក់នេះបានស្វះស្វែងរកមូលដ្ឋាននៃទេវវិទ្យា «ដាក់ឈ្មោះលើវា ហើយទាមទារយកទៅ»។ តាមរយៈការធ្វើបែបនោះ គាត់បានបើកបង្ហាញឲ្យឃើញអំពីគ្រោះថ្នាក់នានានៃការបង្រៀនរបស់វាដែលគ្មានក្នុងព្រះគម្ពីរ។

**Ferdinando, Keith** ***The Battle is God's*** **(ACTS, ឆ្នាំ២០១២)។**

សៀវភៅនេះរៀបរាប់អំពីបញ្ហានៃការឈឺចាប់ និងការរងទុក្ខ ដោយនិយាយអំពីសង្គ្រាមខាងឯវិញ្ញាណក្នុងបរិបទនៃទ្វីបអាហ្វ្រិក។

**Rees, Stephen Jesus:** ***Suffering Saviour, Sovereign Lord*** **(ACTS, ឆ្នាំ២០១២)។**

សៀវភៅនេះគឺជាការតែងសេចក្ដីមួយចំនួនដែលផ្ដោតលើចម្រៀងនៃអ្នកបម្រើក្នុងកណ្ឌគម្ពីរអេសាយ និងកណ្ឌគម្ពីរភីលីពជំពូក២។ ជាដំបូង ការតែងសេចក្ដីនេះគឺជាសេចក្ដីអធិប្បាយដែលគាត់បានចែកចាយនៅឯសិក្ខាសាលានានានៅជុំវិញពិភពលោកនេះ។ សេចក្ដីអធិប្បាយទាំងនោះផ្ដោតលើព្រះគ្រីស្ទយ៉ាងពេញទី។ នេះគឺជាគំរូដ៏ល្អណាស់អំពីរបៀបនៃកាត់ស្រាយព្រះបន្ទូលរបស់ព្រះជាម្ចាស់ឲ្យបានត្រឹមត្រូវ ដើម្បីឲ្យអ្នកស្ដាប់ពិតជាឮសំឡេងរបស់ព្រះជាម្ចាស់បានមែន។ សព្វថ្ងៃនេះ យើងត្រូវការគំរូបែបដូចនេះយ៉ាងខ្លាំងណាស់ ខណៈពេលដែលមានមនុស្សជាច្រើនបំប្លែងព្រះបន្ទូលឲ្យនិយាយនូវអ្វីៗដែលពួកគាត់ចង់និយាយ។

# មានធនធានជាច្រើនទៀតនៅ៖

ផ្លូវពិត
plovpit.com

**For ordering information please visit:**

ប្រសិនបើលោកអ្នកចង់ជាវសៀវភៅនេះ សូមចូលទៅកាន់គេហទំព័រ៖

http://www.cambodianchristianresources.com/prosperity/

# ហើយទាញយកសៀវភៅជា ច្រើនទៀតដោយឥតគិតថ្លៃនៅ៖

CambodianChristianResources.com